# សេចក្តីកំណត់
# ចំពោះមាត្រានីមួយៗនៃ
# ច្បាប់
# ស្តីពី
# ការអនុវត្តក្រមរដ្ឋប្បវេណី

រៀបចំដោយ
គណៈកម្មការទទួលបន្ទុកកិច្ចការផ្នែកច្បាប់រដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីកម្ពុជា
និង
ក្រុមការងារជប៉ុនទទួលបន្ទុករៀបចំសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

ក្រសួងយុត្តិធម៌

ភ្នំពេញ ២០១១

សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
ត្រូវបានបោះពុម្ពដោយ
គម្រោងអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌
របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ( JICA )
ប្រចាំក្រសួងយុត្តិធម៌ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១១
រាជធានីភ្នំពេញ

គម្រោងអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌
គឺជាគម្រោងសហប្រតិបត្តិការបច្ចេកទេស
រវាង
ក្រសួងយុត្តិធម៌
និង
ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

សិទ្ធិអ្នកនិពន្ធ © សាស្ត្រាចារ្យ **MINAMI Toshifumi** ឆ្នាំ ២០១១
ISBN: 9789996326042

# បុព្វកថា

នៅក្នុងអាណត្តិទី៣ នៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលលើវិស័យយុត្តិធម៌ ក្រសួងយុត្តិធម៌សម្រេចបាននូវសមិទ្ធផលជាទីមោទនៈជាច្រើនក្នុងវិស័យនីតិកម្ម។ ជាសក្ខីភាព មួយដ៏ថ្លៃថ្លានៃមោទនភាពនេះ គឺអត្ថិភាពនៃក្រមរដ្ឋប្បវេណីដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៤ នីតិកាលទី២ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។ ទោះបីជា ក្រមរដ្ឋប្បវេណីត្រូវបានប្រកាសឱ្យប្រើក៏ដោយ ក៏បញ្ញត្តិនៃក្រមនេះ មិនទាន់ត្រូវបានអនុវត្តនៅឡើយទេ ដោយរង់ចាំនូវច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលជាច្បាប់មួយដើម្បីធ្វើការសម្របសម្រួលជាមួយបទប្បញ្ញត្តិច្បាប់ និង បទដ្ឋានគតិយុត្តធរមាននានា ឱ្យមានភាពស៊ីសង្វាក់នឹងគ្នាក្នុងការអនុវត្ត។

ក្រោមការខិតខំប្រឹងប្រែងជាបន្តទៀត ក្នុងគោលបំណងដើម្បីសម្រេចឱ្យបាននូវការអនុវត្តនូវបញ្ញត្តិនៃក្រមរដ្ឋប្បវេណី គណៈកម្មការទទួលបន្ទុកកិច្ចការផ្នែកច្បាប់រដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ដោយមានការឧបត្ថម្ភគាំទ្រពីប្រទេសជប៉ុនជាមិត្ត ក៏បានបញ្ចប់នូវការតាក់តែងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។ ជាលទ្ធផល ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីក៏ត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និងព្រឹទ្ធសភាបានអនុម័តកាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី២ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១។

ទន្ទឹមគ្នានេះដែរ ដើម្បីជាការបន្ថែមលើវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និង ក្រមរដ្ឋប្បវេណី និង ដើម្បីធ្វើឱ្យមានភាពជឿជាក់ថា បទប្បញ្ញត្តិនៃច្បាប់ និងក្រមនេះ ត្រូវបានយល់ជ្រួតជ្រាបទៅក្នុងចំណោមមហាជន ក៏ដូចជាជួយសម្រួលដល់ការស្វែងយល់ ការបកស្រាយ និងការអនុវត្តដោយមន្ត្រី និងស្ថាប័នអនុវត្ត សៀវភៅស្តីពីសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានចងក្រង និងបោះពុម្ពឡើង។

ទាំងអស់នេះ គឺបានប្រសូតចេញពីកិច្ចខំប្រឹងប្រែង របស់ក្រុមការងារនៃក្រសួងយុត្តិធម៌កម្ពុជា និងក្រុមការងារជប៉ុន ក្នុងបុព្វហេតុក្រមរដ្ឋប្បវេណីកម្ពុជាមួយ ប្រកបដោយការផ្លាស់ប្តូរ និង ប្រសិទ្ធភាពខ្ពស់សំដៅឆ្ពោះទៅរកការរួមចំណែកកសាងនីតិរដ្ឋ នៅកម្ពុជា។

ក្រសួងយុត្តិធម៌មានជំនឿយ៉ាងមុតមាំថា  សៀវភៅស្តីពី  សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីនេះ  នឹងក្លាយជាជំនួយដ៏សំខាន់មួយ  ដើម្បីជួយសម្រួលដល់ការស្វែងយល់របស់បណ្ដាអ្នកស្រាវជ្រាវនានា ជាពិសេសរបស់អ្នកអនុវត្តច្បាប់ដោយផ្ទាល់តែម្តង។ ៕

រាជធានីភ្នំពេញ,ថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ២០១១

**រដ្ឋមន្ត្រី**

អង្គ.វង្សវឌ្ឍនា

**សមាសភាពនៃគណៈកម្មការទទួលបន្ទុករៀបចំសេចក្ដីព្រាងក្រមរដ្ឋប្បវេណីកម្ពុជា :**

| | |
|---|---|
| ឯកឧត្ដម **អង្គ វង្ស វឌ្ឍានា** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ( ប្រធាន) |
| ឯកឧត្ដម **ស៊ុយ នូ** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ( អាណត្តិទី ១) |
| ឯកឧត្ដម **អ៊ី ជន** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ( អាណត្តិទី ២) |
| ឯកឧត្ដម **ហ៊ី សោភា** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ |
| លោកជំទាវ **ចាន់ សុន្ធាវី** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ |
| ឯកឧត្ដម **យូ ប៊ុនឡេង** | ប្រធានសាលាឧទ្ធរណ៍ |
| ឯកឧត្ដម **គង់ ស្រ៊ឹម** | អនុប្រធានតុលាការកំពូល |
| ឯកឧត្ដម **ប៊ុន ហុន** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ |
| ឯកឧត្ដម **កើត រិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ |
| ឯកឧត្ដម **ជួន តេជ** | អគ្គាធិការរងក្រសួងយុត្តិធម៌ |
| ឯកឧត្ដម **ប៉ែន ពេជ្រសាលី** | អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងយុត្តិធម៌ |
| ឯកឧត្ដម **ផូវ សំតី** | អគ្គនាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌ ក្រសួងយុត្តិធម៌ |
| លោក **យូរ ឧត្តរា** | ចៅក្រមតុលាការកំពូល |
| លោក **សាលី ធារ៉ា** | ចៅក្រមតុលាការកំពូល |
| លោកស្រី **ខៀវ សុខា** | ចៅក្រមតុលាការកំពូល |
| លោក **សឹង បញ្ញាវុឌ្ឍ** | ចៅក្រមតុលាការកំពូល |
| លោក **ហ៊ឹង ធីឫទ្ធិ** | ចៅក្រមតុលាការកំពូល |
| លោក **សិរិទ្ធ សុផល** | ចៅក្រមសាលាឧទ្ធរណ៍ |
| លោក **ម៉ុង មុន្នីចរិយា** | ប្រធានសាលាដំបូងខេត្តព្រះសីហនុ |
| លោក **ទូច ថារិទ្ធិ** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ក្រសួងយុត្តិធម៌ |
| លោក **ទិត្យ ឫទ្ធី** | ចៅក្រមក្រសួងយុត្តិធម៌ |

**សមាសភាពនៃក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី :**

| | |
|---|---|
| លោក **MORISHIMA Akio** | សាស្ត្រាចារ្យកិត្តិយសសាកលវិទ្យាល័យ Nagoya ( ប្រធាន) |
| លោក **KAMATA Kaoru** | សាស្ត្រាចារ្យសាកលវិទ្យាល័យ Waseda |
| លោក **MATSUMOTO Tsuneo** | សាស្ត្រាចារ្យសាកលវិទ្យាល័យ Hitotsubashi |
| លោក **MINAMI Toshifumi** | ចៅក្រមសាលាឧទ្ធរណ៍នៃតំបន់ Tokyo |
| លោក **MOTOYAMA Atsushi** | សាស្ត្រាចារ្យសាកលវិទ្យាល័យ Ritsumeikan |

| | |
|---|---|
| លោក **NOMI Yoshihisa** | សាស្ត្រាចារ្យសាកលវិទ្យាល័យ Gakushuin |
| លោក **NOMURA Toyohiro** | ព្រឹទ្ធបុរស និង សាស្ត្រាចារ្យសាកលវិទ្យាល័យ Gakushuin |
| លោក **YAMAMOTO Yutaka** | សាស្ត្រាចារ្យសាកលវិទ្យាល័យ Kyoto |
| លោក **TANAMURA Masayuki** | សាស្ត្រាចារ្យសាកលវិទ្យាល័យ Waseda |
| លោក **URAKAWA Michitaro** | សាស្ត្រាចារ្យសាកលវិទ្យាល័យ Waseda |

**ជំនាញការរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ប្រចាំក្រសួងយុត្តិធម៌ :**

| | |
|---|---|
| លោក **SAKANO Issei** | អតីតទីប្រឹក្សា នៃគម្រោងអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **KAMIKI Atsushi** | អតីតទីប្រឹក្សាច្បាប់ នៃគម្រោងអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| កញ្ញា **MANABE Kana** | អតីតទីប្រឹក្សាច្បាប់ នៃគម្រោងអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| កញ្ញា **TERAUCHI Kozue** | អតីតអ្នកសម្របសម្រួលនៃគម្រោងអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **KIYOHARA Hiroshi** | អតីតទីប្រឹក្សាច្បាប់ នៃគម្រោងអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **HARADA Masayoshi** | ទីប្រឹក្សាច្បាប់ នៃគម្រោងអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោកស្រី **KANETAKE Emiko** | ទីប្រឹក្សាច្បាប់ នៃគម្រោងអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| កញ្ញា **TAMIYA Ayako** | ទីប្រឹក្សាច្បាប់ នៃគម្រោងអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |

**អ្នកនិពន្ធ :**

សាស្ត្រាចារ្យ **MINAMI Toshifumi**

**អ្នកបកប្រែ :**

| | |
|---|---|
| លោក **SAKANO Issei** | អតីតទីប្រឹក្សា នៃគម្រោងអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **ស្វាយ ឡេង** | អ្នកបកប្រែជាប់កិច្ចសន្យា |

**អ្នកត្រួតពិនិត្យ និង កែសម្រួលក្នុងសេចក្ដីកំណត់ :**

| | |
|---|---|
| លោក **កែវ ចាន់នី** | មន្ត្រីច្បាប់ជាន់ខ្ពស់ នៃគម្រោងអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ នៃទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិរបស់ប្រទេសជប៉ុន (JICA) |
| លោក **សួន ពលរក្ស** | ជំនួយការ នៃគម្រោងអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ នៃទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិរបស់ប្រទេសជប៉ុន (JICA) |

## មាតិកា


**ជំពូកទី ១ បទប្បញ្ញត្តិទូទៅ** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ **១**

**មាត្រា ១ ..** គោលដៅ ---------------------------------------- ១

**មាត្រា ២ ..** គោលបំណង ---------------------------------------- ២

**មាត្រា ៣ ..** វិសាលភាព ---------------------------------------- ២

**មាត្រា ៤ ..** កាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី -------------------- ២

**មាត្រា ៥ ..** គោលការណ៍នៃការអនុវត្តក្រមរដ្ឋប្បវេណី -------------------- ២

**ជំពូកទី ២ បញ្ញត្តិសារធាតុ**~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ **៦**

**មាត្រា ៦ ..** ការដាក់ជូនបញ្ជីសារពើភ័ណ្ឌ ជាអាទិ៍ ទៅតុលាការ -------------៦

**មាត្រា ៧ ..** ការជូនដំណឹងអំពីការបង្ហាញឆន្ទៈទៅអ្នកនៅឆ្ងាយ -------------- ៧

**មាត្រា ៨ ..** និយមន័យនៃលិខិតដែលមានកាលបរិច្ឆេទស្ថាពរ ----------------៩

**មាត្រា ៩ ..** អត្ថន័យនៃលិខិតយថាភូត ------------------------------- ១១

**មាត្រា ១០ ..** ការកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី-------------------១៣

**មាត្រា ១១ ..** សិទ្ធិអំណាចរបស់មន្ត្រីទទួលបន្ទុកកិច្ចការសារការី ជាអាទិ៍ ------- ១៤

**មាត្រា ១២ ..** ការប្រកាសជាសាធារណៈ --------------------------------- ១៦

**មាត្រា ១៣ ..** សិទ្ធិរបស់កម្មសិទ្ធិករនៃដី------------------------------- ១៦

**មាត្រា ១៤ ..** ភោគៈ ---------------------------------------------១៧

**មាត្រា ១៥ ..** ករណីលទ្ធកម្មកម្មសិទ្ធិ --------------------------------- ១៩

**មាត្រា ១៦ ..** អន្តរប្បញ្ញត្តិ ---------------------------------------- ២០

**មាត្រា ១៧ ..** អត្រាការប្រាក់ដែលត្រូវបានកម្រិត ជាអាទិ៍------------------ ២១

**ជំពូកទី ៣ ការចុះបញ្ជីនីតិបុគ្គល**~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ **២៤**

**មាត្រា ១៨ ..** សមត្ថកិច្ចលើការចុះបញ្ជីនីតិបុគ្គល ------------------------ ២៤

**មាត្រា ១៩ ..** បែបបទ និង ទម្រង់នៃការចុះបញ្ជីនីតិបុគ្គល ---------------- ២៥

**មាត្រា ២០ ..** ពាក្យសុំចុះបញ្ជីនីតិបុគ្គល --------------------------------- ២៦

**មាត្រា ២១ ..** ការប្រតិបត្តិការចុះបញ្ជី ---------------------------------២៧

**មាត្រា ២២ ..** ការចុះបញ្ជីចំពោះការផ្លាស់ប្តូរ ជាអាទិ៍ --------------------- ២៨

**មាត្រា ២៣ ..** ការបញ្ជាក់ ------------------------------------------ ២៩

**មាត្រា ២៤ ..** ករណីលើកលែងចំពោះការចុះបញ្ជីទីស្នាក់ការសាខា ------------៣០

**មាត្រា ២៥ ..** ការប្រគល់សិទ្ធិឱ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើប្រកាស ---------------------------------- ៣០

**ជំពូកទី ៤ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ** ~~~~~~~~~~~~~~~~~~~~~~~~~~~ **៣១**

**មាត្រា ២៦ ..** សមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ---------- ៣១

**មាត្រា ២៧ ..** បែបបទ និង ទម្រង់នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ---- ៣១

**មាត្រា ២៨ ..** ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ---------------- ៣១

**មាត្រា ២៩ ..** ការប្រតិបត្តិការចុះបញ្ជី ----------------------------------- ៣២

**មាត្រា ៣០ ..** ការចុះបញ្ជីចំពោះការផ្លាស់ប្តូរ ជាអាទិ៍ -------------------- ៣២

**មាត្រា ៣១ ..** ការបញ្ជាក់ --------------------------------------------- ៣៤

**មាត្រា ៣២ ..** ការប្រគល់សិទ្ធិឱ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើប្រកាស ---------------------------------- ៣៤

**ជំពូកទី ៥ អន្តរប្បញ្ញត្តិ** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ **៣៥**

**មាត្រា ៣៣ ..** ការអនុញ្ញាតឱ្យអនីតិជនប្រកបអាជីវកម្ម -------------------- ៣៥

**មាត្រា ៣៤ ..** ការចាត់ចែងអំពីសាជីវកម្ម ឬមូលនិធិដែលមានអត្ថិភាពតាំងពីមុន កាលបរិច្ឆេទនៃការអនុវត្ត ---------------------------------- ៣៦

**មាត្រា ៣៥ ..** ការចុះបញ្ជីសាជីវកម្ម ឬមូលនិធិដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទ នៃការអនុវត្ត ជាអាទិ៍ ---------------------------------- ៣៩

**មាត្រា ៣៦ ..** បញ្ជីទ្រព្យសម្បត្តិ ឬ បញ្ជីរាយនាមសមាជិក---------------- ៤១

**មាត្រា ៣៧ ..** បញ្ញត្តិពិសេសអំពីពេលដែលនីតិបុគ្គលត្រូវបានបង្កើត----------- ៤១

**មាត្រា ៣៨ ..** អានុភាពនៃសិទ្ធិប្រត្យក្សដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត ---------------------------------------------- ៤២

**មាត្រា ៣៩ ..** ការកាន់កាប់ចលនវត្ថុតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត ------- ៤៥

**មាត្រា ៤០ ..** ឧបាគមន៍តាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត --------------- ៤៦

**មាត្រា ៤១ ..** អំឡុងពេលដែលសិទ្ធិជួលរយៈពេលវែងតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត មានអត្ថិភាព------------------------------------------ ៤៦

**មាត្រា ៤២ ..** ផលុបភោគដែលត្រូវបានដាក់ធានារ៉ាប់រង------------------ ៤៧

**មាត្រា ៤៣ ..** អន្តរប្បញ្ញត្តិស្តីពីសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ដែលត្រូវបានចុះបញ្ជី ---------------------------------------------- ៤៨

**មាត្រា ៤៤** .. អន្តរប្បញ្ញត្តិស្តីពីការប្រាក់សមាស -------------------------- ៤៩

**មាត្រា ៤៥** .. អន្តរប្បញ្ញត្តិស្តីពីការមិនអនុវត្តកាតព្វកិច្ច -------------------- ៥០

**មាត្រា ៤៦** .. អន្តរប្បញ្ញត្តិស្តីពីបញ្ញត្តិពិសេសអំពីកាតព្វកិច្ចជាប្រាក់------------៥៣

**មាត្រា ៤៧** .. អន្តរប្បញ្ញត្តិស្តីពីការទូទាត់------------------------------- ៥៤

**មាត្រា ៤៨** .. អន្តរប្បញ្ញត្តិស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិ---------------- ៥៥

**មាត្រា ៤៩** .. ពេលចាប់ផ្តើមការអនុវត្តបញ្ញត្តិស្តីពីការផ្អាកអាជ្ញាយុកាល និង ការបង្អង់ ការសម្រេចអាជ្ញាយុកាល ------------------------------ ៥៧

**មាត្រា ៥០** .. ការអនុវត្តដូចគ្នាចំពោះអំឡុងពេលដែលច្បាប់បានកំណត់ ------- ៥៨

**មាត្រា ៥១** .. អន្តរប្បញ្ញត្តិស្តីពីកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់--------- ៥៨

**មាត្រា ៥២** .. អន្តរប្បញ្ញត្តិក្នុងករណីដែលវត្ថុជួលមានវិការៈ---------------- ៥៩

**មាត្រា ៥៣** .. អន្តរប្បញ្ញត្តិស្តីពីសេចក្តីចម្រើនដោយឥតហេតុ ---------------- ៦០

**មាត្រា ៥៤** .. ការធានាកាតព្វកិច្ចតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត---------- ៦១

**មាត្រា ៥៥** .. ការចាត់ចែងអំពីការដាក់ធានា --------------------------៦៣

**មាត្រា ៥៦** .. ការចាត់ចែងអំពីកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគប្រសុក្យដែលមិនទាន់ ចុះបញ្ជី ------------------------------------------ ៦៤

**មាត្រា ៥៧** .. អំឡុងពេលដែលសិទ្ធិលើការបញ្ចាំអចលនវត្ថុ មានអត្ថិភាព --------៦៦

**មាត្រា ៥៨** .. ការកំណត់ការធានាបំណុលអណ្តែតសាកល-----------------៦៧

**មាត្រា ៥៩** .. ការបាត់ខ្លួនរបស់សហព័ទ្ធ------------------------------៦៧

**មាត្រា ៦០** .. អន្តរប្បញ្ញត្តិស្តីពីការប្រកាសផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍----៦៩

**មាត្រា ៦១** .. អន្តរប្បញ្ញត្តិស្តីពីការប្តឹងជំទាស់ និង ការប្តឹងទាស់មិនឱ្យរៀបអាពាហ៍ពិពាហ៍ ---------------------------------------------- ៧០

**មាត្រា ៦២** .. អន្តរប្បញ្ញត្តិស្តីពីការលុបចោលអាពាហ៍ពិពាហ៍ ជាអាទិ៍-------- ៧១

**មាត្រា ៦៣** .. អន្តរប្បញ្ញត្តិស្តីពីមូលហេតុនៃការលែងលះគ្នា ---------------- ៧៤

**មាត្រា ៦៤** .. អន្តរប្បញ្ញត្តិស្តីពីនីតិវិធីលែងលះគ្នា --------------------- ៧៥

**មាត្រា ៦៥** .. ការសន្មតបិតុភាព ជាអាទិ៍-------------------------------៧៧

**មាត្រា ៦៦** .. ការទទួលស្គាល់ដោយបង្ខំ------------------------------ ៨០

**មាត្រា ៦៧** .. សុំកូនដែលបានធ្វើមុនកាលបរិច្ឆេទនៃការអនុវត្ត--------------- ៨៤

**មាត្រា ៦៨** .. អន្តរប្បញ្ញត្តិស្តីពីការដាក់ពាក្យសុំកូន --------------------- ៨៤

**មាត្រា ៦៩ ..** អំណាចមេបាក្រោយការលែងលះគ្នា ---------------------- ៨៥

**មាត្រា ៧០ ..** អន្តរប្បញ្ញត្តិស្តីពីការសុំដកហូតអំណាចមេបា ជាអាទិ៍ ----------- ៨៦

**មាត្រា ៧១ ..** ការអនុវត្តបញ្ញត្តិស្តីពីសន្តតិកម្ម ----------------------------- ៨៦

**ជំពូកទី ៦ ប្រតិបត្តិការដែលមានកិច្ចធានា~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៨៧**

**មាត្រា ៧២ ..** គោលបំណងនៃជំពូកនេះ ----------------------------------- ៨៨

**មាត្រា ៧៣ ..** អានុភាពនៃប្រតិបត្តិការដែលមានកិច្ចធានា ដែលត្រូវបានធ្វើឡើងនៅមុន កាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី ------------------ ៨៩

**មាត្រា ៧៤ ..** ការប្តូរទៅប្រតិបត្តិការដោយផ្អែកលើក្រមរដ្ឋប្បវេណី ----------- ៩០

**មាត្រា ៧៥ ..** បញ្ញត្តិសន្មត ------------------------------------------ ៩១

**មាត្រា ៧៦ ..** អាទិភាពរវាងប្រតិបត្តិការដោយយោងតាមច្បាប់ស្តីពីប្រតិបត្តិការដែលមាន កិច្ចធានា និង ប្រតិបត្តិការដោយយោងតាមក្រមរដ្ឋប្បវេណី ----- ៩១

**មាត្រា ៧៧ ..** ការការពារបុគ្គលសុច្ចរិត ------------------------------ ៩២

**ជំពូកទី ៧ វិសោធនកម្ម និង និរាករណ៍នូវបទប្បញ្ញត្តិមួយចំនួននៃច្បាប់ជាធរមាន ~~~~~~~៩៤**

**មាត្រា ៧៨ ..** និរាករណ៍នូវបទប្បញ្ញត្តិមួយចំនួននៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ------------------------------------------------------- ៩៤

**មាត្រា ៧៩ ..** និរាករណ៍នូវបទប្បញ្ញត្តិមួយចំនួននៃក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា ------------- ៩៥

**មាត្រា ៨០ ..** វិសោធនកម្មនូវបទប្បញ្ញត្តិមួយចំនួននៃច្បាប់ភូមិបាល ឆ្នាំ២០០១ -----៩៦

**មាត្រា ៨១ ..** វិសោធនកម្មនូវបទប្បញ្ញត្តិមួយចំនួននៃក្រមរដ្ឋប្បវេណី ---------- ១០០

**មាត្រា ៨២ ..** ការចាត់ចែងអំពីក្រមរដ្ឋប្បវេណីចាស់ -------------------- ១០៦

**មាត្រា ៨៣ ..** អានុភាពនៃច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត------------- ១០៦

**ជំពូកទី ៨ អវសានប្បញ្ញត្តិ ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~១០៧**

**មាត្រា ៨៤ ..** កាលបរិច្ឆេទនៃការអនុវត្ត--------------------------------១០៧

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

## មាត្រា ១.-គោលដៅ

ច្បាប់នេះ បញ្ញត្តិអំពីកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះនៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ (តទៅហៅថា “ក្រមរដ្ឋប្បវេណី”) ដែលកំណត់ក្នុងកថាខណ្ឌទី ១ មាត្រា ១៣០៥ (កាលបរិច្ឆេទនៃការអនុវត្តជាអាទិ៍) នៃក្រមរដ្ឋប្បវេណី និង អំពីវិធានការអន្តរកាល និង ចំណុចចាំបាច់ផ្សេងទៀតដែលទាក់ទងនឹងការអនុវត្តក្រមរដ្ឋប្បវេណី ដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៣០៥ នោះ។

(កំណត់)

មាត្រានេះចែងអំពីគោលបំណងនៃច្បាប់នេះ។ កថាខណ្ឌទី ១ មាត្រា ១៣០៥ នៃក្រមរដ្ឋប្បវេណីចែងថា "ក្រមនេះត្រូវអនុវត្តចាប់តាំងពីថ្ងៃដែលកំណត់ផ្សេងដោយច្បាប់" ដែលមានន័យថា កាលបរិច្ឆេទនៃការអនុវត្តត្រូវកំណត់ដោយច្បាប់ផ្សេងពីក្រមរដ្ឋប្បវេណី។ ច្បាប់នេះគឺជា "ច្បាប់ផ្សេង" នោះ ហើយមានគោលបំណងកំណត់នូវកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី។ ចំពោះមូលហេតុស្តីពីការកំណត់កាលបរិច្ឆេទនៃការអនុវត្ត និង កាលបរិច្ឆេទនៃការអនុវត្ត សូមមើលសេចក្តីកំណត់ក្នុងមាត្រាបន្ទាប់។

កថាខណ្ឌទី ២ នៃមាត្រា ១៣០៥ ដដែលចែងថា "ចំពោះវិធានការអន្តរកាលដែលទាក់ទងនឹងការអនុវត្តក្រមនេះ និង ចំណុចចាំបាច់ផ្សេងទៀតដែលទាក់ទងនឹងការអនុវត្តក្រមនេះ ត្រូវកំណត់ផ្សេងដោយច្បាប់"។ ក្រមរដ្ឋប្បវេណីមិនបានកំណត់និយមន័យនៃលិខិតដែលមានកាលបរិច្ឆេទស្ថាពរ ឬ លិខិតយថាភូត ជាអាទិ៍ ទេ។ ប៉ុន្តែការកំណត់និយមន័យ ជាអាទិ៍ នោះ ត្រូវមានជាចាំបាច់ដើម្បីអនុវត្តជាក់ស្តែងនូវក្រមរដ្ឋប្បវេណី។ ហេតុដូច្នេះ ច្បាប់នេះកំណត់អំពីចំណុចនេះ។ លើសពីនេះទៅទៀត ដោយសារតែច្បាប់ភូមិបាល ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ និង ក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា មានចែងនូវបញ្ញត្តិជាច្រើនពាក់ព័ន្ធជាមួយនឹងបញ្ហាដែលកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ទើបមានភាពចាំបាច់ក្នុងការសម្របសម្រួលបញ្ញត្តិនៃច្បាប់នោះជាមួយក្រមរដ្ឋប្បវេណី។ ក្នុងគោលបំណងធ្វើការសម្របសម្រួលបែបនេះ ច្បាប់នេះបញ្ញត្តផងដែរនូវវិធានការអន្តរកាល ព្រមទាំងការធ្វើវិសោធនកម្ម និង ការធ្វើឱ្យនិរាករណ៍នូវច្បាប់ទាំងនោះដែលមិនស៊ីសង្វាក់គ្នាជាមួយក្រមរដ្ឋប្បវេណី ជាអាទិ៍។

## មាត្រា ២.- គោលបំណង

ច្បាប់នេះ មានគោលបំណងធានាស្ថិរភាពនៃទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី និង ធានាឱ្យមានការអនុវត្តបានត្រឹមត្រូវនូវបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី។

## មាត្រា ៣.- វិសាលភាព

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះបញ្ហាដែលទាក់ទងនឹងការអនុវត្តក្រមរដ្ឋប្បវេណី។

## មាត្រា ៤.- កាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី

ក្រមរដ្ឋប្បវេណីត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ។

(កំណត់)

យោងតាមកថាខណ្ឌទី ១ មាត្រា ៩៣ នៃរដ្ឋធម្មនុញ្ញកម្ពុជា ជាគោលការណ៍ ច្បាប់ទាំងឡាយត្រូវចូលជាធរមាននៅរាជធានីភ្នំពេញ ក្នុងរយៈពេល ១០ ថ្ងៃគត់ និង នៅទូទាំងប្រទេស ក្នុងរយៈពេល ២០ ថ្ងៃគត់ ក្រោយថ្ងៃដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ។ ប៉ុន្តែ ច្បាប់ដែលនាំឱ្យមានឥទ្ធិពលលើប្រជាពលរដ្ឋយ៉ាងទូលំទូលាយ ដូចក្រមរដ្ឋប្បវេណី គួរតែចាប់ផ្តើមអនុវត្តក្រោយអំឡុងពេលសមរម្យដើម្បីផ្សព្វផ្សាយទៅប្រជាពលរដ្ឋ បន្ទាប់ពីការចូលជាធរមាន។ ហេតុដូច្នេះ ដោយយោងតាមកថាខណ្ឌទី ១ មាត្រា ១៣០៥ នៃក្រមរដ្ឋប្បវេណី មាត្រានេះកំណត់ថា ក្រមរដ្ឋប្បវេណីត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ ហើយដោយយោងតាមមាត្រា ៨៤ នៃច្បាប់នេះ ក្រោយពីចូលជាធរមាននៅទូទាំងប្រទេស ច្បាប់នេះត្រូវផ្សព្វផ្សាយក្នុងរយៈពេល ៦ ប្រាំមួយខែ ទើបអនុវត្ត។

## មាត្រា ៥.- គោលការណ៍នៃការអនុវត្តក្រមរដ្ឋប្បវេណី

១-ក្រមរដ្ឋប្បវេណី មិនត្រូវអនុវត្តចំពោះបញ្ហាដែលបានកើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្តដែលកំណត់នៅក្នុងមាត្រា ៤ (កាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី) ខាងលើនេះ (តទៅហៅថា “កាលបរិច្ឆេទនៃការអនុវត្ត”) ឡើយ លើកលែងតែមានបញ្ញត្តិផ្សេងទៀត។ ប៉ុន្តែ ទំនាក់ទំនងគតិយុត្តជាបន្តដែលបានកើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្ត ហើយនៅតែមានអត្ថិភាពក្រោយកាលបរិច្ឆេទនៃការអនុវត្ត ត្រូវអនុលោមតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី គិតត្រឹមពីកាលបរិច្ឆេទនៃការ

អនុវត្ត។

២-អានុភាពដែលបានកើតឡើងដោយបទដ្ឋានគតិយុត្ត ឬ បញ្ញត្តិទំនៀមទម្លាប់នៃកម្ពុជានៅមុនកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី មិនត្រូវបានរារាំងឡើយ ក្រោយកាលបរិច្ឆេទនៃការអនុវត្ត លើកលែងតែមានបញ្ញត្តិផ្សេងទៀតនៅក្នុងជំពូកទី ៥ (អន្តរប្បញ្ញត្តិ) នៃច្បាប់នេះ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ មិនត្រូវរារាំងការយកក្រមរដ្ឋប្បវេណីមកអនុវត្តជាគោលការណ៍សមធម៌ ចំពោះបញ្ហាដែលកើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្ត ក្នុងករណីពុំមានបទដ្ឋានគតិយុត្ត ឬ បញ្ញត្តិទំនៀមទម្លាប់ ដែលកំណត់អំពីបញ្ហានេះ ឬ ក្នុងករណីមិនដឹងច្បាស់ថាមានបញ្ញត្តិទំនៀមទម្លាប់។

(កំណត់)

មាត្រានេះកំណត់ពីគោលការណ៍ថាតើក្រមរដ្ឋប្បវេណីអាចអនុវត្តបានដោយមានអានុភាពប្រតិសកម្ម ឬ អានុភាពមានចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត។ គោលការណ៍នៃការអនុវត្តច្បាប់ដោយមានអានុភាពប្រតិសកម្មគឺឈរលើទស្សនៈថា គោលគំនិតនៃច្បាប់ថ្មី ឬ ច្បាប់ដែលត្រូវបានធ្វើវិសោធនកម្ម គួរតែមានវិសាលភាពលើបញ្ហាឱ្យបានច្រើនតាមលទ្ធភាពដែលអាចធ្វើទៅបាន។ ជាពិសេស ក្នុងករណីដែលគ្មានច្បាប់ជាធរមានលើវិស័យជាក់លាក់ណាមួយទេ ការអនុវត្តដោយមានអានុភាពប្រតិសកម្មគឺមានគុណសម្បត្តិ។ ផ្ទុយទៅវិញ ប្រសិនបើច្បាប់សារធាតុណាមួយត្រូវបានអនុវត្តដោយមានអានុភាពប្រតិសកម្ម សិទ្ធិដែលពលរដ្ឋមួយចំនួនមានស្រាប់ហើយនោះអាចត្រូវបានដកហូត (ក៏ប៉ុន្តែ ការអនុវត្តបែបនេះធ្វើឱ្យមានគុណសម្បត្តិច្រើនលើសលប់សម្រាប់ម្ចាស់សិទ្ធិថ្មី)។ ដោយសារមូលហេតុទាំងនេះហើយទើបការសម្របសម្រួលរវាងគុណសម្បត្តិ និង គុណវិបត្តិ មានសារៈសំខាន់ណាស់។ម្យ៉ាងទៀតដោយសារតែច្បាប់ភូមិបាល ក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច និង ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ មានអត្ថិភាពនៅកម្ពុជារួចហើយ ប្រសិនបើក្រមរដ្ឋប្បវេណីត្រូវអនុវត្តដោយមានអានុភាពប្រតិសកម្ម ភាពរើករវរអាចនឹងកើតឡើងចំពោះផ្នែកដែលពាក់ព័ន្ធជាមួយច្បាប់សារធាតុទាំងអស់នេះ ដូច្នេះចាំបាច់ត្រូវធ្វើការសម្របសម្រួល។ ដោយឈរលើភាពចាំបាច់ក្នុងការការពារនូវផលប្រយោជន៍ដែលមានស្រាប់ហើយ ប្រសិនបើត្រូវអនុវត្តក្រមរដ្ឋប្បវេណីដោយមានអានុភាពប្រតិសកម្មចំពោះគ្រប់ផ្នែកទាំងអស់ ហើយរៀបចំបញ្ញត្តិដើម្បីសម្របសម្រួលជាមួយនឹងច្បាប់សារធាតុដែលកំពុងនៅជាធរមានទាំងនោះ វាមានន័យថា ត្រូវបញ្ចូលអំពីខ្លឹមសារនៃច្បាប់សារធាតុជាធរមានទាំងអស់នៅក្នុងអន្តរប្បញ្ញត្តិ ហេតុដូច្នេះ គ្មានប្រយោជន៍ទេ។ ដោយហេតុនេះហើយបានជាកថាខណ្ឌទី ១ នៃមាត្រានេះបញ្ជាក់ថា

ជាគោលការណ៍ ក្រមរដ្ឋប្បវេណីត្រូវអនុវត្តចំពោះបញ្ហាដែលកើតឡើងក្រោយកាលបរិច្ឆេទនៃការអនុវត្ត ដោយឡែក បញ្ញត្តិពិសេសត្រូវបានដាក់បញ្ចូលនៅក្នុងច្បាប់នេះសម្រាប់ករណីដែលចាំបាច់ឱ្យមានអានុភាពអនុវត្តប្រតិសកម្ម។ មាត្រា ១ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីជប៉ុនក៏បានប្រើគោលការណ៍នីតិកម្មដូចគ្នានេះដែរ។ ចំពោះទំនាក់ទំនងគតិយុត្តជាបន្ត ច្បាប់នេះបញ្ញត្តថា ត្រូវអនុលោមតាមក្រមរដ្ឋប្បវេណី ដោយគិតចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត ហើយរៀបចំបញ្ញត្តិសម្របសម្រួលទៀត។

ប្រហែលជាអាចកើតមានចម្ងល់ថាតើ "បញ្ហា" អ្វីខ្លះទៅដែលបានកើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្តដូចមានចែងក្នុងវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ នោះ។ ជាឧទាហរណ៍ បើទោះជាកិច្ចសន្យាលក់ទិញត្រូវបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ ប្រសិនបើភាគីណាមួយមិនអនុវត្តកាតព្វកិច្ចទេ តើការធ្វើកិច្ចសន្យាត្រូវបានរាប់ចូលទៅក្នុងពាក្យថា "បញ្ហា" ឬ ការមិនអនុវត្តកាតព្វកិច្ចទៅវិញទេដែលជា "បញ្ហា" នោះដែរឬទេ? ក្នុងករណីនេះ ដោយសារតែខ្លឹមសារនៃការលក់ទិញមានចែងនៅក្នុងកិច្ចសន្យារួចហើយ ហើយការអនុវត្តកាតព្វកិច្ចគឺជាការប្រតិបត្តិទៅតាមខ្លឹមសារនៃកិច្ចសន្យាតែប៉ុណ្ណោះ ហេតុដូច្នេះ ត្រូវបកស្រាយថា កិច្ចសន្យាលក់ទិញ គឺជា "បញ្ហា" ហើយក្រមរដ្ឋប្បវេណីមិនអនុវត្តចំពោះកិច្ចសន្យាលក់ទិញនោះទាំងស្រុងតែម្តងទេ។ ចំពោះបញ្ញត្តិស្តីពីសិទ្ធិវិលាយនៅក្នុងក្រមរដ្ឋប្បវេណី ក៏ដូចគ្នាដែរ គឺក្រមរដ្ឋប្បវេណីមិនត្រូវអនុវត្តឡើយ។ ម្យ៉ាងទៀត ទោះបីជាការសងក្រោយកាលបរិច្ឆេទនៃការអនុវត្តហាក់ដូចជាបញ្ហាថ្មី ហើយអាចគិតថាអាចអនុលោមទៅតាមក្រមរដ្ឋប្បវេណីក៏ដោយ ក៏ក្រមរដ្ឋប្បវេណីមិនអាចយកទៅអនុវត្តបានទេ គឺដូចបានរៀបរាប់ពីខាងលើ។ ប៉ុន្តែ ក្នុងករណីដែលមានការមិនអនុវត្តកាតព្វកិច្ចដែលកើតឡើងក្រោយកាលបរិច្ឆេទនៃការអនុវត្ត មាត្រា ៤៣ នៃច្បាប់នេះបានបញ្ញត្តពិសេសថា ក្រមរដ្ឋប្បវេណីត្រូវអនុវត្តចំពោះការមិនអនុវត្តកាតព្វកិច្ចនោះ។ ចំពោះសេចក្តីលម្អិតអំពីចំណុចនេះ សូមមើលសេចក្តីកំណត់ក្នុងមាត្រា ៤៥។ ចម្ងល់នេះគឺកើតមានចំពោះទំនាក់ទំនងគតិយុត្តផ្សេងៗជាច្រើន។ យើងពន្យល់អំពីបញ្ហានីមួយៗនេះជាសេចក្តីកំណត់បន្ថែម បន្ទាប់ពីសេចក្តីកំណត់អំពីអវសានប្បញ្ញត្តិ។

វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ បញ្ញត្តពីគោលការណ៍ជាមូលដ្ឋានថា ចំពោះទំនាក់ទំនងគតិយុត្តជាបន្តត្រូវអនុលោមតាមកិច្ចការកន្លងមក រហូតដល់កាលបរិច្ឆេទនៃការអនុវត្ត និង ត្រូវអនុលោមតាមក្រមរដ្ឋប្បវេណីចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត។ ការសម្របសម្រួលដែលចាំបាច់ដោយសារយកគោលការណ៍នេះត្រូវបានរៀបចំនៅក្នុងជំពូកទី ៥ សម្រាប់ករណីនីមួយៗ។ វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ នេះមិនប្រើពាក្យ "ទំនាក់ទំនងនៃកិច្ចសន្យាជាបន្ត" ទេ ប៉ុន្តែ គឺប្រើពាក្យ "ទំនាក់ទំនងគតិយុត្តជាបន្ត" ហេតុដូច្នេះ បញ្ញត្តិនោះត្រូវអនុវត្តផងដែរចំពោះទំនាក់ទំនងរវាងដីដែលនៅជាប់គ្នា និង ទំនាក់ទំនងនៃឋានៈបុគ្គល ដូចជាអាពាហ៍ពិពាហ៍ ជាអាទិ៍។

កថាខណ្ឌទី ២ បញ្ញត្តថា ទំនាក់ទំនងគតិយុត្តទាំងឡាយណាដែលបានកើតឡើងដោយមានសុពលភាពនៅមុនពេលអនុវត្តក្រមរដ្ឋប្បវេណីត្រូវបន្តមានអានុភាពនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត លើកលែងតែមានកំណត់

ផ្សេងនៅក្នុងជំពូកទី ៥។ តាមពិតទៅ កថាខណ្ឌនេះមិនចាំបាច់មានក៏បានដែរ ពីព្រោះថា បើទោះជាកថាខណ្ឌទី ១ មិនបានទទួលយកគោលការណ៍នៃការអនុវត្តដោយមានអានុភាពប្រតិសកម្មក៏ដោយ ក៏កថាខណ្ឌនេះត្រូវបានតាក់តែងឡើងជាការបង្ការទុកជាមុនដែរ។ យើងមិនមែនគិតត្រឹមតែបទដ្ឋានគតិយុត្តកម្ពុជាប៉ុណ្ណោះទេ ក៏ប៉ុន្តែយើងរាប់បញ្ចូលទាំងបញ្ញត្តិទំនៀមទម្លាប់ផងដែរដើម្បីឱ្យស្របទៅនឹងមាត្រា ៧៩ នៃច្បាប់ភូមិបាលដែលចែងថា "ការចាត់ចែងមរតកត្រូវស្ថិតនៅក្រោមវិធានទាំងឡាយនៃទំលាប់ប្រពៃណីក្នុងរឿងនេះក្នុងពេលរង់ចាំការប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណីថ្មី"។

កថាខណ្ឌទី ៣ ត្រូវបានបញ្ញត្តឡើងដោយហេតុថា ក្រមរដ្ឋប្បវេណីមិនត្រូវអនុវត្តដោយមានអានុភាពប្រតិសកម្មចំពោះបញ្ហាដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណីទេ បើទោះជាមិនមានច្បាប់ពាក់ព័ន្ធនឹងបញ្ហាទាំងនេះ ក្រៅពីច្បាប់ភូមិបាល ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ និង ក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច ក៏ដោយ។ ប្រសិនបើបញ្ហាទាំងឡាយដែលបានកើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តអាចដោះស្រាយបានដោយត្រឹមត្រូវទៅតាមច្បាប់ទាំងនោះ និង បញ្ញត្តិទំនៀមទម្លាប់ នេះជាធម្មតាទេដែលយើងត្រូវអនុវត្តតាមច្បាប់ទាំងនោះ។ ប៉ុន្តែប្រសិនបើគ្មានបញ្ញត្តិច្បាប់ ឬ បទដ្ឋានគតិយុត្ត ឬ ប្រសិនបើមិនអាចកំណត់បានថា មិនមានបញ្ញត្តិទំនៀមទម្លាប់ទេ គេអាចអនុវត្តក្រមរដ្ឋប្បវេណីជាគោលការណ៍សមធម៌បាន។ ដោយហេតុថា នាសម័យកាលបច្ចុប្បន្ន ទោះបីជាគ្មានច្បាប់ជាក់លាក់ក៏ដោយ ក៏ចៅក្រមត្រូវបានអនុញ្ញាតឱ្យធ្វើការសម្រេចសេចក្តីដោយឈរលើគោលការណ៍សមធម៌ដែរ នោះកថាខណ្ឌនេះអាចចាត់ទុកបានថាជាបញ្ញត្តិបន្ថែមចំពោះករណីបែបនេះ។ កថាខណ្ឌនេះគឺផ្អែកទៅលើមូលហេតុដែលថា មានករណីច្រើនដែលក្រមរដ្ឋប្បវេណីដើរតួនាទីជាបញ្ញត្តិបំពេញបន្ថែមចំពោះការបកស្រាយអំពីឆន្ទៈ។ ហេតុដូច្នេះ ប្រសិនបើមានភាពច្បាស់លាស់ហើយថា បញ្ហាមួយអាចត្រូវបានដោះស្រាយបានដោយប្រើច្បាប់ដែលមានស្រាប់ គឺច្បាប់នោះត្រូវយកទៅអនុវត្តចំពោះបញ្ហានោះ ប៉ុន្តែ ប្រសិនបើគ្មានច្បាប់សម្រាប់ដោះស្រាយបញ្ហាណាមួយទេ ក្រមរដ្ឋប្បវេណីនឹងត្រូវយកទៅអនុវត្តចំពោះបញ្ហានោះក្នុងក្របខ័ណ្ឌនៃគោលការណ៍សមធម៌។ ក្នុងករណីបែបនេះ បើទោះជាការខកខានក្នុងការអនុវត្តក្រមរដ្ឋប្បវេណីរបស់ចៅក្រមមិនបង្កជាការមិនអនុវត្តច្បាប់ក៏ដោយ ដោយសារតែមានកថាខណ្ឌនេះហើយ ចៅក្រមគួរតែអនុវត្តក្រមរដ្ឋប្បវេណី។

# ជំពូកទី ២

# បញ្ញត្តិសារធាតុ

## មាត្រា ៦.-ការដាក់ជូនបញ្ជីសារពើភ័ណ្ឌ ជាអាទិ៍ ទៅតុលាការ

១-តុលាការដែលកំណត់ក្នុងកថាខណ្ឌទី ១ មាត្រា ៧២ (ករណីយកិច្ចធ្វើសេចក្តីរាយការណ៍អំពីការស្រាវជ្រាវទ្រព្យសម្បត្តិនីតិបុគ្គល) នៃក្រមរដ្ឋប្បវេណី គឺជាសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនៃទីស្នាក់ការកណ្តាលរបស់នីតិបុគ្គល។

២-តុលាការដែលទទួលការដាក់ជូនបញ្ជីសារពើភ័ណ្ឌជាអាទិ៍ ពីនីតិបុគ្គលអាចស្រាវជ្រាវនីតិបុគ្គលនោះ បង្គាប់ឱ្យនីតិបុគ្គលនោះធ្វើនីតិវិធីដែលកំណត់ក្នុងមាត្រា ៧៨ (ធនក្ស័យនៅក្នុងពេលជម្រះបញ្ជី) នៃក្រមរដ្ឋប្បវេណីភ្លាមៗ និង ធ្វើការចាត់ចែងចាំបាច់ផ្សេងទៀត ដើម្បីធ្វើការជម្រះបញ្ជីឱ្យបានឆាប់រហ័ស និងត្រឹមត្រូវ។

(កំណត់)

មាត្រា ៧២ នៃក្រមរដ្ឋប្បវេណីកំណត់ពីករណីយកិច្ចសេចក្តីរាយការណ៍អំពីការស្រាវជ្រាវទ្រព្យសម្បត្តិនីតិបុគ្គល។ កថាខណ្ឌទី ១ នៃមាត្រា ៧២ នោះចែងថា "ក្រោយពេលឡើងកាន់តំណែង អ្នកជម្រះបញ្ជីត្រូវស្រាវជ្រាវស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់នីតិបុគ្គល ធ្វើបញ្ជីសារពើភ័ណ្ឌ និង តារាងតុល្យការ និង ដាក់ជូនតុលាការដោយគ្មានការយឺតយ៉ាវ" ហើយកថាខណ្ឌផ្សេងទៀតបានចែងថា អ្នកជម្រះបញ្ជីត្រូវទទួលការយល់ព្រមពីមហាសន្និបាតសមាជិក ជាអាទិ៍ ជាមុនសិន មុននឹងដាក់ទៅតុលាការ។ កថាខណ្ឌទី ១ នៃមាត្រានេះកំណត់អំពីតុលាការដែលត្រូវទទួលការដាក់ឯកសារដែលបានកំណត់នៅក្នុងមាត្រា ៧២ នៃក្រមរដ្ឋប្បវេណី។ ប្រហែលជាមានទស្សនៈខ្លះជំទាស់ថា គួរតែកំណត់អំពីបញ្ហានេះនៅក្នុងក្រមរដ្ឋប្បវេណី។ ក៏ប៉ុន្តែ ក្នុងក្រមរដ្ឋប្បវេណីមិនមានបញ្ញត្តិណាមួយដែលកំណត់ច្បាស់លាស់អំពីសមត្ថកិច្ចតុលាការទេ គឺទុកឱ្យក្រមនីតិវិធីរដ្ឋប្បវេណីកំណត់វិញ។ ប្រសិនបើសមត្ថកិច្ចតុលាការមានកំណត់តែក្នុងមាត្រា ៧២ នៃក្រមរដ្ឋប្បវេណី នោះមានបញ្ហាលើភាពស៊ីសង្វាក់គ្នាជាមួយបញ្ញត្តិដទៃទៀត។ ដោយហេតុនេះហើយបានជាយើងចែងអំពីសមត្ថកិច្ចតុលាការក្នុងមាត្រានេះ។

កថាខណ្ឌទី ២ កំណត់ពីចំណុចដែលតុលាការត្រូវធ្វើការចាត់ចែងដែលទទួលឯកសារ។ ដោយយោងតាមមាត្រា ៨២ នៃក្រមរដ្ឋប្បវេណីជប៉ុនដែលផ្តល់ឱ្យតុលាការនូវសិទ្ធិអំណាចក្នុងការធ្វើការស្រាវជ្រាវចាំបាច់ដើម្បីត្រួតពិនិត្យកថាខណ្ឌនេះផ្តល់អំណាចឱ្យតុលាការធ្វើការចាត់ចែងផ្សេងទៀតផងដែរ។ រីឯការដកហូតតំណែងរបស់អ្នកជម្រះបញ្ជីវិញ ដោយហេតុថា មាត្រា ៦៩ នៃក្រមរដ្ឋប្បវេណីកម្ពុជាចែងថា អ្នកជម្រះបញ្ជីអាចត្រូវដកហូតតំណែងបាន

លុះត្រាតែមានពាក្យសុំពីអ្នកដែលពាក់ព័ន្ធផលប្រយោជន៍ ដូច្នេះ ដើម្បីឱ្យមានភាពស៊ីសង្វាក់គ្នាជាមួយខ្លឹមសារនេះ យើងមិនគាត់តែងបញ្ញត្តិអំពីការដកហូតដោយឆន្ទានុសិទ្ធិរបស់តុលាការទេ។ "ការចាត់ចែងចាំបាច់ផ្សេងទៀត" រាប់បញ្ចូលទាំងការទាមទារឱ្យធ្វើសេចក្តីរាយការណ៍បន្ថែមទៀតក្នុងអំឡុងពេលដំណើរការជម្រះបញ្ជី ជាអាទិ៍ ។

## មាត្រា ៧.-ការជូនដំណឹងអំពីការបង្ហាញឆន្ទៈទៅអ្នកនៅឆ្ងាយ

១-ការបង្ហាញឆន្ទៈទៅអ្នកនៅឆ្ងាយ អាចបញ្ជាក់បានដោយប្រើ "ការផ្តល់ដំណឹងឆ្លើយតបពីការបានទទួល" នៃលិខិតអនុសិដ្ឋដែលមាន "ការផ្តល់ដំណឹងឆ្លើយតបពីការបានទទួល" និងឯកសារចម្លងនៃលិខិតដែលត្រូវបានចុះនិទ្ទេសដោយក្រឡាបញ្ជីតុលាការ តាមវិធីខាងក្រោម :

ក-អ្នកបង្ហាញឆន្ទៈត្រូវយកមកនូវលិខិតដែលនឹងត្រូវផ្ញើជូនតាមរយៈលិខិតអនុសិដ្ឋ ឯកសារចម្លងនៃលិខិតនេះ និងរូបមន្តនៃ "ការផ្តល់ដំណឹងឆ្លើយតបពីការបានទទួល" ឱ្យក្រឡាបញ្ជីតុលាការ។ ប្រសិនបើក្រឡាបញ្ជីតុលាការអាចធ្វើឯកសារចម្លងនៃលិខិតនោះដោយខ្លួនឯង ក្រឡាបញ្ជីតុលាការអាចលើកលែងឱ្យអ្នកបង្ហាញឆន្ទៈពីការបង្ហាញឯកសារចម្លងនៃលិខិតនោះបាន។

ខ-ក្រឡាបញ្ជីតុលាការត្រូវ :

-ពិនិត្យ និង បញ្ជាក់ថា ឯកសារនោះពិតជាឯកសារចម្លងនៃលិខិតដែលនឹងត្រូវផ្ញើជូនតាមរយៈលិខិតអនុសិដ្ឋ ឬ ធ្វើឯកសារចម្លងនៃលិខិតដែលនឹងត្រូវផ្ញើជូនតាមរយៈលិខិតអនុសិដ្ឋនោះ

-ដាក់លិខិតដើមនៅក្នុងស្រោមសំបុត្រ និងបិទស្រោមសំបុត្រនោះ

-ចុះលេខដូចគ្នា និងបោះត្រាផ្លូវការនៅរឹមទំព័រនៃឯកសារចម្លងស្រោមសំបុត្រ និងរូបមន្តនៃ "ការផ្តល់ដំណឹងឆ្លើយតបពីការបានទទួល"

-ចុះនិទ្ទេសលើឯកសារចម្លងថា បានធ្វើតាមបែបបទខាងលើនេះ

-ប្រគល់ឯកសារទាំងនេះ ទៅអ្នកបង្ហាញឆន្ទៈ។

នៅពេលធ្វើនីតិវិធីខាងលើនេះ ក្រឡាបញ្ជីតុលាការត្រូវសរសេរថ្ងៃ ខែ ឆ្នាំ លេខ និង ឈ្មោះអ្នកបង្ហាញឆន្ទៈនៅក្នុងសៀវភៅ។

គ-អ្នកបង្ហាញឆន្ទៈត្រូវផ្ញើជូនឯកសារដើមដែលត្រូវបានដាក់ក្នុងស្រោមសំបុត្រ តាមបែបបទខាងលើនេះ តាមលិខិតអនុសិដ្ឋ។

២-ដើម្បីធ្វើនីតិវិធីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកបង្ហាញឆន្ទៈត្រូវបង់ពន្ធដែលត្រូវបានកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ចំណូលពន្ធនេះ ត្រូវបង្វែរចូលទៅថវិការដ្ឋ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវរារាំងវិធីបញ្ជាក់ផ្សេងទៀតឡើយ។

(កំណត់)

មាត្រានេះកំណត់អំពីគំរូនៃវិធីជូនដំណឹងអំពីការបង្ហាញឆន្ទៈទៅអ្នកដែលនៅឆ្ងាយ។ ក្រមនីតិវិធីរដ្ឋប្បវេណីប្រកាន់យកនូវគោលការណ៍ជំនឿទុកចិត្តដោយសេរី ហើយមិនមានការកម្រិតទៅលើការបញ្ជាក់ចំពោះការបង្ហាញឆន្ទៈទេ ដូច្នេះ អនុញ្ញាតឱ្យធ្វើការបញ្ជាក់បានដោយការសាកសួរភាគីបាន។ ប៉ុន្តែ ប្រសិនបើភាគីណាម្ខាងអះអាងថា ខ្លួនបានជូនដំណឹងទៅភាគីម្ខាងទៀតពីការរំលាយកិច្ចសន្យាតាមរយៈសំបុត្រ ឬ តាមរយៈទូរស័ព្ទហើយ តែភាគីម្ខាងទៀតបដិសេធការអះអាងនេះនៅក្នុងអំឡុងពេលនៃការសាកសួរភាគីដោយលើកឡើងថា ខ្លួនមិនដែលបានទទួលការជូនដំណឹងតាមរយៈសំបុត្រ ឬ តាមទូរស័ព្ទទេ (ឬ ភាគីម្ខាងទៀតនោះអះអាងថា ខ្លួនបានទទួលទូរស័ព្ទពិតមែន តែមិនមែនទូរស័ព្ទអំពីការរំលាយកិច្ចសន្យាទេ) វានឹងធ្វើឱ្យមានការពិបាកសម្រាប់ចៅក្រមក្នុងការទទួលស្គាល់អង្គហេតុនៃការបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យា បើផ្អែកតែទៅលើសេចក្តីថ្លែងការណ៍របស់ភាគីតែម្ខាងៗបែបនេះ។ ហេតុដូច្នេះ មាត្រានេះកំណត់អំពីវិធីបញ្ជាក់អំពីការបង្ហាញឆន្ទៈទៅអ្នកនៅឆ្ងាយ ដោយប្រើប្រាស់ប្រព័ន្ធលិខិតអនុសិដ្ឋដែលមានស្រាប់នៅកម្ពុជា។

វិធីនេះមានកំណត់នៅក្នុងកថាខណ្ឌទី ១។ ប្រសិនបើលិខិតដែលមានបោះត្រាដោយក្រឡាបញ្ជីត្រូវបានផ្ញើតាមរយៈលិខិតអនុសិដ្ឋតាមវិធីដែលបានកំណត់ក្នុងបញ្ញត្តិនោះ ប្រៃសណីយ៍នឹងប្រគល់លិខិតនៃការផ្តល់ដំណឹងឆ្លើយតបពីការបានទទួលដែលមានចុះលេខ និង ចុះនិទ្ទេសទៅឱ្យអ្នកផ្ញើ ក្រោយពេលធ្វើការផ្ញើទៅអ្នកដែលត្រូវទទួលលិខិតអនុសិដ្ឋនោះរួចហើយ។ ដោយសារតែលេខដែលចុះនិទ្ទេសលើឯកសារចម្លងដោយក្រឡាបញ្ជីនោះដូចគ្នាទៅនឹងលេខដែលមាននៅក្នុងលិខិតនៃការផ្តល់ដំណឹងឆ្លើយតបពីការបានទទួល ភាគីដែលបង្ហាញឆន្ទៈអាចបង្ហាញឯកសារទាំងពីរដើម្បីបញ្ជាក់ថា ច្បាប់ដើមត្រូវបានផ្ញើទៅភាគីម្ខាងទៀតហើយ។ ប្រសិនបើភាគីម្ខាងទៀតប្រកែកអំពីភាពត្រឹមត្រូវក្នុងការផ្ញើឯកសារទាំងនោះ ក្រឡាបញ្ជីអាចបញ្ជាក់អំពីកាលបរិច្ឆេទ លេខ ព្រមជាមួយនឹងឈ្មោះរបស់

អ្នកបង្ហាញឆន្ទៈនោះ តាមរយៈសៀវភៅដែលសរសេរចូលនូវចំណុចទាំងនោះ ហេតុដូច្នេះ ភាគីដែលបង្ហាញឆន្ទៈអាចបញ្ជាក់អំពីភាពត្រឹមត្រូវនៃឯកសារនោះ (ដូចមានចែងនៅក្នុងវាក្យខណ្ឌទី ២ ចំណុច ក នៃកថាខណ្ឌទី ១ ប្រសិនបើនៅតុលាការមានម៉ាស៊ីនថតចម្លង ក្រឡាបញ្ជីអាចថតចម្លងឯកសារដោយខ្លួនឯងបាន ហើយក្រឡាបញ្ជីគួរតែប្រើវិធីនេះ ដោយសារភាពដូចគ្នានៃច្បាប់ដើម និង ឯកសារចម្លងត្រូវបានធានាដោយមិនចាំបាច់ពិនិត្យអំពីខ្លឹមសារនៃឯកសារទាំងពីរ បើថតចម្លងដោយម៉ាស៊ីនថតចម្លង)។ យើងបានធ្វើការពិភាក្សាជាមួយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍រួចហើយ ហើយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ក៏បានឯកភាពចំពោះវិធីខាងលើនេះដែរ។

កថាខណ្ឌទី ២ កំណត់អំពីការយកពន្ធចំពោះការបញ្ជាក់នេះ។

កថាខណ្ឌទី ៣ ចែងថា ការបង្ហាញឆន្ទៈទៅអ្នកនៅឆ្ងាយអាចបញ្ជាក់បានដោយវិធីផ្សេងទៀតក្រៅពីវិធីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ។ ឧទាហរណ៍ថា ប្រសិនបើអ្នកបង្ហាញឆន្ទៈប្រើប្រព័ន្ធផ្ញើសារតាមរយៈអ៊ិនធើណែត គេអាចបោះពុម្ពចេញពីអ៊ិនធើណែតនូវសារអេឡិចត្រូនិចដែលបានផ្ញើចេញនោះបាន។

## មាត្រា ៨.-និយមន័យនៃលិខិតដែលមានកាលបរិច្ឆេទស្ថាពរ

“លិខិតដែលមានកាលបរិច្ឆេទស្ថាពរ” ដែលកំណត់ក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៤៥៩ (ឧបាទេសកម្មដោយការសង) កថាខណ្ឌទី ២ នៃមាត្រា ៥០៣ (លក្ខខណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) កថាខណ្ឌទី ២ នៃមាត្រា ៨៤១ (លក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) និង កថាខណ្ឌទី ២ នៃមាត្រា ៥០៣ (លក្ខខណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤៥៩ (ឧបាទេសកម្មដោយការសង) និង មាត្រា ៥១៣ (ការបង្កើតអនុប្បទានឋានៈក្នុងកិច្ចសន្យា) នៃក្រមរដ្ឋប្បវេណី សំដៅលើលិខិតខាងក្រោម :

ក-លិខិតយថាភូត។

ចំពោះលិខិតយថាភូត កាលបរិច្ឆេទនៃការធ្វើលិខិតនោះ ត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ។

ខ-លិខិតឯកជនដែលសារការី ឬ ក្រឡាបញ្ជីតុលាការចុះនិទ្ទេសអំពីកាលបរិច្ឆេទដែលខ្លួនត្រូវបានបង្ហាញលិខិតឯកជននេះ និង ចុះហត្ថលេខា។

ក្នុងករណីនេះ កាលបរិច្ឆេទនោះត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ។

គ-លិខិតឯកជនដែលមានជនណាម្នាក់ក្នុងចំណោមជនដែលបានចុះហត្ថលេខាលើលិខិតនោះ បានទទួលមរណភាព។

ក្នុងករណីនេះ ថ្ងៃដែលជននោះទទួលមរណភាព ត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរ។

ឃ-លិខិតឯកជនដែលត្រូវបានយកជាអាគតដ្ឋាន នៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្ថាពរ។

ក្នុងករណីនេះ កាលបរិច្ឆេទនៅក្នុងលិខិតដែលមានកាលបរិច្ឆេទស្ថាពរនោះ ត្រូវក្លាយជាកាលបរិច្ឆេទស្ថាពរសម្រាប់លិខិតឯកជនដែលត្រូវបានយកជាអាគតដ្ឋាននោះ។

(កំណត់)

មាត្រានេះកំណត់អំពីនិយមន័យនៃលិខិតដែលមានកាលបរិច្ឆេទស្ថាពរ ហើយមានគោលគំនិតដូចគ្នានឹងមាត្រា ៥ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីជប៉ុនដែរ។ ទោះបីជាកថាខណ្ឌទី ៣ នៃមាត្រា ៤៥៩ (ឧបាទេសកម្មដោយការសង) កថាខណ្ឌទី ២ នៃមាត្រា ៥០៣ (ល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) និង កថាខណ្ឌទី ២ នៃមាត្រា ៨៤១ (ល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) ជាអាទិ៍ នៃក្រមរដ្ឋប្បវេណីបានចែងថា ចាំបាច់មានលិខិតដែលមានកាលបរិច្ឆេទស្ថាពរដើម្បីតតាំងអនុប្បទានសិទ្ធិលើបំណុល ឬ ការបញ្ចាំសិទ្ធិលើបំណុលចំពោះតតិយជនក៏ដោយ ក៏មិនមានការឱ្យនិយមន័យចំពោះលិខិតដែលមានកាលបរិច្ឆេទស្ថាពរនៅក្នុងមាត្រាទាំងនោះដែរ ដូច្នេះ យើងកំណត់អំពីនិយមន័យនៃលិខិតដែលមានកាលបរិច្ឆេទស្ថាពរនៅក្នុងមាត្រានេះ។

ចំណុចនីមួយៗនៃមាត្រានេះចែងថា លិខិតយថាភូត ជាអាទិ៍ ជាលិខិតដែលមានកាលបរិច្ឆេទស្ថាពរ។ ការកំណត់នូវនិយមន័យ និង វិធីធ្វើ "លិខិតយថាភូត" មិនមានចែងនៅក្នុងចំណុច ក ទេ ប៉ុន្តែមាត្រា ៩ បានកំណត់អំពីរបៀបធ្វើលិខិតយថាភូតប្រភេទខ្លះ ហើយកថាខណ្ឌទី ២ នៃមាត្រា ១១ បានកំណត់អំពីរបៀបធ្វើលិខិតយថាភូតដែលត្រូវធ្វើឡើងដោយមន្ត្រីទទួលបន្ទុកកិច្ចការសារការី។

ប្រសិនបើមានភាពចាំបាច់ក្នុងការផ្ញើលិខិតដែលមានកាលបរិច្ឆេទស្ថាពរទៅភាគីម្ខាងទៀត គឺអាចផ្ញើលិខិតដែលមានកាលបរិច្ឆេទស្ថាពរដូចមានកំណត់ក្នុងមាត្រានេះ តាមរយៈលិខិតអនុសិដ្ឋដូចមានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៧ បានដោយសុវត្ថិភាព។ ចំពោះអនុប្បទានសិទ្ធិលើបំណុល គេក៏អាចប្រើប្រាស់វិធីជាបន្តបន្ទាប់នេះបានផងដែរ គឺអនុប្បទាយី និង កូនបំណុលរៀបចំជាលិខិតឯកជនចំពោះអនុប្បទានសិទ្ធិលើបំណុល (តាមកិច្ចការជាក់ស្តែង

ភាគច្រើនយកលិខិតកិច្ចសន្យាអនុប្បទានសិទ្ធិលើបំណុលរវាងអនុប្បទាយី និង អនុប្បទានិក ដែលកូនបំណុលចុះនិទ្ទេសអំពីការយល់ព្រមអនុប្បទានសិទ្ធិលើបំណុលនោះមកប្រើជាលិខិតឯកជន) ហើយប្រតិបត្តិតាមវិធីដែលបានកំណត់ក្នុងចំណុច ខ ។

## មាត្រា ៩.-អត្ថន័យនៃលិខិតយថាភូត

"លិខិតយថាភូត" ដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតខាងក្រោម :

ក-លិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៣៣៦ (ការបង្កើតកិច្ចសន្យាដោយសំណើ និងស្វីការ) មាត្រា ៥១៦ (ការបង្កើតកិច្ចសន្យាលក់ទិញ) និង មាត្រា ៨៦២ (អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលត្រូវធ្វើឡើងដោយសារការី ឬ លិខិតឯកជនដែលសារការីចុះនិទ្ទេសថាលិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ និងចុះកាលបរិច្ឆេទ និងហត្ថលេខាក្រោយពេលខ្លួនបញ្ជាក់ថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់។ ប៉ុន្តែ ចំពោះលិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៣៣៦ (ការបង្កើតកិច្ចសន្យាដោយសំណើ និងស្វីការ) និង មាត្រា ៨៦២ (អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី លិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើង ដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជីក៏ជាលិខិតយថាភូតដែរ។

ខ-លិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៨៤៥ (ការតតាំងនៃហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី។

គ-លិខិតយថាភូតដែលកំណត់ក្នុងមាត្រា ១១៧២ (បុគ្គលដែលមិនអាចក្លាយជាសាក្សី ជាអាទិ៍) មាត្រា ១១៧៣ (មរតកសាសន៍ដោយលិខិតយថាភូត) និង មាត្រា ១១៨១ (បទប្បញ្ញត្តិពិសេសចំពោះមរតកសាសន៍របស់ជនជាតិខ្មែរដែលរស់នៅបរទេស) នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលត្រូវបានធ្វើឡើងដោយសារការី ឬ កុងស៊ុលតាមបញ្ញត្តិនៃមាត្រានីមួយៗ ខាងលើនេះ។

(កំណត់)

មាត្រានេះកំណត់អំពីនិយមន័យនៃ "លិខិតយថាភូត" ។

មាត្រា ៣៣៦ និង មាត្រា ៨៦២ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានលើកឡើងនៅក្នុងចំណុច ក ចែងថា ចាំបាច់មានលិខិតយថាភូតដើម្បីបង្កើតអានុភាពនៃកិច្ចសន្យាដែលមានគោលបំណងផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ (ដូចជា កិច្ចសន្យាលក់ទិញ ឬ កិច្ចសន្យាប្រទានកម្ម ជាដើម) ឬ ការចាត់ចែងហ៊ីប៉ូតែក។ លើសពីនេះទៅទៀត លិខិតយថាភូត ក៏មានភាពចាំបាច់ដើម្បីធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិ ឬ ការចាត់ចែងហ៊ីប៉ូតែកដែរ។ បើផ្អែកទៅលើស្មារតីនៃបញ្ញត្តិ នៃមាត្រា ៩៤៤ នៃក្រមរដ្ឋប្បវេណីចាស់ និង បញ្ញត្តិចាប់ពីមាត្រា ២ នៃច្បាប់សារការី ឆ្នាំ១៩៥៤ ជាអាទិ៍ លិខិតយថាភូតសម្រាប់ការចុះបញ្ជីអាចជាលិខិតណាមួយ គឺ (១) លិខិតយថាភូតដែលធ្វើឡើងដោយសារការី (ដែល តាមពិតទៅ បច្ចុប្បន្ននេះមិនមានទេ) ឬ (២) ឯកសារដែលមានសរសេរឈ្មោះ អត្តសញ្ញាណដីដែលជាកម្មវត្ថុនៃ ការចុះបញ្ជី និង ចំណុចផ្សេងទៀតដែលត្រូវសរសេរចូលទៅក្នុងទម្រង់ជាក់លាក់មួយ ហើយអនុប្បទាយី អនុប្បទានិក សាក្សីពីររូប ផ្តិតស្នាមមេដៃ និង មេឃុំ ចៅសង្កាត់ ឬ ចៅហ្វាយស្រុក-ខ័ណ្ឌ ចុះហត្ថលេខា និង ប្រថាប់ត្រា ផ្លូវការផងដែរ ចំពោះមុខការិយាល័យចុះបញ្ជី។ ចំពោះមាត្រា ៣៣៦ និង មាត្រា ៨៦២ នៃក្រមរដ្ឋប្បវេណី លិខិតយថាភូតដែលរៀបចំដោយសារការី (រួមបញ្ចូលទាំងឯកសារឯកជនដែលសារការីបានបញ្ជាក់ថា ឯកសារនេះ ស្របតាមច្បាប់ ហើយបានចុះនិទ្ទេសអំពីការបញ្ជាក់នោះ និង កាលបរិច្ឆេទ ហើយចុះហត្ថលេខា) ជាប្រភេទមួយ នៃលិខិតយថាភូត។ ប្រសិនបើមានលិខិតយថាភូតប្រភេទនេះ កិច្ចសន្យាផ្ទេរកម្មសិទ្ធិ និង ការចាត់ចែងហ៊ីប៉ូតែកនឹង បង្កើតអានុភាពតាមក្រមរដ្ឋប្បវេណី។ ប្រសិនបើភាគីម្ខាងទៀតមិនសហការក្នុងការចុះបញ្ជីទេ គេអាចដាក់ពាក្យ បណ្តឹងទៅតុលាការដែលមានកម្មវត្ថុទាមទារឱ្យចុះបញ្ជីបាន ហើយប្រសិនបើសាលក្រម ឬ សាលដីកាទទួលស្គាល់ ការទាមទាររបស់ដើមចោទ ការចុះបញ្ជីអាចត្រូវអនុញ្ញាតឱ្យធ្វើឡើងដោយគ្មានកិច្ចសហការពីភាគីម្ខាងទៀត តាម មាត្រា ៥២៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ មាត្រា ១១ ចែងថា មន្ត្រីទទួលបន្ទុកកិច្ចការសារការីក៏អាចធ្វើលិខិតយថាភូត នេះបានដែរ។

ម្យ៉ាងទៀត លិខិតយថាភូតមានភាពចាំបាច់ដើម្បីធ្វើការចុះបញ្ជី។ តាមច្បាប់ភូមិបាល ប្រសិនបើមានឯកសារ ដែលត្រូវបានរៀបចំឡើងដោយស្ថាប័នមានសមត្ថកិច្ចធ្វើការចុះបញ្ជីដូចមានកំណត់ក្នុងចំណុច (២) ខាងលើ ការចុះ បញ្ជីអាចធ្វើទៅបានដោយមិនចាំបាច់មានលិខិតយថាភូតដែលធ្វើឡើងដោយសារការីទេ។ ប្រសិនបើឯកសារប្រភេទ នេះអាចធ្វើឱ្យការចុះបញ្ជីប្រព្រឹត្តទៅបានដែរ គឺមិនមានបញ្ហាអ្វីទេក្នុងការទទួលស្គាល់អានុភាពនៃការផ្ទេរកម្មសិទ្ធិ ឬ ការចាត់ចែងហ៊ីប៉ូតែកនោះ ដោយទទួលស្គាល់ថា បំពេញល័ក្ខខ័ណ្ឌទម្រង់។ ដោយហេតុនោះបានជាយើងកំណត់ថា ឯកសារប្រភេទនោះគឺជាលិខិតយថាភូតសម្រាប់ការផ្ទេរកម្មសិទ្ធិ ឬ ការចាត់ចែងហ៊ីប៉ូតែក ហើយទទួលស្គាល់ថា ឯកសារនោះបានបំពេញល័ក្ខខ័ណ្ឌទម្រង់តាមច្បាប់សារធាតុ។

បន្ទាប់ពីនេះ លិខិតយថាភូតដែលមានចែងនៅក្នុងមាត្រា ៥១៦ នៃក្រមរដ្ឋប្បវេណី គឺជាឯកសារដែលធ្វើឡើង

ដោយស្ម័គ្រចិត្ត ក្នុងករណីដែលគូភាគីព្រមព្រៀងក្នុងការធ្វើលិខិតយថាភូតដើម្បីជៀសវាងវិវាទនាពេលអនាគត ហេតុដូច្នេះ យើងកម្រិតតែលិខិតយថាភូតដែលបានធ្វើឡើងដោយសារការីប៉ុណ្ណោះ។ ម្យ៉ាងទៀត មាត្រា ១១ នៃច្បាប់នេះចែងថា មន្ត្រីទទួលបន្ទុកកិច្ចការសារការីក៏អាចធ្វើលិខិតយថាភូតប្រភេទនោះបានដែរ។

ចំណុច ខ កំណត់អំពីនិយមន័យនៃលិខិតយថាភូតសម្រាប់កិច្ចសន្យាបង្កើតហ៊ីប៉ូតែក។ ដោយសារមាត្រា ៨៤៤ នៃក្រមរដ្ឋប្បវេណីកំណត់ថា ហ៊ីប៉ូតែកអាចត្រូវបង្កើតឡើងដោយកិច្ចព្រមព្រៀងផ្ទាល់មាត់ ដូច្នេះ លិខិតយថាភូតដូចមានកំណត់ក្នុងមាត្រា ៨៤៥ សំដៅទៅលើឯកសារដែលចាំបាច់សម្រាប់ធ្វើការចុះបញ្ជី។ ហេតុដូច្នេះ ចំណុច ខ នៃមាត្រានេះចែងថា លិខិតយថាភូតនៃមាត្រា ៨៤៥ នោះ សំដៅទៅលើលិខិតដែលរៀបចំដោយស្ថាប័នមានសមត្ថកិច្ចដើម្បីធ្វើការចុះបញ្ជី។

ចំណុច គ កំណត់អំពីនិយមន័យនៃមតកសាសន៍ដោយលិខិតយថាភូត។ មាត្រានេះចង្អុលបង្ហាញមាត្រាយោងពីព្រោះចំណុចពាក់ព័ន្ធនឹងបញ្ហាថាតើអ្នកណាជាអ្នករៀបចំ ហើយត្រូវរៀបចំយ៉ាងដូចម្ដេច គឺមានកំណត់លម្អិតក្នុងមាត្រា ១១៧២ មាត្រា ១១៧៣ និង មាត្រា ១១៨១ នៃក្រមរដ្ឋប្បវេណីរួចហើយ ។

## មាត្រា ១០.-ការកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី

១-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី ដែលត្រូវទទួលបន្ទុកកិច្ចការសារការីជាបណ្ដោះអាសន្នតាមតម្រូវការចាំបាច់ នៅក្នុងអំឡុងពេលរហូតដល់មានការកំណត់ផ្សេងនៅក្នុងច្បាប់មិនលើសពី ២ នាក់ នៅក្នុងដែនសមត្ថកិច្ចនៃសាលាដំបូង ក្នុងចំណោមចៅក្រម ព្រះរាជអាជ្ញា ឬ ឥស្សរជនជាមន្ត្រីរាជការសាធារណៈ ដែលមានបទពិសោធន៍ការងារផ្នែកវិស័យច្បាប់ និងមានសញ្ញាបត្រនីតិសាស្ត្រចាប់ពីបរិញ្ញាបត្រឡើងទៅ។

២-ចៅក្រមដែលត្រូវបានកំណត់ថាជាមន្ត្រីទទួលបន្ទុកកិច្ចការសារការី ត្រូវបានចាត់ទុកថា មានហេតុនៃការដកហូតសមត្ថកិច្ចដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៧ (ការដកហូតចៅក្រមពីសមត្ថកិច្ចជំនុំជម្រះ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះរឿងក្ដីដែលខ្លួនបានចាត់ចែងកិច្ចការសារការី។

៣-ចំពោះសារការី និងមន្ទីរសារការីដែលបានតែងតាំងនិងបង្កើតឡើងមុនច្បាប់នេះ ត្រូវបន្តមានសមត្ថកិច្ចបំពេញកិច្ចការសារការីស្របតាមក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និង ច្បាប់ជាធរមាន។

(កំណត់)

មាត្រានេះ និង មាត្រា ១១ គឺជាបញ្ញត្តិស្ដីពីមន្ត្រីទទួលបន្ទុកកិច្ចការសារការី។ សារការីមានភាពចាំបាច់ដើម្បីអនុវត្តក្រមរដ្ឋប្បវេណីប្រកបដោយភាពរលូន និង ដើម្បីប្រតិបត្តិការជួញដូរប្រកបដោយសុវត្ថិភាព ប៉ុន្តែដោយសារតែប្រព័ន្ធសារការីដែលបានកំណត់ក្នុងច្បាប់សារការីចាស់មិនមានដំណើរការនាពេលបច្ចុប្បន្ន ទើបយើងសម្រេចថាបង្កើតប្រព័ន្ធមន្ត្រីទទួលបន្ទុកកិច្ចការសារការីដែលជាប្រព័ន្ធបណ្ដោះអាសន្នរហូតដល់ពេលមានច្បាប់សារការីថ្មី។

មាត្រានេះពាក់ព័ន្ធជាមួយនឹងការកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី។ កថាខណ្ឌទី ១ ចែងថា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការីពីសំណាក់ចៅក្រម ព្រះរាជអាជ្ញា ឬ ឥស្សរជនជាមន្ត្រីរាជការសាធារណៈដែលមានបទពិសោធន៍ការងារផ្នែកវិស័យច្បាប់ និង មានសញ្ញាបត្រនីតិសាស្ត្រចាប់ពីបរិញ្ញាបត្រឡើងទៅ។ ដោយសារតែប្រព័ន្ធសារការីអាចចាត់ទុកថាជាប្រព័ន្ធរដ្ឋបាលវិស័យយុត្តិធម៌ តាមលក្ខណៈនៃប្រព័ន្ធនេះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី។

កថាខណ្ឌទី ២ ចែងថា ក្នុងករណីដែលចៅក្រមត្រូវបានកំណត់ជាមន្ត្រីទទួលបន្ទុកកិច្ចការសារការី ប្រសិនបើចៅក្រមនោះទទួលបន្ទុករឿងក្ដីដែលខ្លួនបានចាត់ចែងកិច្ចការសារការី វាមិនមានលក្ខណៈសមរម្យឡើយ ហេតុដូច្នេះក្នុងករណីនេះ ត្រូវចាត់ទុកថាមានហេតុដែលត្រូវដកហូតចៅក្រមតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ហេតុដូច្នេះ ចំពោះសាលាដំបូងណាដែលមានចៅក្រមមិនសូវច្រើន គួរតែកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការីពីក្នុងចំណោមព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារង។

## មាត្រា ១១.-សិទ្ធិអំណាចរបស់មន្ត្រីទទួលបន្ទុកកិច្ចការសារការី ជាអាទិ៍

១-មន្ត្រីទទួលបន្ទុកកិច្ចការសារការី ត្រូវធ្វើកិច្ចការរបស់សារការី ដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី និងច្បាប់នេះ ដូចជាការផ្ដល់សេចក្ដីបញ្ជាក់លើលក្ខន្តិកៈ ការធ្វើលិខិតយថាភូត ជាអាទិ៍ ជាបណ្ដោះអាសន្ន។

២-ដើម្បីធ្វើលិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៩ (អត្ថន័យនៃលិខិតយថាភូត) នៃច្បាប់នេះ មន្ត្រីទទួលបន្ទុកកិច្ចការសារការី ត្រូវពិនិត្យ និង បញ្ជាក់អត្តសញ្ញាណរបស់ភាគីដោយសាក្សី ឬ សំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើត ហើយក្រៅពីនេះត្រូវធ្វើការចាត់ចែងដែលកំណត់ក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌។

៣-បុគ្គលដែលប្រើប្រាស់សេវារបស់មន្ត្រីទទួលបន្ទុកកិច្ចការសារការីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបង់ពន្ធ។ ចំណូលពន្ធនេះត្រូវបង្វែរ

ចូលទៅថវិការដ្ឋ។

៤-ការបង្កើតលិខិតយថាភូត ដែលត្រូវបានធ្វើឡើងដោយមន្ត្រីទទួលបន្ទុកកិច្ចការសារការី ការប្រគល់ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ ដែលមានអានុភាពដូចគ្នានឹងច្បាប់ដើមនៃលិខិតយថាភូត និងចំណុចចាំបាច់ផ្សេងទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

៥-ប្រាក់ពន្ធ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

(កំណត់)

បញ្ញត្តិនេះកំណត់ពីសិទ្ធិអំណាចរបស់មន្ត្រីទទួលបន្ទុកកិច្ចការសារការី។

កថាខណ្ឌទី ១ ចែងថា មន្ត្រីទទួលបន្ទុកកិច្ចការសារការីត្រូវធ្វើកិច្ចការរបស់សារការីជាបណ្ដោះអាសន្ន ដូចជាការផ្ដល់សេចក្ដីបញ្ជាក់លើលក្ខន្តិកៈ និង ការធ្វើលិខិតយថាភូត ជាអាទិ៍ ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី និងក្នុងច្បាប់នេះ។ មន្ត្រីទទួលបន្ទុកកិច្ចការសារការីអាចធ្វើត្រឹមតែ "កិច្ចការសារការីដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី និង ច្បាប់នេះ" ប៉ុណ្ណោះ ហើយមិនមានសិទ្ធិរៀបចំធ្វើលិខិតដែលបញ្ជាក់សេចក្ដីថ្លែងការណ៍ថា កូនបំណុលនឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីទេ។ សិទ្ធិអំណាចរបស់មន្ត្រីទទួលបន្ទុកកិច្ចការសារការីដែលមាននៅក្នុងច្បាប់នេះមាន ដូចជាការធ្វើលិខិតដែលមានកាលបរិច្ឆេទស្ថាពរដែលកំណត់ក្នុងចំណុច ខ នៃមាត្រា ៨ ជាអាទិ៍។ មន្ត្រីទទួលបន្ទុកកិច្ចការសារការីមិនអាចធ្វើ "លិខិតយថាភូត" ដែលមានចែងក្នុងមាត្រា ៥៦ នៃច្បាប់នេះបានទេ ពីព្រោះតែលិខិតនោះត្រូវបានធ្វើឡើងតាមច្បាប់ភូមិបាល ហើយត្រូវបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត។

កថាខណ្ឌទី ២ កំណត់អំពីចំណុចដែលទាមទារឱ្យមានការប្រុងប្រយ័ត្ននៅពេលធ្វើលិខិតយថាភូត។ ការបញ្ជាក់ទៅលើអត្តសញ្ញាណគឺជាបញ្ហាសំខាន់បំផុតដែលត្រូវយកចិត្តទុកដាក់នៅពេលធ្វើលិខិតយថាភូត។ បន្ថែមពីលើនេះ ចំណុច ក នៃមាត្រា ៩ បានកំណត់ខ្លះៗអំពីរបៀបធ្វើលិខិតយថាភូត។

កថាខណ្ឌទី ៣ គឺជាបញ្ញត្តិស្ដីពីពន្ធ។

កថាខណ្ឌទី ៤ ចែងថា ចំណុចលម្អិតទាក់ទងនឹងការបង្កើតលិខិតយថាភូតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ តុលាការត្រូវរក្សាទុកលិខិតយថាភូតច្បាប់ដើម ដូចមូលសាលក្រមដែរ ហើយប្រគល់ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ទៅឱ្យអ្នកស្នើសុំ (ធ្វើដូច្នេះគឺដើម្បីជៀសវាងការបាត់បង់ និង ការលួចកែប្រែច្បាប់ដើម)។ លើសពីនេះទៅទៀត ដោយសារតែវាមានភាពសមរម្យដែរដែលចែងនៅក្នុងច្បាប់នេះថា ឯកសារចម្លង

ដែលមានសេចក្តីបញ្ជាក់នោះមានអានុភាពដូចគ្នានឹងច្បាប់ដើមនៃលិខិតយថាភូត ទើបបានកំណត់អំពីចំណុចនេះក្នុងកថាខណ្ឌទី ៤។

## មាត្រា ១២.-ការប្រកាសជាសាធារណៈ

១-ការប្រកាសជាសាធារណៈដែលកំណត់ក្នុងកថាខណ្ឌទី ២ មាត្រា ១៩១ (កម្មសិទ្ធិវត្ថុបាត់) នៃក្រមរដ្ឋប្បវេណី ត្រូវធ្វើឡើងដោយប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាល ឃុំ សង្កាត់ ដែលកំណត់ក្នុងកថាខណ្ឌដដែលនោះ ដោយវិធីបិទប្រកាសដែលសរសេរអំពីប្រភេទ និង លក្ខណៈនៃវត្ថុរើស ព្រមទាំងកាលបរិច្ឆេទ និង ទីកន្លែងដែលរើសវត្ថុនោះនៅកន្លែងបិទប្រកាសរបស់ប៉ុស្តិ៍នគរបាលនោះ។

២-ការប្រកាសជាសាធារណៈដែលកំណត់ក្នុងមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) កថាខណ្ឌទី ២ នៃមាត្រា ១២៩១ (ការជ្រើសតាំងអ្នកគ្រប់គ្រង) មាត្រា ១២៩៦ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុលជាអាទិ៍) ឬ កថាខណ្ឌទី ១ នៃមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈ ស្វែងរកសន្តតិជន) នៃក្រមរដ្ឋប្បវេណី ត្រូវធ្វើឡើងដោយបិទប្រកាសរបស់តុលាការ និងការចុះក្នុងព្រឹត្តិបត្ររបស់ក្រសួងយុត្តិធម៌។

(កំណត់)

មាត្រានេះកំណត់អំពីនីតិវិធីលម្អិតស្តីពីការប្រកាសជាសាធារណៈដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី។

## មាត្រា ១៣.-សិទ្ធិរបស់កម្មសិទ្ធិករនៃដី

១-ចំពោះកម្មសិទ្ធិលើដី "ការប្រើប្រាស់ និងការអាស្រ័យផលវត្ថុដែលជាកម្មសិទ្ធិ" ដែលកំណត់ក្នុងមាត្រា ១៣៨ (និយមន័យនៃកម្មសិទ្ធិ) នៃក្រមរដ្ឋប្បវេណី ត្រូវរួមបញ្ចូលការរៀបចំ ឬ ការកែប្រែដោយសេរីនូវប្រភេទ និងរចនាសម្ព័ន្ធដើមនៃដី ស្របតាមការប្រើប្រាស់ដែលកម្មសិទ្ធិករចង់ធ្វើតាមការកំណត់នៃច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត។

២-ត្រូវចាត់ទុកជាការកែប្រែនូវប្រភេទ ឬ រចនាសម្ព័ន្ធដើមនៃដី ចំពោះការ

អនុវត្តកថាខណ្ឌទី ១ ខាងលើនេះ មានការគាស់រានដី ការកាប់ព្រៃឈើ ការដាំដំណាំលើដីនោះ ការចាក់បំពេញដី ការឈូសពង្រាបភ្នំ ការជីកយកដីចេញ ការជីកអណ្ដូងរ៉ែ ឬ កន្លែងយកថ្ម ការរៀបចំ ឬ ការធ្វើឱ្យស្ងួតដែនវារិជាត ការរៀបចំដីកសិកម្មទៅជាដីប្រជុំជន ការបង្កើតតំបន់ឧស្សាហកម្ម និង ការបង្កើតទីតាំងរោងចក្រ ជាអាទិ៍។

(កំណត់)

មាត្រានេះគឺជាបញ្ញត្តិបកស្រាយដើម្បីបញ្ជាក់ច្បាស់លាស់នូវបញ្ញត្តិនៃមាត្រា ១៣៨ នៃក្រមរដ្ឋប្បវេណី ។ មាត្រា ១៣៨ នេះបានចែងថា "កម្មសិទ្ធិ សំដៅទៅលើសិទ្ធិដែលកម្មសិទ្ធិករនោះអាចប្រើប្រាស់ អាស្រ័យផល និង ចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួន ដោយសេរីបាន នៅក្នុងទំហំដែលច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងៗទៀតបានកម្រិត" មានន័យថា កម្មសិទ្ធិករមានសិទ្ធិអំណាចប្រើប្រាស់ដោយខ្លួនឯង ជាអាទិ៍ នូវវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួន ហើយអាចសន្និដ្ឋានថា ក្នុងសិទ្ធិអំណាចនោះ មានសិទ្ធិរៀបចំ និង កែប្រែនូវប្រភេទ និង រចនាសម្ព័ន្ធដើមនៃដីផងដែរ ។

ដោយឡែកមាត្រា ៨៨ និង មាត្រា ៨៩ នៃច្បាប់ភូមិបាលកំណត់អំពីសិទ្ធិអំណាចរបស់កម្មសិទ្ធិករក្នុងការរៀបចំ និង កែប្រែនូវប្រភេទ និង រចនាសម្ព័ន្ធនៃដី ព្រមទាំងកំណត់អំពីវិធីជាក់ស្ដែងនៃការរៀបចំ និង កែប្រែ រីឯក្នុងក្រមរដ្ឋប្បវេណី គ្មានបញ្ញត្តិដូចមាត្រាទាំងពីរនោះទេ គឺទុកឱ្យបកស្រាយដូចខាងលើ។ មាត្រានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងបញ្ជាក់អំពីចំណុចនេះដើម្បីជៀសវាងមន្ទិលសង្ស័យក្នុងការបកស្រាយ (មានការបារម្ភថា អាចមានការបកស្រាយថា ក្រមរដ្ឋប្បវេណីមិនទទួលស្គាល់សិទ្ធិអំណាចនោះ ដោយសារបញ្ញត្តិនៃមាត្រា ៨៨ និង មាត្រា ៨៩ នៃច្បាប់ភូមិបាលមិនត្រូវបានបញ្ចូលនៅក្នុងក្រមរដ្ឋប្បវេណី ទោះបីជាបញ្ញត្តិសារធាតុផ្សេងៗនៃច្បាប់ភូមិបាលត្រូវបានបញ្ចូលនៅក្នុងក្រមរដ្ឋប្បវេណីក៏ដោយ) ។

កថាខណ្ឌទី ១ នៃមាត្រានេះចែងជាបញ្ញត្តិបកស្រាយមាត្រា ១៣៨ នៃក្រមរដ្ឋប្បវេណីអំពីផ្នែកសំខាន់នៃមាត្រា ៨៨ នៃច្បាប់ភូមិបាល។ ហើយកថាខណ្ឌទី ២ គឺជាបញ្ញត្តិបកស្រាយកថាខណ្ឌទី ១ ដែលយកខ្លឹមសារទាំងស្រុងនៃមាត្រា ៨៩ នៃច្បាប់ភូមិបាលមកបញ្ចូល (ពាក្យថា "ក្នុងន័យនៃច្បាប់នេះ" ក្នុងមាត្រា ៨៩ ត្រូវបានកែប្រែទៅជា "ចំពោះការអនុវត្តកថាខណ្ឌទី ១ ខាងលើនេះ" វិញ) ។

## មាត្រា ១៤.-គោគៈ

១-ចំពោះដីដែលប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីថ្មី ត្រូវបានចេញ ក្រៅពីត្រូវអនុលោមតាមបញ្ញត្តិនៃច្បាប់

ភូមិបាលដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ (តទៅហៅថា "ច្បាប់ភូមិបាល ឆ្នាំ ២០០១") និង មាត្រា ២៤២ (ការការពារភោគីអចលនវត្ថុដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់) នៃក្រមរដ្ឋប្បវេណី បញ្ញត្តិនៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះដីនោះ ដោយចាត់ទុកថាភោគៈដែលប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីនោះ ត្រូវបានចេញជាកម្មសិទ្ធិ លើកលែងតែបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈភោគៈនោះ។

២-បុគ្គលដែលទទួលការចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ឬ អនុប្បទានិករបស់បុគ្គលនោះ អាចបង្កើតសិទ្ធិប្រត្យក្ស ប្រើប្រាស់ និង អាស្រ័យផល ឬ សិទ្ធិប្រាតិភោគប្រត្យក្សបាន ដោយអនុលោមទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ។

(កំណត់)

មាត្រានេះ និង មាត្រាពីរបន្ទាប់ (មាត្រា ១៥ និង មាត្រា ១៦) គឺជាបញ្ញត្តិអំពីដីដែលប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីត្រូវបានចេញ ដោយយោងតាមច្បាប់ភូមិបាល និង បទដ្ឋានគតិយុត្តពាក់ព័ន្ធ។ ច្បាប់ភូមិបាលមានបញ្ញត្តិអំពីការបង្កើតឡើងវិញនូវកម្មសិទ្ធិលើអចលនវត្ថុ ចាប់ពីមាត្រា ២៩។ ជាពិសេស មាត្រា ៣៩ ចែងថា ភោគៈដែលស្របតាមបញ្ញត្តិនៃច្បាប់នេះបង្កើតបានជាសិទ្ធិភណ្ឌិក (សិទ្ធិប្រត្យក្ស) ហើយភោគៈនេះអាចជាកម្មវត្ថុនៃការផ្លាស់ប្តូរ ផ្ទេរសិទ្ធិ ឬ ជាកម្មវត្ថុនៃកិច្ចការជំនួញ។ ម្យ៉ាងទៀត មាត្រា ២៤២ នៃក្រមរដ្ឋប្បវេណីកំណត់អំពីការការពារអ្នកកាន់កាប់ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី។ ប៉ុន្តែចំពោះភោគៈនេះ ដីដែលត្រូវបានចុះបញ្ជីមានលក្ខណៈដាច់ដោយដុំដោយយោងតាមបញ្ញត្តិនៃមាត្រា ៤០ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១ ជាអាទិ៍ ជាសារវន្ត ស្ទើរតែគ្មានភាពខុសគ្នានឹងដីដែលជាកម្មវត្ថុនៃកម្មសិទ្ធិ ហេតុដូច្នេះ យើងអាចសន្និដ្ឋានថា ការអនុវត្តបញ្ញត្តិនៃក្រមរដ្ឋប្បវេណីទាំងស្រុងចំពោះភោគៈ នោះគឺជាការសមរម្យ។ ដោយហេតុនេះ កថាខណ្ឌទី ១ នៃមាត្រានេះចែងថា ចំពោះដីដែលត្រូវបានចុះបញ្ជីភោគៈ ហើយដែលប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីត្រូវបានចេញ ភោគៈដែលប័ណ្ណនោះត្រូវបានចេញ ត្រូវបានចាត់ទុកថាជាកម្មសិទ្ធិក្នុងទំហំនៃការអនុវត្តក្រម

រដ្ឋប្បវេណី។

ម្យ៉ាងទៀត នៅក្នុងកថាខណ្ឌទី ១ នេះ មានពាក្យថា "លើកលែងតែបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈភោគៈ" ដែលទុកលទ្ធភាពក្នុងការបកស្រាយ ។ នេះគឺដើម្បីទប់ស្កាត់កុំឱ្យធ្វើលទ្ធកម្មដោយអាជ្ញាយុកាល ជាអាទិ៍ ។

កថាខណ្ឌទី ២ ចែងថា "ភោគីអាចបង្កើតសិទ្ធិប្រត្យក្សផ្សេង ដូចជាហ៊ីប៉ូតែក ឬ សិទ្ធិជួលអចិន្ត្រៃយ៍ ជាអាទិ៍ ដោយអនុលោមទៅតាមកថាខណ្ឌទី ១" មានន័យថា ក្នុងកម្រិតដែលភោគៈនោះត្រូវបានចាត់ទុកថាជាកម្មសិទ្ធិ ចំពោះការអនុវត្តក្រមរដ្ឋប្បវេណី។ ក្នុងករណីដែលអនុវត្តហ៊ីប៉ូតែកដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី អ្នកទិញធ្វើលទ្ធកម្មកម្មសិទ្ធិ ប៉ុន្តែ ចំពោះការអនុវត្តហ៊ីប៉ូតែកដោយផ្អែកលើភោគៈវិញ កម្មវត្ថុនៃការលក់ដោយបង្ខំមិនមែនជាកម្មសិទ្ធិលើដីទេ គឺភោគៈ។ ម្យ៉ាងទៀត ចំពោះសិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល ក៏ដូចគ្នាដែរ គឺសិទ្ធិទាំងនោះដែលត្រូវបានបង្កើតលើដីភោគៈ មិនមែនផ្អែកលើកម្មសិទ្ធិឡើយ ហេតុដូច្នេះ សិទ្ធិនោះមិនមែនជាសិទ្ធិជួលអចិន្ត្រៃយ៍ ជាអាទិ៍ ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីទេ គឺជាសិទ្ធិដែលត្រូវបានទទួលស្គាល់គ្រាន់តែក្នុងកម្រិតដែលភោគៈនោះត្រូវបានចាត់ទុកថាជាកម្មសិទ្ធិចំពោះការអនុវត្តក្រមរដ្ឋប្បវេណីប៉ុណ្ណោះ។ កថាខណ្ឌទី ២ រំឭកបញ្ជាក់អំពីចំណុចនេះ។

## មាត្រា ១៥.-ករណីលទ្ធកម្មកម្មសិទ្ធិ

១-ក្នុងករណីដែលបុគ្គលដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៤ (ភោគៈ) ខាងលើនេះ បានធ្វើលទ្ធកម្មកម្មសិទ្ធិលើដី ដោយយោងតាមបញ្ញត្តិនៃច្បាប់ភូមិបាល ឆ្នាំ ២០០១ សិទ្ធិដែលត្រូវបានបង្កើតលើដីនោះ មុនពេលលទ្ធកម្មនោះ ត្រូវក្លាយទៅជាសិទ្ធិដែលយកកម្មសិទ្ធិលើដីនោះ ឬ ដីដដែលជាកម្មវត្ថុនៃកម្មសិទ្ធិនោះមកធ្វើជាកម្មវត្ថុ។

២-ក្នុងការអនុវត្តក្រមរដ្ឋប្បវេណី ប្រសិនបើបញ្ហាអំពីអំឡុងពេលកើតឡើងចំពោះសិទ្ធិដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អំឡុងពេលត្រូវគណនា ចាប់ពីពេលដែលសិទ្ធិនោះត្រូវបានបង្កើតជាដំបូង។ ប៉ុន្តែ ចំពោះអាជ្ញាយុកាលនៃលទ្ធកម្មអំឡុងពេលនោះ ត្រូវគណនាចាប់ពីពេលដែលដីដែលនឹងត្រូវបានធ្វើលទ្ធកម្មនោះបានក្លាយទៅជាកម្មវត្ថុនៃកម្មសិទ្ធិ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីករណីដែលភោគីបានធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើដី ដោយយោងតាមបញ្ញត្តិនៃច្បាប់ភូមិបាល។

ក្នុងករណីនេះ ភោគីធ្វើលទ្ធកម្មកម្មសិទ្ធិដំបូង ហេតុដូច្នេះ ប្រសិនបើភោគីបានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្ស ជាអាទិ៍ ដោយផ្អែកលើភោគៈនោះ មានបញ្ហាកើតឡើងថាតើសិទ្ធិនោះត្រូវក្លាយទៅជាសិទ្ធិអ្វី។ មាត្រានេះកំណត់ថា "សិទ្ធិដែលត្រូវបានបង្កើតលើដីនោះ ត្រូវក្លាយទៅជាសិទ្ធិដែលយកកម្មសិទ្ធិលើដីនោះ ឬ ដីដដែលជាកម្មវត្ថុនៃកម្មសិទ្ធិនោះមកធ្វើជាកម្មវត្ថុ" មានន័យថា សិទ្ធិដែលផ្អែកលើភោគៈត្រូវក្លាយទៅជាសិទ្ធិដែលយកដី ឬ កម្មសិទ្ធិលើដីមកធ្វើជាកម្មវត្ថុដោយស្វ័យប្រវត្តិ។ ម្យ៉ាងទៀត ក្នុងករណីដែលភោគីបានបង្កើតហ៊ីប៉ូតែកលើដីភោគៈ ហើយហ៊ីប៉ូតែកនោះត្រូវបានចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ នោះហ៊ីប៉ូតែកក៏ត្រូវចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ដោយចម្លងពីសៀវភៅចាស់ដែរនៅពេលចុះបញ្ជីកម្មសិទ្ធិ។

កថាខណ្ឌទី ២ ជាបញ្ញត្តិសម្រាប់ការគណនាក្នុងករណីខាងលើនេះ។ លក្ខណៈជាសារវន្តនៃសិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល ជាអាទិ៍ ដែលត្រូវបានបង្កើតដោយយោងតាមបញ្ញត្តិនៃមាត្រា ១៤ ខាងលើនេះ គ្មានភាពខុសគ្នានឹងសិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល ជាអាទិ៍ ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីទេ ហេតុដូច្នេះ កថាខណ្ឌទី ២ ចែងថា អំឡុងពេលត្រូវគណនាចាប់ពីពេលដែលសិទ្ធិត្រូវបានបង្កើតជាដំបូង។ ប៉ុន្តែចំពោះអាជ្ញាយុកាលនៃលទ្ធកម្មវិញមានអញ្ញត្រកម្ម ដូច្នេះ វាក្យខណ្ឌទី ២ បានបញ្ជាក់អំពីចំណុចនេះ។ ដោយយោងតាមវាក្យខណ្ឌទី ២ នេះ មានភាពច្បាស់លាស់ថា ចំពោះដីដែលភោគៈត្រូវបានចុះបញ្ជី ទោះបីជាកាន់កាប់ដីនោះដោយមានឆន្ទៈយកជាកម្មសិទ្ធិក៏ដោយ ក៏ភោគីនោះមិនអាចធ្វើលទ្ធកម្មនូវកម្មសិទ្ធិឡើយ។

## មាត្រា ១៦.-អន្តរប្បញ្ញត្តិ

បញ្ញត្តិនៃមាត្រា ៣៨ (អានុភាពនៃសិទ្ធិប្រត្យក្សដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត) បញ្ញត្តិចាប់ពីមាត្រា ៤១ (អំឡុងពេលដែលសិទ្ធិជួលរយៈពេលវែងតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្តមានអត្ថិភាព) ដល់មាត្រា ៤៣ (អន្តរប្បញ្ញត្តិស្តីពីសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ដែលត្រូវបានចុះបញ្ជី) និងបញ្ញត្តិចាប់ពីមាត្រា ៥៤ (ការធានាកាតព្វកិច្ច តាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត) ដល់មាត្រា ៥៧ (អំឡុងពេលដែលសិទ្ធិលើការបញ្ចាំអចលនវត្ថុមានអត្ថិភាព) នៃច្បាប់នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីដែលប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ត្រូវបានចេញនៅមុនកាលបរិច្ឆេទនៃការអនុវត្ត។

(កំណត់)

មាត្រានេះជាបញ្ញត្តិអំពីភោគៈដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត។ ច្បាប់នេះមានអន្តរប្បញ្ញត្តិដែលចាំបាច់សម្រាប់ការអនុវត្តក្រមរដ្ឋប្បវេណីនៅក្នុងជំពូកទី ៥។ ប៉ុន្តែ ចំពោះភោគៈដែលត្រូវបានចុះបញ្ជី ក៏គួរតែមានបញ្ញត្តិបែបនេះដែរ ហេតុដូច្នេះ មាត្រានេះត្រូវបានរៀបចំឡើង។

មាត្រានេះចង្អុលបង្ហាញមាត្រាដែលចាំបាច់មានអន្តរប្បញ្ញត្តិសម្រាប់ភោគៈ ហើយឱ្យយកមកអនុវត្តដូចគ្នាផងដែរចំពោះភោគៈនោះ។ ចំពោះមាត្រានីមួយៗ សូមមើលសេចក្តីកំណត់សម្រាប់មាត្រានីមួយៗនោះ។

## មាត្រា ១៧.-អត្រាការប្រាក់ដែលត្រូវបានកម្រិត ជាអាទិ៍

១-អត្រាការប្រាក់ដែលត្រូវបានកម្រិត ដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥៨៥ (ការកម្រិតការប្រាក់) នៃក្រមរដ្ឋប្បវេណី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រឹមអត្រាចាប់ពី ១០ (ដប់) ភាគរយទៅ ៣០ (សាមសិប) ភាគរយក្នុង ១ (មួយ) ឆ្នាំ។

២-ចំពោះការព្រមព្រៀងអំពីការកំណត់ជាមុននូវចំនួននៃសំណង ក្នុងករណីមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ ប្រសិនបើផលចែកនៃចំនួនប្រាក់សំណងការខូតខាតដែលបានកំណត់មុន នោះជាមួយនឹងប្រាក់ដើម លើសពីអត្រាដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ភាគដែលលើសនោះត្រូវទុកជាមោឃៈ។

៣-ប្រកាសខាងលើអាចកំណត់អត្រាដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើបាន ត្រឹមទំហំពី ១,២ ទៅ ២ ដង នៃអត្រាការប្រាក់ដែលត្រូវបានកម្រិត ដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ។

៤-កថាខណ្ឌទី ៣ និង កថាខណ្ឌទី ៤ នៃមាត្រា ៥៨៥ (ការកម្រិតការប្រាក់) នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីកូនបំណុលដែលបានបង់ផ្នែកលើស ដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើ។

៥-បញ្ញត្តិនៃកថាខណ្ឌទី ២ និង កថាខណ្ឌទី ៤ ខាងលើ ត្រូវអនុវត្តចំពោះប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ដោយចាត់ទុកថា ប្រាក់ធានានោះជាការកំណត់ជាមុននូវចំនួននៃសំណងក្នុងកម្រិតនៃការអនុវត្តបញ្ញត្តិនៃកថាខណ្ឌទី ២

និង  កថាខណ្ឌ ទី ៤ ខាងលើនេះ។

៦-ក្នុងករណីមិនមានការសន្យាពិសេសណាមួយស្តីពីប្រាក់សំណងការខូចខាត ចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច  ក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ដែលភ្ជាប់ជាមួយនឹងការប្រាក់ បញ្ញត្តិនៃមាត្រានេះ និង មាត្រា ៥៨៥ (ការកម្រិតការប្រាក់) នៃក្រមរដ្ឋប្បវេណី ត្រូវអនុវត្តចំពោះប្រាក់សំណងការខូតខាតចំពោះការយឺតយ៉ាវ ដោយចាត់ទុកថា ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវនោះជាការប្រាក់ ក្នុងកម្រិតនៃការអនុវត្តបញ្ញត្តិនៃមាត្រានេះ និង  មាត្រា ៥៨៥ (ការកម្រិតការប្រាក់) នៃក្រមរដ្ឋប្បវេណីនោះ។

(កំណត់)

កថាខណ្ឌទី ១ មាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណីដែលចែងថា "អត្រាការប្រាក់ដែលត្រូវបានកម្រិត សំដៅទៅលើអត្រាការប្រាក់អតិបរមាដែលអាចកំណត់បានដោយស្របច្បាប់ តាមការព្រមព្រៀងរបស់ភាគី ដែលកំណត់ដោយច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងទៀត" តម្រូវឱ្យច្បាប់ផ្សេង ឬ បទដ្ឋានគតិយុត្តផ្សេងទៀតកំណត់អត្រាការប្រាក់ដែលត្រូវបានកម្រិត។ ម្យ៉ាងទៀត ក្រមរដ្ឋប្បវេណីគ្មានបញ្ញត្តិអំពីករណីដែលភាគីនៃកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់កំណត់ជាមុននូវចំនួនទឹកប្រាក់នៃសំណងការខូចខាតចំពោះការមិនអនុវត្តកាតព្វកិច្ចទេ ប៉ុន្តែ ករណីនេះអាចចាត់ទុកថាដូចគ្នានឹងករណីដែលមានការព្រមព្រៀងអំពីការប្រាក់ ហេតុដូច្នេះ មានការចាំបាច់ចែងអំពីកម្រិតនៃការប្រាក់ក្នុងករណីនេះដែរ។ មាត្រានេះគឺជាបញ្ញត្តិអំពីចំណុចទាំងនេះ។

កថាខណ្ឌទី ១ គឺជាបញ្ញត្តិដែលប្រគល់សិទ្ធិក្នុងការកំណត់អត្រាការប្រាក់ដែលត្រូវបានកម្រិតឱ្យទៅប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប៉ុន្តែ ការប្រគល់សិទ្ធិទាំងស្រុងមានបញ្ហា ដូច្នេះ កថាខណ្ឌទី ១ នេះ កំណត់អំពីអត្រាអតិបរមា ៣០ ភាគរយ និង អត្រាអប្បបរមា ១០ ភាគរយ។ កថាខណ្ឌទី ១ មាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី ប្រើពាក្យ "ច្បាប់ និង បទដ្ឋានគតិយុត្ត" ដែលសំដៅទៅមិនមែនតែ "ច្បាប់" ប៉ុណ្ណោះទេ ហេតុដូច្នេះ ហាក់ដូចជាអាចកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌តែម្តងបានដែរ ប៉ុន្តែ ការកម្រិតនូវចំនួននៃសំណងដែលត្រូវបានកំណត់ជាមុន ជាចំណុចដែលត្រូវចែងនៅក្នុងច្បាប់ ហេតុដូច្នេះ មាត្រានេះកំណត់អំពីចំណុចនេះ ព្រមទាំងអត្រាការប្រាក់ដែលត្រូវបានកម្រិត។

កថាខណ្ឌទី ២ គឺជាបញ្ញត្តិសារធាតុអំពីការកម្រិតនូវចំនួននៃសំណងដែលត្រូវបានកំណត់ជាមុន មានខ្លឹមសារដូចគ្នានឹងផ្នែកខាងដើមនៃកថាខណ្ឌទី ៣ មាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី។

កថាខណ្ឌទី ៣ កំណត់អត្រាការប្រាក់ដែលត្រូវបានកម្រិតចំពោះចំនួននៃសំណងដែលត្រូវបានកំណត់ជាមុន

ហើយចែងថា អាចកំណត់នូវអត្រានោះដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រឹមទំហំពី ១, ២ ទៅ ២ ដង នៃអត្រាដែលត្រូវបានកម្រិតចំពោះការប្រាក់។ បញ្ញត្តិនេះទទួលស្គាល់អត្រាចំពោះចំនួននៃសំណងនេះខ្ពស់ជាងអត្រាចំពោះការប្រាក់ ដោយមូលហេតុថា ក្នុងករណីមិនអនុវត្តកាតព្វកិច្ច អាចមានករណីដែលម្ចាស់បំណុលចំណាយសោហ៊ុយដើម្បីប្រមូល ឬ ករណីដែលទទួលសំណងមិនបាន ហេតុដូច្នេះ ត្រូវទទួលស្គាល់អត្រាខ្ពស់ស្របនឹងហានិភ័យនោះ។

កថាខណ្ឌទី ៤ គឺជាបញ្ញត្តិដែលតម្រូវឱ្យយកបញ្ញត្តិអំពីករណីដែលភាគីកំណត់អត្រាការប្រាក់លើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិតមកអនុវត្តដូចគ្នាផងដែរចំពោះករណីដែលភាគីកំណត់ចំនួននៃសំណងលើសពីអត្រាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ដើម្បីឱ្យមានកម្រិតតាមផ្លូវច្បាប់ដូចគ្នា។

កថាខណ្ឌទី ៥ គឺជាបញ្ញត្តិចាត់ទុកចំពោះការព្រមព្រៀងអំពីប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា។ កថាខណ្ឌទី ៥ មាត្រា ៤០៣ នៃក្រមរដ្ឋប្បវេណី បានកំណត់ថា "ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យាត្រូវសន្មតថាជាការកំណត់ជាមុននូវចំនួនសំណង" ប៉ុន្តែ ទោះបីជាមានបញ្ញត្តិសន្មតក៏ដោយ ក៏ការសន្មតនេះអាចត្រូវបានបដិសេធ បើមានការបញ្ជាក់ផ្ទុយពីការសន្មតនោះដែរ។ ហេតុដូច្នេះ ដើម្បីឱ្យសម្រេចនូវខ្លឹមសារនៃការកម្រិត កថាខណ្ឌទី ៥ ចាត់ទុកថា ប្រាក់ធានាសំណងនោះជាការកំណត់ជាមុននូវចំនួននៃសំណង ។

កថាខណ្ឌទី ៦ គឺជាបញ្ញត្តិចំពោះករណីដែលភាគីបានព្រមព្រៀងគ្នាអំពីការប្រាក់នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ តែមិនបានកំណត់ចំនួននៃសំណងក្នុងករណីនៃការមិនអនុវត្តកាតព្វកិច្ចទេ។ វាក្យខណ្ឌទី ២ និង វាក្យខណ្ឌទី ៣ កថាខណ្ឌទី ១ មាត្រា ៣៩៩ នៃក្រមរដ្ឋប្បវេណីចែងថា ប្រសិនបើអត្រាការប្រាក់ក្នុងកិច្ចសន្យាខ្ពស់ជាងអត្រាការប្រាក់ដែលច្បាប់បានកំណត់ អត្រាការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវត្រូវគណនាតាមអត្រាការប្រាក់ក្នុងកិច្ចសន្យា។ ហេតុដូច្នេះ ក្នុងករណីដែលភាគីមិនបានកំណត់ចំនួននៃសំណង អត្រានៃចំនួនសំណងក៏ត្រូវបានកម្រិតក្នុងទំហំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះដែរ។ ប៉ុន្តែ តាមមាត្រានេះ ការកម្រិតនូវការកំណត់ជាមុននូវចំនួននៃសំណងធូរជាងអត្រាការប្រាក់ដែលត្រូវបានកម្រិត ហើយករណីនេះនាំឱ្យមានការសង្ស័យថាតើត្រូវយកអត្រាណាមួយមកគណនាប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវ។ អាស្រ័យហេតុនេះ កថាខណ្ឌទី ៦ បញ្ជាក់អំពីចំណុចនេះ។ យោងតាមកថាខណ្ឌទី ៦ នេះ បញ្ញត្តិនៃមាត្រានេះត្រូវអនុវត្តចំពោះប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវ ដោយចាត់ទុកថា ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវនោះជាការប្រាក់ ដូច្នេះ ការប្រាក់នៃប្រាក់សំណងនោះត្រូវបានកម្រិតក្នុងទំហំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ។

## ជំពូកទី ៣
## ការចុះបញ្ជីនីតិបុគ្គល

### មាត្រា ១៨.-សមត្ថកិច្ចលើការចុះបញ្ជីនីតិបុគ្គល

១-កិច្ចការដែលទាក់ទងនឹងការចុះបញ្ជីនីតិបុគ្គល ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងយុត្តិធម៌។

២-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចាត់តាំងមន្ត្រីទទួលបន្ទុកកិច្ចការដែលទាក់ទងនឹងការចុះបញ្ជីនីតិបុគ្គល។ បញ្ជីនីតិបុគ្គល ត្រូវរក្សាទុកនៅក្រសួងយុត្តិធម៌។

(កំណត់)

មាត្រានេះកំណត់ពីស្ថាប័នដែលមានសមត្ថកិច្ចលើការចុះបញ្ជីនីតិបុគ្គល។ ក្រមរដ្ឋប្បវេណីត្រូវបានតាក់តែងឡើងដោយផ្អែកលើការចុះបញ្ជីនីតិបុគ្គលដែលត្រូវប្រតិបត្តិនៅទូទាំងប្រទេស រីឯច្បាប់នេះវិញត្រូវបានតាក់តែងឡើងដោយផ្អែកលើការចុះបញ្ជីនីតិបុគ្គលទាំងនេះនៅត្រឹមតែក្រសួងយុត្តិធម៌ដែលមានទីតាំងនៅរាជធានីភ្នំពេញប៉ុណ្ណោះ។ ទាក់ទងនឹងការចុះបញ្ជីពាណិជ្ជកម្ម មានច្បាប់ចែងតម្រូវឱ្យចុះបញ្ជីនៅតុលាការពាណិជ្ជកម្ម ហេតុនេះហើយទាក់ទងនឹងការចុះបញ្ជីនីតិបុគ្គលវិញ អាចគិតថាជាសមត្ថកិច្ចរបស់សាលាដំបូង។ ក៏ប៉ុន្តែបច្ចុប្បន្ននេះ នៅមានបញ្ហាកង្វះឧបករណ៍សម្ភារៈ ដូច្នេះហើយបានជាក្នុងដំណាក់កាលចាប់ផ្តើមដំបូងនេះ គប្បីឱ្យក្រសួងយុត្តិធម៌ចាត់ចែងកិច្ចការនេះសិន ហេតុនេះហើយបានជាមាត្រានេះបានចែងថា "បញ្ជីនីតិបុគ្គលត្រូវរក្សានៅក្រសួងយុត្តិធម៌"។ ម្យ៉ាងទៀត ទាក់ទងនឹងការចុះបញ្ជីពាណិជ្ជកម្មវិញ ជាគោលការណ៍ ត្រូវទៅធ្វើនៅតុលាការពាណិជ្ជកម្ម ក៏ប៉ុន្តែយោងតាម មាត្រា ៥៤ (ថ្មី) នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ដែលបានចែងថា "ក្នុងរយៈកាលដែលព្រះរាជាណាចក្រកម្ពុជា នៅមិនទាន់មានតុលាការពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្មត្រូវរៀបចំ ថែរក្សាច្បាប់ចម្លងនៃសៀវភៅបញ្ជីពាណិជ្ជកម្ម និងច្បាប់ដើមនៃរាល់ឯកសារដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្ម ការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម រហូតដល់តុលាការពាណិជ្ជកម្ម ត្រូវបានបង្កើតឡើង" ក្រសួងពាណិជ្ជកម្មមានសមត្ថកិច្ចលើការចុះបញ្ជី។ ពេលណាសាលាដំបូងនីមួយៗបានរៀបចំដើម្បីចុះបញ្ជីនីតិបុគ្គលបានហើយ ពេលនោះអាចធ្វើវិសោធនកម្មច្បាប់នេះបាន។ ប៉ុន្តែ ដោយសារតែមិនទាន់ច្បាស់ថា ការចុះបញ្ជីនីតិបុគ្គលអាចនឹងត្រូវប្រតិបត្តិនៅទូទាំងប្រទេសព្រមគ្នាបាន ដូច្នេះហើយក្រោមស្ថានភាពនេះ ច្បាប់នេះចង្អុលបង្ហាញត្រឹមតែផែនការប្រតិបត្តិការចុះបញ្ជីនីតិបុគ្គលត្រឹមក្របខ័ណ្ឌនៃក្រសួងយុត្តិធម៌ប៉ុណ្ណោះ។

## មាត្រា ១៩.-បែបបទ និង ទម្រង់នៃការចុះបញ្ជីនីតិបុគ្គល

បែបបទ និង ទម្រង់នៃការចុះបញ្ជីនីតិបុគ្គលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

(កំណត់)

ខ្លឹមសារលម្អិតនៃការចុះបញ្ជីនីតិបុគ្គលត្រូវតែកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ចំពោះការចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជា មានបញ្ជីកាលប្បវត្តិ និង បញ្ជីវិភាគី (មាត្រា ៣០ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម)។ វាមានលទ្ធភាពក្នុងការដំណើរការបញ្ជីវិភាគីដោយកម្មវិធីកុំព្យូទ័រ (មាត្រា ៣២ និង ៣៣ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម)។ ប៉ុន្តែចំពោះសេចក្តីសម្រេចថាតើការចុះបញ្ជីនីតិបុគ្គលត្រូវធ្វើជាក្រដាស (ក្នុងករណីនេះ ការចុះបញ្ជីត្រូវធ្វើឡើងដោយពាក្យសុំជាលាយលក្ខណ៍អក្សរដោយភ្ជាប់ជាមួយនឹងឯកសារនីមួយៗដែលសរសេរតាមចំណុចនីមួយៗដែលត្រូវចុះបញ្ជី ដូចជាឯកសារដែលសរសេរអំពីអភិបាល ជាដើម ហើយប្រសិនបើមានការផ្លាស់ប្តូរចំណុចណាមួយដែលត្រូវបានចុះបញ្ជីហើយ គឺប្តូរតែទម្រង់ណាដែលបានសរសេរចូលនូវចំណុចនោះ មានន័យថា ត្រូវប្រើទម្រង់សម្រាប់ចុះបញ្ជីដើម្បីធ្វើការចុះបញ្ជី ហើយចងក្រងជាសំណុំឯកសារតាមនីតិបុគ្គលនីមួយៗ) ឬ ដោយកម្មវិធីកុំព្យូទ័រ (ហ្វូលដ័រមួយត្រូវរៀបចំឡើងសម្រាប់នីតិបុគ្គលមួយ) គឺអាស្រ័យទៅលើប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ចំណុចនេះត្រូវទុកឱ្យពិភាក្សាបន្តទៀត។

ក្នុងករណីដែលប្រើកុំព្យូទ័រ នឹងមានបញ្ហាពាក់ព័ន្ធនឹងសិទ្ធិប្រើប្រាស់ទិន្នន័យ និងបញ្ហាចូលលួចទិន្នន័យតាមរយៈបណ្តាញទូទាំងប្រទេស។ ក៏ប៉ុន្តែបញ្ហានេះអាចដោះស្រាយបាន បើសិនជាមានតែក្រសួងយុត្តិធម៌ជាអ្នកគ្រប់គ្រងដោយប្រើកុំព្យូទ័រដាច់តែឯងដោយមិនតភ្ជាប់នឹងបណ្តាញ ហើយកំណត់ឱ្យបុគ្គលជាក់លាក់ណាមានសិទ្ធិប្រើប្រាស់ (ពាក់ព័ន្ធនឹងបញ្ហានេះ កថាខណ្ឌទី ២ នៃមាត្រា ១៨ នឹងមានន័យសំខាន់)។

ម្យ៉ាងទៀត ទាក់ទងនឹងការចុះបញ្ជីពាណិជ្ជកម្មកម្ពុជា នៅក្នុងមាត្រា ៣០ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម បញ្ជីពាណិជ្ជកម្មមានពីរបែប គឺបញ្ជីកាលប្បវត្តិ និង បញ្ជីវិភាគី។ យោងតាមមាត្រា ៣១ នៃច្បាប់នេះ ការចុះបញ្ជីកាលប្បវត្តិត្រូវធ្វើឡើងដោយចុះប្រតិវេទន៍ក្នុងគល់បញ្ជីកាលប្បវត្តិតាមលំដាប់។ ប្រតិវេទន៍មានលេខរៀង ហេតុនេះហើយគេអាចទៅបើកមើលឯកសារនៅក្នុងបញ្ជីវិភាគីបានតាមរយៈលេខរៀងនេះ។ ដូច្នេះបញ្ជីដែលត្រូវចុះនោះមាន ២ បែប (មាត្រា ៣០ ថ្មី នៃច្បាប់ដដែល) រីឯការស្វែងរកទិន្នន័យពីបញ្ជីវិភាគីវិញ គេនឹងប្រើកុំព្យូទ័រ។ ក៏ប៉ុន្តែបញ្ហាធំនៃវិធីចុះបញ្ជីនេះគឺការផ្សាយជាសាធារណៈពុំមានលក្ខណៈគ្រប់គ្រាន់ទេ ហេតុនេះហើយគប្បីកុំយកវិធីនេះមកអនុវត្តជាការល្អ។

ក្នុងករណីដែលបានជ្រើសរើសវិធីចុះបញ្ជីដោយប្រើក្រដាសវិញ នៅក្នុងទម្រង់នៃពាក្យសុំ គួរតែចុះនូវចំណុច

នីមួយៗក្នុងក្រដាសផ្សេងៗគ្នា ជាពិសេស ចំណុចពាក់ព័ន្ធនឹងអភិបាល ជាអាទិ៍ គប្បីប្រើក្រដាសផ្សេង (ចាំបាច់ត្រូវធ្វើការកំណត់នូវទម្រង់ និង ប្រភេទក្រដាស)។ ក្រៅពីនេះ ពេលមានការប្តូរអភិបាល ជាអាទិ៍ គ្រាន់តែប្តូរក្រដាសដែលបានចុះអំពីចំណុចដែលបានប្តូរទៅបានហើយ រីឯក្រដាសចាស់វិញ ត្រូវកំណត់ពេលរក្សាទុកប៉ុន្មានឆ្នាំដើម្បីឱ្យដឹងថា នាពេលមុនៗ តើអ្នកណាជាអ្នកមានសិទ្ធិតំណាង។

ម្យ៉ាងទៀត ពាក្យសុំ និង ឯកសារភ្ជាប់ត្រូវរក្សាទុកដាច់ដោយឡែកពីបញ្ជី ហើយមិនត្រូវចាត់ទុកថាជាបញ្ជីទេ។ មូលហេតុដែលត្រូវរក្សាទុកនេះគឺពេលក្រោយ បើសិនជាមានបញ្ហាថាតើអ្នកដែលបានដាក់ពាក្យសុំនាពេលនោះជាអ្នកដែលមានសិទ្ធិត្រឹមត្រូវដែរឬទេនោះ យើងអាចយកមកធ្វើជាភស្តុតាងបាន។

## មាត្រា ២០.-ពាក្យសុំចុះបញ្ជីនីតិបុគ្គល

១-ពាក្យសុំចុះបញ្ជីត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

២-ចំណុចដែលកំណត់ក្នុងកថាខណ្ឌទី ១ មាត្រា ៥០ (ចំណុចដែលត្រូវចុះបញ្ជី) នៃក្រមរដ្ឋប្បវេណី ត្រូវសរសេរចូលទៅក្នុងពាក្យសុំ ហើយអ្នកតំណាងរបស់សាជីវកម្ម ឬ មូលនិធិដែលនឹងត្រូវក្លាយទៅជានីតិបុគ្គលត្រូវចុះបញ្ជី។ ពាក្យសុំត្រូវសរសេរចូលផងដែរនូវចំណុចដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៨៧ (ចំណុចដែលត្រូវចុះបញ្ជី និង អំឡុងពេលចុះបញ្ជី) នៃក្រមរដ្ឋប្បវេណី ប្រសិនបើជាសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬចំណុចដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១០២ (ចំណុចដែលត្រូវចុះបញ្ជី និង អំឡុងពេលចុះបញ្ជី) នៃក្រមរដ្ឋប្បវេណី ប្រសិនបើជាសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ឬ ចំណុចដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១១៥ (ចំណុចដែលត្រូវចុះបញ្ជី និង អំឡុងពេលចុះបញ្ជី) នៃក្រមរដ្ឋប្បវេណី ប្រសិនបើជាមូលនិធិ។

៣-ពាក្យសុំត្រូវភ្ជាប់មកជាមួយនូវលក្ខន្តិកៈ លិខិតអនុញ្ញាតដែលចេញដោយស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ ក្នុងករណីជាមូលនិធិ និងឯកសារផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

(កំណត់)

មាត្រានេះកំណត់ចំណុចដែលត្រូវសរសេរចូលនៅក្នុងពាក្យសុំចុះបញ្ជី។ ដោយហេតុថា ចំណុចដែលត្រូវចុះបញ្ជីមានកំណត់ច្បាស់នៅក្នុងក្រមរដ្ឋប្បវេណីហើយ កថាខណ្ឌទី ២ នៃមាត្រានេះកំណត់អំពីចំណុចដែលត្រូវសរសេរចូល

ទៅក្នុងពាក្យសុំ ដោយផ្អែកទៅលើចំណុចដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីទាំងនោះ។ ដូចដែលបានពន្យល់ក្នុងមាត្រាមុននេះដែរ គប្បីធ្វើការកំណត់អំពីទម្រង់នៃពាក្យសុំ ហើយបំពេញបន្ថែមនូវចំណុចដែលខ្វះខាតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ នេះគឺដើម្បីចៀសវាងនូវចំណុចជាន់គ្នារវាងក្រមរដ្ឋប្បវេណី និង ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

កថាខណ្ឌទី ៣ កំណត់អំពីឯកសារដែលរួមមានលក្ខន្តិកៈដែលត្រូវភ្ជាប់មកជាមួយពាក្យសុំ និង ទាមទារឱ្យដាក់ច្បាប់ដើមនៃឯកសារទាំងនេះផងដែរ។ ប៉ុន្តែ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចកំណត់អំពីនីតិវិធីស្តីពីការប្រគល់ច្បាប់ដើមវិញ។ មានន័យថា ប្រសិនបើអ្នកដាក់ពាក្យសុំបានដាក់ច្បាប់ដើម និង ឯកសារចម្លងជាមួយគ្នានោះ ក្រសួងយុត្តិធម៌ត្រូវប្រគល់ឯកសារច្បាប់ដើមទៅអ្នកដាក់ពាក្យសុំវិញ ហើយក្រសួងរក្សាទុកតែឯកសារចម្លងប៉ុណ្ណោះ។ រីឯ "ឯកសារផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌" វិញ គឺមានដូចជាឯកសារបញ្ជាក់អំពីភាពដូចគ្នានៃអ្នកដាក់ពាក្យសុំ ហើយក្នុងករណីដែលជានីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិតគឺមានលិខិតបញ្ជាក់ថា មានទ្រព្យសម្បត្តិយ៉ាងតិច ២០ លានរៀល ជាដើម។

## មាត្រា ២១.-ការប្រតិបត្តិការចុះបញ្ជី

មន្ត្រីដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៨ (សមត្ថកិច្ចលើការចុះបញ្ជីនីតិបុគ្គល) នៃច្បាប់នេះ មិនអាចប្រតិបត្តិការចុះបញ្ជីឱ្យនីតិបុគ្គលណាមួយបានទេ រហូតទាល់តែអាចបញ្ជាក់បានថា ពាក្យសុំនោះត្រឹមត្រូវតាម ក្រមរដ្ឋប្បវេណី និង បទដ្ឋានគតិយុត្តផ្សេងទៀត។

(កំណត់)

មាត្រានេះចែងអំពីករណីយកិច្ចរបស់មន្ត្រីទទួលបន្ទុកកិច្ចការចុះបញ្ជីនីតិបុគ្គល នៅពេលចុះបញ្ជីនីតិបុគ្គល។

ពាក្យថា "ត្រឹមត្រូវតាមក្រមរដ្ឋប្បវេណី" មានន័យថា ឧទាហរណ៍ ក្នុងករណីនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត តើមានលក្ខន្តិកៈដែលបានចែងត្រឹមត្រូវតាមមាត្រា ៨២ នៃក្រមរដ្ឋប្បវេណីដែរឬទេ ឬ តើនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិតនោះមានទ្រព្យសម្បត្តិយ៉ាងតិច ២០ លានរៀលដែរឬទេ (មាត្រា ៨៣) ឬ តើនីតិបុគ្គលនោះបានជ្រើសរើសអភិបាល និង អ្នកត្រួតពិនិត្យតាមលក្ខន្តិកៈដែរឬទេ ជាអាទិ៍? ក្រៅពីនេះ ឈ្មោះនីតិបុគ្គលក៏ត្រូវឱ្យមានលក្ខណៈស្របនឹងកថាខណ្ឌទី ២ មាត្រា ៨៧ នៃក្រមរដ្ឋប្បវេណីដែរ។

ពាក្យថា "ត្រឹមត្រូវតាមបទដ្ឋានគតិយុត្តផ្សេងទៀត" មានន័យថា អាចមានច្បាប់ពិសេសកំណត់អំពីលក្ខណសម្បត្តិដើម្បីធ្វើជាអភិបាល ជាអាទិ៍។

ក្នុងករណីការសុំចុះបញ្ជីនេះស្របនឹងច្បាប់ ឬ បទដ្ឋានគតិយុត្ត មន្ត្រីត្រូវធ្វើនីតិវិធី ដោយគ្មានការយឺតយ៉ាវ។

ក្នុងករណីមិនស្របច្បាប់ ឬ បទដ្ឋានគតិយុត្តទេ ត្រូវលើកពាក្យសុំចោល ហើយនីតិវិធីនៃករណីនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## មាត្រា ២២.-ការចុះបញ្ជីចំពោះការផ្លាស់ប្តូរ ជាអាទិ៍

១-ប្រសិនបើមានការផ្លាស់ប្តូរនូវចំណុចដែលបានសរសេរចូលនៅពេលចុះបញ្ជីនីតិបុគ្គល អ្នកតំណាងនីតិបុគ្គលត្រូវដាក់ពាក្យសុំចុះបញ្ជីចំពោះការផ្លាស់ប្តូរនោះ។

២-ប្រសិនបើនីតិបុគ្គលត្រូវបានរំលាយ អ្នកជម្រះបញ្ជីត្រូវដាក់ពាក្យសុំចុះបញ្ជីដែលកំណត់ក្នុងមាត្រា ៧០ (ការចុះបញ្ជីអំពីអ្នកជម្រះបញ្ជី និងការរំលាយ) និង មាត្រា ៨០ (ការចុះបញ្ជីអំពីការបញ្ចប់ការជម្រះបញ្ជី) នៃក្រមរដ្ឋប្បវេណី។

៣-ចំណុចដែលត្រូវសរសេរចូលក្នុងពាក្យសុំ និង ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងពាក្យសុំសម្រាប់ការដាក់ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

(កំណត់)

មាត្រានេះកំណត់ជាមូលដ្ឋានអំពីការចុះបញ្ជីអំពីការផ្លាស់ប្តូរ។ ខ្លឹមសារនៃនីតិវិធីចុះបញ្ជីជាលម្អិតនឹងកំណត់នៅក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ កថាខណ្ឌទី ១ នៃមាត្រានេះនឹងមានបញ្ហាក្នុងទំនាក់ទំនងនឹងមាត្រា ៥២ នៃក្រមរដ្ឋប្បវេណី។ មាត្រា ៥២ ចែងអំពីការចុះបញ្ជីអំពីការផ្លាស់ប្តូរទីតាំងនៃទីស្នាក់ការ ហើយមាត្រានេះតម្រូវឱ្យចុះបញ្ជីទាំងនៅទីតាំងចាស់ ទាំងនៅទីតាំងថ្មី។ នេះគឺដោយសារតែក្រមរដ្ឋប្បវេណីត្រូវបានចែងឡើងដោយផ្អែកលើប្រព័ន្ធដែលមានកន្លែងចុះច្រើនកន្លែង ក៏ប៉ុន្តែ ក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីនេះ កន្លែងចុះបញ្ជីមានតែមួយកន្លែងទេ គឺក្រសួងយុត្តិធម៌។ ហេតុនេះហើយ ការចុះបញ្ជីអំពីការផ្លាស់ប្តូរទីតាំងទីស្នាក់ការកណ្តាលត្រូវអនុវត្តតាមកថាខណ្ឌទី ១ នៃមាត្រានេះ។ នេះគឺបានមកពីការបកស្រាយកថាខណ្ឌទី ២ នៃមាត្រា ១៨ ត្រង់ "បញ្ជីនីតិបុគ្គលត្រូវរក្សាទុកនៅក្រសួងយុត្តិធម៌" និង កថាខណ្ឌទី ១ នៃមាត្រានេះបាន។

ប្រសិនបើប្រព័ន្ធចុះបញ្ជីត្រូវបានរៀបចំឡើងដោយប្រើក្រដាស គួរតែសរសេរចូលនូវចំណុចដែលត្រូវចុះបញ្ជីក្រោយការផ្លាស់ប្តូរ (ឧទាហរណ៍ថា ប្រសិនបើអភិបាលត្រូវផ្លាស់ប្តូរ គឺគ្រប់ទាំងចំណុចចុះបញ្ជីដែលបានសរសេរចូលនៅក្នុងទម្រង់ស្តីពីអភិបាល) ទៅក្នុងទម្រង់ដែលភ្ជាប់ជាមួយពាក្យសុំ ហើយចាត់ទុកទម្រង់ដែលភ្ជាប់មកជាមួយ

នោះជាបញ្ជីថ្មី (ជាឧទាហរណ៍ គឺទម្រង់ថ្មីសម្រាប់អភិបាល) ហើយដាក់ទម្រង់ចាស់នៅទំព័រចុងក្រោយនៃសំណុំឯកសារសម្រាប់នីតិបុគ្គលនោះ ដោយទុកជាបញ្ជីបិទចោល។ ប្រសិនបើប្រព័ន្ធចុះបញ្ជីធ្វើឡើងតាមម៉ាស៊ីនកុំព្យូទ័រ គេគួរតែដាក់បញ្ជីថ្មីនៅក្នុងហ្វូលដ័រសម្រាប់នីតិបុគ្គលនោះ ហើយបង្កើតហ្វូលដ័រថ្មីមួយទៀតនៅក្នុងហ្វូលដ័រចាស់ ដើម្បីដាក់បញ្ជីចាស់ទុកជាបញ្ជីបិទចោល។

ចំពោះករណីផ្លាស់ប្តូរអ្នកតំណាង ក្នុងករណីនេះ អ្នកតំណាងថ្មីគឺជាអ្នកត្រូវដាក់ពាក្យសុំផ្លាស់ប្តូរ។ រីឯឯកសារដែលត្រូវដាក់ភ្ជាប់ជាមួយមានដូចជា លិខិតបញ្ជាក់អំពីការផ្លាស់ប្តូរអភិបាលដោយផ្អែកលើលក្ខន្តិកៈ ឧទាហរណ៍ដូចជាកំណត់ហេតុស្តីពីមហាសន្និបាតដែលបានធ្វើសេចក្តីសម្រេច ជាដើម។ ក្រសួងយុត្តិធម៌នឹងចេញប្រកាសដើម្បីកំណត់អំពីករណីនេះ។

ចំពោះករណីរំលាយនីតិបុគ្គល អ្នកជម្រះបញ្ជីជាអ្នកដាក់ពាក្យចុះបញ្ជីអំពីការរំលាយនេះ ហើយមូលហេតុនៃការរំលាយមានចែងក្នុងមាត្រា ៦៤ នៃក្រមរដ្ឋប្បវេណី។ គឺចាំបាច់ត្រូវភ្ជាប់នូវឯកសារបញ្ជាក់អំពីអង្គហេតុនេះ (ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសាលក្រមសម្រេចរំលាយនីតិបុគ្គល ជាដើម)។ ក្រសួងយុត្តិធម៌នឹងចេញប្រកាសដើម្បីកំណត់អំពីករណីនេះ។

## មាត្រា ២៣.-ការបញ្ជាក់

១-បុគ្គលណាក៏ដោយ ក៏អាចសុំឱ្យធ្វើការបញ្ជាក់ ចំពោះចំណុចដែលបានចុះ ឬមិនបានចុះនៅក្នុងបញ្ជីនីតិបុគ្គលបានដែរ ដោយត្រូវបង់សោហ៊ុយ។

២-បុគ្គលដែលមានផលប្រយោជន៍អាចទាមទារមើលពាក្យសុំ និងឯកសារភ្ជាប់ជាមួយនឹងពាក្យសុំនោះបាន ដោយត្រូវបង់សោហ៊ុយ។

(កំណត់)

មាត្រានេះចែងពីការបញ្ជាក់នូវចំណុចចុះបញ្ជី។ ការថតចម្លងបញ្ជីដែលបានចុះហើយធ្វើការបញ្ជាក់លើឯកសារថតចម្លងនេះ គឺជាវិធីមួយងាយស្រួល ហើយច្បាស់លាស់ផង។ ទាក់ទងនឹង "ការបញ្ជាក់នូវចំណុចដែលមិនបានចុះនៅក្នុងបញ្ជី" ត្រូវឱ្យអ្នកដាក់ពាក្យសុំសរសេរច្បាស់លាស់ក្នុងពាក្យសុំថា "សូមបញ្ជាក់ថា ពុំមានចុះបញ្ជីអំពី ........ ទេ" ហើយនៅខាងក្រោមនោះ ត្រូវសរសេរបញ្ជាក់ថា "សូមបញ្ជាក់ថា ចំណុចខាងលើនេះគឺពិតជាត្រឹមត្រូវ" ហើយមន្ត្រីដែលបានបញ្ជាក់ ត្រូវចុះឈ្មោះ ចុះហត្ថលេខានៅលើនោះ។ នេះគឺជាវិធីមួយងាយស្រួល។ ទាក់ទងនឹងវិធី ឬ ទម្រង់ជាដើម ក្រសួងយុត្តិធម៌នឹងកំណត់តាមរយៈប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ កថាខណ្ឌទី ២ កំណត់សម្រាប់ជនដែលមានផលប្រយោជន៍ដែលចង់ទាមទារមើលលក្ខន្តិកៈ និង ឯកសារផ្សេងទៀត។ សូមធ្វើការពិភាក្សាថាតើគប្បីអនុញ្ញាតឱ្យស្នើសុំឯកសារចម្លងបានដែរឬទេ ក្រៅពីការទាមទារមើលនោះ។

## មាត្រា ២៤.-ករណីលើកលែងចំពោះការចុះបញ្ជីទីស្នាក់ការសាខា

ទោះបីមានបញ្ញត្តិនៃជំពូកទី ២ (នីតិបុគ្គល) ក្នុងគន្ថីទី ២ ស្តីពីបុគ្គលនៃក្រមរដ្ឋប្បវេណីក៏ដោយ ការចុះបញ្ជីដែលត្រូវធ្វើឡើងនៅទីតាំងនៃទីស្នាក់ការកណ្តាលនៃនីតិបុគ្គល ត្រូវធ្វើនៅក្រសួងយុត្តិធម៌ ហើយមិនចាំបាច់ដាក់ពាក្យសុំដើម្បីចុះបញ្ជីនៅទីតាំងនៃទីស្នាក់ការសាខានៃនីតិបុគ្គលទេ រហូតដល់ពេលមានការកំណត់ផ្សេងដោយច្បាប់។

(កំណត់)

ក្រមរដ្ឋប្បវេណីកំណត់អំពីការចុះបញ្ជីទីស្នាក់ការសាខា ដោយផ្អែកលើការសន្និដ្ឋានថា ការចុះបញ្ជីអាចធ្វើនៅទូទាំងប្រទេស។ ប៉ុន្តែ ដូចបានពន្យល់នៅក្នុងកំណត់នៃមាត្រា ១៨ ច្បាប់នេះកំណត់តែអំពីការចុះបញ្ជីដែលត្រូវធ្វើនៅក្រសួងយុត្តិធម៌ប៉ុណ្ណោះ។ ហេតុដូច្នេះ មាត្រានេះតាក់តែងឡើងដើម្បីជាវិធានការអន្តរកាល។ ចំពោះការចុះបញ្ជីពាណិជ្ជកម្ម ក៏ដូចគ្នាដែរ គឺទោះបីជាមាត្រា ១១ ចាស់នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម កំណត់ថាការចុះបញ្ជីពាណិជ្ជកម្មត្រូវចាត់ចែងដោយតុលាការពាណិជ្ជកម្មក៏ដោយ ក៏មាត្រា ៥៤ ចាស់នៃច្បាប់ដដែលនេះចែងពីវិធានការអន្តរកាលដែលកំណត់ថា កិច្ចការចុះបញ្ជីពាណិជ្ជកម្មនេះត្រូវចាត់ចែងដោយក្រសួងពាណិជ្ជកម្ម។

## មាត្រា ២៥.-ការប្រគល់សិទ្ធិឱ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើប្រកាស

ទម្រង់នៃពាក្យសុំ និង បញ្ហាផ្សេងទៀតដែលចាំបាច់សម្រាប់ការចុះបញ្ជីនីតិបុគ្គល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ចំនួនសោហ៊ុយត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

(កំណត់)

មាត្រានេះចែងអំពីការប្រគល់សិទ្ធិឱ្យធ្វើប្រកាស។

## ជំពូកទី ៤
## ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

### មាត្រា ២៦.-សមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

១-កិច្ចការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

២-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចាត់តាំងមន្ត្រីទទួលបន្ទុកកិច្ចការដែលទាក់ទងនឹងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។ បញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធត្រូវរក្សាទុកនៅក្រសួងយុត្តិធម៌។

(កំណត់)

ដូចគ្នាទៅនឹងសេចក្ដីពន្យល់ក្នុងកំណត់នៃមាត្រា ១៨។ បញ្ញត្តិនេះទំនងជាមិនមានបញ្ហាអ្វីទេ ប្រសិនបើក្រសួងយុត្តិធម៌មិនទទួលបន្ទុកចាត់ចែងកិច្ចការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធក្នុងអំឡុងពេលសមរម្យណាមួយ ពីព្រោះថា កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធទំនងជាមិនត្រូវបានសុំចុះបញ្ជីញឹកញាប់ទេ។

### មាត្រា ២៧.-បែបបទ និង ទម្រង់នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

បែបបទ និង ទម្រង់នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

(កំណត់)

ដូចគ្នាទៅនឹងសេចក្ដីពន្យល់ក្នុងកំណត់នៃមាត្រា ១៩ ។

បញ្ញត្តិនេះត្រូវបានរៀបចំឡើងដោយយកបុរេល័ក្ខខ័ណ្ឌថា ក្នុងករណីដែលមានអចលនវត្ថុក្នុងចំណោមកម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ភាគីនៃកិច្ចសន្យាមិនអាចតតាំងខ្លឹមសារនៃកិច្ចសន្យានោះចំពោះតតិយជនបានទេ ប្រសិនបើមិនបានចុះបញ្ជីចំពោះអចលនវត្ថុនីមួយៗ។

### មាត្រា ២៨.-ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

១-ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវធ្វើរួមគ្នា និងជាលាយល័ក្ខណ៍អក្សរដោយប្ដីប្រពន្ធ ឬ ដោយបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍។

២-ពាក្យសុំត្រូវសរសេរចូលនូវឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ កាលបរិច្ឆេទចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ខ្លឹមសារនៃកិច្ចសន្យានោះ និងចំណុចផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

៣-ពាក្យសុំត្រូវភ្ជាប់មកជាមួយនូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាលាយលក្ខណ៍អក្សរ និងឯកសារផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

(កំណត់)

ដូចគ្នាទៅនឹងសេចក្តីពន្យល់ក្នុងកំណត់នៃមាត្រា ២០។

## មាត្រា ២៩.-ការប្រតិបត្តិការចុះបញ្ជី

មន្ត្រីដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ២៦ (សមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) នៃច្បាប់នេះ មិនអាចប្រតិបត្តិការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធបានទេ រហូតទាល់តែអាចបញ្ជាក់បានថា ពាក្យសុំនោះត្រឹមត្រូវតាមក្រមរដ្ឋប្បវេណី និងបទដ្ឋានគតិយុត្តផ្សេងទៀត។

(កំណត់)

ដូចគ្នាទៅនឹងសេចក្តីពន្យល់ក្នុងកំណត់នៃមាត្រា ២១ ។

## មាត្រា ៣០.-ការចុះបញ្ជីចំពោះការផ្លាស់ប្តូរ ជាអាទិ៍

១-ប្រសិនបើមានការផ្លាស់ប្តូរនូវចំណុចដែលបានចុះក្នុងបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំចុះបញ្ជីចំពោះការផ្លាស់ប្តូរនោះ។

២-ប្រសិនបើប្តីប្រពន្ធបានរំលាយអាពាហ៍ពិពាហ៍ ឬ ប្រសិនបើបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានរំលាយកំជាប់ពាក្យប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានោះ ត្រូវដាក់ពាក្យលុបចោលការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាមួយគ្នា។

៣-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ជនដែលបានកំណត់ខាងក្រោមនេះ អាចដាក់ពាក្យសុំលុបចោលការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធតែឯកឯងបាន ប្រសិនបើមានហេតុដូចតទៅនេះ :

ក-ប្រសិនបើសហព័ទ្ធណាម្នាក់បានស្លាប់ គឺសហព័ទ្ធដែលនៅរស់។

ខ-ប្រសិនបើមានសេចក្តីសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិ ក្នុងសាលក្រម ឬ សាលដីកាវិលាយអាពាហ៍ពិពាហ៍ដែលបានចូលជាស្ថាពរ គឺ អតីតសហព័ទ្ធណាម្នាក់។

គ-ប្រសិនបើតុលាការបានសម្រេចសេចក្តីអំពីការបែងចែកទ្រព្យសម្បត្តិដោយការវិលាយអាពាហ៍ពិពាហ៍ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ហើយសេចក្តីសម្រេចនោះចូលជាស្ថាពរ គឺ អតីតសហព័ទ្ធណាម្នាក់។

ឃ-ប្រសិនបើហេតុការណ៍ដែលវិលាយកិច្ចាប់ពាក្យ ត្រូវបានបញ្ជាក់ដោយជាក់លាក់ នៅក្នុងសាលក្រម ឬ សាលដីកាស្ថាពរ ដែលសម្រេចអំពីការទាមទារដោយផ្អែកលើហេតុការណ៍វិលាយកិច្ចាប់ពាក្យ គឺ ភាគីណាម្នាក់។

៤-ចំណុចដែលត្រូវសរសេរចូលក្នុងពាក្យសុំ និងឯកសារដែលត្រូវភ្ជាប់ជាមួយនឹងពាក្យសុំ សម្រាប់ការដាក់ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

(កំណត់)

មាត្រានេះកំណត់ជាមូលដ្ឋានអំពីការចុះបញ្ជីចំពោះការផ្លាស់ប្តូរ។

ខ្លឹមសារនៃនីតិវិធីចុះបញ្ជីជាលម្អិតនឹងកំណត់នៅក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ប្រសិនបើប្រព័ន្ធចុះបញ្ជីត្រូវបានរៀបចំឡើងដោយប្រើក្រដាស គួរតែសរសេរចូលនូវចំណុចដែលត្រូវចុះបញ្ជីក្រោយការផ្លាស់ប្តូរទៅក្នុងទម្រង់ដែលភ្ជាប់ជាមួយពាក្យសុំ ហើយចាត់ទុកទម្រង់ដែលភ្ជាប់មកជាមួយនោះជាបញ្ជីថ្មី ហើយដាក់ទម្រង់ចាស់នៅទំព័រចុងក្រោយនៃសំណុំឯកសារសម្រាប់កិច្ចសន្យានោះ ដោយទុកជាបញ្ជីបិទចោល។ ប្រសិនបើប្រព័ន្ធចុះបញ្ជីធ្វើឡើងតាមម៉ាស៊ីនកុំព្យូទ័រ គេគួរតែដាក់បញ្ជីថ្មីនៅក្នុងហ្វូលដ័រសម្រាប់កិច្ចសន្យានោះ ហើយបង្កើតហ្វូលដ័រថ្មីមួយទៀតនៅក្នុងហ្វូលដ័រចាស់ដើម្បីដាក់បញ្ជីចាស់ទុកជាបញ្ជីបិទចោល។

ម្យ៉ាងទៀត ទោះបីជាទម្រង់បញ្ជីចាស់ត្រូវបានបិទហើយក៏ដោយ ទម្រង់បញ្ជីចាស់នោះគួរតែរក្សាទុកមួយ

រយៈសិនដែរ ដើម្បីឱ្យគេអាចធ្វើសេចក្តីបញ្ជាក់ដូចដែលបានចែងនៅក្នុងមាត្រាបន្ទាប់នេះ។

## មាត្រា ៣១.-ការបញ្ជាក់

បុគ្គលណាក៏ដោយ ក៏អាចសុំឱ្យធ្វើការបញ្ជាក់ចំពោះចំណុចដែលបានចុះ ឬ មិនបានចុះនៅក្នុងបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបានដែរ ដោយត្រូវបង់សោហ៊ុយ។

(កំណត់)

មាត្រានេះកំណត់អំពីការបញ្ជាក់ចំពោះចំណុចដែលបានចុះក្នុងបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ ករណីនេះខុសពីការចុះបញ្ជីនីតិបុគ្គល គឺការអនុញ្ញាតឱ្យមើលពាក្យសុំចុះបញ្ជី ឬ ឯកសារផ្សេងៗដែលភ្ជាប់ជាមួយមានភាពចាំបាច់តិចតួចណាស់។ ប៉ុន្តែ មាត្រានេះតម្រូវឱ្យរក្សាទុកឯកសារទាំងនោះ ដោយសារពេលមានវិវាទស្តីពីអត្ថិភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឬ ការផ្លាស់ប្តូរខ្លឹមសារនៃកិច្ចសន្យា ឯកសារទាំងនោះអាចយកមកប្រើប្រាស់ជាឯកសារសម្រាប់វិនិច្ឆ័យ ដោយទទួលការផ្ទុកផ្តាក់ឱ្យប្រគល់ឯកសារពីតុលាការ។

## មាត្រា ៣២.-ការប្រគល់សិទ្ធិឱ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើប្រកាស

ទម្រង់នៃពាក្យសុំ ការបញ្ជាក់ និង បញ្ហាផ្សេងទៀតដែលចាំបាច់សម្រាប់ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ចំនួនសោហ៊ុយត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

(កំណត់)

មាត្រានេះចែងអំពីការប្រគល់សិទ្ធិឱ្យធ្វើប្រកាស។

# ជំពូកទី ៥
# អន្តរប្បញ្ញត្តិ

( កំណត់)

តាមពិតទៅ អន្តរប្បញ្ញត្តិដែលតាក់តែងឡើងដោយសារការធ្វើវិសោធនកម្ម និង/ឬ ធ្វើឱ្យនិរាករណ៍នូវច្បាប់ដែលមានកន្លងមក ត្រូវបញ្ចូលទៅក្នុងផ្នែកបន្ទាប់ពីជំពូកទី ៧ " វិសោធនកម្ម និង និរាករណ៍នូវបទប្បញ្ញត្តិមួយចំនួននៃច្បាប់ជាធរមាន"។ ប៉ុន្តែ ដោយសារតែបញ្ញត្តិនៃជំពូកទី ៧ មិនត្រូវបានប្រើប្រាស់ទេក្នុងស្ថានភាពជាក់ស្តែង អន្តរប្បញ្ញត្តិដែលត្រូវអនុវត្តជាក់ស្តែង ត្រូវបញ្ចូលនៅក្នុងផ្នែកមុនបញ្ញត្តិទាំងឡាយនៃជំពូកទី ៧ ។

## មាត្រា ៣៣.-ការអនុញ្ញាតឱ្យអនីតិជនប្រកបអាជីវកម្ម

ការអនុញ្ញាតឱ្យអនីតិជនប្រកបអាជីវកម្ម ដោយអ្នកមានអំណាចមេបា ដែលបានធ្វើឡើងមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវចាត់ទុកជាការអនុញ្ញាតឱ្យប្រកបអាជីវកម្មដោយផ្អែកលើបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ២០ (អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម) នៃក្រមរដ្ឋប្បវេណី។

( កំណត់ )

កថាខណ្ឌទី ១ មាត្រា ២០ នៃក្រមរដ្ឋប្បវេណីអនុញ្ញាតឱ្យអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ផ្តល់ការអនុញ្ញាតឱ្យអនីតិជនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនប្រកបអាជីវកម្ម ដោយបញ្ញត្តថា "អនីតិជនដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មមួយប្រភេទ ឬ ច្រើនប្រភេទ ពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថភាពដូចនីតិជន ចំពោះមុខជំនួញនោះ"។ គេអាចគិតឃើញថា អាចមានអនីតិជនខ្លះបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មពីអ្នកមានអំណាចមេបារួចទៅហើយនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ក៏ប៉ុន្តែ ការអនុញ្ញាតនោះមិនមែនធ្វើឡើងដោយផ្អែកលើក្រមរដ្ឋប្បវេណីទេ។ ហេតុដូច្នេះ មាត្រានេះផ្តល់ឱ្យការអនុញ្ញាតនោះមានអានុភាពគតិយុត្តដោយចែងថា ការអនុញ្ញាតនោះត្រូវចាត់ទុកថាជាការអនុញ្ញាតដែលធ្វើឡើងដោយផ្អែកលើក្រមរដ្ឋប្បវេណី។

ក្នុងមាត្រានេះ មិនរាប់បញ្ចូលអ្នកអាណាព្យាបាលសម្រាប់អនីតិជនទេ ដោយហេតុថា របបអាណាព្យាបាលសម្រាប់អនីតិជននេះមិនទាន់មាននៅឡើយនាពេលបច្ចុប្បន្ន។ បញ្ហាទាំងឡាយដែលពាក់ព័ន្ធជាមួយអ្នកអាណាព្យាបាលតាមស្ថានភាពជាក់ស្តែងត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក។ ប៉ុន្តែ បន្ទាប់ពីកាលបរិច្ឆេទនៃការអនុវត្ត បុគ្គលទាំងនោះមិនត្រូវចាត់ទុកថាជាអ្នកតំណាងដែលច្បាប់បានកំណត់ទេ ដូច្នេះ មិនអាចធ្វើសកម្មភាពគតិយុត្តបានទេ។

ចំពោះសមត្ថភាពរបស់អនីតិជន កថាខណ្ឌទី ២ មាត្រា ២១ នៃក្រមរដ្ឋប្បវេណីចែងអំពីអត្ថាធិនភាពរបស់អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍។ មានន័យថា អនីតិជនត្រូវបានចាត់ទុកថាបានក្លាយមកជាជនឯករាជ្យដោយសារអាពាហ៍ពិពាហ៍ និង បានរួចផុតពីអំណាចមេបា។ ដោយពិចារណាទៅលើអត្ថន័យនៃកថាខណ្ឌនេះ យើងអាចយល់បានថា ទោះបីជាអនីតិជនបានរៀបអាពាហ៍ពិពាហ៍នៅមុនកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ ក៏បញ្ញត្តិនេះត្រូវយកមកអនុវត្តនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តផងដែរ។ ដូច្នេះ មិនមានអន្តរប្បញ្ញត្តិដែលពាក់ព័ន្ធចំពោះករណីនេះទេ។

ចំពោះមាត្រា ២៣ នៃក្រមរដ្ឋប្បវេណីដែលចែងអំពីកិច្ចសន្យាការងាររបស់អនីតិជនវិញ ដោយសារតែមាត្រា ១៨១ នៃច្បាប់ការងារចែងថា គ្មានក្មេងណាម្នាក់អាយុតិចជាង ១៨ ឆ្នាំ ភេទណាក៏ដោយ ដែលមិនទាន់ផុតពីការគ្រប់គ្រងរបស់ឪពុកម្តាយ ឬ អ្នកអាណាព្យាបាល អាចចុះកិច្ចសន្យាការងារដោយគ្មានការយល់ព្រមអំពីជនដែលខ្លួននៅក្រោមការគ្រប់គ្រងនោះទេ ហេតុដូច្នេះ ទើបវាហាក់មានភាពចាំបាច់ដែលត្រូវធ្វើការសម្របសម្រួលរវាងបញ្ញត្តិនៃច្បាប់ទាំងពីរនេះ។ ក៏ប៉ុន្តែ មាត្រា ២៣ នៃក្រមរដ្ឋប្បវេណីចែងថា អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនអាចធ្វើកិច្ចសន្យាការងារជំនួសអនីតិជនបានទេ ហេតុដូច្នេះ អាចបកស្រាយថាកិច្ចសន្យាការងារណាមួយដែលធ្វើឡើងដោយអនីតិជន ត្រូវវិនិច្ឆ័យដោយផ្អែកលើច្បាប់ការងារ។ ម្យ៉ាងទៀតអាចបកស្រាយបានដែរថា អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីកម្មប្រភេទណាមួយដោយអនុលោមតាមមាត្រា ២០ នៃក្រមរដ្ឋប្បវេណី ត្រូវបានចាត់ទុកថារួចផុតពីអំណាចមេបាមួយផ្នែកត្រឹមទំហំនោះ ហើយត្រូវនឹងអនីតិជនដែលបានផុតពីការគ្រប់គ្រងរបស់ឪពុកម្តាយ ឬ អ្នកអាណាព្យាបាលតាមច្បាប់ការងារ។ មានន័យថាវាមិនមានទំនាស់រវាងមាត្រាទាំងពីរនេះទេ ដូច្នេះក៏មិនចាំបាច់មានការសម្របសម្រួលអ្វីដែរ។ លើសពីនេះទៅទៀតទោះបីជាមិនច្បាស់ថា នៅមុនកាលបរិច្ឆេទនៃការអនុវត្ត អ្នកមានអំណាចមេបា ជាអាទិ៍ អាចធ្វើកិច្ចសន្យាការងារជំនួសអនីតិជនបាន ហើយកិច្ចសន្យាដែលផ្ទុយទៅនឹងកថាខណ្ឌទី ១ នៃមាត្រា ២៣ ត្រូវបានចាត់ទុកថាមានសុពលភាពក៏ដោយ ក៏កិច្ចសន្យានោះអាចត្រូវរំលាយដោយអនុលោមតាមកថាខណ្ឌទី ៣ នៃមាត្រា ២៣ ក្រោយកាលបរិច្ឆេទនៃការអនុវត្តបានដដែល ។ ហេតុដូច្នេះ មិនចាំបាច់តាក់តែងឱ្យមានបញ្ញត្តិដើម្បីសម្របសម្រួលទេ។

## មាត្រា ៣៤.-ការចាត់ចែងអំពីសាជីវកម្ម ឬមូលនិធិដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត

១-សាជីវកម្មដែលមានទ្រព្យសម្បត្តិឯករាជ្យមានតម្លៃមិនតិចជាង ២០.០០០.០០០ (ម្ភៃលាន) រៀល ហើយដែលជាសាជីវកម្មមានគោលបំណងមិនទាញយកចំណេញ ឬ មូលនិធិដែលមានទ្រព្យសម្បត្តិឯករាជ្យមានតម្លៃ មិនតិចជាង ២០០.

០០០.០០០ (ពីររយលាន) រៀល ហើយដែលជាមូលនិធិមានគោលបំណងបម្រើផលប្រយោជន៍សាធារណៈនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវធ្វើតាមនីតិវិធីដែលកំណត់ចាប់ពីកថាខណ្ឌទី ២ ខាងក្រោមនេះទៅ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសាជីវកម្មដែលមានទ្រព្យសម្បត្តិឯករាជ្យ មានតម្លៃតិចជាង ២០.០០០.០០០ (ម្ភៃលាន) រៀល ហើយដែលត្រូវនឹងនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ដែលកំណត់ក្នុងមាត្រា ១០១ (ការបង្កើត និង លក្ខន្តិកៈ) នៃក្រមរដ្ឋប្បវេណី។

២-ក្នុងករណីដែលសាជីវកម្មដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវនឹងនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិតដែលកំណត់ក្នុងមាត្រា ៨២ (ការបង្កើត និង លក្ខន្តិកៈ) នៃក្រមរដ្ឋប្បវេណី អ្នកតំណាងសាជីវកម្មនោះ ត្រូវធ្វើឯកសារដែលបញ្ជាក់អំពីចំណុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រាដដែល និងចំណុចផ្សេងទៀតដែលបានកំណត់ដោយសមាជិក ហើយចាំបាច់មានការទទួលសេចក្តីបញ្ជាក់ពីសារការីចំពោះឯកសារនេះ ក្នុងអំឡុងពេល ៣ (បី) ខែចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត។

៣-ក្នុងករណីដែលសាជីវកម្មដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវនឹងនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិតដែលកំណត់ក្នុងមាត្រា ១០១ (ការបង្កើត និង លក្ខន្តិកៈ) នៃក្រមរដ្ឋប្បវេណី អ្នកតំណាងសាជីវកម្មនោះ ត្រូវធ្វើឯកសារដែលបញ្ជាក់អំពីចំណុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រាដដែល និងចំណុចផ្សេងទៀតដែលបានកំណត់ដោយសមាជិក ហើយចាំបាច់មានការទទួលសេចក្តីបញ្ជាក់ពីសារការីចំពោះឯកសារនេះក្នុងអំឡុងពេល ៣ (បី) ខែ ចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត។

៤-ក្នុងករណីដែលមូលនិធិដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវនឹងនីតិបុគ្គលមូលនិធិដែលកំណត់ក្នុងមាត្រា ១១០ (ការបង្កើត និង លក្ខន្តិកៈ) នៃក្រមរដ្ឋប្បវេណី អ្នកតំណាងមូលនិធិនោះ ត្រូវធ្វើឯកសារដែលបញ្ជាក់អំពីចំណុច

នីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រាដដែល និង ចំណុចផ្សេងទៀត ដែលបានកំណត់ដោយអ្នកដែលបានធ្វើវិភាគទានទ្រព្យសម្បត្តិ និង ត្រូវទទួលសេចក្តីបញ្ជាក់ពីសារការីចំពោះឯកសារនេះ ហើយចាំបាច់ដាក់ជូនឯកសារនោះទៅស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ និង ទទួលការអនុញ្ញាតពីសំណាក់ស្ថាប័ននោះ ក្នុងអំឡុងពេល ៣ (បី) ខែ ចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត។ ប៉ុន្តែប្រសិនបើឃើញថា ឯកសារនោះ មានភាពផ្ទុយនឹងក្រមរដ្ឋប្បវេណី ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ឬ យល់ឃើញថាចាំបាច់សម្រាប់ ផលប្រយោជន៍សាធារណៈនោះ ស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ ចាំបាច់ត្រូវបង្គាប់ឱ្យកែប្រែឯកសារនោះ។

៥-ឯកសារដែលកំណត់ចាប់ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ ខាងលើនេះត្រូវមានអានុភាពជាលក្ខន្តិកៈ ចាប់ពីពេលទទួលសេចក្តីបញ្ជាក់ពីសារការី។

៦-សាជីវកម្ម ឬ មូលនិធិដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ ឬ ដោយប្រកាស នៅមុនកាលបរិច្ឆេទ នៃការអនុវត្ត ក្នុងទំហំនៃការអនុវត្តចាប់ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៥ ខាងលើនេះ ត្រូវចាត់ទុកថាបានទទួលសេចក្តីបញ្ជាក់ដោយសារការី ឬ ការអនុញ្ញាតដោយស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យនៅកាលបរិច្ឆេទនៃការអនុវត្ត។

(កំណត់)

បញ្ញត្តិនៃមាត្រានេះ និង មាត្រា ៣៧ នៃច្បាប់នេះមានគោលបំណងផ្តល់ឱ្យនីតិបុគ្គលភាពដោយមានអានុភាពប្រតិសកម្មចាប់ពីកាលបរិច្ឆេទនៃការអនុវត្តដល់សាជីវកម្មមានគោលបំណងមិនទាញយកចំណេញ ឬ មូលនិធិបម្រើប្រយោជន៍សាធារណៈដែលបានកើតឡើង និង មានទ្រព្យសម្បត្តិឯករាជ្យនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ប្រសិនបើសាជីវកម្ម ឬ មូលនិធិនោះធ្វើតាមនីតិវិធីដែលបានកំណត់។ ប្រសិនបើមិនមានបញ្ញត្តិដូច្នេះទេ សាជីវកម្ម ឬ មូលនិធិទាំងនោះត្រូវធ្វើតាមនីតិវិធីដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី និង ត្រូវដាក់ពាក្យសុំចុះបញ្ជីដើម្បីទទួលបាននីតិបុគ្គលភាព ពោលគឺពួកគេមិនអាចទទួលបាននីតិបុគ្គលភាពនៅកាលបរិច្ឆេទនៃការអនុវត្តទេ។ ដូច្នេះ មាត្រានេះត្រូវបានតាក់តែងឡើងក្នុងគោលបំណងធានាស្ថិរភាពគតិយុត្តដោយឱ្យសាជីវកម្ម និង មូលនិធិទាំងនោះមានភាពបន្តតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត។

កថាខណ្ឌទី ១ នៃមាត្រានេះផ្តល់ឱកាសដើម្បីទទួលបានដោយងាយស្រួលនូវនីតិបុគ្គលភាពដល់សាជីវកម្មទទួលខុសត្រូវមានកម្រិតដែលមានទ្រព្យសម្បត្តិមិនតិចជាង ២០.០០០.០០០ (ម្ភៃលាន) រៀល ស្របតាមល័ក្ខខ័ណ្ឌដូចបានកំណត់ក្នុងមាត្រា ៨៣ នៃក្រមរដ្ឋប្បវេណី ឬ មូលនិធិដែលមានទ្រព្យសម្បត្តិមិនតិចជាង ២០០.០០០.០០០ (ពីររយលាន) រៀល ស្របតាមការកំណត់ក្នុងមាត្រា ១១១ នៃក្រមរដ្ឋប្បវេណី។ វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ គឺសម្រាប់សាជីវកម្មទទួលខុសត្រូវគ្មានកម្រិតដែលមិនមានការកំណត់អំពីល័ក្ខខ័ណ្ឌទ្រព្យសម្បត្តិ។

បញ្ញត្តិចាប់ពីកថាខណ្ឌទី ២ កំណត់ថា សាជីវកម្ម ឬ មូលនិធិត្រូវរៀបចំឯកសារដូចបានកំណត់ក្នុងក្រមរដ្ឋប្បវេណីអាស្រ័យទៅតាមប្រភេទរបស់នីតិបុគ្គល ហើយត្រូវទទួលសេចក្តីបញ្ជាក់ពីសារការីចំពោះឯកសារទាំងនោះក្នុងអំឡុងពេល ៣ ខែ គិតចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត។ មូលហេតុដែលចាំបាច់ត្រូវដាក់កម្រិតចំពោះអំឡុងពេល គឺដើម្បីធានាស្ថិរភាពគតិយុត្ត។ ប្រសិនបើសាជីវកម្ម ឬ មូលនិធិដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខកខានមិនបានធ្វើតាមនីតិវិធីក្នុងអំឡុងពេលដែលបានកំណត់នេះទេ គឺគ្មាននីតិវិធីណាផ្សេងក្រៅពីត្រូវបង្កើតសាជាថ្មីឱ្យស្របតាមក្រមរដ្ឋប្បវេណី ហើយទទួលបាននីតិបុគ្គលភាពនៅពេលចុះបញ្ជីបង្កើតនោះទេ។

កថាខណ្ឌទី ៥ ត្រូវបានរៀបចំឡើងដោយស្របនឹងកថាខណ្ឌទី ៣ មាត្រា ៨២ កថាខណ្ឌទី ៣ មាត្រា ១០១ និង កថាខណ្ឌទី ៣ មាត្រា ១១០ នៃក្រមរដ្ឋប្បវេណីដែលបានកំណត់ថា លក្ខន្តិកៈពុំមានអានុភាពឡើយ បើពុំបានទទួលសេចក្តីបញ្ជាក់ពីសារការីទេ។

## មាត្រា ៣៥.-ការចុះបញ្ជីសាជីវកម្ម ឬមូលនិធិដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត ជាអាទិ៍

១-ក្នុងករណីដែលអ្នកតំណាងសាជីវកម្ម ឬ មូលនិធិដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣៤ (ការចាត់ចែងអំពីសាជីវកម្ម ឬ មូលនិធិដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត) ខាងលើនេះ បានទទួលសេចក្តីបញ្ជាក់ពីសារការី ឬ ការអនុញ្ញាតពីសំណាក់ស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យដោយយោងតាមបញ្ញត្តិ ចាប់ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រាដដែលនេះ សាជីវកម្ម ឬ មូលនិធិ នោះចាំបាច់ត្រូវចុះបញ្ជីអំពីចំណុចខាងក្រោមនេះ នៅក្រសួងយុត្តិធម៌ ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ :

ក-ចំណុចដែលកំណត់ក្នុងមាត្រា ៥០ (ចំណុចដែលត្រូវចុះបញ្ជី) នៃក្រមរដ្ឋប្បវេណី។

១-ថ្ងៃ ខែ ឆ្នាំទទួលសេចក្តីបញ្ជាក់ពីសារការី ឬ ថ្ងៃ ខែ ឆ្នាំដែលបានទទួលការអនុញ្ញាតពីសំណាក់ស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ។

២-អំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវគិតចាប់ពីថ្ងៃទទួលលិខិតបញ្ជាក់អំពីសេចក្តីបញ្ជាក់ពីសារការី ឬ ថ្ងៃដែលលិខិតអនុញ្ញាតបានមកដល់។

(កំណត់)

មាត្រានេះចែងអំពីនីតិវិធីសម្រាប់ចុះបញ្ជីសាជីវកម្ម ឬ មូលនិធិដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត ហើយដែលកថាខណ្ឌទី ១ នៃមាត្រា ៣៤ ត្រូវយកមកអនុវត្ត។ ចំពោះសាជីវកម្ម ឬ មូលនិធិដែលមានអត្ថិភាពមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវចុះអំពី :

-ចំណុចដែលកំណត់ក្នុងមាត្រា ៥០ (ចំណុចដែលត្រូវចុះបញ្ជី) នៃក្រមរដ្ឋប្បវេណី

-ថ្ងៃ ខែ ឆ្នាំដែលបានទទួលសេចក្តីបញ្ជាក់ពីសារការី ឬ ថ្ងៃ ខែ ឆ្នាំដែលបានទទួលការអនុញ្ញាតពីសំណាក់ស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ

ក៏ប៉ុន្តែទាក់ទងនឹងចំណុចដែលត្រូវចុះបញ្ជីអំពីការបង្កើត ក្រមរដ្ឋប្បវេណីមានចែងអំពី :

- ចំណុចដែលត្រូវចុះបញ្ជីអំពីនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត (មាត្រា ៨៧)

- ចំណុចដែលត្រូវចុះបញ្ជីអំពីនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត (មាត្រា ១០២)

- ចំណុចដែលត្រូវចុះបញ្ជីអំពីនីតិបុគ្គលមូលនិធិ (មាត្រា ១១៥)

រីឯមាត្រា ៣៥ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីនេះវិញមិនតម្រូវឱ្យចុះបញ្ជីចំណុចទាំងនេះទេ។ នេះគឺដោយសារថា ឱ្យតែបានចុះបញ្ជីអំពីចំណុចដែលមានចែងចាប់ពីមាត្រា ៥០ នៃក្រមរដ្ឋប្បវេណីទៅ នឹងអាចតតាំងចំពោះតតិយជនបានអំពីទំហំសមត្ថភាពទទួលសិទ្ធិ (ឬ សមត្ថភាពក្នុងការធ្វើសកម្មភាព) ឬ អ្នកតំណាង ឬ មូលហេតុនៃការរំលាយដែលបានកំណត់ដោយលក្ខន្តិកៈ។ ដូច្នេះហើយ យ៉ាងហោចណាស់ក៏ត្រូវចុះបញ្ជីអំពីចំណុចទាំងនេះ ដូច្នេះដើម្បីសម្រួលដល់ការចុះបញ្ជីនីតិបុគ្គលចំពោះនីតិបុគ្គលដែលមានអត្ថិភាពរួចហើយ ជាវិធានការអន្តរកាល មាត្រានេះតម្រូវឱ្យចុះបញ្ជីបែបនេះ។ ក្រមរដ្ឋប្បវេណីត្រូវបានអនុវត្តហើយ ដូច្នេះគប្បីទាមទារឱ្យធ្វើការចុះបញ្ជីនូវចំណុចដែលមានចែងក្នុងមាត្រា ៨៧ ជាអាទិ៍ តាមរយៈប្រកាសរបស់ក្រសួងយុត្តិធម៌ លើសពីនេះ ទោះជាគ្មានក៏ដោយ ក៏គប្បីមិនលើកពាក្យសុំចោលដែរ។

ម្យ៉ាងទៀត ការចុះបញ្ជីដែលមានចែងក្នុងមាត្រា ៣៥ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីនេះមិនមែន

ជាការចុះបញ្ជីអំពីការបង្កើតនីតិបុគ្គលទេ ក៏ប៉ុន្តែ ត្រូវតែអនុវត្តដូចគ្នានឹងការចុះបញ្ជីអំពីការបង្កើតដែរ ដូច្នេះ ហើយ ពាក្យសុំ និង ឯកសារឧបសម្ព័ន្ធត្រូវចាត់ចែងប្រហាក់ប្រហែលគ្នានឹងការចុះបញ្ជីអំពីការបង្កើតដែរ។

## មាត្រា ៣៦.-បញ្ជីទ្រព្យសម្បត្តិ ឬ បញ្ជីរាយនាមសមាជិក

ក្នុងករណីដែលសាជីវកម្ម ឬ មូលនិធិដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃ មាត្រា ៣៤ (ការចាត់ចែងអំពីសាជីវកម្ម ឬ មូលនិធិដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត) នៃច្បាប់នេះ គ្មានបញ្ជីទ្រព្យសម្បត្តិ ឬ បញ្ជីរាយនាមសមាជិកទេ សាជីវកម្ម ឬ មូលនិធិនោះ ចាំបាច់ត្រូវធ្វើបញ្ជីនោះដោយគ្មានការយឺតយ៉ាវ នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ហើយត្រូវទុកបញ្ជីនោះនៅទីស្នាក់ការនីមួយៗ។

(កំណត់)

មាត្រានេះមានគោលបំណងធានាឱ្យបានថា នីតិបុគ្គលត្រូវរៀបចំធ្វើ និង រក្សាទុកនូវបញ្ជីទ្រព្យសម្បត្តិ និង បញ្ជីរាយនាមសមាជិក ដូចបានកំណត់ក្នុងមាត្រា ៩៥ នៃក្រមរដ្ឋប្បវេណី។

## មាត្រា ៣៧.-បញ្ញត្តិពិសេសអំពីពេលដែលនីតិបុគ្គលត្រូវបានបង្កើត

ក្នុងករណីដែលសាជីវកម្ម ឬ មូលនិធិដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃ មាត្រា ៣៤ (ការចាត់ចែងអំពីសាជីវកម្ម ឬ មូលនិធិដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត) នៃច្បាប់នេះ បានអនុវត្តនីតិវិធីដែលកំណត់ចាប់ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រាដដែល និង នៅក្នុងមាត្រា ៣៥ (ការចុះបញ្ជីសាជីវកម្ម ឬ មូលនិធិដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្តជាអាទិ៍) នៃច្បាប់នេះ មុនកាលបរិច្ឆេទដែលកំណត់ក្នុងបញ្ញត្តិទាំងនោះ សាជីវកម្ម ឬ មូលនិធិនោះ ត្រូវបានចាត់ទុកថាមាននីតិបុគ្គលភាពដោយប្រតិសកម្មតាំងពីកាលបរិច្ឆេទនៃការអនុវត្ត។

(កំណត់)

មាត្រានេះចែងថា នៅពេលដែលសាជីវកម្ម ឬ មូលនិធិដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត

ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ៣៤ នៃច្បាប់នេះ បានអនុវត្តតាមនីតិវិធីដែលបានកំណត់ពីមាត្រា ៣៤ និង មាត្រា ៣៥ នៃច្បាប់នេះ សាជីវកម្ម ឬ មូលនិធិនោះត្រូវបានចាត់ទុកថាបានទទួលនីតិបុគ្គលភាពដោយប្រតិសកម្ម ចាប់តាំងពីកាលបរិច្ឆេទនៃការអនុវត្ត។ មាត្រានេះត្រូវបានតាក់តែងឡើងក្នុងគោលបំណងធានានូវភាពបន្តតាំងពីមុន កាលបរិច្ឆេទនៃការអនុវត្ត និង ស្ថិរភាពគតិយុត្ត។

ដោយសារតែក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាមិនទទួលស្គាល់សមត្ថភាពក្នុងការធ្វើបណ្តឹងចំពោះសាជីវកម្ម ជាអាទិ៍ ដែលមិនមាននីតិបុគ្គលភាព ដូច្នេះ សាជីវកម្ម ឬ មូលនិធិដែលមានអត្ថិភាពចាប់តាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត មិនអាចធ្វើបណ្តឹងបានទេ រហូតដល់ពេលសាជីវកម្ម ឬ មូលនិធិនោះបំពេញនីតិវិធីចុះបញ្ជីតាមបញ្ញត្តិនេះជាមុនសិន។ បើទោះជាសាជីវកម្ម ឬ មូលនិធិ ដាក់ពាក្យបណ្តឹងក៏ដោយ ក៏បណ្តឹងនោះនឹងត្រូវលើកចោលដោយសារបណ្តឹង នោះផ្ទុយនឹងច្បាប់ដែរ។ ប៉ុន្តែ ភាពផ្ទុយនឹងច្បាប់នោះនឹងត្រូវបានជួសជុល ប្រសិនបើសាជីវកម្ម ឬ មូលនិធិបានធ្វើការ ចុះបញ្ជីតាមនីតិវិធីដែលបានកំណត់នៅក្នុងមាត្រា ៣៤ និង មាត្រា ៣៥ នៃច្បាប់នេះ។

## មាត្រា ៣៨.-អានុភាពនៃសិទ្ធិប្រត្យក្សដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត

១-សិទ្ធិប្រត្យក្សដែលកំណត់នៅក្នុងគន្ថីទី ៣ ស្តីពីសិទ្ធិប្រត្យក្សនៃក្រមរដ្ឋប្បវេណី ទោះបីសិទ្ធិប្រត្យក្សនោះបានកើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ ក៏មានអានុភាពដូចដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី គិតចាប់ពីកាលបរិច្ឆេទនៃការអនុវត្តដែរ។

២-សិទ្ធិជួលរយៈពេលវែង ផលុបភោគ សិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យនៅ ឬ សេវភាពកើតពីការព្រមព្រៀង ដោយផ្អែកលើច្បាប់ភូមិបាលឆ្នាំ ២០០១ មុនពេលត្រូវបានធ្វើវិសោធនកម្ម ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៨០ (ការធ្វើវិសោធនកម្មលើបញ្ញត្តិមួយចំនួននៃច្បាប់ភូមិបាលឆ្នាំ ២០០១) នៃច្បាប់នេះ ត្រូវចាត់ទុកជាសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យនៅ ឬ សេវភាព ដោយផ្អែកលើក្រមរដ្ឋប្បវេណី គិតចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត។ ក្នុងករណីនេះ អំឡុងពេលដែលសិទ្ធិទាំងនោះមានអត្ថិភាព ត្រូវគណនាចាប់ពីថ្ងៃដែលសិទ្ធិនោះត្រូវបានបង្កើតដោយផ្អែកលើច្បាប់ភូមិបាលឆ្នាំ ២០០១។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះមានខ្លឹមសារដូចគ្នានឹងមាត្រា ៣៦ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុនដែរដែលចែងអំពីអានុភាពនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តនៃសិទ្ធិប្រត្យក្សដែលបានកើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ដូចជាកម្មសិទ្ធិដែលបានកើតឡើងស្របតាមវិធានដើម្បីបង្កើតឡើងវិញនូវកម្មសិទ្ធិដោយផ្អែកលើច្បាប់ភូមិបាលឆ្នាំ ២០០១ ជាអាទិ៍។ ជាលទ្ធផលនៃការអនុវត្តកថាខណ្ឌនេះ ក្នុងករណីដែលដីឡូត៍ជាក់លាក់ណាមួយជាកម្មវត្ថុនៃកម្មសិទ្ធិអវិភាគដែលបានកំណត់នៅក្នុងមាត្រា ១៦៨ នៃច្បាប់ភូមិបាល ប្រសិនបើការព្រមព្រៀងពាក់ព័ន្ធនឹងការគ្រប់គ្រង ឬ ការបែងចែកដី ត្រូវបានបង្កើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ការព្រមព្រៀងនោះនឹងមានសុពលភាពជាការសម្រេចអំពីកិច្ចការដែលទាក់ទងនឹងការគ្រប់គ្រងវត្ថុកម្មសិទ្ធិអវិភាគដោយយោងតាមមាត្រា ២០៨ (ការគ្រប់គ្រងវត្ថុកម្មសិទ្ធិអវិភាគ) ឬ កិច្ចសន្យាដែលត្រូវបានធ្វើឡើង ដោយយោងតាមមាត្រា ២១១ (សិទ្ធិទាមទារបែងចែកវត្ថុកម្មសិទ្ធិអវិភាគ) នៃក្រមរដ្ឋប្បវេណី បន្ទាប់ពីកាលបរិច្ឆេទនៃការអនុវត្តដែរ។

កថាខណ្ឌទី ២ នៃមាត្រានេះត្រូវបានតាក់តែងឡើងដោយសារតែការផ្លាស់ប្តូរនៅក្នុងច្បាប់មូលដ្ឋានសម្រាប់សិទ្ធិប្រត្យក្សពីច្បាប់ភូមិបាលទៅក្រមរដ្ឋប្បវេណី។ វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ ត្រូវបានតាក់តែងឡើងដើម្បីកំណត់ឱ្យច្បាស់ថា អំឡុងពេលនៃសិទ្ធិមិនត្រូវគណនាដោយគិតចាប់ពីកាលបរិច្ឆេទនៃការអនុវត្តទេ។ សូមធ្វើការកត់សម្គាល់ថា មាត្រា ៤១ ចែងអំពីបញ្ញត្តិពិសេសចំពោះអំឡុងពេលនៃសិទ្ធិជួលរយៈពេលវែងដែលត្រូវបានបង្កើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត។

បញ្ហាដែលអាចកើតចេញពីការបកស្រាយមាត្រានេះ មានដូចខាងក្រោម :

បញ្ហាជាបឋម គឺច្បាប់ភូមិបាលមានបញ្ញត្តិច្រើនដែលពាក់ព័ន្ធជាមួយសេវភាពកើតពីធម្មជាតិចាប់តាំងពីមាត្រា ១៤៤ ចំណែកក្រមរដ្ឋប្បវេណីវិញ មិនមានបញ្ញត្តិណាដែលពាក់ព័ន្ធនឹងសេវភាពកើតពីធម្មជាតិនេះទេ។ ផ្ទុយទៅវិញក្រមរដ្ឋប្បវេណីមានបញ្ញត្តិដែលចែងអំពីទំនាក់ទំនងរវាងដីដែលនៅជាប់គ្នានៅក្នុងមាត្រាចាប់ពី ១៤៣ ដល់មាត្រា ១៥៤ ដែលស្រដៀងគ្នាស្ទើរតែទាំងស្រុងទៅនឹងបញ្ញត្តិស្តីពីសេវភាពដែលកើតពីធម្មជាតិក្នុងមាត្រាចាប់ពី ១៤៤ នៃច្បាប់ភូមិបាល។ ហើយដោយផ្អែកលើមាត្រានេះ បញ្ញត្តិអំពីកម្មសិទ្ធិក្នុងក្រមរដ្ឋប្បវេណីត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទនៃការអនុវត្តចំពោះកម្មសិទ្ធិលើដីដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត ហេតុដូច្នេះ បញ្ញត្តិស្តីពីទំនាក់ទំនងរវាងដីដែលនៅជាប់គ្នាចាប់ពីមាត្រា ១៤៣ ដល់មាត្រា ១៥៤ នៃក្រមរដ្ឋប្បវេណី ក៏ត្រូវអនុវត្តដែរ។

បញ្ហាបន្ទាប់ គឺតាមច្បាប់ភូមិបាល ការបង្កើតសិទ្ធិប្រត្យក្សដែលត្រូវបានកម្រិត បើមិនធ្វើតាមរូបមន្តផ្លូវការជាកំណត់ គឺមិនមានសុពលភាពឡើយ។ ប៉ុន្តែ អាចធ្វើការបកស្រាយដោយផ្អែកលើកថាខណ្ឌទី ១ នៃមាត្រានេះបានថាសិទ្ធិប្រត្យក្សដែលត្រូវបានកម្រិតដែលត្រូវបានបង្កើតឡើងដោយធ្វើតាមរូបមន្តផ្លូវការ ប៉ុន្តែ មិនទាន់បានចុះបញ្ជីចប់

សព្វគ្រប់នៅឡើយ នៅកាលបរិច្ឆេទនៃការអនុវត្ត អាចត្រូវបានចុះបញ្ជីជាសិទ្ធិប្រត្យក្សដែលត្រូវបានកម្រិតតាមក្រមរដ្ឋប្បវេណី។ មាត្រា ៥៦ នៃច្បាប់នេះត្រូវបានបង្កើតឡើងក្នុងគោលបំណងនេះ។

លើសពីនេះទៅទៀត កថាខណ្ឌទី ១ នៃមាត្រានេះអនុវត្តចំពោះករណីដែលការកាន់កាប់ ឬ ឧបការកាន់កាប់ (ការកាន់កាប់ "សិទ្ធិលើទ្រព្យសម្បត្តិ" ដែលមិនមែនជាវត្ថុ) ដែលមានមុនកាលបរិច្ឆេទនៃការអនុវត្ត ហេតុដូច្នេះ ការកាន់កាប់ ឬ ឧបការកាន់កាប់ទាំងនោះមានសុពលភាពនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តតាមច្បាប់នេះ។ ហេតុដូច្នេះ ក្នុងករណីដែលការកាន់កាប់ត្រូវបានដកហូតនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ប្រសិនបើការដកហូតនោះកើតឡើងមិនតិចជាង ១ ឆ្នាំ នៅមុនកាលបរិច្ឆេទនៃការអនុវត្ត គេអាចធ្វើការទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញបាន។ ម្យ៉ាងទៀត ដោយសារការកាន់កាប់សំដៅទៅលើស្ថានភាពជាក់ស្តែង អាជ្ញាយុកាលនៃលទ្ធកម្មអាចអនុវត្តចំពោះវត្ថុដែលត្រូវបានកាន់កាប់តាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត។ ល័ក្ខខ័ណ្ឌសម្រាប់អាជ្ញាយុកាលនៃលទ្ធកម្មគឺការកាន់កាប់ដោយជាក់ស្តែងនោះបន្តរហូតឥតដាច់ ក្នុងអំឡុងពេលជាក់លាក់មួយ។ ប្រសិនបើអង្គហេតុរបៀបនេះត្រូវបានបំពេញ បន្ទាប់ពីកាលបរិច្ឆេទនៃការអនុវត្ត (ឧទាហរណ៍ថា អំឡុងពេលនោះបានកន្លងហួសបន្ទាប់ពីកាលបរិច្ឆេទនៃការអនុវត្ត) ក្រមរដ្ឋប្បវេណីត្រូវអនុវត្តដោយអនុលោមទៅតាមកថាខណ្ឌទី ១ នៃមាត្រា ៥ និងកថាខណ្ឌទី ១ នៃមាត្រានេះ។ បន្ថែមពីលើនេះទៅទៀត បញ្ញត្តិនៃមាត្រា ២៤២ និង មាត្រា ២៤៣ នៃក្រមរដ្ឋប្បវេណីពាក់ព័ន្ធជាមួយនឹងការការពារភោគីអចលនវត្ថុនឹងត្រូវអនុវត្តចំពោះការកាន់កាប់ដែលមានមុនកាលបរិច្ឆេទនៃការអនុវត្ត។ ជាឧទាហរណ៍ កថាខណ្ឌទី ៣ មាត្រា ២៤៣ នៃក្រមរដ្ឋប្បវេណីត្រូវអនុវត្តចំពោះករណីទាំងឡាយណាដែលការបំពានការកាន់កាប់បានកើតមានឡើងក្នុងអំឡុងពេល ៣ ឆ្នាំនៅមុនកាលបរិច្ឆេទនៃការអនុវត្ត។

ប៉ុន្តែ ផ្ទុយទៅវិញ ចំពោះសិទ្ធិទាមទារឱ្យសងវិញនូវចំណាយដើម្បីបង្កើនតម្លៃ ជាអាទិ៍ ដោយសារតែការចំណាយដើម្បីបង្កើនតម្លៃត្រូវបានចាត់ទុកថាជា "បញ្ហា" ដែលមានចែងក្នុងកថាខណ្ឌទី ១ មាត្រា ៥ នៃច្បាប់នេះ ក្រមរដ្ឋប្បវេណីនឹងអនុវត្តតែចំពោះចំណាយដើម្បីបង្កើនតម្លៃដែលកើតឡើងក្រោយកាលបរិច្ឆេទនៃការអនុវត្តតែប៉ុណ្ណោះ។ គោលគំនិតនេះគឺដូចគ្នានឹងគោលគំនិតនៃសិទ្ធិទាមទារឱ្យសងវិញនូវសោហ៊ុយ (មាត្រា ៦០៤ មាត្រា ៦២៨ មាត្រា ៦៤៦ មាត្រា ៦៨៦ និង មាត្រា ៧៣៤ នៃក្រមរដ្ឋប្បវេណី) ដូចមានរៀបរាប់នៅក្នុងកំណត់ពន្យល់បន្ថែមបន្ទាប់ពីមាត្រាចុងក្រោយនៃច្បាប់នេះ។ សិទ្ធិទាមទារឱ្យសងវិញនូវចំណាយដើម្បីបង្កើនតម្លៃជាសិទ្ធិលើបំណុល ប៉ុន្តែ សិទ្ធិលើបំណុលនេះត្រូវបានបង្កើតឡើងដោយបញ្ញត្តិនៃច្បាប់ មិនមែនដោយកិច្ចសន្យាទេ ដូច្នេះ វាជារឿងធម្មតាទេដែលបញ្ញត្តិនៃក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តចំពោះករណីដែលសកម្មភាពដែលជាមូលហេតុនៃការបង្កើតសិទ្ធិលើបំណុលនោះ ដូចជាសកម្មភាពចេញចំណាយដើម្បីបង្កើនតម្លៃ ជាអាទិ៍ ត្រូវបានធ្វើឡើងនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត (ក្រោយពេលដែលច្បាប់ចាប់ផ្តើមអនុវត្ត)។

## មាត្រា ៣៩.-ការកាន់កាប់ចលនវត្ថុតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត

១-ប្រសិនបើជនដែលកាន់កាប់ចលនវត្ថុ តាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត បំពេញលក្ខខណ្ឌដែលកំណត់ក្នុងមាត្រា ១៩៣ (លទ្ធកម្មដោយសុច្ចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមរដ្ឋប្បវេណី ជននោះត្រូវទទួលសិទ្ធិ ដែលអាចអនុវត្តលើចលនវត្ថុនោះនៅកាលបរិច្ឆេទនៃការអនុវត្ត។ ក្នុងករណីនេះ បញ្ញត្តិនៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះអានុភាពនៃកិច្ចសន្យាផ្ទេរអនុប្បទានកម្មសិទ្ធិត្រឹមកម្រិតនៃការអនុវត្តមាត្រា ១៩៣ (លទ្ធកម្មដោយសុច្ចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមរដ្ឋប្បវេណីតែប៉ុណ្ណោះ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវរារាំងក្នុងការអនុវត្តបញ្ញត្តិនៃមាត្រា ១៩៤ (អនុប្បទាននូវវត្ថុ លួច ឬ វត្ថុបាត់) នៃក្រមរដ្ឋប្បវេណី។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះត្រូវបានតាក់តែងឡើងដើម្បីធានានូវការអនុវត្តដោយមានអានុភាពប្រតិសកម្មនៃមាត្រា ១៩៣ នៃក្រមរដ្ឋប្បវេណីអំពីលទ្ធកម្មដោយសុចរិតដើម្បីការពារអ្នកធ្វើលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុដែលមានខ្លឹមសារដូចគ្នានឹងមាត្រា ៣៩ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីប្រទេសជប៉ុនដែរ។ ក្រមរដ្ឋប្បវេណីទទួលស្គាល់ការលក់វត្ថុរបស់អ្នកដទៃ (កថាខណ្ឌទី ២ នៃមាត្រា ៥៣១) រីឯមាត្រា ៣៥ នៃក្រឹត្យ-ច្បាប់លេខ ៣៨ ក្រ.ច មិនទទួលស្គាល់ឡើយ។ ជាលទ្ធផល រាល់ការលក់វត្ថុរបស់អ្នកដទៃដែលធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តមិនបានបំពេញនូវល័ក្ខខ័ណ្ឌនៃ "កិច្ចសន្យាអនុប្បទានកម្មសិទ្ធិដែលមានសុពលភាព" ដែលបានកំណត់នៅក្នុងមាត្រា ១៩៣ នៃក្រមរដ្ឋប្បវេណីទេ។ ហេតុដូច្នេះ វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រានេះចែងថា ក្រមរដ្ឋប្បវេណីត្រូវអនុវត្តដោយមានអានុភាពប្រតិសកម្មចំពោះករណីដែលពាក់ព័ន្ធទៅនឹងសុពលភាពនៃកិច្ចសន្យាអនុប្បទានកម្មសិទ្ធិដើម្បីឱ្យមានលទ្ធផលដូចគ្នានឹងករណីដែលអនុវត្តមាត្រា ១៩៣ ក្រោយកាលបរិច្ឆេទនៃការអនុវត្ត។ ម្យ៉ាងទៀតក្នុងករណីដែលអ្នកលក់ ឬ ម្ចាស់កម្មសិទ្ធិពិតប្រាកដបានដាក់ពាក្យបណ្តឹងទាមទារឱ្យអ្នកទិញប្រគល់វិញនូវវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញនៅមុនកាលបរិច្ឆេទនៃការអនុវត្ត អ្នកទិញមិនអាចអះអាងពីលទ្ធកម្មដោយសុចរិត ដោយផ្អែកលើមាត្រានេះបានទេ ទោះបីជានៅក្រោយកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ ព្រោះការអះអាងបែបនោះត្រូវបានចាត់ទុកថាជាការបំពានសិទ្ធិ។

កថាខណ្ឌទី ២ នៃមាត្រានេះមានគោលបំណងបញ្ជាក់ឱ្យច្បាស់ថា ទោះបីជាចលនវត្ថុណាមួយត្រូវបានធ្វើលទ្ធកម្មដោយសុចរិតនៅមុនកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ ក៏មាត្រា ១៩៤ នៃក្រមរដ្ឋប្បវេណី ចាំបាច់ត្រូវយកមកអនុវត្ត

ដើម្បីការពារកម្មសិទ្ធិករដើមចំពោះករណីដែលចលនវត្ថុនោះត្រូវបានគេលួច ឬ ត្រូវបានធ្វើឱ្យបាត់ដែរ។

## មាត្រា ៤០.-ឧបាគមន៍តាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត

១-ជនដែលស្ថិតនៅក្នុងស្ថានភាពដែលអាចធ្វើលទ្ធកម្មលើកម្មសិទ្ធិ បើយោងតាមបញ្ញត្តិនៃមាត្រា ១៩៨ (ការជាប់គ្នា ការលាយច្របល់គ្នានៃចលនវត្ថុ) ឬ មាត្រា ១៩៩ (ការកែច្នៃចលនវត្ថុ) នៃក្រមរដ្ឋប្បវេណី តាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិឯកត្តជន ឬ ម្ចាស់នៃកម្មសិទ្ធិអវិភាគ ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី គិតចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត។ ប៉ុន្តែបញ្ញត្តិនេះមិនរារាំងសិទ្ធិដែលតតិយជនបានធ្វើលទ្ធកម្មដោយត្រឹមត្រូវឡើយ។

២-ជនដែលបាត់បង់សិទ្ធិ ដោយសារអនុវត្តតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចទាមទារប្រាក់សំណង ដោយយោងតាមបញ្ញត្តិនៃមាត្រា ២០១ (ឧបាគមន៍ និង សិទ្ធិទាមទារប្រាក់សំណង) នៃក្រមរដ្ឋប្បវេណី។

(កំណត់)

មាត្រានេះគ្របដណ្តប់លើករណីដែលចលនវត្ថុពីរ ឬ ច្រើនដែលមានម្ចាស់កម្មសិទ្ធិផ្សេងគ្នាត្រូវបានធ្វើឧបាគមន៍ដោយការជាប់គ្នា ការលាយច្របល់គ្នា ឬ ដោយការកែច្នៃ នៅមុនកាលបរិច្ឆេទនៃការអនុវត្ត។ កថាខណ្ឌទី ១ នៃមាត្រានេះអនុវត្តគោលការណ៍សិទ្ធិមួយចំពោះវត្ថុមួយចំពោះករណីទាំងនេះ ដើម្បីផ្ទេរទៅរករបបទ្រព្យសម្បត្តិដែលគ្រប់គ្រងដោយក្រមរដ្ឋប្បវេណីដែលមានលំនាំដូចមាត្រា ៤២ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីប្រទេសជប៉ុន។

កថាខណ្ឌទី ២ នៃមាត្រានេះកំណត់អំពីប្រាក់សំណងចំពោះជនទាំងឡាយដែលបាត់បង់សិទ្ធិដោយសារឧបាគមន៍នៃចលនវត្ថុបែបនោះ។

## មាត្រា ៤១.-អំឡុងពេលដែលសិទ្ធិជួលរយៈពេលវែងតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត មានអត្ថិភាព

ចំពោះពោះសិទ្ធិជួលចិរយៈពេលវែងដែលត្រូវបានបង្កើតឡើងតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្តដោយផ្អែកលើច្បាប់ភូមិបាលឆ្នាំ ២០០១ ហើយដែលអំឡុងពេលនៅសល់មានលើសពី ៥០ (ហាសិប) ឆ្នាំ នៅកាលបរិច្ឆេទនៃការអនុវត្ត ទោះបីមានបញ្ញត្តិនៃមាត្រា ២៤៧ (អំឡុងពេលដែលសិទ្ធិជួលអចិន្ត្រៃយ៍មានអត្ថិភាព) នៃ

ក្រមរដ្ឋប្បវេណីក៏ដោយ ក៏សិទ្ធិនោះត្រូវមានអត្ថិភាពក្នុងអំឡុងពេលដែលបានកំណត់ដោយការព្រមព្រៀងដែរ។ ប៉ុន្តែ ចំពោះសិទ្ធិជួលរយៈពេលវែងដែលអំឡុងពេលនៅសល់ មានលើសពី ៩៩ (កៅសិបប្រាំបួន) ឆ្នាំ វិញ អំឡុងពេលដែលសិទ្ធិនោះមានអត្ថិភាព ត្រូវកំណត់ជា ៩៩ (កៅសិបប្រាំបួន) ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត។

(កំណត់)

មាត្រានេះកំណត់អំពីអំឡុងពេលដែលសិទ្ធិជួលរយៈពេលវែងដែលត្រូវបានបង្កើតឡើង ដោយផ្អែកលើច្បាប់ភូមិបាលឆ្នាំ ២០០១ នៅមុនកាលបរិច្ឆេទនៃការអនុវត្ត។ ដោយយោងទៅលើមាត្រា ២៤៤ នៃក្រមរដ្ឋប្បវេណី សិទ្ធិជួលរយៈពេលវែងលើអចលនវត្ថុក្នុងអំឡុងពេលមិនតិចជាង ១៥ ឆ្នាំ ត្រូវចាត់ទុកថាជាសិទ្ធិជួលអចិន្ត្រៃយ៍ដែលជាសិទ្ធិប្រត្យក្សមួយប្រភេទ ហើយមាត្រា ២៤៧ នៃក្រមរដ្ឋប្បវេណីចែងថា អំឡុងពេលដែលសិទ្ធិជួលអចិន្ត្រៃយ៍មានអត្ថិភាពមិនអាចឱ្យលើសពី ៥០ ឆ្នាំបានឡើយ ហើយមានចែងទៀតថា ប្រសិនបើបានបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ដែលមានអំឡុងពេលលើសពី ៥០ ឆ្នាំ ត្រូវបន្ថយមកត្រឹម ៥០ ឆ្នាំ។ ផ្ទុយទៅវិញ ច្បាប់ភូមិបាលមិនមានការកម្រិតអំឡុងពេលសម្រាប់សិទ្ធិជួលរយៈពេលវែងទេ។ ហេតុដូច្នេះ សិទ្ធិជួលរយៈពេលវែងដែលត្រូវបានបង្កើតឡើងដោយផ្អែកលើច្បាប់ភូមិបាលអាចមានអំឡុងពេលលើសពី ៥០ ឆ្នាំ ប៉ុន្តែ បញ្ញត្តិអំពីសិទ្ធិជួលអចិន្ត្រៃយ៍នៃក្រមរដ្ឋប្បវេណី ក៏ត្រូវអនុវត្តចំពោះសិទ្ធិជួលរយៈពេលវែងបែបនេះ ក្រោយកាលបរិច្ឆេទនៃការអនុវត្តដែរ។ ករណីនេះនាំឱ្យមានសង្ស័យអំពីអំឡុងពេលនៅសល់នៅកាលបរិច្ឆេទនៃការអនុវត្ត។ មាត្រានេះចែងថា ទោះបីជាអំឡុងពេលនៅសល់នៃសិទ្ធិជួលអចិន្ត្រៃយ៍មានលើសពី ៥០ ឆ្នាំ ក៏ដោយ ក៏សិទ្ធិជួលរយៈពេលវែងនោះ (ត្រូវជាសិទ្ធិជួលអចិន្ត្រៃយ៍ ក្រោយកាលបរិច្ឆេទនៃការអនុវត្ត) បន្តមានអត្ថិភាពរហូតដល់ទីបញ្ចប់នៃអំឡុងពេលដែលបានកំណត់ដោយការព្រមព្រៀងដែរ ដើម្បីការពារសិទ្ធិដែលត្រូវបានទទួលរួចហើយ។ ប៉ុន្តែ ប្រសិនបើអំឡុងពេលនេះវែងហួសហេតុ នោះមានភាពផ្ទុយនឹងគោលគំនិតនៃមាត្រា ២៤៧ ហេតុដូច្នេះ វាក្យខណ្ឌទី ២ ចែងថា ចំពោះសិទ្ធិជួលរយៈពេលវែងដែលអំឡុងពេលនៅសល់មានលើសពី ៩៩ ឆ្នាំ នៅកាលបរិច្ឆេទនៃការអនុវត្ត អំឡុងពេលនោះត្រូវបន្ថយត្រឹម ៩៩ ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត។

## មាត្រា ៤២.- ផលុបភោគដែលត្រូវបានដាក់ធានារ៉ាប់រង

ចំពោះផលុបភោគដែលត្រូវបានបង្កើតឡើង នៅមុនកាលបរិច្ឆេទនៃការអនុវត្តដោយផ្អែកលើច្បាប់ភូមិបាលឆ្នាំ ២០០១ ហើយវត្ថុដែលជាកម្មវត្ថុនៃផលុបភោគនោះបានដាក់ធានារ៉ាប់រង ក្នុងករណីដែលកម្មវត្ថុនោះត្រូវវិនាស ដោយ

ករណីប្រធានសក្តិ ក្នុងអំឡុងពេលនៃការធានារ៉ាប់រងដោយបុព្វលាភ ធានារ៉ាប់រងដែលបានបង់នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ហើយបើកម្មសិទ្ធិករ ឬ ផលុបភោគី បានទទួលថ្លៃធានារ៉ាប់រង នោះភាគីម្ខាងទៀតអាចទាមទារឱ្យជួសជុល ឬ សាងសង់ឡើងវិញនូវវត្ថុដែលជាកម្មវត្ថុនោះ ដោយយកថ្លៃធានារ៉ាប់រងនោះបាន ទោះបីនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ។

(កំណត់)

កថាខណ្ឌទី ២ មាត្រា ១៣១ នៃច្បាប់ភូមិបាលចែងថា ចំពោះអចលនវត្ថុដែលបានដាក់ធានារ៉ាប់រង ប្រសិនបើអចលនវត្ថុនោះត្រូវបានវិនាស ហើយកម្មសិទ្ធិករ ឬ ផលុបភោគី អាចទទួលបាននូវថ្លៃធានារ៉ាប់រងនោះ ភាគីម្ខាងទៀតអាចទាមទារឱ្យធ្វើការជួសជុល ឬ សាងសង់អចលនវត្ថុនោះឡើងវិញបាន ដោយយកថ្លៃធានារ៉ាប់រងនោះ ប៉ុន្តែក្រមរដ្ឋប្បវេណីមិនមានបញ្ញត្តិបែបដូច្នេះទេ។ ដោយហេតុនេះបានជាមាត្រានេះត្រូវបានតាក់តែងឡើងដើម្បីធានាការសម្របសម្រួលចាំបាច់នេះ។ ក្នុងករណីដែលអចលនវត្ថុត្រូវបានដាក់ធានារ៉ាប់រងត្រូវវិនាសក្រោយកាលបរិច្ឆេទនៃការអនុវត្ត ប្រសិនបើការវិនាសនោះកើតឡើងនៅក្នុងអំឡុងពេលធានារ៉ាប់រងដែលបុព្វលាភរ៉ាប់រងត្រូវបានបង់រួចហើយនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ភាគីម្ខាងទៀតក៏ត្រូវបានការពារដូចគ្នាតាមកថាខណ្ឌទី ២ មាត្រា ១៣១ នៃច្បាប់ភូមិបាលដែរ។ ប៉ុន្តែ ប្រសិនបើកិច្ចសន្យាធានារ៉ាប់រងត្រូវបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត តែបុព្វលាភធានារ៉ាប់រងត្រូវបានបង់នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ករណីនេះមិនត្រូវទទួលស្គាល់ថាជាសិទ្ធិដែលត្រូវបានទទួលរួចហើយទេ ហេតុដូច្នេះ ក្រមរដ្ឋប្បវេណីត្រូវយកទៅអនុវត្ត ហើយភាគីម្ខាងទៀតមិនអាចទទួលបាននូវការការពារដូចកន្លងមកឡើយ។

មូលហេតុដែលក្រមរដ្ឋប្បវេណីមិនមានបញ្ញត្តិដូចកថាខណ្ឌទី ២ មាត្រា ១៣១ នៃច្បាប់ភូមិបាល ពីព្រោះ (១) វាមិនសមរម្យទេដែលត្រូវដាក់បន្ទុកធ្ងន់ទៅលើភាគីតែម្ខាង ក្នុងករណីដែលទ្រព្យត្រូវបានខូចខាត ឬ អន្តរាយដោយសារតែប្រធានសក្តិ (២) អ្នកដែលទិញធានារ៉ាប់រងដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ហេតុដូច្នេះ ផលប្រយោជន៍ធានារ៉ាប់រងត្រូវទទួលដោយភាគីដែលបង់បុព្វលាភធានារ៉ាប់រង (៣) ទោះបីជាគ្មានការព្រមព្រៀងរវាងភាគីក៏ដោយ ក៏ការចែងបញ្ញត្តិបែបនោះ គឺផ្ទុយនឹងគោលការណ៍សេរីភាពក្នុងការធ្វើកិច្ចសន្យា និង ស្វ័យភាពនៃបុគ្គលឯកជនដែរ។

## មាត្រា ៤៣.-អន្តរប្បញ្ញត្តិស្តីពីសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ដែលត្រូវបានចុះបញ្ជី

ប្រសិនបើសិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅ ដែលត្រូវបានបង្កើតដោយ

ផ្អែកលើច្បាប់ភូមិបាលឆ្នាំ ២០០១ ត្រូវបានចុះបញ្ជី ដោយផ្អែកលើបញ្ញត្តិនៃកថាខណ្ឌទី ៣ មាត្រា ១២០ នៃច្បាប់ភូមិបាលឆ្នាំ ២០០១ ដែលត្រូវយកមកអនុវត្តដោយយោងតាមបញ្ញត្តិនៃមាត្រា ១៣៩ នៃច្បាប់ដដែល ទោះបីមានបញ្ញត្តិនៃមាត្រា ២៧៧ (លក្ខខណ្ឌតតាំងនៃសិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យនៅ) នៃក្រមរដ្ឋប្បវេណីក៏ដោយ ហើយទោះបីមិនប្រើប្រាស់ ឬអាស្រ័យនៅជាក់ស្តែងក៏ដោយ ក៏សិទ្ធិនោះអាចតតាំងចំពោះតតិយជនបានដែរ។

(កំណត់)

ប្រហែលជាអាចមានសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅដែលត្រូវបានចុះបញ្ជីរួចហើយនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ដោយសារតែការចុះបញ្ជីប្រភេទនេះត្រូវបានអនុញ្ញាតដោយកថាខណ្ឌទី ១ មាត្រា ១៣៩ និង កថាខណ្ឌទី ៣ មាត្រា ១២០ នៃច្បាប់ភូមិបាល (បើទោះជាមាត្រា ២២៩ នៃច្បាប់នោះមិនសំដៅទៅលើផលុបភោគសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅក៏ដោយ ក៏ផលុបភោគអាចត្រូវបានចុះបញ្ជីតាមកថាខណ្ឌទី ៣ មាត្រា ១២០ នៃច្បាប់នោះបានដែរ)។ មាត្រា ២៧៤ នៃក្រមរដ្ឋប្បវេណីកំណត់អំពីល័ក្ខខ័ណ្ឌតតាំងចំពោះតតិយជននៃសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ គឺការកាន់កាប់ជាក់ស្តែង។ ប៉ុន្តែ ប្រសិនបើសិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅនោះត្រូវបានចុះបញ្ជីរួចហើយ វាមានភាពសមរម្យដែរក្នុងការទទួលស្គាល់នូវការបំពេញល័ក្ខខ័ណ្ឌតតាំងចំពោះតតិយជន ទោះបីជាមិនមានការកាន់កាប់ជាក់ស្តែងក៏ដោយ។ ដោយសារតែហេតុផលនេះ ទើបមាត្រានេះត្រូវបានតាក់តែងឡើង។

## មាត្រា ៤៤.- អន្តរប្បញ្ញត្តិស្តីពីការប្រាក់សមាស

១-បញ្ញត្តិនៃមាត្រា ៣១៩ (ការប្រាក់សមាស) នៃក្រមរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយចំពោះការប្រាក់ដែលបានកើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្ត។

២-ចំពោះការអនុវត្តកថាខណ្ឌទី ២ នៃមាត្រា ៥៨៦ (ពេលវេលានៃការបង់ការប្រាក់ និងការប្រាក់សមាសដែលកំណត់ដោយច្បាប់) នៃក្រមរដ្ឋប្បវេណី ត្រូវអនុលោមតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ។

(កំណត់)

មាត្រានេះពាក់ព័ន្ធនឹងបញ្ហាថាតើការប្រាក់សមាសត្រូវយកទៅអនុវត្តដែរឬទេ ក្នុងករណីដែលសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់បានបង្កើតការប្រាក់នៅមុនកាលបរិច្ឆេទនៃការអនុវត្ត។

ទំនាក់ទំនងនៃសិទ្ធិលើបំណុលដែលជាមូលដ្ឋាននៃការកើតឡើងនៃការប្រាក់ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥ នៃច្បាប់នេះ ពីព្រោះទំនាក់ទំនងនោះត្រូវបានបង្កើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត។ ចំពោះសិទ្ធិទាមទារការប្រាក់គឺជាផ្នែកមួយនៃសិទ្ធិលើបំណុលដែលអាចបែងចែកពីសិទ្ធិលើបំណុលជាមូលដ្ឋាន ហើយអាចត្រូវបានធ្វើអនុប្បទានដោយឯករាជ្យ ដោយបែងចែកពីសិទ្ធិលើបំណុលជាមូលដ្ឋាន។ ដោយសារតែសិទ្ធិលើបំណុលនេះត្រូវចាត់ទុកថាជាសិទ្ធិលើបំណុលដែលត្រូវបានបង្កើតថ្មីពីមួយថ្ងៃទៅមួយថ្ងៃ ច្បាប់សម្រាប់គ្រប់គ្រងលើសិទ្ធិនេះអាចជាច្បាប់ចាស់ ឬ ក្រមរដ្ឋប្បវេណី គឺវាអាស្រ័យទៅតាមកាលបរិច្ឆេទនៃការបង្កើតដូចមានកំណត់ក្នុងកថាខណ្ឌទី ១ មាត្រា ៥ នៃច្បាប់នេះ។ ដូច្នេះ ចំពោះការប្រាក់សមាស ហាក់ដូចជាត្រូវយកទៅអនុវត្តតែចំពោះសិទ្ធិលើបំណុលចំពោះការប្រាក់ដែលកើតឡើងនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តប៉ុណ្ណោះ។ ប៉ុន្តែ អាចមានការបកស្រាយម្យ៉ាងទៀតថា ចាប់តាំងពីកាលបរិច្ឆេទនៃការអនុវត្តមក ការប្រាក់សមាសត្រូវអនុវត្តចំពោះរាល់ការប្រាក់ទាំងអស់ដែលបានកើតមុនកាលបរិច្ឆេទនៃការអនុវត្តដែរ ដោយចាត់ទុកថា "ការដាស់តឿន" ដែលបានកំណត់នៅក្នុងមាត្រា ៣១៩ នៃក្រមរដ្ឋប្បវេណីជា "បញ្ញាថ្មី" (ដែលបានកំណត់ក្នុងមាត្រា ៥ នៃច្បាប់នេះ)។ ដោយហេតុនេះ ដើម្បីជៀសវាងការបកស្រាយបែបនេះ មាត្រានេះចែងថា មាត្រា ៣១៩ នៃក្រមរដ្ឋប្បវេណីមិនត្រូវយកមកអនុវត្តឡើយចំពោះការប្រាក់ដែលបានកើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្ត។

កថាខណ្ឌទី ២ នៃមាត្រានេះកំណត់ពីវិធានការដូចគ្នាដើម្បីអនុវត្តកថាខណ្ឌទី ២ មាត្រា ៥៨៦ នៃក្រមរដ្ឋប្បវេណី ។

ប្រសិនបើការគណនាការប្រាក់មានភាពស្មុគស្មាញដោយសារតែមាត្រានេះ ភាគីអាចបង្កើតឧបកិច្ចសន្យាខ្ចីបរិភោគ (មាត្រា ៥៨២ នៃក្រមរដ្ឋប្បវេណី) នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។

## មាត្រា ៤៥.-អន្តរប្បញ្ញត្តិស្តីពីការមិនអនុវត្តកាតព្វកិច្ច

១-ប្រសិនបើបុគ្គលដែលបានទទួលបន្ទុកកាតព្វកិច្ចតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត បុគ្គលនោះត្រូវទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចនោះ ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលម្ចាស់បំណុលប្រកែកមិនទទួលនូវការអនុវត្តកាតព្វកិច្ច ឬ មិនអាចទទួលការអនុវត្តកាតព្វកិច្ចបាន។

៣-ក្នុងករណីដែលកាតព្វកិច្ចនៃកិច្ចសន្យាដែលបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវបានអនុវត្តនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តបញ្ញត្តិស្តីពី

ការទទួលខុសត្រូវក្នុងការធានា នៅក្នុងក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្ត ចំពោះការអនុវត្តកាតព្វកិច្ចនោះ។

(កំណត់)

មាត្រានេះគឺជាអន្តរប្បញ្ញត្តិដែលពាក់ព័ន្ធនឹងការមិនអនុវត្តកាតព្វកិច្ច ហើយកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃមាត្រានេះស្រដៀងគ្នាទៅនឹងមាត្រា ៥៣ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីប្រទេសជប៉ុន។

មាត្រានេះគឺផ្អែកលើមូលដ្ឋាននៃការសន្និដ្ឋានថា នៅពេលដែលអ្នកមានកាតព្វកិច្ចតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្តមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត ករណីនេះត្រូវគ្រប់គ្រងដោយច្បាប់ចាស់ ដោយអនុលោមទៅតាមកថាខណ្ឌទី ១ មាត្រា ៥ នៃច្បាប់នេះ។ មានន័យថា ក្នុងករណីដែលភាគីនៃកិច្ចសន្យាដែលត្រូវបានបង្កើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្ត បានព្រមព្រៀងគ្នាកំណត់ពេលត្រូវអនុវត្តកាតព្វកិច្ចនៅពេលណាមួយនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ប្រសិនបើកូនបំណុលមិនបានអនុវត្តកាតព្វកិច្ច (ការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច) ឬ ក្លាយទៅជាអលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចនៅពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ច នោះមាត្រានេះមិនត្រូវយកមកអនុវត្តចំពោះករណីនេះទេ។ ក្នុងករណីនេះ "បញ្ហា" (កថាខណ្ឌទី ១ នៃមាត្រា ៥) នៃការមិនអនុវត្តកាតព្វកិច្ចបានកើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ដូច្នេះត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក។ ទោះបីជាម្ចាស់បំណុលអនុវត្តសិទ្ធិរំលាយកិច្ចសន្យា ឬ ទាមទារសំណងការខូចខាតនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ ក៏សិទ្ធិរំលាយ ជាអាទិ៍ នោះបានកើតឡើងតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្តដែរ ដោយហេតុនោះហើយ ទើបត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក។ មូលហេតុគឺដោយសារតែការអនុវត្តក្រមរដ្ឋប្បវេណីចំពោះករណីទាំងនោះនឹងនាំឱ្យមានវិវាទកើតសាជាថ្មីឡើងវិញ ហើយមិនសមរម្យទេ។ ហេតុនេះហើយ មាត្រានេះគ្របដណ្តប់តែករណីនៃការមិនអនុវត្តកាតព្វកិច្ច ជាអាទិ៍ ដែលកើតឡើងក្រោយកាលបរិច្ឆេទនៃការអនុវត្តប៉ុណ្ណោះ។

កថាខណ្ឌទី ១ នៃមាត្រានេះបញ្ជាក់ច្បាស់ថា ក្នុងករណីដែលបុគ្គលដែលមានកាតព្វកិច្ចតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត ក្លាយទៅជាស្ថានភាពមិនអនុវត្តកាតព្វកិច្ចនោះក្រោយកាលបរិច្ឆេទនៃការអនុវត្ត ក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តចំពោះទំនាក់ទំនងគតិយុត្តដែលជាលទ្ធផលនៃការមិនអនុវត្តកាតព្វកិច្ច។ មាត្រានេះកំណត់អំពីខ្សែបន្ទាត់ព្រំដែននៃលទ្ធភាពអនុវត្តរបបច្បាប់ចាស់ និង ក្រមរដ្ឋប្បវេណី ទាក់ទងទៅនឹងទំនាក់ទំនងនៃកាតព្វកិច្ចតាមមធ្យោបាយដូចគ្នា ដែលមានចែងនៅក្នុងកថាខណ្ឌទី ១ មាត្រា ៥ នៃច្បាប់នេះ ដែលកំណត់អំពីលទ្ធភាពអនុវត្តក្រមរដ្ឋប្បវេណីដោយចែងថា បញ្ហាដែលបានកើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តត្រូវគ្រប់គ្រងដោយច្បាប់ចាស់ ហើយកំណត់ថា ក្រមរដ្ឋប្បវេណីត្រូវអនុវត្តចំពោះបញ្ហាដែលកើតឡើងចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត (វាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រា ៥) ហើយចែងទៀតថា ចំពោះទំនាក់ទំនងគតិយុត្តជាបន្តដែល

កើតឡើងចាប់តាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត ហើយនៅតែមានអត្ថិភាពក្រោយកាលបរិច្ឆេទនៃការអនុវត្ត ក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តចាប់ពីកាលបរិច្ឆេទនៃការអនុវត្តប៉ុណ្ណោះ (វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ៥)។

ជាលទ្ធផលនៃការអនុវត្តកថាខណ្ឌទី ១ នៃមាត្រានេះ នៅក្នុងករណីដែលអ្នកលក់ និង អ្នកទិញបានបង្កើតកិច្ចសន្យានៅមុនកាលបរិច្ឆេទនៃការអនុវត្តដែលមានខ្លឹមសារតម្រូវឱ្យអ្នកលក់ធ្វើការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញនៅពេលកំណត់មួយក្រោយកាលបរិច្ឆេទនៃការអនុវត្ត ប្រសិនបើអ្នកលក់មិនបានប្រគល់វត្ថុនោះនៅពេលកំណត់នោះទេ អ្នកលក់ត្រូវទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច ដោយយោងទៅតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី។ នៅក្នុងករណីនេះ ដោយសារតែវាអាចត្រូវបានយល់ឃើញថា "បញ្ហា" ថ្មី (កថាខណ្ឌទី ១ មាត្រា ៥ នៃច្បាប់នេះ) នៃការមិនអនុវត្តកាតព្វកិច្ចរបស់អ្នកលក់កើតឡើងនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ក្រមរដ្ឋប្បវេណីត្រូវអនុវត្តចំពោះលទ្ធផលនៃការមិនអនុវត្តកាតព្វកិច្ចនោះ។ ចាំបាច់ត្រូវធ្វើការកត់សម្គាល់នៅទីនេះថា ដោយសារតែកិច្ចសន្យានោះត្រូវបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត គេគួរតែយល់ថា ខ្លឹមសារនៃកាតព្វកិច្ចគឺស្ថិតនៅក្រោមច្បាប់ចាស់ ហើយបញ្ហាថាតើមាន ឬ គ្មានការមិនអនុវត្តកាតព្វកិច្ចគឺដោយផ្អែកលើបញ្ញត្តិនៃច្បាប់ចាស់ លើកលែងតែករណីដែលត្រូវនឹងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រានេះដែលនឹងត្រូវធ្វើការពន្យល់នាពេលក្រោយ។ មានន័យថា ចំពោះឧទាហរណ៍ខាងលើ ទោះបីជាពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ចប្រគល់គឺនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ ក៏ខ្លឹមសារនៃការអនុវត្តកាតព្វកិច្ច និង អត្ថិភាព ឬ នត្ថិភាពនៃការអនុវត្តកាតព្វកិច្ច (ថាតើមានការមិនអនុវត្តកាតព្វកិច្ចឬទេនោះ) ត្រូវគ្រប់គ្រងដោយរបបច្បាប់ចាស់។

ជាបន្ត អាចមានករណីដែលកិច្ចសន្យាត្រូវបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ហើយកូនបំណុលបានអនុវត្តកាតព្វកិច្ចនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ប៉ុន្តែការអនុវត្តនោះមិនបានពេញលេញ ឬ មានវិការៈក្នុងការអនុវត្តកាតព្វកិច្ច។ ករណីបែបនេះ ក៏ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមកដែរ។ ការអនុវត្តមិនពេញលេញគឺជាប្រភេទមួយនៃការមិនអនុវត្តកាតព្វកិច្ច ហើយការទទួលខុសត្រូវក្នុងការធានាអាចត្រូវបានគិតថាមានលក្ខណៈដូចគ្នានឹងការមិនអនុវត្តកាតព្វកិច្ចដែរ។ ទោះបីជាការទទួលខុសត្រូវក្នុងការធានាត្រូវបានគេយល់ថាជាការទទួលខុសត្រូវដែលកំណត់ដោយច្បាប់ក៏ដោយ ច្បាប់ជាមូលដ្ឋានដែលពាក់ព័ន្ធគួរតែជាច្បាប់ចាស់ដោយសារតែការទទួលខុសត្រូវក្នុងការធានានោះបានកើតឡើងតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត។ ប៉ុន្តែ ក្នុងករណីកិច្ចសន្យាដែលត្រូវបានបង្កើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តកំណត់ថា ត្រូវអនុវត្តកាតព្វកិច្ចនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ប៉ុន្តែការអនុវត្តជាក់ស្តែងត្រូវបានធ្វើឡើងនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ប្រសិនបើម្ចាស់បំណុលទទួលយកការអនុវត្តនោះ ប៉ុន្តែ ការអនុវត្តនោះមិនពេញលេញ ឬ មានវិការៈ គឺវាមានភាពសមរម្យដែលចាត់ទុកករណីនេះថាភាគីបានធ្វើការផ្លាស់ប្តូរពេលកំណត់អនុវត្តកាតព្វកិច្ចពីពេលកំណត់ដែលមានចែងនៅក្នុងកិច្ចសន្យាទៅជាពេលកំណត់ដែលស្ថិតនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ហើយការមិនអនុវត្តកាតព្វកិច្ចនេះបានកើតឡើងនៅក្រោយ

កាលបរិច្ឆេទនៃការអនុវត្ត ដើម្បីឱ្យក្រមរដ្ឋប្បវេណីអាចយកមកអនុវត្តបានចំពោះលទ្ធផលនៃការមិនអនុវត្តកាតព្វកិច្ចនេះ។ ក្នុងករណីនេះ មានតែពេលកំណត់ត្រូវអនុវត្តទេដែលត្រូវបានផ្លាស់ប្តូរ ដោយឡែកខ្លឹមសារនៃកាតព្វកិច្ចគឺនៅដដែល។ ក្នុងករណីបែបនេះ ប្រសិនបើការអនុវត្តមានវិការៈ កថាខណ្ឌទី ៣ នៃមាត្រានេះត្រូវយកមកអនុវត្ត។

កថាខណ្ឌទី ២ នៃមាត្រានេះពាក់ព័ន្ធទៅនឹងការយឺតយ៉ាវរបស់ម្ចាស់បំណុលក្នុងការទទួលយកការអនុវត្តកាតព្វកិច្ច។ មាត្រា ៤៥៦ នៃក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តចំពោះករណីដែលម្ចាស់បំណុលមានការយឺតយ៉ាវក្នុងការទទួលនូវការអនុវត្តកាតព្វកិច្ចនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តចំពោះកិច្ចសន្យាដែលបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត។

កថាខណ្ឌទី ៣ នៃមាត្រានេះបញ្ជាក់ថា ក្នុងករណីកិច្ចសន្យាដែលត្រូវបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ហើយដែលកូនបំណុលអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត បញ្ញត្តិស្តីពីការទទួលខុសត្រូវក្នុងការធានានៅក្នុងក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះការអនុវត្តកាតព្វកិច្ចនោះ។ ទោះបីជារបបច្បាប់ចាស់ត្រូវអនុវត្តចំពោះខ្លឹមសារនៃកាតព្វកិច្ចដោយសារតែកិច្ចសន្យាត្រូវបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ ក៏មាត្រានេះតម្រូវឱ្យយកច្បាប់ដែលមាននៅពេលអនុវត្តកាតព្វកិច្ចមកអនុវត្តចំពោះការទទួលខុសត្រូវក្នុងការធានាដែរ ពីព្រោះការទទួលខុសត្រូវក្នុងការធានា ជាទូទៅ មិនមានចែងនៅក្នុងកិច្ចសន្យាទេ ហើយច្រើនតែត្រូវអនុលោមតាមបញ្ញត្តិនៃច្បាប់។ ប្រសិនបើយល់ឃើញថា ការទទួលខុសត្រូវក្នុងការធានាគឺជាការទទួលខុសត្រូវដែលកំណត់ដោយច្បាប់ ការទទួលខុសត្រូវដែលច្បាប់បានកំណត់នេះត្រូវកើតឡើងដោយការអនុវត្តកាតព្វកិច្ច ហេតុដូច្នេះ ការពន្យល់អំពីការយកច្បាប់ដែលមាននៅពេលអនុវត្តកាតព្វកិច្ចមកអនុវត្តដូចខាងលើ មានភាពងាយស្រួលយល់ជាង។ ប្រសិនបើយល់ឃើញថា ការទទួលខុសត្រូវក្នុងការធានាជាការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច បញ្ញត្តិនៃកថាខណ្ឌទី ៣ នេះត្រូវចាត់ទុកថាជាបញ្ញត្តិពិសេសចំពោះកថាខណ្ឌទី ១ មាត្រា ៥ នៃច្បាប់នេះ។

## មាត្រា ៤៦.-អន្តរប្បញ្ញត្តិស្តីពីបញ្ញត្តិពិសេសអំពីកាតព្វកិច្ចជាប្រាក់

ក្នុងករណីដែលបុគ្គលទទួលបន្ទុកកាតព្វកិច្ចដែលមានគោលបំណងឱ្យសងជាប្រាក់ មិនបានអនុវត្តកាតព្វកិច្ចនោះ តាំងពីមុនកាលបរិច្ឆេទនៃការអនុវត្តទេ បញ្ញត្តិនៃមាត្រា ៣៩៩ (បញ្ញត្តិពិសេសអំពីកាតព្វកិច្ចជាប្រាក់) នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្ត ចំពោះចំនួនទឹកប្រាក់ដែលជាសំណងនៃការខូចខាតដែលកើតឡើងនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។

(កំណត់)

មាត្រានេះមានខ្លឹមសារដូចគ្នានឹងមាត្រា ៥៦ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីប្រទេសជប៉ុនដែរ។ មាត្រា

៣៩៩ នៃក្រមរដ្ឋប្បវេណីបានបញ្ញត្តនូវវិធានពិសេសចំពោះកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ ដោយមានមូលហេតុថា ជានិច្ចកាល ប្រាក់តែងតែអាចងាយរកបាន និងស្ថានភាពជាក់ស្តែងចំពោះករណីនីមួយៗមិនទាមទារឱ្យយកពិចារណាដើម្បីគណនាចំនួននៃសំណងការខូចខាតទេ ហើយចំនួននៃសំណងការខូចខាតនោះមានភាពច្បាស់លាស់ស្រាប់ហើយ។ មាត្រានេះមានគោលបំណងអនុវត្តមាត្រា ៣៩៩ នៃក្រមរដ្ឋប្បវេណីឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ពីព្រោះថា បញ្ញត្តិនៃមាត្រា ៣៩៩ នោះមានភាពសមហេតុសមផល។ មាត្រា ៣៩៩ នៃក្រមរដ្ឋប្បវេណីត្រូវអនុវត្តតែចំពោះចំនួនទឹកប្រាក់នៃសំណងការខូតខាតដែលកើតឡើងនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តប៉ុណ្ណោះ រីឯការគណនាចំនួនទឹកប្រាក់នៃសំណងការខូតខាតដែលបានកើតមាននៅមុនកាលបរិច្ឆេទនៃការអនុវត្តវិញ ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក។

## មាត្រា ៤៧.- អន្តរប្បញ្ញត្តិស្តីពីការទូទាត់

១-ទោះបីកាតព្វកិច្ចបានកើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ ក៏អាចរួចផុតពីកាតព្វកិច្ចនោះដោយការទូទាត់ ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីបានដែរ។

២-ក្នុងករណីដែលកាតព្វកិច្ចទាំងសងខាងស្របនឹងលក្ខខណ្ឌទូទាត់ទៅវិញទៅមកតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត អានុភាពនៃការរលត់កាតព្វកិច្ចដោយការទូទាត់ ត្រូវកើតឡើងដោយប្រតិសកម្ម មកដល់ត្រឹមកាលបរិច្ឆេទនៃការអនុវត្ត។

(កំណត់)

មាត្រានេះមានអានុភាពដូចគ្នានឹងមាត្រា ៥៨ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីប្រទេសជប៉ុនដែរ។ ដោយសារតែការទូទាត់គឺជាប្រភេទមួយនៃការសង វិធីសងដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីគួរតែត្រូវបានទទួលស្គាល់ចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត ហេតុដូច្នេះ មាត្រានេះត្រូវបានរៀបចំឡើង។ កថាខណ្ឌទី ១ នៃមាត្រានេះមានគោលបំណងបញ្ជាក់ឱ្យច្បាស់ចំពោះចំណុចនេះ។ សិទ្ធិលើបំណុលដែលយកមកទូទាត់អាចជាសិទ្ធិលើបំណុលដែលបានកើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តក៏បាន ក្រោយកាលបរិច្ឆេទនៃការអនុវត្តក៏បាន។

កថាខណ្ឌទី ២ នៃមាត្រានេះគឺជាបញ្ញត្តិពិសេសចំពោះពេលដែលបង្កើតអានុភាពនៃការទូទាត់។ មាត្រា ៤៦៦ នៃក្រមរដ្ឋប្បវេណីចែងថា អានុភាពនៃការទូទាត់ត្រូវកើតឡើងដោយប្រតិសកម្មតាំងពីពេលដែលកាតព្វកិច្ចទាំងពីរនោះសមស្របទៅនឹងការទូទាត់ (ពេលកំណត់ត្រូវអនុវត្តចុងក្រោយនៃកាតព្វកិច្ចទាំងពីរ លើកលែងតែប្រយោជន៍នៃការកំណត់ពេលត្រូវបានបោះបង់)។ ហេតុដូច្នេះ ចាប់តាំងពីពេលនោះមក សិទ្ធិលើបំណុលទាំងឡាយដែលត្រូវ

បានទូទាត់នឹងមិនបង្កើតការប្រាក់ ឬ ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចទេ។ ប្រសិនបើបញ្ញត្តិនៃមាត្រានេះយកមកអនុវត្តដោយគ្មានល័ក្ខខ័ណ្ឌទេ អាចនឹងមានករណីខ្លះដែលសិទ្ធិទាមទារការប្រាក់ ជាអាទិ៍ ក្លាយទៅជាគ្មានអត្ថិភាពដោយសារតែការអនុវត្តដោយប្រតិសកម្មនូវបញ្ញត្តិនៃក្រមរដ្ឋប្បវេណី។ ដោយហេតុនោះ បានជាកថាខណ្ឌទី ២ នៃមាត្រានេះកំណត់នូវព្រំដែននៃការអនុវត្តដោយប្រតិសកម្មត្រឹមកាលបរិច្ឆេទនៃការអនុវត្តដើម្បីធានាដល់ផលប្រយោជន៍របស់ភាគីទាំងសងខាង។

ជាលទ្ធផលនៃការអនុវត្តមាត្រានេះ ប្រសិនបើសិទ្ធិលើបំណុល A មានភ្ជាប់ការប្រាក់ ២ % ក្នុងមួយឆ្នាំដែលត្រូវបានបង្កើតឡើងរយៈពេល ៤ ឆ្នាំ មុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវបានទូទាត់ជាមួយសិទ្ធិលើបំណុល B មានភ្ជាប់ការប្រាក់ ៥ % ក្នុងមួយឆ្នាំដែលត្រូវបានបង្កើតឡើងរយៈពេល ១ ឆ្នាំ នៅមុនកាលបរិច្ឆេទនៃការអនុវត្ត នៅ ១ ឆ្នាំក្រោយកាលបរិច្ឆេទនៃការអនុវត្ត ទោះបីជាសិទ្ធិលើបំណុលទាំងពីរបានកើនការប្រាក់ ១០ % រៀងៗខ្លួន នៅពេលទូទាត់ក៏ដោយ ក៏ការទូទាត់ត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋានថា សិទ្ធិលើបំណុល A បានបង្កើតការប្រាក់ ៨ % រីឯសិទ្ធិលើបំណុល B បានបង្កើតការប្រាក់ ៥ % ដែរ។

## មាត្រា ៤៨.-អន្តរប្បញ្ញត្តិស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិ

១-បញ្ញត្តិស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិនៅក្នុងក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះសិទ្ធិលើបំណុលដែលមិនទាន់រលត់ដោយអាជ្ញាយុកាល មុនកាលបរិច្ឆេទនៃការអនុវត្ត។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើក៏ដោយ ប្រសិនបើអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិដែលបានចាប់ផ្តើមគិតមុនកាលបរិច្ឆេទនៃការអនុវត្តវែងជាងអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី សិទ្ធិលើបំណុលនោះ មិនត្រូវផុតអាជ្ញាយុកាលនៃការរំលត់សិទ្ធិរហូតដល់ពេលផុតអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិដែលបានកំណត់ដោយច្បាប់ ឬ បទដ្ឋានគតិយុត្តកន្លងមក។ ប៉ុន្តែ ក្នុងករណីដែលអំឡុងពេលអាជ្ញាយុកាលដែលនៅសល់នោះ វែងជាងអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី ដោយគណនាចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត នោះបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្ត ដោយគណនាចាប់ពីកាលបរិច្ឆេទនៃការអនុវត្តនោះទៅ។

៣-ចំពោះសិទ្ធិដែលគ្មានកំណត់អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិ បញ្ញត្តិស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនៅក្នុងក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដោយគណនាពីកាលបរិច្ឆេទនៃការអនុវត្ត។

(កំណត់)

មាត្រា ២៥ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច ចែងថា អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលគឺ ៥ ឆ្នាំ ដោយមិនមានករណីលើកលែង ប៉ុន្តែ មាត្រា ៤៨២ នៃក្រមរដ្ឋប្បវេណីចែងជាគោលការណ៍ថា អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលគឺ ៥ ឆ្នាំ ហើយមាត្រា ៤៨៣ វិញចែងអំពីអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិដែលមានរយៈពេលខ្លីជាងនោះគឺ ២ ឆ្នាំ ចំពោះសិទ្ធិលើបំណុលអំពីថ្លៃទំនិញដែលផលិតករលក់ទៅឱ្យអ្នកដែលមិនមែនជាពាណិជ្ជករជាអាទិ៍។ ចំពោះករណីនេះ ការសម្របសម្រួលជាមួយមាត្រា ២៥ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច គឺមានភាពចាំបាច់ណាស់។

ក្រៅពីនោះ ហាក់ដូចជាមានសិទ្ធិលើបំណុលខ្លះដែលស្ថិតនៅក្រៅទំហំនៃទំនាក់ទំនងកិច្ចសន្យាដែលបានចែងនៅក្នុងក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច ដោយហេតុនោះ សិទ្ធិលើបំណុលនោះមិនស្ថិតនៅក្នុងអំឡុងពេលនៃអាជ្ញាយុកាលដែលកំណត់ដោយក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច ទេ។ គោលគំនិតនៃអាជ្ញាយុកាលគឺដើម្បីដោះស្រាយបញ្ហាការរលត់បាត់នៃភស្តុតាងដែលហួសរយៈពេលមួយក៏ដូចជាគោលបំណងមិនការពារដល់ជនទាំងឡាយណាដែលមិនអនុវត្តសិទ្ធិដែលខ្លួនអាចអនុវត្តបានក្នុងអំឡុងពេលវែងហួសហេតុ។ ការពន្លាតនូវគោលគំនិតនេះទៅដល់សិទ្ធិលើបំណុលទាំងឡាយដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត នឹងជាវិភាគទានចំពោះស្ថិរភាពគតិយុត្ត។ ហេតុដូច្នេះ ដើម្បីសម្រេចនូវគោលគំនិតនេះ មាត្រានេះត្រូវបានតាក់តែងឡើងដើម្បីអនុវត្តបញ្ញត្តិដែលពាក់ព័ន្ធនឹងអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលចែងក្នុងក្រមរដ្ឋប្បវេណី ចំពោះសិទ្ធិលើបំណុលទាំងឡាយដែលមិនទាន់រលត់ដោយអាជ្ញាយុកាលនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ក៏ដូចជាដើម្បីធ្វើការសម្របសម្រួលឱ្យបានសមរម្យចំពោះការអនុវត្តនេះ។ មាត្រានេះត្រូវបានរៀបចំឡើងដោយយកបញ្ញត្តិចាប់ពីមាត្រា ២៩ ដល់មាត្រា ៣២ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីប្រទេសជប៉ុនមកគិតពិចារណា។

កថាខណ្ឌទី ១ នៃមាត្រានេះចែងអំពីគោលការណ៍ដែលស្របនឹងគោលគំនិតដែលបានរៀបរាប់ខាងលើដោយបញ្ញត្តថា បញ្ញត្តិស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិនៅក្នុងក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះសិទ្ធិលើបំណុលដែលមិនទាន់រលត់ដោយអាជ្ញាយុកាលមុនកាលបរិច្ឆេទនៃការអនុវត្ត ។

កថាខណ្ឌទី ២ នៃមាត្រានេះកំណត់អំពីការសម្របសម្រួលចំពោះអំឡុងពេលនៃអាជ្ញាយុកាល។ ជាឧទាហរណ៍ ក្នុងករណីដែលផលិតករម្នាក់បានលក់ផលិតផលមួយទៅឱ្យជនម្នាក់ដែលមិនមែនជាពាណិជ្ជករកាលពី ២ ឆ្នាំ

មុនកាលបរិច្ឆេទនៃការអនុវត្ត អំឡុងពេល ៥ ឆ្នាំសម្រាប់អំឡុងពេលនៃអាជ្ញាយុកាលតាមមាត្រា ២៥ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច ត្រូវយកមកអនុវត្ត ប្រសិនបើគ្មានបញ្ញត្តិពិសេសនៅក្នុងច្បាប់នេះ។ ក្នុងករណីនេះ វាទំនងជាសមរម្យដែលអំឡុងពេលខ្លីនៃអាជ្ញាយុកាលដែលចែងនៅក្នុងក្រមរដ្ឋប្បវេណីត្រូវអនុវត្តដោយយោងតាមកថាខណ្ឌទី ១ នៃមាត្រានេះដើម្បីដោះស្រាយស្ថានភាពក្នុងរយៈពេលខ្លី ប៉ុន្តែ ប្រសិនបើអនុវត្តដូច្នេះ សិទ្ធិលើបំណុលនោះនឹងត្រូវរលត់ដោយអាជ្ញាយុកាល ព្រមជាមួយគ្នានឹងកាលបរិច្ឆេទនៃការអនុវត្តដែលវានឹងធ្វើឱ្យមានការភ្ញាក់ផ្អើល និង អយុត្តិធម៌ចំពោះម្ចាស់បំណុលណាស់។ ដោយហេតុនោះហើយបានជាអំឡុងពេល ២ ឆ្នាំ សម្រាប់អំឡុងពេលនៃអាជ្ញាយុកាលគិតចាប់ពីកាលបរិច្ឆេទនៃការអនុវត្តត្រូវបានកំណត់យក។

កថាខណ្ឌទី ៣ នៃមាត្រានេះចែងថា បញ្ញត្តិដែលពាក់ព័ន្ធជាមួយនឹងអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តចំពោះសិទ្ធិដែលមិនមានអាជ្ញាយុកាលនៃការរលត់ (តាមច្បាប់ចាស់) ដោយគិតអំឡុងពេលនៃអាជ្ញាយុកាលនោះចាប់ពីកាលបរិច្ឆេទនៃការអនុវត្តដើម្បីសម្រេចនូវគោលបំណងដូចបានរៀបរាប់ខាងលើ។ ករណីនេះ ដើម្បីអនុវត្តកថាខណ្ឌទី ៣ នៃមាត្រានេះ គេត្រូវធ្វើការកត់សម្គាល់ថា បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធជាមួយការទាមទារឱ្យធ្វើបដិទានសន្តតិកម្មនៅក្នុងមាត្រា ១៣០១ នៃក្រមរដ្ឋប្បវេណីមិនត្រូវយកមកអនុវត្តចំពោះសន្តតិកម្មដែលបានចាប់ផ្តើមនៅមុនកាលបរិច្ឆេទនៃការអនុវត្តឡើយ។ ប្រសិនបើបុគ្គលណាម្នាក់ដែលមិនមែនជាសន្តតិជនពិតប្រាកដបានធ្វើសន្តតិកម្មនូវទ្រព្យសម្បត្តិដោយមានកំហុស ស្ថានភាពបែបនោះនឹងត្រូវបានដោះស្រាយដោយចាត់ទុកថា បុគ្គលនោះធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិដែលខ្លួនកាន់កាប់តាមរយៈសន្តតិកម្មដែលមានកំហុសនោះ នៅពេលហួសអំឡុងពេលអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ។

## មាត្រា ៤៩.-ពេលចាប់ផ្តើមការអនុវត្តបញ្ញត្តិស្តីពីការផ្អាកអាជ្ញាយុកាល និង ការបង្អង់ការសម្រេចអាជ្ញាយុកាល

ក្នុងករណីដែលបញ្ញត្តិនៃមាត្រា ៤៨ (អន្តរប្បញ្ញត្តិស្តីពីអាជ្ញាយុកាលនៃការរលត់សិទ្ធិ) ខាងលើនេះ ត្រូវយកមកអនុវត្តបញ្ញត្តិស្តីពីការផ្អាកអាជ្ញាយុកាល និងការបង្អង់ការសម្រេចអាជ្ញាយុកាល នៅក្នុងក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត។

(កំណត់)

មាត្រានេះពាក់ព័ន្ធទៅនឹងការផ្អាកអាជ្ញាយុកាល និង ការបង្អង់ការសម្រេចអាជ្ញាយុកាលចំពោះករណីដែលបញ្ញត្តិពាក់ព័ន្ធនឹងអាជ្ញាយុកាលនៃការរលត់សិទ្ធិនៅក្នុងក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តដោយយោងតាមបញ្ញត្តិនៃមាត្រា ៤៨ ខាងលើនេះ។ នៅពេលបញ្ញត្តិដែលទាក់ទងនឹងអាជ្ញាយុកាលនៃការរលត់សិទ្ធិនៅក្នុងក្រមរដ្ឋប្បវេណី

ត្រូវយកមកអនុវត្តដោយយោងតាមបញ្ញត្តិនៃមាត្រា ៤៨ ខាងលើនេះ បញ្ញត្តិទាំងឡាយទាក់ទងនឹងការផ្អាកនិងការបង្អង់ការសម្រេចអាជ្ញាយុកាលនៅក្នុងក្រមរដ្ឋប្បវេណី ក៏គួរតែត្រូវយកមកអនុវត្តដែរ។ ដើម្បីសម្រេចនូវគោលបំណងនេះ មាត្រានេះត្រូវបានរៀបចំឡើងដោយយកបញ្ញត្តិនៃមាត្រា ៣៣ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីប្រទេសជប៉ុនមកគិតពិចារណា។

## មាត្រា ៥០.- ការអនុវត្តដូចគ្នាចំពោះអំឡុងពេលដែលច្បាប់បានកំណត់

បញ្ញត្តិនៃមាត្រា ៤៨ (អន្តរប្បញ្ញត្តិស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិ) និង មាត្រា ៤៩ (ពេលចាប់ផ្តើមការអនុវត្តបញ្ញត្តិស្តីពីការផ្អាកអាជ្ញាយុកាល និង ការបង្អង់ការសម្រេចអាជ្ញាយុកាល) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអំឡុងពេលដែលច្បាប់បានកំណត់ដែលគ្មានលក្ខណៈជាអំឡុងពេលនៃអាជ្ញាយុកាល។

(កំណត់)

មាត្រានេះស្រដៀងគ្នាទៅនឹងមាត្រា ៣៤ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីប្រទេសជប៉ុនដែរ គឺពាក់ព័ន្ធជាមួយនឹងអំឡុងពេលដូចជាអំឡុងពេលដែលច្បាប់បានកំណត់ទុកជាមុន (délai préfix) ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់។

## មាត្រា ៥១.- អន្តរប្បញ្ញត្តិស្តីពីកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់

ក្នុងករណីដែលអ្នកខ្ចីនៃកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ដែលត្រូវបានបង្កើតឡើង នៅមុនកាលបរិច្ឆេទនៃការអនុវត្ត បានទទួលមរណភាព នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃមាត្រា ៦១ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច ចុះនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា (តទៅហៅថា "ក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច") មិនត្រូវយកមកអនុវត្តឡើយ។

(កំណត់)

ចំពោះកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ វាក្យខណ្ឌទី ២ មាត្រា ៦១ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច ចែងថា "បើអ្នកជំពាក់បំណុលស្លាប់ ប្រាក់ដែលជំពាក់នោះតម្រូវឱ្យទារភ្លាមបាន ហើយទាយាទនៃអ្នកស្លាប់ត្រូវកាត់មរតកសងជាមុនសិន រួចសឹមចែកមរតកជាក្រោយ"។ ប្រសិនបើគេបកស្រាយថា បញ្ញត្តិនេះទាក់ទងតែ

ជាមួយសន្តតិកម្មប៉ុណ្ណោះ មិនចាំបាច់មានបញ្ញត្តិពិសេសទេ ពីព្រោះថា បញ្ញត្តិនេះនឹងត្រូវយកមកអនុវត្តចំពោះករណីដែលកូនបំណុលបានទទួលមរណភាពនៅមុនកាលបរិច្ឆេទនៃការអនុវត្ត រីឯបញ្ញត្តិស្ដីពីសន្តតិកម្មនៅក្នុងក្រមរដ្ឋប្បវេណីនឹងត្រូវយកមកអនុវត្តចំពោះករណីដែលកូនបំណុលបានទទួលមរណភាពនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។ ប៉ុន្តែ ប្រសិនបើគេបកស្រាយថា បញ្ញត្តិនេះគឺជាវិធានពិសេសសម្រាប់សន្តតិកម្មដែលទាក់ទងនឹងកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ (មានន័យថាជាបញ្ញត្តិពិសេសចំពោះកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់តែប៉ុណ្ណោះ) នោះអាចមានលទ្ធភាពយកបញ្ញត្តិនេះមកអនុវត្តចំពោះករណីដែលកូនបំណុលទទួលមរណភាពនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តបានដែរ។ ដោយហេតុនោះបានជាមាត្រានេះត្រូវបានដាក់បញ្ចូលជាការបញ្ជាក់បន្ថែមដើម្បីជៀសវាងការបកស្រាយបែបនោះ។ ដោយមានមូលហេតុដូចបានរៀបរាប់ខាងលើ មាត្រានេះត្រូវបានរៀបចំឡើងជាអន្តរប្បញ្ញត្តិពាក់ព័ន្ធនឹងកិច្ចសន្យាខ្ចីបរិភោគ មិនមែនជាអន្តរប្បញ្ញត្តិពាក់ព័ន្ធនឹងសន្តតិកម្មទេ។

## មាត្រា ៥២.- អន្តរប្បញ្ញត្តិក្នុងករណីដែលវត្ថុជួលមានវិការៈ

១-ក្នុងករណីដែលភតិសន្យាដែលបានធ្វើឡើងមុនកាលបរិច្ឆេទនៃការអនុវត្ត នៅតែមានអត្ថិភាពក្រោយកាលបរិច្ឆេទនៃការអនុវត្តនេះ បញ្ញត្តិនៃមាត្រា ៦០៥ (ការទទួលខុសត្រូវរបស់ភតិបតីចំពោះវិការៈនៃវត្ថុជួល) នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះភតិសន្យានោះ។ ក្នុងករណីនេះ ប្រសិនបើអំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ៦ នៃមាត្រា ៦០៥ (ការទទួលខុសត្រូវរបស់ភតិបតីចំពោះវិការៈនៃវត្ថុជួល) នៃក្រមរដ្ឋប្បវេណី បានចាប់ផ្ដើមមានដំណើរការមុនកាលបរិច្ឆេទនៃការអនុវត្ត អំឡុងពេលនោះ គឺ ១ (មួយ) ឆ្នាំ ដោយគណនាចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអំឡុងពេល ១ (មួយ) ឆ្នាំ ដែលកំណត់ក្នុងកថាខណ្ឌទី ៦ នៃមាត្រា ៦០៥ (ការទទួលខុសត្រូវរបស់ភតិបតីចំពោះវិការៈនៃវត្ថុជួល) នៃក្រមរដ្ឋប្បវេណីបានកន្លងផុត ១ (មួយ) ឆ្នាំ មុនកាលបរិច្ឆេទនៃការអនុវត្ត។

(កំណត់)

មាត្រានេះចែងអំពីបញ្ញត្តិស្ដីពីវិធីសង្គ្រោះក្នុងករណីវត្ថុដែលជាកម្មវត្ថុនៃភតិសន្យាដែលបានបង្កើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តមានវិការៈ។ ដោយយោងទៅតាមកថាខណ្ឌទី ១ មាត្រា ៥ និង មាត្រា ៤៥

នៃច្បាប់នេះ ប្រសិនបើមានវិការៈចំពោះវត្ថុដែលកូនបំណុលប្រគល់ទៅឱ្យម្ចាស់បំណុលដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួន ជាគោលការណ៍ ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ហើយបញ្ញត្តិនៃក្រមរដ្ឋប្បវេណីមិនត្រូវយកមកអនុវត្តទេ។ ប៉ុន្តែ មាត្រានេះចែងពីករណីលើកលែងចំពោះភតិសន្យាដោយគិតពិចារណាទៅដល់ភាពមានជាបន្តរបស់ភតិសន្យានោះ។

យោងទៅលើមាត្រា ៦០៥ នៃក្រមរដ្ឋប្បវេណី ប្រសិនបើមានវិការៈកំបាំងក្នុងវត្ថុជួល ភតិកៈអាចទាមទារឱ្យជួសជុលវិការៈនោះ ឬ ឱ្យដូរយកវត្ថុដែលគ្មានវិការៈ អាចទាមទារឱ្យកាត់បន្ថយថ្លៃឈ្នួល និង អាចរំលាយភតិសន្យា (ការរំលាយភតិសន្យាអាចធ្វើបានតែក្នុងករណីដែលភតិកៈមិនអាចសម្រេចបាននូវគោលបំណងនៃភតិសន្យាដោយសារវិការៈកំបាំងនោះប៉ុណ្ណោះ)។ ផ្អែកទៅលើហេតុផលដូចមានរៀបរាប់ខាងដើម ក្នុងករណីភតិសន្យាដែលត្រូវបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តបន្តមានអត្ថិភាពក្រោយកាលបរិច្ឆេទនៃការអនុវត្តនោះមាត្រា ៦០៥ ត្រូវយកមកអនុវត្ត។ វាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រានេះបញ្ជាក់អំពីគោលគំនិតនេះ។ ជាមួយគ្នានេះដែរ កថាខណ្ឌទី ៦ នៃមាត្រា ៦០៥ ចែងថា ការទាមទារឱ្យជួសជុល ឱ្យដូរ ឱ្យបន្ថយថ្លៃឈ្នួល និងការរំលាយ ត្រូវអនុវត្តនៅក្នុងអំឡុងពេល ១ ឆ្នាំ គិតចាប់ពីថ្ងៃដែលភតិកៈបានដឹង ឬ ពេលដែលត្រូវដឹងអំពីហេតុនោះបាន។ ហេតុដូច្នេះ មិនមានបញ្ហាអ្វីទេក្នុងការអនុវត្តមាត្រា ៦០៥ ប្រសិនបើភតិកៈបានដឹងអំពីវិការៈ ឬហេតុដែលភតិកៈត្រូវដឹងអំពីវិការៈនោះកើតឡើងនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។

ប៉ុន្តែ វាមានបញ្ហាក្នុងករណីដែលផ្តល់ឱ្យភតិកៈនូវការសង្គ្រោះដោយប្រតិសកម្ម ដោយអនុវត្តបញ្ញត្តិនេះចំពោះករណីដែលភតិកៈបានដឹង ឬ ត្រូវដឹងក្នុងអំឡុងពេលយូរមុនកាលបរិច្ឆេទនៃការអនុវត្ត។ ដោយហេតុនោះ កថាខណ្ឌទី ២ នៃមាត្រានេះដកករណីដែលភតិកៈបានដឹង ឬ ត្រូវដឹងលើសពី ១ ឆ្នាំ មុនកាលបរិច្ឆេទនៃការអនុវត្តជាអាទិ៍ ចេញពីទំហំនៃការសង្គ្រោះ។ មានន័យថា មាត្រានេះមានគោលបំណងផ្តល់នូវការសង្គ្រោះដល់ភតិកៈដែលបានដឹង ឬ ត្រូវដឹងអំពីវិការៈក្នុងអំឡុងពេលមិនលើសពី ១ ឆ្នាំ នៅមុនកាលបរិច្ឆេទនៃការអនុវត្តតែប៉ុណ្ណោះ ហើយអំឡុងពេល ១ ឆ្នាំ ដើម្បីអនុវត្តសិទ្ធិនោះត្រូវគណនាដោយគិតចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត (វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រានេះ)។

## មាត្រា ៥៣.-អន្តរប្បញ្ញត្តិស្តីពីសេចក្តីចម្រើនដោយឥតហេតុ

បញ្ញត្តិនៃមាត្រា ៧៤១ (ការផ្តល់តាវកាលិកដោយមូលហេតុខុសច្បាប់) នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តផងដែរ ចំពោះសេចក្តីចម្រើនដោយឥតហេតុដែលបានកើតឡើង មុនកាលបរិច្ឆេទនៃការអនុវត្ត។

(កំណត់)

មាត្រា ៧៤១ នៃក្រមរដ្ឋប្បវេណីចែងថា ក្នុងករណីដែលសេចក្តីចម្រើនដោយឥតហេតុបានកើតឡើងដោយមោឃភាពនៃកិច្ចសន្យាដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬ ទំនៀមទម្លាប់ល្អ ជាអាទិ៍ ការទាមទារឱ្យសងមិនត្រូវបានអនុញ្ញាតឡើយ ។ ចំពោះសេចក្តីចម្រើនដោយឥតហេតុដែលបានកើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ក៏គួរតែមានការកម្រិតដូចគ្នានឹងមាត្រា ៧៤១ នៃក្រមរដ្ឋប្បវេណីដែរ ហេតុដូច្នេះ មាត្រានេះត្រូវបានរៀបចំឡើង។ ម្យ៉ាងទៀត មាត្រា ៧៤១ ចែងថា ការទាមទារឱ្យសងមិនត្រូវបានអនុញ្ញាតឡើយ មានន័យថា សកម្មភាពនៃការសងមិនមែនមោឃៈទេ។ ដូច្នេះ ប្រសិនបើសេចក្តីចម្រើនដោយឥតហេតុបែបនេះត្រូវបានសងទៅវិញនៅមុនកាលបរិច្ឆេទនៃការអនុវត្តរួចហើយ មាត្រានេះមិនត្រូវយកមកអនុវត្តទេ។ ដោយហេតុនេះ បានជាវាត្រូវបានគេគិតថា ការអនុវត្តមាត្រា ៧៤១ ដោយប្រតិសកម្មនឹងមិនបង្កឱ្យមានការកើតឡើងនូវវិវាទជាថ្មីឡើយ។

## មាត្រា ៥៤.-ការធានាកាតព្វកិច្ចតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត

១-ទោះបីជាសិទ្ធិប្រាតិភោគប្រត្យក្សដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី បានកើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ ក៏សិទ្ធិប្រាតិភោគប្រត្យក្សនោះ មានអានុភាពដូចដែលកំណត់ក្នុងក្រមរដ្ឋប្បវេណីដែរ នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។

២-សិទ្ធិលើការបញ្ចាំ ឬ ហ៊ីប៉ូតែក ដោយផ្អែកលើច្បាប់ភូមិបាលឆ្នាំ ២០០១ ត្រូវចាត់ទុកថាជាសិទ្ធិលើការបញ្ចាំ ឬ ហ៊ីប៉ូតែក ដោយផ្អែកលើក្រមរដ្ឋប្បវេណីនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។

៣-ការបញ្ចាំសិទ្ធិដែលត្រូវបានបង្កើតឡើង នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ហើយដែលអាចតតាំងចំពោះកូនបំណុលទី ៣ ឬ តតិយជនផ្សេងទៀត តាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត ក៏អាចតតាំងចំពោះកូនបំណុលទី ៣ ឬ តតិយជនផ្សេងទៀតក្រោយកាលបរិច្ឆេទនៃការអនុវត្តបានដែរ។

៤-ការបញ្ចាំចលនវត្ថុ ដោយផ្អែកលើក្រឹត្យ-ច្បាប់ លេខ៣៨ ក្រ.ច ត្រូវចាត់ទុកថាជាសិទ្ធិលើការបញ្ចាំ ដោយផ្អែកលើក្រមរដ្ឋប្បវេណី នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។

(កំណត់)

បញ្ញត្តិនេះគឺដើម្បីធ្វើការសម្របសម្រួលដែលចាំបាច់រវាងសិទ្ធិប្រាតិភោគប្រត្យក្សដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត និង សិទ្ធិប្រាតិភោគប្រត្យក្សដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី។ នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត គ្មានសិទ្ធិប្រាតិភោគប្រត្យក្សណាមួយក្រៅពីសិទ្ធិប្រាតិភោគប្រត្យក្សដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីត្រូវបានបង្កើតឡើយ លើកលែងតែមានចែងជាពិសេសនៅក្នុងច្បាប់ផ្សេង ដោយផ្អែកលើគោលការណ៍កំណត់សិទ្ធិប្រត្យក្សដោយច្បាប់ (សិទ្ធិប្រត្យក្សអាចបង្កើតបានតែតាមប្រភេទ និង ខ្លឹមសារដែលត្រូវបានទទួលស្គាល់ដោយច្បាប់ប៉ុណ្ណោះ)។

កថាខណ្ឌទី ១ នៃមាត្រានេះគឺជាអន្តរប្បញ្ញត្តិដែលមានខ្លឹមសារដូចគ្នានឹងមាត្រា ៣៦ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីប្រទេសជប៉ុនដែរ។ មូលហេតុដែលតាក់តែងកថាខណ្ឌទី ១ បន្ថែមលើកថាខណ្ឌទី ២ ដែលចែងអំពីអន្តរប្បញ្ញត្តិពាក់ព័ន្ធទៅនឹងសិទ្ធិលើការបញ្ចាំ និង ហ៊ីប៉ូតែក គឺដើម្បីយកក្រមរដ្ឋប្បវេណីទៅអនុវត្តចំពោះសិទ្ធិលើការបញ្ចាំចលនវត្ថុ និង ប្រាតិភោគដោយអនុប្បទានដែលមិនបានចែងនៅក្នុងច្បាប់ភូមិបាល។

ឯកសិទ្ធិទាមទារឱ្យមានច្បាប់មូលដ្ឋាននៅពេលដែលសិទ្ធិលើបំណុល (ដែលត្រូវបានធានាដោយឯកសិទ្ធិ) កើតឡើង ប៉ុន្តែដោយសារតែមិនមានបញ្ញត្តិពាក់ព័ន្ធនឹងឯកសិទ្ធិនៅក្នុងច្បាប់ចាស់។ ហេតុដូច្នេះ តាមការបកស្រាយកថាខណ្ឌទី ១ នៃមាត្រានេះមិនគ្របដណ្តប់ទៅលើឯកសិទ្ធិទេ។ ឯកសិទ្ធិដោយផ្អែកលើបញ្ញត្តិនៃក្រមរដ្ឋប្បវេណីមិនមានអានុភាពចំពោះសិទ្ធិលើបំណុលដែលបានកើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តទេ។

កថាខណ្ឌទី ២ នៃមាត្រានេះត្រូវបានតាក់តែងឡើងដោយមានគោលបំណងដូចគ្នានឹងគោលបំណងនៃកថាខណ្ឌទី ២ មាត្រា ៣៨ នៃច្បាប់នេះដែរ។ ដោយសារច្បាប់មូលដ្ឋាននៃសិទ្ធិប្រាតិភោគប្រត្យក្សនេះត្រូវផ្លាស់ប្តូរពីច្បាប់ភូមិបាលទៅក្រមរដ្ឋប្បវេណីនៅកាលបរិច្ឆេទនៃការអនុវត្ត បញ្ញត្តិចាត់ទុកត្រូវបានរៀបចំឡើង។

កថាខណ្ឌទី ៣ នៃមាត្រានេះចែងអំពីការបញ្ចាំសិទ្ធិដែលរបបច្បាប់ចាស់ទទួលស្គាល់ថាមានល័ក្ខខ័ណ្ឌតតាំងតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្តរួចហើយដើម្បីការពារការបញ្ចាំសិទ្ធិនេះនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។ ការបញ្ចាំសិទ្ធិទាំងឡាយណាដែលមិនបានបំពេញល័ក្ខខ័ណ្ឌតតាំងគឺមិនមានអានុភាពតតាំងចំពោះតតិយជនឡើយ ទោះបីជាមានអានុភាពរវាងគូភាគីក៏ដោយ។ ការបញ្ចាំបែបនោះត្រូវបានយល់ឃើញថាមិនចាំបាច់មានការការពារជាពិសេសឡើយ។ ម្យ៉ាងទៀត ចំពោះអានុភាពនៃការបញ្ចាំសិទ្ធិដែលត្រូវបានបង្កើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តត្រូវគ្រប់គ្រងដោយច្បាប់ចាស់។ ទោះបីជាការបញ្ចាំសិទ្ធិមួយផ្សេងទៀតត្រូវបានបង្កើតឡើងចំពោះសិទ្ធិលើបំណុលតែមួយដូចគ្នានៅក្រោយកាលបរិច្ឆេទនៃការអនុវត្តដោយផ្អែកលើបញ្ញត្តិនៃក្រមរដ្ឋប្បវេណីក៏ដោយ ប្រសិនបើការបញ្ចាំដែលបានបង្កើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តមានអានុភាពតតាំងចំពោះកូនបំណុលទី ៣ និង តតិយជនផ្សេងទៀតតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត ការបញ្ចាំមុននោះត្រូវមានអាទិភាពលើការបញ្ចាំក្រោយ។

កថាខណ្ឌទី ៤ នៃមាត្រានេះទាក់ទងនឹងការបញ្ចាំចលនវត្ថុដែលមានចែងនៅក្នុងបញ្ញត្តិចាប់ពីមាត្រា ៦៤ នៃ ក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច។ ដោយសារតែការបញ្ចាំចលនវត្ថុដែលបានចែងនៅក្នុងក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច នោះស្ទើរតែដូចគ្នាទាំងស្រុងនឹងសិទ្ធិលើការបញ្ចាំចលនវត្ថុដែលបានចែងនៅក្នុងក្រមរដ្ឋប្បវេណី កថាខណ្ឌនេះត្រូវបានដាក់បញ្ចូលជា "បញ្ញត្តិចាត់ទុក" ដើម្បីរក្សានូវភាពបន្តឥតដាច់។

## មាត្រា ៥៥.-ការចាត់ចែងអំពីការដាក់ធានា

១-ការដាក់ធានា ដោយផ្អែកលើច្បាប់ភូមិបាលឆ្នាំ ២០០១ ត្រូវចាត់ទុកជាហ៊ីប៉ូតែក ដោយផ្អែកលើក្រមរដ្ឋប្បវេណី ក្រោយកាលបរិច្ឆេទនៃការអនុវត្ត។

២-ការចុះបញ្ជីអំពីការដាក់ធានា ត្រូវចាត់ទុកជាការចុះបញ្ជីហ៊ីប៉ូតែកដែលត្រូវបានចាត់ទុកដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ។ ប៉ុន្តែបញ្ញត្តិនេះមិនរារាំងភាគីក្នុងការចុះបញ្ជីហ៊ីប៉ូតែក ដោយលុបចោលការចុះបញ្ជីអំពីការដាក់ធានា។

៣-ម្ចាស់សិទ្ធិលើការដាក់ធានា ត្រូវប្រគល់ប័ណ្ណកម្មសិទ្ធិទៅអ្នកបង្កើតវិញភ្លាមក្រោយកាលបរិច្ឆេទនៃការអនុវត្ត។

(កំណត់)

មាត្រានេះពាក់ព័ន្ធនឹងការចាត់ចែងអំពីការដាក់ធានាដែលបានចែងនៅក្នុងច្បាប់ភូមិបាល។ ការសម្របសម្រួលជាមួយច្បាប់ភូមិបាលគឺមានភាពចាំបាច់ ដោយសារច្បាប់ភូមិបាលចាត់ទុកការដាក់ធានាជាសិទ្ធិប្រាតិភោគប្រត្យក្ស ចំណែកក្រមរដ្ឋប្បវេណីមិនទទួលស្គាល់ការដាក់ធានាជាសិទ្ធិប្រាតិភោគប្រត្យក្សទេ។ មាត្រា ២១៩ នៃច្បាប់ភូមិបាលចែងចំពោះ "ការដាក់ធានា" ថា កូនបំណុលប្រគល់ទៅឱ្យម្ចាស់បំណុលរបស់ខ្លួន "មិនមែនជាទ្រព្យទេតែជាប័ណ្ណកម្មសិទ្ធិនៃទ្រព្យនោះ" ហើយបើតាមច្បាប់នេះ "ការដាក់ធានា" គឺមិនមែនយកការកាន់កាប់មកជាបុរេល័ក្ខខ័ណ្ឌទេ (ទោះបីជាមានការកាន់កាប់ក៏ដោយ ក៏ការកាន់កាប់នោះត្រូវធ្វើឡើងដោយផ្អែកលើកិច្ចសន្យាដាច់ដោយឡែកមួយដែរ ដូច្នេះ មិនចាំបាច់គិតដល់បញ្ហានេះទេនៅក្នុងដំណាក់កាលផ្លាស់ប្តូរពីច្បាប់ភូមិបាលទៅក្រមរដ្ឋប្បវេណី)។ ដោយហេតុនោះ វាមានភាពសមរម្យក្នុងការចាត់ទុកការដាក់ធានានេះជាហ៊ីប៉ូតែកក្នុងចំណោមសិទ្ធិប្រាតិភោគប្រត្យក្សលើអចលនវត្ថុដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី។

កថាខណ្ឌទី ១ នៃមាត្រានេះ គឺជា "បញ្ញត្តិចាត់ទុក" ដើម្បីសម្រេចនូវគោលបំណងដូចខាងលើ ។

កថាខណ្ឌទី ២ នៃមាត្រានេះគឺជា "បញ្ញត្តិចាត់ទុក" ដែលទាក់ទងនឹងការចុះបញ្ជី។ ដោយសារតែការចុះបញ្ជី

មានភាពចាំបាច់ដើម្បីបង្កើតការដាក់ធានាដោយយោងតាមច្បាប់ភូមិបាល រាល់ការដាក់ធានាទាំងឡាយត្រូវតែចុះបញ្ជីដោយគ្មានការលើកលែង។ ដោយហេតុនោះ បញ្ញត្តិចាត់ទុកនេះត្រូវបានតាក់តែងឡើងដើម្បីរក្សានូវអានុភាពនៃការចុះបញ្ជីទាំងឡាយនោះ។ វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ គឺជាបញ្ញត្តិដែលមានគោលបំណងបញ្ជាក់បន្ថែមថា ម្ចាស់សិទ្ធិលើការដាក់ធានាអាចលុបចោលការចុះបញ្ជីអំពីការដាក់ធានា ហើយចុះបញ្ជីអំពីហ៊ីប៉ូតែកជំនួសវិញបាន ប្រសិនបើគេចង់ធ្វើដូច្នេះ។

ម្យ៉ាងទៀត ដោយសារមាត្រានេះគឺជាបញ្ញត្តិសម្រាប់ការដាក់ធានាដែលត្រូវបានបង្កើតឡើងដោយយោងតាមបញ្ញត្តិនៃច្បាប់ភូមិបាល មាត្រានេះមិនត្រូវយកមកអនុវត្តចំពោះការដាក់ធានាដាក់ស្តែងដែលមិនត្រូវបានចុះបញ្ជីឡើយ។ ហេតុដូច្នេះ ការដាក់ធានាដាក់ស្តែងដែលមិនត្រូវបានចុះបញ្ជីមិនអាចត្រូវបានសន្និដ្ឋានថាជាហ៊ីប៉ូតែកដែលមិនទាន់ត្រូវបានចុះបញ្ជីទេ។

កថាខណ្ឌទី ៣ នៃមាត្រានេះពាក់ព័ន្ធទៅនឹងការទាមទារឱ្យប្រគល់វិញនូវប័ណ្ណកម្មសិទ្ធិសម្រាប់ការដាក់ធានា។ ខណៈពេលដែលការដាក់ធានាតម្រូវឱ្យកូនបំណុលប្រគល់នូវប័ណ្ណកម្មសិទ្ធិ ម្ចាស់បំណុលហ៊ីប៉ូតែកមិនតម្រូវយ៉ាងដូច្នោះទេ។ ហេតុដូច្នេះ បញ្ញត្តិនេះជាបញ្ញត្តិដែលមានអានុភាពកំណត់ថា ប័ណ្ណកម្មសិទ្ធិដែលបញ្ជាក់ពីកម្មសិទ្ធិត្រូវប្រគល់ទៅអ្នកបង្កើតវិញភ្លាមនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត នៅពេលដែលការដាក់ធានាត្រូវបានប្តូរទៅជាហ៊ីប៉ូតែកដោយផ្អែកលើមាត្រានេះ។ វាប្រហែលជាអាចទៅរួចដែលចែងថា ប័ណ្ណកម្មសិទ្ធិនោះត្រូវតែប្រគល់ទៅវិញដើម្បីជាថ្នូរនឹងការចុះបញ្ជីហ៊ីប៉ូតែក ប៉ុន្តែ វិធីនេះមិនត្រូវបានប្រើប្រាស់ទេ ដោយហេតុថា ការដាក់ធានាខ្លះប្តូរទៅជាហ៊ីប៉ូតែកដោយមិនមានការចុះបញ្ជីហ៊ីប៉ូតែក ("ការចុះបញ្ជីដោយការចាត់ទុក")។

## មាត្រា ៥៦.-ការចាត់ចែងអំពីកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សដែលមិនទាន់ចុះបញ្ជី

១-ក្នុងករណីធ្វើកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ ដោយលិខិតយថាភូតដែលបានកំណត់នៅក្នុងមាត្រា ២០៧ នៃច្បាប់ភូមិបាលឆ្នាំ ២០០១ ហើយវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំនោះ ត្រូវបានប្រគល់រួច តែមិនទាន់ចុះបញ្ជីនៅមុនកាលបរិច្ឆេទនៃការអនុវត្តទេ អានុភាពនៃសិទ្ធិលើការបញ្ចាំនោះ ត្រូវកើតឡើងតាំងពីកាលបរិច្ឆេទនៃការអនុវត្ត។

២-ក្នុងករណីធ្វើកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ដោយលិខិតយថាភូតដែលបានកំណត់នៅក្នុងមាត្រា ២០១ នៃ ច្បាប់ភូមិបាលឆ្នាំ ២០០១ តែមិនទាន់ចុះបញ្ជីនៅមុនកាលបរិច្ឆេទនៃការអនុវត្តទេ អានុភាពនៃហ៊ីប៉ូតែកនោះ ត្រូវកើតឡើងតាំងពីកាល

បរិច្ឆេទនៃការអនុវត្ត។

៣-ក្នុងករណីធ្វើកិច្ចសន្យាបង្កើតសិទ្ធិលើការដាក់ធានា ដោយលិខិតយថាភូត ដែលកំណត់ក្នុងមាត្រា ២២០ នៃច្បាប់ភូមិបាលឆ្នាំ ២០០១ តែមិនទាន់ចុះបញ្ជី នៅមុនកាលបរិច្ឆេទនៃការអនុវត្តទេ ត្រូវចាត់ទុកថាធ្វើកិច្ចសន្យាបង្កើតហ៊ីប៉ូតែក នៅកាលបរិច្ឆេទនៃការអនុវត្ត។

៤-ប្រសិនបើហ៊ីប៉ូតែកដែលកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះត្រូវបានចុះបញ្ជី ម្ចាស់បំណុលហ៊ីប៉ូតែកត្រូវប្រគល់ប័ណ្ណកម្មសិទ្ធិទៅអ្នកបង្កើតវិញ។

(កំណត់)

មាត្រានេះកំណត់អំពីការចាត់ចែងកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សដែលមិនទាន់ចុះបញ្ជី។ តាមច្បាប់ភូមិបាល សិទ្ធិប្រាតិភោគប្រត្យក្សដែលមិនបានចុះបញ្ជីមិនមានអានុភាពឡើយ ក៏ប៉ុន្តែ តាមក្រមរដ្ឋប្បវេណីវិញ ការចុះបញ្ជីពុំមែនជាល័ក្ខខ័ណ្ឌដាច់ខាតដើម្បីបង្កើតអានុភាពនោះទេ វាជាល័ក្ខខ័ណ្ឌតតាំងចំពោះការបង្កើតសិទ្ធិប្រាតិភោគប្រត្យក្ស។ ដូច្នេះ មាត្រានេះចែងថា សិទ្ធិប្រាតិភោគប្រត្យក្សទាំងឡាយណាដែលត្រូវបានធ្វើកិច្ចសន្យាបង្កើតឡើងដោយយោងតាមច្បាប់ភូមិបាលនៅមុនកាលបរិច្ឆេទនៃការអនុវត្តត្រូវចាត់ចែងតាមវិធានដូចគ្នាដែលបានរៀបរាប់ខាងលើ ហើយប្តូរទៅជាសិទ្ធិប្រាតិភោគប្រត្យក្សដែលបានចែងនៅក្នុងក្រមរដ្ឋប្បវេណី។ តាមក្រមរដ្ឋប្បវេណី កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ ឬ ហ៊ីប៉ូតែក មិនទាមទារឱ្យធ្វើជាលាយលក្ខណ៍អក្សរទេ (មាត្រា ៨៤៣ និង មាត្រា ៨៣៩ ប៉ុន្តែ ចំពោះកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំគឺជាកិច្ចសន្យាដែលតម្រូវឱ្យមានការប្រគល់វត្ថុជាចាំបាច់ (មាត្រា ៨១៨) ផ្ទុយទៅវិញ ច្បាប់ភូមិបាលចែងថា កិច្ចសន្យាទាំងពីរប្រភេទត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ។ ចំពោះស្ថានភាពបែបនេះ ដើម្បីធ្វើការប្តូរឱ្យប្រកបដោយភាពរលូននូវសិទ្ធិលើការបញ្ចាំ និង ហ៊ីប៉ូតែកតាមច្បាប់ភូមិបាលទៅជាសិទ្ធិលើការបញ្ចាំ និង ហ៊ីប៉ូតែក តាមក្រមរដ្ឋប្បវេណីថ្មីនៅកាលបរិច្ឆេទនៃការអនុវត្ត ការសម្របសម្រួលដែលចាំបាច់ចំពោះល័ក្ខខ័ណ្ឌរវាងរបបច្បាប់ចាស់ និង ច្បាប់ថ្មី ត្រូវបានយកមកគិតគូរពិចារណានៅក្នុងមាត្រានេះ ។

កថាខណ្ឌទី ១ នៃមាត្រានេះទាក់ទងនឹងសិទ្ធិលើការបញ្ចាំ។ យោងតាមមាត្រា ២០៧ នៃច្បាប់ភូមិបាល សិទ្ធិលើការបញ្ចាំត្រូវបង្កើតឡើង នៅពេលដែលកិច្ចសន្យាបញ្ចាំអចលនវត្ថុត្រូវបានធ្វើជាលាយលក្ខណ៍អក្សរតាមរូបមន្តយថាភូត ដោយអាជ្ញាធរមានសមត្ថកិច្ច ហើយកិច្ចសន្យាបញ្ចាំនោះត្រូវបានចុះបញ្ជីនៅអង្គភាពសុរិយោដី។ ក៏ប៉ុន្តែ ទោះបីជាសិទ្ធិលើការបញ្ចាំមិនទាន់បានចុះបញ្ជីក៏ដោយ ប្រសិនបើកិច្ចសន្យាបញ្ចាំត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរតាមរូបមន្តយថាភូត ហើយវត្ថុដែលជាកម្មវត្ថុនៃការដាក់បញ្ចាំត្រូវបានប្រគល់ទៅឱ្យម្ចាស់

សិទ្ធិលើការបញ្ចាំដោយកូនបំណុល (មាត្រា ៨១៨ នៃក្រមរដ្ឋប្បវេណី) នោះកថាខណ្ឌទី ១ នេះទទួលស្គាល់អានុភាពនៃសិទ្ធិលើការបញ្ចាំចាប់តាំងពីកាលបរិច្ឆេទនៃការអនុវត្ត។

កថាខណ្ឌទី ២ នៃមាត្រានេះទាក់ទងនឹងហ៊ីប៉ូតែក។ មាត្រា ២០១ នៃច្បាប់ភូមិបាលចែងថា កិច្ចសន្យាហ៊ីប៉ូតែកត្រូវរៀបចំតាមរូបមន្តយថាភូត ហើយត្រូវតែចុះបញ្ជីនៅអង្គភាពសុរិយោដី។ ប៉ុន្តែ ចំពោះកិច្ចសន្យាហ៊ីប៉ូតែកដែលត្រូវបានធ្វើឡើងតាមរូបមន្តយថាភូត ទោះបីជាមិនទាន់បានចុះបញ្ជីក៏ដោយ ក៏កថាខណ្ឌទី ២ នេះទទួលស្គាល់អានុភាពនៃហ៊ីប៉ូតែកចាប់តាំងពីកាលបរិច្ឆេទនៃការអនុវត្តដែរ។

កថាខណ្ឌទី ៣ នៃមាត្រានេះពាក់ព័ន្ធនឹងការដាក់ធានា ហើយចែងពីល័ក្ខខ័ណ្ឌដូចគ្នានឹងល័ក្ខខ័ណ្ឌហ៊ីប៉ូតែក ពីព្រោះមាត្រា ២២០ នៃច្បាប់ភូមិបាលចែងពីល័ក្ខខ័ណ្ឌការដាក់ធានាដូចគ្នានឹងល័ក្ខខ័ណ្ឌ ហ៊ីប៉ូតែកដែលបានកំណត់ក្នុងមាត្រា ២០១ ដែរ។ ប៉ុន្តែ បញ្ញត្តិនេះត្រូវបានចែងឡើងដាច់ដោយឡែកពីកថាខណ្ឌទី ២ ទេ ពីព្រោះតែការដាក់ធានាត្រូវប្តូរទៅជាហ៊ីប៉ូតែកវិញ។

កថាខណ្ឌទី ៤ នៃមាត្រានេះពាក់ព័ន្ធទៅនឹងការទាមទារឱ្យប្រគល់មកវិញនូវប័ណ្ណកម្មសិទ្ធិ នៅពេលដែលការដាក់ធានាត្រូវបានចុះបញ្ជីជាហ៊ីប៉ូតែកនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។

ម្យ៉ាងទៀត ប្រសិនបើប្រើពាក្យ "លិខិតយថាភូត" តែប៉ុណ្ណោះ នោះអាចមានការភាន់ច្រឡំថា វាជាលិខិតយថាភូតដោយផ្អែកលើច្បាប់នេះ ហើយកថាខណ្ឌទី ១ មាត្រា ១១ នៃច្បាប់នេះអាចអនុវត្តបាន។ ដើម្បីជៀសវាងបញ្ហានេះ មាត្រានេះបញ្ជាក់ច្បាស់លាស់ថា "លិខិតយថាភូត" នៅក្នុងមាត្រានេះគឺជាលិខិតយថាភូតដោយផ្អែកលើច្បាប់ភូមិបាល។

## មាត្រា ៥៧.- អំឡុងពេលដែលសិទ្ធិលើការបញ្ចាំអចលនវត្ថុ មានអត្ថិភាព

ចំពោះការបញ្ចាំអចលនវត្ថុដែលត្រូវបានបង្កើតឡើង នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ហើយដែលអំឡុងពេលនៅសល់ ដែលសិទ្ធិលើការបញ្ចាំនោះមានអត្ថិភាព មានលើសពី ៥ (ប្រាំ) ឆ្នាំ នៅកាលបរិច្ឆេទនៃការអនុវត្ត នោះអំឡុងពេលដែលសិទ្ធិនោះមានអត្ថិភាព ត្រូវកំណត់ជា ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត។

(កំណត់)

មាត្រានេះមានគោលបំណងធានាការសម្របសម្រួលជាចាំបាច់រវាងច្បាប់ភូមិបាល និង ក្រមរដ្ឋប្បវេណី ចំពោះអំឡុងពេលដែលសិទ្ធិលើការបញ្ចាំអចលនវត្ថុមានអត្ថិភាព ដោយហេតុថា កថាខណ្ឌទី ២ មាត្រា ២០៩ នៃច្បាប់ភូមិបាលចែងថា អំឡុងពេលនៃការដាក់បញ្ចាំអចលនវត្ថុមិនអាចលើសពី ១០ ឆ្នាំបានឡើយ ចំណែក

កថាខណ្ឌទី ១ មាត្រា ៨៣៨ នៃក្រមរដ្ឋប្បវេណីចែងថា សិទ្ធិលើការបញ្ចាំអចលនវត្ថុមិនអាចលើសពី ៥ ឆ្នាំបានឡើយ ។

## មាត្រា ៥៨.-ការកំណត់ការធានាបំណុលអណ្តែតសាកល

ក្នុងករណីធ្វើកិច្ចសន្យាធានាបំណុលអណ្តែត ដោយមិនកំណត់ទំនាក់ទំនងគតិយុត្តជានិរន្តរ៍ ដែលជាមូលដ្ឋាននៃការកើតកាតព្វកិច្ចចម្បង នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ប្រាក់ដើមនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ដោយកិច្ចសន្យាធានាបំណុលអណ្តែតនោះ ត្រូវកំណត់ជាស្ថាពរនៅកាលបរិច្ឆេទនៃការអនុវត្ត។

(កំណត់)

ប្រសិនបើកិច្ចសន្យាធានាបំណុលអណ្តែតសាកលដោយមិនកំណត់ទំនាក់ទំនងគតិយុត្តជានិរន្តរ៍ដែលជាមូលដ្ឋាននៃការកើតកាតព្វកិច្ចចម្បងត្រូវបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត បើយោងតាមខ្លឹមសារនៃកថាខណ្ឌទី ១ មាត្រា ៥ នៃច្បាប់នេះ ក្រមរដ្ឋប្បវេណីនឹងត្រូវយកមកអនុវត្តចំពោះកិច្ចសន្យានេះ នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។ ប៉ុន្តែ កថាខណ្ឌទី ១ មាត្រា ៩០២ នៃក្រមរដ្ឋប្បវេណីមិនទទួលស្គាល់អានុភាពនៃការធានាបំណុលអណ្តែតសាកលបែបនេះទេ។ បញ្ហានោះគឺថាតើត្រូវដោះស្រាយយ៉ាងដូចម្តេចចំពោះសុពលភាពនៃកិច្ចសន្យាធានាបំណុលអណ្តែតសាកលដែលត្រូវបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តនោះ។ ដើម្បីដោះស្រាយស្ថានភាពបែបនេះ មាត្រានេះមានគោលបំណងតម្រូវឱ្យធានាតែចំពោះកាតព្វកិច្ចដែលត្រូវបានធានាដែលបានកើតឡើងរហូតដល់កាលបរិច្ឆេទនៃការអនុវត្តប៉ុណ្ណោះ ដោយកំណត់ថា ប្រាក់ដើមនៃសិទ្ធិលើបំណុលដែលត្រូវបានធានាត្រូវកំណត់ជាស្ថាពរនៅកាលបរិច្ឆេទនៃការអនុវត្ត។

## មាត្រា ៥៩.-ការបាត់ខ្លួនរបស់សហព័ន្ធ

ក្នុងករណីមានពាក្យសុំឱ្យប្រកាសអំពីការបាត់ខ្លួនរបស់សហព័ន្ធ ដែលបានធ្វើឡើងដោយផ្អែកលើបញ្ញត្តិនៃមាត្រា ១០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដែលត្រូវបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥៦ ក្រ. ចុះនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩ (តទៅហៅថា “ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ”) នៅមុនកាលបរិច្ឆេទនៃការអនុវត្តការប្រកាសអំពីការបាត់ខ្លួននោះ ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក។

(កំណត់)

មាត្រា ១០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារចែងអំពីការប្រកាសអំពីការបាត់ខ្លួនដើម្បីរៀបអាពាហ៍-ពិពាហ៍ថ្មី ដោយកំណត់ថា ក្នុងករណីដែលសហព័ទ្ធណាបាត់ខ្លួនកន្លងហួសពី ១ ឆ្នាំ ហើយគ្មាននរណាដឹងថា ជននោះស្លាប់ ឬ រស់ តុលាការអាចប្រកាសអំពីការបាត់ខ្លួនបាន។ ដោយឡែកក្រមរដ្ឋប្បវេណីវិញ បញ្ញត្តិចាប់ពីមាត្រា ៤១ នៃក្រមនេះបានកំណត់អំពីការប្រកាសអំពីការបាត់ខ្លួនធម្មតា (ការបាត់ខ្លួនដែលចាត់ទុកថាបានទទួលមរណភាព) ហើយជាគោលការណ៍ អំឡុងពេល ៥ ឆ្នាំ ចាំបាច់កន្លងហួសដើម្បីប្រកាសអំពីការបាត់ខ្លួន។ ហេតុដូច្នេះ ការសម្របសម្រួលគឺចាំបាច់ណាស់សម្រាប់បញ្ញត្តិទាំងពីរនេះ។ មាត្រានេះចែងថា ក្នុងករណីដែលពាក្យសុំឱ្យប្រកាសអំពីការបាត់ខ្លួនត្រូវបានដាក់ ដោយអនុលោមទៅតាមមាត្រា ១០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារនៅមុនកាលបរិច្ឆេទនៃការអនុវត្ត បញ្ញត្តិនៃមាត្រា ១០ នេះ ត្រូវយកមកអនុវត្តចំពោះការប្រកាសអំពីការបាត់ខ្លួននេះ។ ការអនុវត្តរបៀបនេះគឺដោយសារតែនីតិវិធីនៃការប្រកាសអំពីការបាត់ខ្លួនខុសគ្នារវាងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ និង ក្រមរដ្ឋប្បវេណី។ ការប្រកាសអំពីការបាត់ខ្លួនដោយយោងតាមមាត្រា ១០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ត្រូវធ្វើតាមនីតិវិធីនៃបណ្តឹង រីឯការប្រកាសតាមក្រមរដ្ឋប្បវេណី ត្រូវធ្វើដោយយោងតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។ ហេតុដូច្នេះ វាមិនសមរម្យទេ ប្រសិនបើច្បាប់ថ្មីត្រូវយកមកអនុវត្តចំពោះការប្រកាសអំពីការបាត់ខ្លួនដែលពាក្យសុំត្រូវបានដាក់នៅមុនកាលបរិច្ឆេទនៃការអនុវត្តនោះ។ ចំពោះករណីនេះ ដូចបានចែងក្នុងមាត្រានេះ "ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក" ហេតុដូច្នេះ ចំពោះនីតិវិធីនៃការប្រកាសអំពីការបាត់ខ្លួនដែលនឹងធ្វើក្រោយកាលបរិច្ឆេទនៃការអនុវត្តដោយផ្អែកលើពាក្យសុំនោះ និង អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន ក៏ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមកដែរ។

ទោះបីជាល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងមាត្រា ១០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ត្រូវបានបំពេញនៅកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ ប៉ុន្តែពាក្យសុំមិនត្រូវបានដាក់នៅមុនកាលបរិច្ឆេទនៃការអនុវត្តទេ បញ្ញត្តិចាប់ពីមាត្រា ៤១ នៃក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្ត។ វាមិនមានភាពចាំបាច់ក្នុងការចែងពីល័ក្ខខ័ណ្ឌពិសេសដើម្បីការពារសហព័ទ្ធទាំងឡាយណាដែលខកខានមិនបានដាក់ពាក្យសុំនោះទេ។ បើធ្វើការបកស្រាយយ៉ាងសាមញ្ញ ចំពោះបញ្ញត្តិនៃមាត្រា ១០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ អានុភាពនៃការប្រកាសអំពីការបាត់ខ្លួនដែលបានកំណត់នៅក្នុងមាត្រា ១០ នេះ ត្រូវបានកម្រិតត្រឹមតែឱ្យសហព័ទ្ធម្ខាងទៀតអាចរៀបអាពាហ៍ពិពាហ៍ថ្មីប៉ុណ្ណោះ ក៏ប៉ុន្តែបើតាមសភាពជាក់ស្តែង អានុភាពនោះជាញឹកញាប់ហាក់ដូចជាត្រូវបានពន្លាតទៅដល់បញ្ហាសន្តតិកម្មទៀតផង។ ទោះបីជាយ៉ាងណាក៏ដោយ វាមិនសមរម្យទេក្នុងការដែលបញ្ញត្តិនោះត្រូវគ្របដណ្តប់លើសន្តតិកម្មដែរ នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។ ក៏ប៉ុន្តែ ចំពោះករណីដែលសន្តតិកម្មត្រូវបានធ្វើរួចហើយដោយសារតែលទ្ធផលនៃការប្រកាសអំពីការបាត់ខ្លួននៅមុនកាលបរិច្ឆេទនៃការអនុវត្ត វាមានភាព

សមរម្យក្នុងការដោះស្រាយនូវស្ថានភាពនេះ ដោយផ្អែកលើការការពារសិទ្ធិដែលបានទទួលរួចហើយតាមមាត្រា ៥ នៃច្បាប់នេះ ដូច្នេះ មិនមានការរៀបចំនូវរបៀបដោះស្រាយពិសេសអ្វីចំពោះបញ្ហានេះទេ។ មានន័យថា គេអាចយល់បានថា នៅពេលដែលបុគ្គលដែលបាត់ខ្លួនត្រឡប់មកវិញ ទ្រព្យសម្បត្តិរបស់បុគ្គលនោះអាចត្រូវទាមទារឱ្យយកមកវិញបានដោយការអនុវត្តមាត្រា ៤៤ នៃក្រមរដ្ឋប្បវេណី ជាគោលការណ៍សមធម៌ (equity) ដោយផ្អែកលើកថាខណ្ឌទី ៣ មាត្រា ៥ នៃច្បាប់នេះ។ម្យ៉ាងទៀត អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យធ្វើបដិទានសន្តតិកម្មត្រូវយកមកអនុវត្តចំពោះការទាមទាររបស់សន្តតិជនពិតប្រាកដ ហេតុដូច្នេះ មិនត្រូវយកមកអនុវត្តចំពោះការទាមទាររបស់ជនដែលចាត់ទុកថាជាមតកជន ។

## មាត្រា ៦០.-អន្តរប្បញ្ញត្តិស្តីពីការប្រកាសផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍

ការប្រកាសផ្សាយជាសាធារណៈ ដែលបានធ្វើឡើងដោយផ្អែកលើបញ្ញត្តិចាប់ពីមាត្រា ១១ ដល់មាត្រា ១៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវចាត់ទុកថាជាការជូនដំណឹងជាសាធារណៈដែលកំណត់ក្នុងមាត្រា ៩៥៩ (ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍) នៃក្រមរដ្ឋប្បវេណី។

(កំណត់)

មាត្រានេះគឺជាអន្តរប្បញ្ញត្តិសម្រាប់ករណីដែលការប្រកាសផ្សាយជាសាធារណៈត្រូវបានធ្វើឡើងដោយផ្អែកលើច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ហើយកាលបរិច្ឆេទនៃការអនុវត្តបានមកដល់មុនការចុះបញ្ជីអាពាហ៍ពិពាហ៍។ ក្រោយកាលបរិច្ឆេទនៃការអនុវត្ត អាពាហ៍ពិពាហ៍អាចធ្វើបានដោយផ្អែកលើក្រមរដ្ឋប្បវេណីតែប៉ុណ្ណោះ ប៉ុន្តែក្នុងករណីដែលការប្រកាសផ្សាយជាសាធារណៈត្រូវបានធ្វើនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ការប្រកាសនេះត្រូវបានធ្វើឡើងដោយផ្អែកលើច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ហេតុដូច្នេះ វាជាការសមរម្យក្នុងការធ្វើឱ្យមានសុពលភាពនូវការប្រកាសផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍ ដោយផ្អែកលើច្បាប់ផ្សេងពីក្រមរដ្ឋប្បវេណី។ ដោយសារមូលហេតុនេះ មាត្រានេះត្រូវបានរៀបចំឡើង។

មាត្រា ៩៥៩ នៃក្រមរដ្ឋប្បវេណីប្រគល់សិទ្ធិទៅបទប្បញ្ញត្តិស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋានចំពោះនីតិវិធីលម្អិតនៃការប្រកាសផ្សាយជាសាធារណៈ ហើយអនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋានដែលត្រូវបានចេញនៅឆ្នាំ ២០០០ ចែងអំពីនីតិវិធីនោះដូចគ្នាទៅនឹងនីតិវិធីដែលបានកំណត់នៅក្នុងច្បាប់ស្តីពីអាពាហ៍-ពិពាហ៍ និង គ្រួសារដែរ។

## មាត្រា ៦១.-អន្តរប្បញ្ញត្តិស្តីពីការប្តឹងជំទាស់ និង ការប្តឹងទាស់មិនឱ្យរៀបអាពាហ៍-ពិពាហ៍

ការប្តឹងជំទាស់ និង ការប្តឹងទាស់មិនឱ្យរៀបអាពាហ៍ពិពាហ៍ ក្នុងករណីដែលកំណត់ក្នុងមាត្រា ៦០ (អន្តរប្បញ្ញត្តិ ស្តីពីការប្រកាសផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍) ខាងលើនេះ ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក។

(កំណត់)

មាត្រា ១៩ ដល់មាត្រា ២០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ គ្រប់គ្រងលើបញ្ហាដែលទាក់ទងទៅនឹងការដាក់បណ្តឹងជំទាស់ និង បណ្តឹងទាស់មិនឱ្យរៀបអាពាហ៍ពិពាហ៍ ក្រោយការប្រកាសផ្សាយជាសាធារណៈ (នៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ពាក្យ "បណ្តឹងជំទាស់" និង "បណ្តឹងទាស់" ត្រូវបានប្រើប្រាស់ក្នុងន័យដូចគ្នា)។ ក្រមរដ្ឋប្បវេណីមិនមានបញ្ញត្តិណាដែលទាក់ទងទៅនឹងការប្តឹងជំទាស់ និង ប្តឹងទាស់នេះទេ ដោយមាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណីទុកបញ្ហានេះឱ្យបទប្បញ្ញត្តិស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋានវិញ។ ទោះបីជាអន្តរប្បញ្ញត្តិស្តីពីការប្តឹងជំទាស់ និង ការប្តឹងទាស់ គួរតែត្រូវបានចែងជាអន្តរប្បញ្ញត្តិនៃបទប្បញ្ញត្តិស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋានក៏ដោយ ដោយសារមាត្រា ៦០ នៃច្បាប់នេះចែងអំពីអន្តរប្បញ្ញត្តិស្តីពីការប្រកាសផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍ អន្តរប្បញ្ញត្តិសម្រាប់ការប្តឹងជំទាស់ និង ការប្តឹងទាស់ក៏ត្រូវបានតាក់តែងក្នុងច្បាប់នេះដែរ។ ឃ្លា "ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក" នៅក្នុងមាត្រានេះត្រូវបានរៀបចំឡើងដើម្បីអនុវត្តបញ្ញត្តិស្តីពីបណ្តឹងជំទាស់ និង ប្តឹងទាស់នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ដែលត្រូវបានធ្វើឱ្យនិរាករណ៍ដោយយោងតាមមាត្រា ៧៨ នៃច្បាប់នេះ។ ដោយផ្អែកលើឃ្លា "ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក" នេះ បញ្ញត្តិស្តីពីបណ្តឹងជំទាស់ និង បណ្តឹងទាស់នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ព្រមទាំងអនុក្រឹត្យ ជាអាទិ៍ ដែលស្ថិតនៅក្រោមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ត្រូវយកមកអនុវត្ត។

មាត្រា ៦០ នៃច្បាប់នេះចាត់ទុកថា ការប្រកាសផ្សាយជាសាធារណៈតាមច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារជាការជូនដំណឹងជាសាធារណៈតាមក្រមរដ្ឋប្បវេណី ប៉ុន្តែនីតិវិធីដើម្បីប្តឹងជំទាស់ និង ប្តឹងទាស់នោះ នៅតែអនុលោមតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារដដែល។ ចំណុចនេះមិនសូវមានភាពសមរម្យប៉ុន្មានដែរទេ។ ប៉ុន្តែ ពីព្រោះតែក្រមរដ្ឋប្បវេណីប្រគល់ឱ្យបទប្បញ្ញត្តិស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋានក្នុងការចែងលម្អិតនូវនីតិវិធីសម្រាប់ការប្រកាសផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍ដែលបានកំណត់នៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ វាមានភាពសមរម្យហើយថា ចំពោះការប្រកាសផ្សាយជាសាធារណៈដែលត្រូវបានធ្វើឡើងដោយផ្អែកលើច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ នីតិវិធីប្តឹងជំទាស់ និង ប្តឹងទាស់ ក៏ត្រូវអនុលោមតាមច្បាប់នោះវិញដែរ។

## មាត្រា ៦២.-អន្តរប្បញ្ញត្តិស្តីពីការលុបចោលអាពាហ៍ពិពាហ៍ ជាអាទិ៍

១-ទោះបីអាពាហ៍ពិពាហ៍ដែលបានធ្វើឡើង នៅមុនកាលបរិច្ឆេទនៃការអនុវត្ត អាចត្រូវបានប្រកាសជាមោឃៈបាន ដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា ២១ ដល់មាត្រា ២៦ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារក៏ដោយ ប្រសិនបើអាពាហ៍-ពិពាហ៍នោះ មិនអាចលុបចោលបាន ដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា ៩៥៩ (ការលុបចោលអាពាហ៍ពិពាហ៍) ដល់មាត្រា ៩៦៣ (ការលុបចោលអាពាហ៍-ពិពាហ៍ដោយការឆបោក ឬ ការគំរាម) នៃក្រមរដ្ឋប្បវេណីទេ អាពាហ៍ពិពាហ៍នោះមិនអាចត្រូវបានប្រកាសជាមោឃៈបានឡើយ។

២-ទោះបីអាពាហ៍ពិពាហ៍ដែលបានធ្វើឡើង នៅមុនកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ ប្រសិនបើមានហេតុដែលកំណត់ចាប់ពីមាត្រា ៩៤៨ (អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) ដល់មាត្រា ៩៥៤ (ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ) នៃក្រមរដ្ឋប្បវេណី អាពាហ៍ពិពាហ៍នោះអាចលុបចោលបាន ដោយផ្អែកលើបញ្ញត្តិចាប់ពីមាត្រា ៩៥៩ (ការលុបចោលអាពាហ៍-ពិពាហ៍) ដល់មាត្រា ៩៦៣ (ការលុបចោលអាពាហ៍ពិពាហ៍ ដោយការឆបោក ឬ ការគំរាម) នៃក្រមរដ្ឋប្បវេណី។ ក្នុងករណីនេះ ចំពោះអាពាហ៍ពិពាហ៍ដែលភាគីរួចខ្លួនពីការគំរាម នៅមុនកាលបរិច្ឆេទនៃការអនុវត្ត តែមិនទាន់កន្លងផុតអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតពីពេលរួចខ្លួនពីការគំរាម នៅកាលបរិច្ឆេទនៃការអនុវត្ត ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៩៦៣ (ការលុបចោលអាពាហ៍ពិពាហ៍ ដោយការឆបោក ឬ ការគំរាម) នៃក្រមរដ្ឋប្បវេណី ក៏ដោយ ភាគីនោះអាចលុបចោលអាពាហ៍ពិពាហ៍បានដោយ យកការគំរាមមកជាមូលហេតុ រហូតដល់អំឡុងពេល ៦ (ប្រាំមួយ) ខែ កន្លងផុត គិតពីពេលដែលភាគីនោះបានរួចខ្លួនពីការគំរាម ។

៣-ក្នុងករណីដែលជនពាក់ព័ន្ធនឹងផលប្រយោជន៍ ក្រៅពីជនដែលកំណត់ក្នុងមាត្រា ៩៦០ (ការលុបចោល អាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់ជាអាទិ៍) នៃក្រមរដ្ឋប្បវេណី បានដាក់ពាក្យសុំប្រកាសមោឃភាពនៃអាពាហ៍ពិពាហ៍

នៅមុនកាលបរិច្ឆេទនៃការអនុវត្តដោយផ្អែកលើបញ្ញត្តិនៃមាត្រា ២៦ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ជនពាក់ព័ន្ធនឹងផលប្រយោជន៍នោះ ក៏មានលក្ខណសម្បត្តិជាដើមចោទនៃបណ្តឹងនោះ ក្រោយកាលបរិច្ឆេទនៃការអនុវត្តដែរ។

(កំណត់)

មាត្រានេះមានគោលបំណងធ្វើការសម្របសម្រួលដែលចាំបាច់ចំពោះល័ក្ខខ័ណ្ឌផ្សេងៗគ្នាដែលទាក់ទងទៅនឹងការលុបចោលអាពាហ៍ពិពាហ៍ ជាអាទិ៍ រវាងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ និង ក្រមរដ្ឋប្បវេណី។ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារចែងថា អាពាហ៍ពិពាហ៍របស់មនុស្សឆ្កួត ឬ របស់ជនដែលមិនដឹងខុសត្រូវ (មាត្រា ២១) ឬ អាពាហ៍ពិពាហ៍របស់ជនដែលមិនទាន់ដល់អាយុរៀបអាពាហ៍ពិពាហ៍ (មាត្រា ២២) ត្រូវទុកជាមោឃៈ ហើយចំពោះអាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំ (មាត្រា ២៣) អាពាហ៍ពិពាហ៍ដោយទ្វេពន្ធភាព (មាត្រា ២៤) និង អាពាហ៍ពិពាហ៍រវាងញាតិ (មាត្រា ២៥) ត្រូវទុកជាមោឃៈដែរ។ ហើយមានការបកស្រាយថា អាពាហ៍ពិពាហ៍ដែលបានកំណត់នៅក្នុងមាត្រា ២១ និង មាត្រា ២២ អាចត្រូវបានផ្តល់សច្ចានុមតិ រីឯក្នុងចំណោមអាពាហ៍ពិពាហ៍ដែលបានកំណត់នៅក្នុងមាត្រា ២៣ មាត្រា ២៤ និង មាត្រា ២៥ អាពាហ៍ពិពាហ៍ខ្លះជាអាពាហ៍ពិពាហ៍មោឃៈដាច់ខាត។ ប៉ុន្តែយោងទៅតាមមាត្រា ២៦ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ក្នុងករណីទាំងពីរនេះ ចាំបាច់ប្តឹងសុំមោឃភាព ហើយទទួលការប្រកាសមោឃភាពដោយតុលាការ។ មាត្រានេះប្រហែលជាមានគោលបំណងដូចគ្នាទៅនឹងចំណុច ក មាត្រា ៩៥៨ នៃក្រមរដ្ឋប្បវេណីក្នុងន័យថា បើទោះបីជាអាពាហ៍ពិពាហ៍នោះត្រូវបានចាត់ទុកជាមោឃៈក៏ដោយ ក៏ចាំបាច់ត្រូវដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍ ដើម្បីជាមូលដ្ឋានរៀបអាពាហ៍ពិពាហ៍ថ្មីទៀតដែរ។ លើសពីនេះទៅទៀត កថាខណ្ឌទី ២ មាត្រា ២៤ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ អាចត្រូវបកស្រាយបានយ៉ាងដូច្នេះថា អាពាហ៍ពិពាហ៍ក្រោយនោះនឹងត្រូវចាត់ទុកថាមានអត្ថិភាព រហូតទាល់តែការប្រកាសមោឃភាពត្រូវបានធ្វើឡើង។

ផ្ទុយទៅវិញ អាពាហ៍ពិពាហ៍របស់បុគ្គលដែលវិកលចរិត ឬ បុគ្គលដែលមិនដឹងខុសត្រូវ ដូចបានចែងនៅក្នុងមាត្រា ២១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ មិនត្រូវបានចាត់ទុកជាមោឃៈតាមក្រមរដ្ឋប្បវេណីទេ។ នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ការប្រកាសមោឃភាពនៃអាពាហ៍ពិពាហ៍មិនអាចធ្វើទៅបានដោយគ្រាន់តែផ្អែកទៅលើមូលហេតុបែបដូច្នេះទេ ពីព្រោះអាពាហ៍ពិពាហ៍គឺជាទំនាក់ទំនងដែលមានជាប់ជានិរន្តរ៍។ ដោយហេតុនេះ បានជានៅក្នុងស្ថានភាពបែបនេះ មធ្យោបាយតែមួយគត់ដើម្បីរំលាយអាពាហ៍ពិពាហ៍នេះ គឺការលែងលះ លើកលែងតែករណីដែលអាពាហ៍ពិពាហ៍ត្រូវបានចាត់ទុកជាមោឃៈដោយសារភាគីមិនមានឆន្ទៈដើម្បីរៀបអាពាហ៍-ពិពាហ៍ជាមួយគ្នា (ចំណុច ក មាត្រា ៩៥៨ នៃក្រមរដ្ឋប្បវេណី) ដោយសារតែវិបត្តិផ្នែកបញ្ញាស្មារតី។ ម្យ៉ាងទៀត

អាចមានការបកស្រាយច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារថា ចំពោះករណី "មោឃភាពដាច់ខាត" តាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ នៅតែបន្តមោឃភាពនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តដែរ។ ប៉ុន្តែដោយសារតែវាតម្រូវឱ្យមានពាក្យបណ្តឹងសុំមោឃភាព និង ការប្រកាសមោឃភាព គេអាចយល់បានថាអាពាហ៍ពិពាហ៍ត្រូវនៅតែបន្តនៅកាលបរិច្ឆេទនៃការអនុវត្ត។ ប្រសិនបើអាពាហ៍ពិពាហ៍មិនត្រូវបានចុះបញ្ជីទេ អាពាហ៍ពិពាហ៍នោះត្រូវទុកជាមោឃៈដោយសារអានុភាពនៃអាពាហ៍ពិពាហ៍មិនត្រូវបានបង្កើតតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ក៏ដូចជាតាមក្រមរដ្ឋប្បវេណីដែរ ហេតុដូច្នេះ មិនចាំបាច់ដាក់ពាក្យបណ្តឹងសុំមោឃភាពដើម្បីរៀបអាពាហ៍ពិពាហ៍ថ្មីទេ ។

កថាខណ្ឌទី ១ នៃមាត្រានេះចែងយ៉ាងទូលំទូលាយថា អាពាហ៍ពិពាហ៍ដែលអាចត្រូវបានប្រកាសជាមោឃៈបានតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ មិនអាចត្រូវបានប្រកាសជាមោឃៈបានទេ លើកលែងតែស្របតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។ ការកំណត់បែបនេះគឺវាមានភាពសមរម្យដោយសារតែរបបអាពាហ៍ពិពាហ៍ដែលទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងសណ្តាប់ធ្នាប់សាធារណៈត្រូវតែស្របគ្នាជាមួយនឹងច្បាប់ថ្មី ពោលគឺក្រមរដ្ឋប្បវេណី ទោះបីជាករណីដែលទំនាក់ទំនងអាពាហ៍ពិពាហ៍បានកើតមានស្រាប់ហើយក៏ដោយ។ បន្ថែមពីនេះ យោងតាមមាត្រានេះ បញ្ញត្តិនៃក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តចំពោះរឿងក្តីដែលកំពុងត្រូវបានចាត់ការនៅកាលបរិច្ឆេទនៃការអនុវត្ត។ ជាឧទាហរណ៍ ចំពោះករណីដែលភាគីមានវិបត្តិផ្នែកបញ្ញាស្មារតី អាពាហ៍ពិពាហ៍អាចនឹងត្រូវបានប្រកាសជាមោឃៈដោយសារតែមូលហេតុនោះ បើតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ក៏ប៉ុន្តែនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត តាមក្រមរដ្ឋប្បវេណីវិញ ការប្រកាសមោឃភាពនៃអាពាហ៍ពិពាហ៍នោះមិនអាចធ្វើទៅបានទេ លើកលែងតែករណីដែលតុលាការយល់ឃើញថា ភាគីមិនមានឆន្ទៈរៀបអាពាហ៍ពិពាហ៍ដោយសារវិបត្តិផ្នែកបញ្ញាស្មារតី។

កថាខណ្ឌទី ២ នៃមាត្រានេះចែងអំពីការអនុវត្តដោយប្រតិសកម្មនូវបញ្ញត្តិនៃក្រមរដ្ឋប្បវេណីចំពោះវិការៈនៃអាពាហ៍ពិពាហ៍ដោយសារបញ្ញត្តិអំពីវិការៈនេះជាបញ្ញត្តិដែលត្រូវអនុវត្តដាច់ខាត (សណ្តាប់ធ្នាប់សាធារណៈ)។ ទោះបីជាកថាខណ្ឌទី ១ មាត្រា ៥ នៃច្បាប់នេះចែងថា ក្រមរដ្ឋប្បវេណីមិនត្រូវយកមកអនុវត្តចំពោះវិការៈនៃកិច្ចសន្យាដែលមាននៅពេលដែលកិច្ចសន្យានោះត្រូវបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ ក៏មាត្រានេះជាករណីលើកលែងដែរ។ វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ គឺជាបញ្ញត្តិសង្គ្រោះដែលផ្តល់អំឡុងពេលវែងជាង ៣ ខែ ដែលមានចែងនៅក្នុងកថាខណ្ឌទី ២ មាត្រា ៩៦៣ នៃក្រមរដ្ឋប្បវេណី ដោយគិតពិចារណាដល់កថាខណ្ឌទី ២ មាត្រា ២៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារដែលកំណត់អំឡុងពេល ៦ ខែ គិតចាប់ពីថ្ងៃដែលគេលែងបង្ខំមកសម្រាប់ការលុបចោលអាពាហ៍ពិពាហ៍ដែលកើតឡើងដោយសារការចាប់បង្ខំ។ ម្យ៉ាងទៀត កថាខណ្ឌទី ២ នៃមាត្រានេះមិនមានផ្តល់ការសង្គ្រោះចំពោះអំឡុងពេលនៃការលុបចោល

អាពាហ៍ពិពាហ៍ក្នុងករណីមានការឆបោកទេ។ មូលហេតុគឺដោយសារតែបើពិចារណាពីទស្សនៈស្តីពីការធានានូវស្ថិរភាពគតិយុត្ត វាមិនសមរម្យទេដែលទៅជ្រៀតជ្រែកចូលដល់ជីវភាពឯកជនរបស់គេ ហើយសុខ១ផ្តល់ការសង្គ្រោះដល់បុគ្គលដែលកំពុងតែបន្តទំនាក់ទំនងអាពាហ៍ពិពាហ៍ទាំងខ្លួនគេផ្ទាល់បានដឹងអំពីការឆបោកដែរនោះ។

កថាខណ្ឌទី ៣ នៃមាត្រានេះគឺជាអន្តរប្បញ្ញត្តិដែលពាក់ព័ន្ធជាមួយនឹងលក្ខណសម្បត្តិជាដើមចោទនៃពាក្យសុំមោឃភាពនៃអាពាហ៍ពិពាហ៍។ មាត្រា ២៦ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ បើកទូលាយឱ្យបុគ្គលដែលមានប្រយោជន៍ក្នុងការប្តឹងសុំមោឃភាព អាចដាក់ពាក្យបណ្តឹងបាន ក៏ប៉ុន្តែមាត្រា ៩៦០ នៃក្រមរដ្ឋប្បវេណីដាក់កម្រិតចំពោះលក្ខណសម្បត្តិជាដើមចោទនៃបណ្តឹងទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍។ ដូច្នេះ អន្តរប្បញ្ញត្តិមានភាពចាំបាច់ចំពោះករណីដែលបុគ្គលក្រៅពីបុគ្គលដែលបានកំណត់នៅក្នុងមាត្រា ៩៦០ នៃក្រមរដ្ឋប្បវេណីបានដាក់ពាក្យបណ្តឹងសុំមោឃភាពនៅមុនកាលបរិច្ឆេទនៃការអនុវត្ត។

## មាត្រា ៦៣.-អន្តរប្បញ្ញត្តិស្តីពីមូលហេតុនៃការលែងលះគ្នា

១-ក្នុងករណីដែលហេតុដែលបានកើតឡើង នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវនឹងមូលហេតុនៃការលែងលះគ្នាដែលកំណត់ក្នុងមាត្រា ៩៧៨ (មូលហេតុនៃការលែងលះគ្នា) នៃក្រមរដ្ឋប្បវេណី ប្តី ឬ ប្រពន្ធ អាចដាក់ពាក្យបណ្តឹងសុំលែងលះគ្នាបាន។

២-ចំពោះបណ្តឹងសុំលែងលះគ្នាដែលបានដាក់មុនកាលបរិច្ឆេទនៃការអនុវត្ត ប្តីប្រពន្ធ ក៏អាចលែងលះគ្នាបានដែរ ប្រសិនបើមានមូលហេតុដែលកំណត់ក្នុងមាត្រា ៣៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ។ ក្នុងករណីនេះ បញ្ញត្តិនៃកថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ នៃមាត្រា ៩៧៨ (មូលហេតុនៃការលែងលះគ្នា) នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ។

(កំណត់)

មូលហេតុនៃការលែងលះខុសគ្នាបន្តិចរវាងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ និង ក្រមរដ្ឋប្បវេណី (ឧទាហរណ៍ ប្រមាថមើលងាយធ្ងន់ធ្ងរចំពោះសហព័ទ្ធ ឬ ចំពោះបុព្វញាតិរបស់សហព័ទ្ធ ឬ អពលានុភាពនៃលិង្គគឺស្ថិតនៅក្នុងចំណោមមូលហេតុនៃការលែងលះតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ក៏ប៉ុន្តែតាមក្រមរដ្ឋប្បវេណីវិញ វាអាស្រ័យទៅលើការយល់ឃើញថាតើវាត្រូវជាមួយនឹងករណីនៃចំណុច ង កថាខណ្ឌទី ១ នៃមាត្រា ៩៧៨ ដែលចែងថា ករណីដែល "ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថា

នឹងអាចបដិទានឡើងវិញបាន" ដែរឬទេ។ លើសពីនេះទៅទៀត ច្បាប់ទាំងពីរកម្រិតនូវមូលហេតុនៃការលែងលះ ប៉ុន្តែក្រមរដ្ឋប្បវេណីមានបញ្ញត្តិអរូបីដែលផ្តល់នូវមូលហេតុទូទៅដូចមានក្នុងចំណុច ង ដែលអាចត្រូវបានគេបកស្រាយបានច្រើនយ៉ាង) ។ ដោយហេតុនោះ បានជាមាត្រានេះមានគោលបំណងធ្វើការសម្របសម្រួលរវាងច្បាប់ទាំងពីរនេះ។

កថាខណ្ឌទី ១ នៃមាត្រានេះចែងអំពីការអនុវត្តដោយប្រតិសកម្មចំពោះមូលហេតុនៃការលែងលះ។ មាត្រា ៧០ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីប្រទេសជប៉ុនមានខ្លឹមសារដូចគ្នានឹងច្បាប់នេះដែរ។ មូលហេតុគឺដោយសារតែការលែងលះនឹងធ្វើនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ហើយវាជារឿងធម្មតាទេដែលយកមូលហេតុនៃការលែងលះគ្នាដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីមកអនុវត្ត។

កថាខណ្ឌទី ២ នៃមាត្រានេះចែងថា ចំពោះបណ្តឹងលែងលះត្រូវបានដាក់នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ការលែងលះអាចអនុញ្ញាតឱ្យធ្វើទៅបាន ប្រសិនបើមានមូលហេតុនៃការលែងលះតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឬ តាមក្រមរដ្ឋប្បវេណី។ គេអាចយល់បានថា សហព័ទ្ធដែលមានមូលហេតុដើម្បីលែងលះទទួលបាននូវឋានៈក្នុងការប្តឹងលែងលះ។ ប៉ុន្តែ សិទ្ធិដែលត្រូវបានទទួលហើយនោះត្រូវបានការពារ តែពេលដែលសហព័ទ្ធនោះបានដាក់ពាក្យបណ្តឹងដែលជាសកម្មភាពជាវិជ្ជមានរួចហើយនៅមុនកាលបរិច្ឆេទនៃការអនុវត្តតែប៉ុណ្ណោះ។ ប៉ុន្តែនៅក្នុងករណីនេះ ដោយសារតែបណ្តឹងលែងលះត្រូវបានជំនុំជម្រះ និង សម្រេចសេចក្តីនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត វាជាការសមរម្យហើយដែលប្រើប្រាស់របបច្រានចោលដោយឆន្ទានុសិទ្ធិរបស់តុលាការតាមកថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី។ ហេតុដូច្នេះ កថាខណ្ឌទី ២ នេះ បានចែងថា បញ្ញត្តិខាងលើនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណីនោះ។

## មាត្រា ៦៤.-អន្តរប្បញ្ញត្តិស្តីពីនីតិវិធីលែងលះគ្នា

១-ការដាក់ពាក្យសុំលែងលះគ្នាទៅក្រុមប្រឹក្សាឃុំ សង្កាត់ និងការបញ្ជូនសំណុំរឿងដែលបានធ្វើឡើងដោយ ក្រុមប្រឹក្សាឃុំ សង្កាត់ទៅតុលាការ ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៤២ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវចាត់ទុកថា បានធ្វើឡើងដោយផ្អែកលើបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៩៨២ (បណ្តឹងនៃការលែងលះគ្នា) នៃក្រមរដ្ឋប្បវេណី។

២-ការចាត់វិធានការបណ្តោះអាសន្នដែលបានធ្វើឡើង ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៤៤ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ដោយតុលាការដែលបានទទួលពាក្យបណ្តឹង នៅកាលបរិច្ឆេទនៃការអនុវត្ត ត្រូវចាត់ទុកជាការចាត់ចែងរក្សា

ការពារដែលបានធ្វើឡើង ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៩៨៣ (ការចាត់ចែងរក្សាការពារ) នៃក្រមរដ្ឋប្បវេណី។

៣-ក្នុងករណីដែលប្រពន្ធសម្រាលកូន នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ឬ មានផ្ទៃពោះ នៅកាលបរិច្ឆេទនៃការអនុវត្ត ប្តីមិនអាចសុំលែងលះគ្នា ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក្រោយកំណើតកូននោះបានឡើយ។ ប្រសិនបើ ប្រពន្ធសម្រាលកូនក្នុងអំឡុងពេល ៣០០ (បីរយ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការអនុវត្តនោះ ត្រូវសន្មតថាប្រពន្ធនោះមានផ្ទៃពោះ នៅកាលបរិច្ឆេទនៃការអនុវត្ត។

(កំណត់)

មាត្រា ៤១ ដល់មាត្រា ៦៨ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ចែងអំពីបញ្ហាដែលទាក់ទងនឹងបណ្តឹងទាក់ទងទៅនឹងឋានៈបុគ្គល។ ពីក្នុងចំណោមបញ្ហាដែលទាក់ទងទៅនឹងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មាត្រានេះចែងអំពីអន្តរប្បញ្ញត្តិសម្រាប់ចំណុចដែលបានចែងនៅក្នុងក្រមរដ្ឋប្បវេណី។

ទាំងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ និង ក្រមរដ្ឋប្បវេណី ចែងជាគោលការណ៍ថា សហព័ទ្ធម្ខាងអាចដាក់ពាក្យបណ្តឹងសុំលែងលះទៅតុលាការ ឬ ដាក់ទៅក្រុមប្រឹក្សាឃុំ សង្កាត់បាន។ មាត្រានេះមានគោលបំណងធានាការសម្របសម្រួលដែលពាក់ព័ន្ធនឹងការដាក់ពាក្យបណ្តឹង និង ពាក្យសុំលែងលះ ។

កថាខណ្ឌទី ១ គឺជា "បញ្ញត្តិចាត់ទុក" ។ ចំពោះពាក្យសុំលែងលះដែលត្រូវបានដាក់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ និង ការបញ្ជូនសំណុំរឿងដោយក្រុមប្រឹក្សាឃុំ សង្កាត់ទៅតុលាការ ដែលបានធ្វើឡើងមុនកាលបរិច្ឆេទនៃការអនុវត្ត មូលដ្ឋានគតិយុត្តនឹងត្រូវផ្លាស់ប្តូរក្រោយកាលបរិច្ឆេទនៃការអនុវត្ត ហេតុដូច្នេះ ដើម្បីឱ្យមានភាពបន្ត "បញ្ញត្តិចាត់ទុក" នេះត្រូវបានរៀបចំឡើង។

កថាខណ្ឌទី ២ នៃមាត្រានេះក៏ជា "បញ្ញត្តិចាត់ទុក" ផងដែរ ដែលពាក់ព័ន្ធជាមួយការចាត់ចែងជាបណ្តោះអាសន្ន។ នៅក្នុងភាសាខ្មែរ "វិធានការបណ្តោះអាសន្ន" ដែលបានកំណត់នៅក្នុងមាត្រា ៤៤ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ និង "ការចាត់ចែងជាបណ្តោះអាសន្ន" តាមមាត្រា ៩៨៣ នៃក្រមរដ្ឋប្បវេណីខុសគ្នាចំពោះមាត្រាមូលដ្ឋាន ហើយខ្លឹមសារ ក៏អាចខុសគ្នាដែរ ហេតុដូច្នេះ មាត្រានេះចែងពី "បញ្ញត្តិចាត់ទុក" ដើម្បីធានាជាសារវន្តនូវអានុភាពនៃ "វិធានការបណ្តោះអាសន្ន" ដែលធ្វើឡើងតាមមាត្រា ៤៤ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។

កថាខណ្ឌទី ៣ នៃមាត្រានេះធានាការសម្របសម្រួលចាំបាច់ដែលពាក់ព័ន្ធទៅនឹងការកម្រិតចំពោះការទាមទារលែងលះ។ មាត្រា ៦៨ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារចែងថា ប្តីមិនអាចសុំលែងលះប្រពន្ធ

របស់ខ្លួនបានទេ ក្នុងអំឡុងពេលដែលប្រពន្ធមានផ្ទៃពោះ រហូតដល់រយៈពេលមួយឆ្នាំក្រោយដែលប្រពន្ធបានសម្រាលកូន។ បញ្ញត្តិនេះអាចយល់បានថាជាបញ្ញត្តិសារធាតុអំពីល័ក្ខខ័ណ្ឌដើម្បីលែងលះ។ ប៉ុន្តែ ក្រមរដ្ឋប្បវេណី គ្មានបញ្ញត្តិបែបនោះទេ ហើយត្រូវបានបកស្រាយថា កថាខណ្ឌទី ២ នៃមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តទៅតាមករណីនីមួយៗ អាស្រ័យទៅតាមស្ថានភាព។ ប៉ុន្តែ កថាខណ្ឌទី ៣ នេះ ត្រូវបានតាក់តែងឡើងដោយសារវាសមហេតុផលដែរដែលថា បញ្ញត្តិដែលមានគោលបំណងដូចគ្នាជាមួយនឹងមាត្រា ៦៨ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ត្រូវយកទៅអនុវត្តចំពោះករណីដែលប្រពន្ធមានផ្ទៃពោះនៅកាលបរិច្ឆេទនៃការអនុវត្ត។ លើសពីនេះទៅទៀត "បញ្ញត្តិសន្មត" ក៏ត្រូវបានដាក់បញ្ចូលនៅក្នុងនេះដែរ ពីព្រោះវាមានការលំបាកណាស់ដើម្បីធ្វើការវិនិច្ឆ័យថាប្រពន្ធមានផ្ទៃពោះពីពេលណា ដោយគ្រាន់តែមើលពីខាងក្រៅតែប៉ុណ្ណោះនោះ។

## មាត្រា ៦៥.-ការសន្មតបិតុភាព ជាអាទិ៍

១-ការសន្មតបិតុភាព និងការបដិសេធនូវបិតុភាពដែលបានកើតឡើងដោយជនដែលត្រូវបានសន្មតថាជាឪពុកជាអាទិ៍ ចំពោះកូនដែលបានកើតនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ កូនដែលបានកើតមុនកាលបរិច្ឆេទនៃការអនុវត្ត អាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពបានដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៩៩១ (បណ្តឹងបដិសេធបិតុភាព ពីកូន) នៃក្រមរដ្ឋប្បវេណី ចំពោះជនដែលត្រូវបានសន្មតថាជាឪពុក។ ប៉ុន្តែការសន្មតបិតុភាពក្នុងករណីនេះ ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។

៣-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ចំពោះលក្ខណសម្បត្តិរបស់ជនដែលអាចដាក់ពាក្យប្តឹងបដិសេធបិតុភាពបាន នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ត្រូវអនុលោមតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី។ ប៉ុន្តែក្នុងករណីដែលទាយាទរបស់ជនដែលត្រូវបានសន្មតថាជាឪពុក បានដាក់ពាក្យប្តឹងបដិសេធបិតុភាពសម្រាប់ជននោះ នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៨៧ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ទាយាទនោះអាចរក្សាបន្តនូវបណ្តឹងនោះ សម្រាប់ជនដែលត្រូវបានសន្មតថាជាឪពុក ក្រោយកាល

បរិច្ឆេទនៃការអនុវត្តបានដែរ។

(កំណត់)

លក្ខខណ្ឌដែលពាក់ព័ន្ធទៅនឹងការសន្មតបិតុភាព និង បណ្តឹងដើម្បីប្រកែកមិនទទួលស្គាល់បិតុភាពដែលបានចែងក្នុងបញ្ញត្តិចាប់ពីមាត្រា ៨២ ដល់មាត្រា ៨៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ និង លក្ខខណ្ឌដែលពាក់ព័ន្ធទៅនឹងការសន្មតបិតុភាព និង បណ្តឹងបដិសេធបិតុភាពដែលបានចែងក្នុងបញ្ញត្តិចាប់ពីមាត្រា ៩៨៨ ដល់មាត្រា ៩៩២ នៃក្រមរដ្ឋប្បវេណី មានភាពខុសគ្នាបន្តិចបន្តួច។ ហេតុដូច្នេះ មាត្រានេះធ្វើការសម្របសម្រួលចាំបាច់ចំពោះលក្ខខណ្ឌនៃច្បាប់ទាំងពីរនោះ។

បើប្រៀបធៀបបញ្ញត្តិនៃច្បាប់ទាំងពីរនេះ មានភាពខុសគ្នាដូចខាងក្រោម :

១.ការសន្មតបិតុភាព : តាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ កូនដែលកើត ១៨០ ថ្ងៃ យ៉ាងតិច ក្រោយថ្ងៃរៀបអាពាហ៍ពិពាហ៍ ឬ ក្នុងរយៈពេល ៣០០ ថ្ងៃ គិតពីថ្ងៃដាច់ចំណងអាពាហ៍ពិពាហ៍ ជាគោលការណ៍ ត្រូវសន្មតថាជាកូនមានខាន់ស្លា។ បន្ថែមពីនេះទៀត ទោះបីជាកូនកើតមកក្នុងអំឡុងពេលតិចជាង ១៨០ ថ្ងៃ ក្រោយថ្ងៃរៀបអាពាហ៍ពិពាហ៍ក៏ដោយ ប្រសិនបើប្តីបានដឹងថា ប្រពន្ធរបស់ខ្លួនមានផ្ទៃពោះតាំងពីមុនពេលរៀបអាពាហ៍ពិពាហ៍ ឬទទួលស្គាល់កូននោះ កូននោះត្រូវសន្មតថាជាកូនរបស់ប្តី ហើយក្នុងករណីដែលអំឡុងពេលសម្រាប់ការសន្មតចំពោះអាពាហ៍ពិពាហ៍មុន និង អាពាហ៍ពិពាហ៍ក្រោយជាន់គ្នា ប្រសិនបើអតីតប្តីមិនតវ៉ាទេ កូនត្រូវបានសន្មតថាជាកូនរបស់ប្តីក្រោយ។ ផ្ទុយទៅវិញ តាមក្រមរដ្ឋប្បវេណី កូនដែលបានកើតនៅក្រោយអំឡុងពេល ១៨០ ថ្ងៃ គិតពីថ្ងៃរៀបអាពាហ៍ពិពាហ៍ ឬ កូនដែលកើតក្នុងអំឡុងពេលមិនលើសពី ៣០០ ថ្ងៃ គិតពីថ្ងៃរំលាយចំណងអាពាហ៍ពិពាហ៍ ត្រូវសន្មតថាមានគភ៌នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ហើយប្រសិនបើអំឡុងពេលសម្រាប់ការសន្មតចំពោះអាពាហ៍ពិពាហ៍មុនជាន់គ្នាជាមួយនឹងអាពាហ៍ពិពាហ៍ក្រោយ កូននោះត្រូវសន្មតថាជាកូននៃអាពាហ៍ពិពាហ៍ក្រោយ។

២. អំឡុងពេលដែលប្តីអាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាព : តាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ប្តីអាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពបានក្នុងអំឡុងពេលមិនលើសពី ២ ខែ គិតពីថ្ងៃដែលប្តីបានដឹងអំពីកំណើតរបស់ទារក រីឯតាមក្រមរដ្ឋប្បវេណីវិញ ប្តីអាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពក្នុងអំឡុងពេល ៦ ខែ គិតពីថ្ងៃដែលខ្លួនបានដឹងអំពីកំណើតរបស់កូន ហើយប្រសិនបើប្តីជាជននៅក្រោមអាណាព្យាបាលទូទៅវិញ ជននោះអាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពក្នុងអំឡុងពេលមិនលើសពី ៦ ខែ គិតពីថ្ងៃដែលលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ។

៣. វិធីបដិសេធបិតុភាពចំពោះកូនដែលកើតក្នុងអំឡុងពេលសន្មត : ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ទាមទារឱ្យមានការបញ្ជាក់ចំពោះអង្គហេតុស្តីពីអសមត្ថភាពរបស់ប្តីក្នុងការរួមដំណេក (ប្តីប្រពន្ធរស់នៅដាច់ឆ្ងាយ

ពីគ្នា ឬ អសមត្ថភាពខាងរាងកាយ ដូចជាអពលានុភាពនៃលិង្គ) ប៉ុន្តែ ក្រមរដ្ឋប្បវេណីមិនបានចែងចំណុចពិសេសណាមួយទេ។

៤. លក្ខណសម្បត្តិជាដើមចោទ : តាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ប្តីអាចដាក់ពាក្យបណ្តឹង ហើយនៅពេលដែលប្តីមិនអាចដាក់ពាក្យបណ្តឹងបានដោយសារប្តីនោះបាត់ខ្លួន ឬ វិកលចរិត ទាយាទរបស់ប្តីនោះអាចដាក់បណ្តឹងជំនួសបាន ក៏ប៉ុន្តែ បញ្ញត្តិបែបនេះមិនមានទេនៅក្នុងក្រមរដ្ឋប្បវេណី។

៥. បណ្តឹងបដិសេធបិតុភាពពីកូន : ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ មិនមានបញ្ញត្តិស្តីពីបញ្ហានេះទេ។ ប៉ុន្តែ តាមក្រមរដ្ឋប្បវេណី កូនអាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពរហូតដល់ ៦ ខែ ក្រោយពេលដែលកូននោះដល់នីតិភាព។

កថាខណ្ឌទី ១ នៃមាត្រានេះចែងថា ការសន្មតអំពីបិតុភាព ជាអាទិ៍ ចំពោះកូនដែលកើតនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ជាគោលការណ៍ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ត្រូវយកមកអនុវត្ត ពីព្រោះវាសមហេតុផលដែលថា ច្បាប់ដែលមានអានុភាពអនុវត្តនៅពេលកំណើតរបស់ទារកត្រូវយកមកអនុវត្តចំពោះការសន្មតបិតុភាព។ មានន័យថា ក្រមរដ្ឋប្បវេណីយកមកអនុវត្តចំពោះកូនកើតក្រោយកាលបរិច្ឆេទនៃការអនុវត្ត។ ចំណុចសំខាន់នៃមាត្រានេះគឺដើម្បីអនុវត្តដោយប្រតិសកម្មចំពោះផ្នែកខ្លះនៃក្រមរដ្ឋប្បវេណី ទោះបីជាការសន្មតបិតុភាពគួរតែចាប់ផ្តើមពីពេលដែលស្ត្រីជាម្តាយមានផ្ទៃពោះក៏ដោយ។ ករណីនេះគឺវាសមទំនងក្នុងការដែលប្រើប្រាស់ពេលនៃការចាប់កំណើតក្នុងផ្ទៃធ្វើជាមូលដ្ឋាន ដើម្បីបែងចែកការអនុវត្តច្បាប់ចាស់ ឬ ច្បាប់ថ្មី ក៏ប៉ុន្តែដោយសារតែពេលចាប់កំណើតក្នុងផ្ទៃមិនមានភាពច្បាស់លាស់ ទើបពេលវេលាកើតត្រូវបានប្រើប្រាស់ធ្វើជាមូលដ្ឋានវិញ។

ជាលទ្ធផលនៃកថាខណ្ឌទី ១ នៃមាត្រានេះ ចំពោះកូនដែលកើតនៅមុនកាលបរិច្ឆេទនៃការអនុវត្ត បញ្ញត្តិចាប់ពីមាត្រា ៨២ ដល់មាត្រា ៨៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ត្រូវយកមកអនុវត្តដើម្បីសម្រេចសេចក្តី មិនមែនតែចំពោះករណីដែលពាក្យបណ្តឹងត្រូវបានដាក់នៅមុនកាលបរិច្ឆេទនៃការអនុវត្ត និងត្រូវអនុវត្តដែលកំពុងចាត់ការនៅកាលបរិច្ឆេទនៃការអនុវត្តប៉ុណ្ណោះទេ គឺត្រូវអនុវត្តផងដែរចំពោះករណីដែលពាក្យបណ្តឹងត្រូវបានដាក់នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។ ដោយសារតែមាត្រា ៨៥ នៃច្បាប់ស្តីពីអាពាហ៍-ពិពាហ៍ និង គ្រួសារចែងថា ប្តីត្រូវដាក់ពាក្យបណ្តឹងប្រកែកមិនទទួលស្គាល់បិតុភាពក្នុងអំឡុងពេលមិនលើសពី ២ ខែគិតពីថ្ងៃដែលខ្លួនបានដឹងអំពីកំណើតនៃកូននោះ បើមិនដូច្នេះទេ បិតុភាពនឹងកើតមានអានុភាពស្ថាពរនៅពេលដែលអំឡុងពេលសម្រាប់បណ្តឹងបដិសេធនោះបានកន្លងហួសពីព្រោះថា ប្តីនោះមិនអាចធ្វើបណ្តឹងនៅក្រោយពេលដែលអំឡុងពេលនោះហួសបានឡើយ។

កថាខណ្ឌទី ២ នៃមាត្រានេះមានគោលបំណងអនុវត្តបញ្ញត្តិនៃក្រមរដ្ឋប្បវេណីដែលអនុញ្ញាតឱ្យកូនដាក់ពាក្យបណ្តឹងបដិសេធបិតុភាព ពីព្រោះច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ មិនមានបញ្ញត្តិពាក់ព័ន្ធជាមួយបញ្ហានេះទេ។

បណ្ដឹងបដិសេធបិតុភាពពីកូននោះ ចាំបាច់ដើម្បីឱ្យកូននោះអាចបង្កើតបុត្តភាពតាមផ្លូវច្បាប់ជាមួយឪពុកបង្កើតពិតប្រាកដរបស់ខ្លួនបាន។ ដូច្នេះ បញ្ញត្តិនេះត្រូវយកមកអនុវត្តចំពោះកូនដែលបានកើតនៅមុនកាលបរិច្ឆេទនៃការអនុវត្ត។

វាក្យខណ្ឌទី ២ កថាខណ្ឌទី ២ នៃមាត្រានេះ មានគោលបំណងបញ្ជាក់ឱ្យច្បាស់នូវខ្លឹមសារដូចតទៅនេះ។ ដូចបានរៀបរាប់ខាងលើ កថាខណ្ឌទី ២ មានគោលបំណងទទួលស្គាល់បណ្ដឹងបដិសេធបិតុភាពពីកូនដែលបានកើតនៅមុនកាលបរិច្ឆេទនៃការអនុវត្ត។ ក្នុងករណីនេះ ការសន្មតអំពីបិតុភាព ជាអាទិ៍ ត្រូវវិនិច្ឆ័យតាមច្បាប់ចាស់ដែលមានអានុភាពនៅពេលដែលកូននោះបានកើត ហេតុដូច្នេះ វាក្យខណ្ឌទី ២ នេះថែងច្បាស់អំពីគោលបំណងនេះ។ ប្រសិនបើមិនមានវាក្យខណ្ឌទី ២ នេះទេ ច្បាប់មូលដ្ឋានសម្រាប់ការសន្មតចំពោះករណីបណ្ដឹងបដិសេធបិតុភាពពីឪពុក និង បណ្ដឹងបដិសេធបិតុភាពពីកូននឹងខុសគ្នា ហើយគ្មានភាពសមហេតុសមផលទេ។

កថាខណ្ឌទី ៣ នៃមាត្រានេះគឺជាអន្តរប្បញ្ញត្តិដែលពាក់ព័ន្ធទៅនឹងអ្នកដែលអាចដាក់ពាក្យបណ្ដឹងបដិសេធបិតុភាពបាន។ ដូចបានរៀបរាប់ទាក់ទងជាមួយកថាខណ្ឌទី ១ នៃមាត្រានេះ ទោះបីជាវាមានភាពសមរម្យដែលថាការសន្មតបិតុភាពគួរធ្វើឡើងដោយផ្អែកលើច្បាប់ដែលមានអានុភាពនៅពេលដែលកូនកើតក៏ដោយ ក៏បញ្ហាថាតើអ្នកណាខ្លះអាចដាក់ពាក្យបណ្ដឹងបដិសេធបិតុភាពបាន គឺជាបញ្ហាផ្សេងពីបញ្ហាសន្មតបិតុភាពដែរ ហើយជាការសមរម្យដែលគោរពតាមស្មារតីនៃក្រមរដ្ឋប្បវេណី។ ដោយសារតែមាត្រា ៨៧ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ មានវិសាលភាពធំពេក បើប្រៀបធៀបជាមួយមាត្រា ៩៩០ និង ៩៩១ នៃក្រមរដ្ឋប្បវេណី កថាខណ្ឌទី ៣ នេះដាក់កម្រិតចំពោះវិសាលភាពនេះ។ ជនទាំងឡាយដែលបានបំពេញល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីត្រូវដាក់ពាក្យបណ្ដឹងបដិសេធបិតុភាពក្នុងអំឡុងពេលដែលបានកំណត់ក្នុងច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ។ ម្យ៉ាងទៀត តាមច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ប្រសិនបើប្ដីជាជនវិកលចរិត ជាអាទិ៍ ទាយាទរបស់ប្ដីអាចមានលក្ខណសម្បត្តិជាដើមចោទបាន។ វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ៣ នេះ គឺជាអន្តរប្បញ្ញត្តិដែលអនុញ្ញាតឱ្យទាយាទនោះអាចបន្តបណ្ដឹងនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី ប្រសិនបើទាយាទនោះបានដាក់ពាក្យបណ្ដឹងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត។ បើទោះជាមិនច្បាស់ថាតើពាក្យ "ជួស" នៅក្នុងមាត្រា ៨៧ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ចង្អុលបង្ហាញពីការទទួលបន្ទុកនីតិវិធីនៃបណ្ដឹង ឬការតំណាងដែលច្បាប់បានកំណត់ក៏ដោយ ក៏វាក្យខណ្ឌទី ២ នេះមានគោលបំណងគ្របដណ្ដប់លើលទ្ធភាពទាំងពីរនេះដែរ ។

## មាត្រា ៦៦.-ការទទួលស្គាល់ដោយបង្ខំ

១-ក្នុងករណីដែលជនដែលបានក្លាយទៅជានីតិជន លើសពីអំឡុងពេល ២

(ពីរ) ឆ្នាំ នៅកាលបរិច្ឆេទនៃការអនុវត្ត បានដឹងជាដំបូងថាជាឪពុកក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ មុនកាលបរិច្ឆេទនៃការអនុវត្ត ជននោះអាចប្តឹងទាមទារឱ្យទទួលស្គាល់ ដោយផ្អែកលើបញ្ញត្តិនៃក្រមរដ្ឋប្បវេណីបាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៩៧ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារក៏ដោយ។ ក្នុងករណីនេះ បញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ១០០១ (បណ្តឹងទាមទារឱ្យទទួលស្គាល់) នៃក្រមរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ។

២-ក្នុងករណីដែលជនដែលបានក្លាយទៅជានីតិជន ក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ មុនកាលបរិច្ឆេទនៃការអនុវត្ត ជននោះអាចប្តឹងទាមទារឱ្យទទួលស្គាល់ ដោយផ្អែកលើបញ្ញត្តិនៃក្រមរដ្ឋប្បវេណីបាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ៣ និង កថាខណ្ឌទី ៤ នៃមាត្រា ១០០១ (បណ្តឹងទាមទារឱ្យទទួលស្គាល់) នៃក្រមរដ្ឋប្បវេណីក៏ដោយ។

(កំណត់)

រាល់ការទទួលស្គាល់ដោយបង្ខំទាំងឡាយនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តត្រូវគ្រប់គ្រងដោយក្រមរដ្ឋប្បវេណី ពីព្រោះ "ការទទួលស្គាល់" គឺជា "បញ្ហា" ដែលមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់នេះ។ ប៉ុន្តែដោយសារតែបញ្ញត្តិចាប់ពីមាត្រា ៩៥ ដល់មាត្រា ១០២ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ និង មាត្រា ១០០១ នៃក្រមរដ្ឋប្បវេណីមានភាពខុសគ្នាខ្លះត្រង់ល័ក្ខខ័ណ្ឌ ជាអាទិ៍ មាត្រានេះចែងពីវិធានការសង្គ្រោះចំពោះករណីដែលអាចទាមទារការទទួលស្គាល់ដោយបង្ខំតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ប៉ុន្តែ ក្លាយទៅជាហួសអំឡុងពេលសម្រាប់បណ្តឹងទាមទារឱ្យទទួលស្គាល់ បើអនុវត្តក្រមរដ្ឋប្បវេណី។

បើប្រៀបធៀបចំណុចខុសគ្នាទាំងនោះ មានភាពខុសគ្នាដូចខាងក្រោម :

១. អំឡុងពេលធ្វើបណ្តឹង : តាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ កូនត្រូវដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់ក្នុងអំឡុងពេល ២ ឆ្នាំ គិតពីថ្ងៃដែលកូនមាននីតិភាព រីឯក្រមរដ្ឋប្បវេណីចែងថា ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់ត្រូវដាក់ក្នុងអំឡុង ១ ឆ្នាំ ដោយគិតចាប់ពីបានដឹងថាជាឪពុក (ករណីដែលកូនជាអនីតិជន ជាអាទិ៍ អំឡុងពេល ១ ឆ្នាំ គិតចាប់ពីពេលដែលកូនបានក្លាយជានីតិជន ឬ ដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) ហើយប្រសិនបើកូននោះទទួលមរណភាព បច្ឆាញាតិផ្ទាល់នៃមរណជនក៏អាចដាក់

ពាក្យបណ្ដឹងក្នុងអំឡុងពេលជាក់លាក់មួយបានដែរ។

២.ជនដែលអាចអនុវត្តសិទ្ធិទាមទារឱ្យទទួលស្គាល់ក្នុងករណីដែលកូនជាអនីតិជន : តាមច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ បណ្ដឹងទាមទារឱ្យទទួលស្គាល់ចំពោះម្ដាយត្រូវបានធ្វើដោយអ្នកអាណាព្យាបាល ហើយបណ្ដឹងទាមទារឱ្យទទួលស្គាល់ចំពោះឪពុកវិញ ត្រូវធ្វើដោយម្ដាយ ឬ ដោយអ្នកអាណាព្យាបាល រីឯតាមក្រមរដ្ឋប្បវេណីវិញ ជនដែលមានសិទ្ធិទាមទារគឺអ្នកតំណាងដែលច្បាប់បានកំណត់។ ចំពោះចំណុចនេះ មិនមានភាពខុសគ្នាខ្លាំងទេ។

៣. ការទទួលស្គាល់ក្រោយមរណភាពរបស់ឪពុក : ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ មិនមានបញ្ញត្តិដែលពាក់ព័ន្ធជាមួយបញ្ហានេះទេ ក៏ប៉ុន្តែ ក្រមរដ្ឋប្បវេណីចែងថា បណ្ដឹងទាមទារឱ្យទទួលស្គាល់អាចត្រូវបានដាក់ក្នុងអំឡុងពេលរហូតដល់ទៅ ១ ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់ឪពុក។

កថាខណ្ឌទី ១ នៃមាត្រានេះគឺជាអន្តរប្បញ្ញត្តិចំពោះបុគ្គលទាំងឡាយដែលបានក្លាយទៅជានីតិជនរួចហើយនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ហើយអំឡុងពេល ២ ឆ្នាំ គិតពីថ្ងៃមាននីតិភាពបានកន្លងផុតរួចហើយនៅកាលបរិច្ឆេទនៃការអនុវត្ត។ តាមច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ កូនមិនអាចដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់បានទេ បន្ទាប់ពីរយៈពេល ២ ឆ្នាំ បានកន្លងហួសក្រោយពេលដែលកូននោះមាននីតិភាព។ ប៉ុន្តែ ដូចដែលបានពន្យល់ខាងលើនេះ បញ្ញត្តិនៃក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តចំពោះករណីទាំងឡាយនៃការទាមទារឱ្យទទួលស្គាល់នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ហេតុដូច្នេះ ទោះបីជាកូនដែលដល់នីតិភាពលើសពីអំឡុងពេល ២ ឆ្នាំ នៅមុនកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ ក៏កូននោះអាចដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់បានដែរក្នុងអំឡុងពេល ១ ឆ្នាំ ក្រោយពីពេលដែលបានដឹងថាជាឪពុក។ ប៉ុន្តែ ប្រសិនបើកូនដែលដល់នីតិភាពលើសពីអំឡុងពេល ២ ឆ្នាំ នៅមុនកាលបរិច្ឆេទនៃការអនុវត្ត បានដឹងថាជាឪពុកក្នុងអំឡុងពេល ១ ឆ្នាំ នៅមុនកាលបរិច្ឆេទនៃការអនុវត្ត នោះអំឡុងពេល ១ ឆ្នាំ ដែលមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីនឹងកន្លងហួសក្នុងរយៈពេលខ្លី។ ដោយហេតុនោះ កថាខណ្ឌទី ១ នេះ មានគោលបំណងការពារករណីបែបនេះ ដោយការកំណត់ការចាប់ផ្ដើមនូវអំឡុងពេល ១ ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការអនុវត្តដើម្បីធានាថា បុគ្គលនោះអាចដាក់ពាក្យបណ្ដឹងដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីបាន។ កថាខណ្ឌទី ១ នេះមិនគ្របដណ្ដប់លើករណីដែលកូនដល់នីតិភាពលើសពីអំឡុងពេល ២ ឆ្នាំ នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ហើយដែលបានដឹងថាជាឪពុកក្នុងអំឡុងពេលមិនតិចជាង ១ ឆ្នាំ នៅមុនកាលបរិច្ឆេទនៃការអនុវត្តទេ ពីព្រោះកូននោះមិនអាចដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់ទាំងតាមច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ និង តាមក្រមរដ្ឋប្បវេណីបានឡើយ។

ប្រសិនបើគ្មានបញ្ញត្តិដូចកថាខណ្ឌទី ១ ដែលបានរៀបរាប់ខាងលើទេ ឪពុកមិនត្រូវបានប្ដឹងក្នុងករណីដែលកូនបានក្លាយជានីតិជនលើសពីអំឡុងពេល ២ ឆ្នាំ នៅមុនកាលបរិច្ឆេទនៃការអនុវត្តឡើយ។ ប៉ុន្តែ ក្នុងករណីនេះ

មិនចាំបាច់ត្រូវការពារសិទ្ធិដែលឪពុកបានទទួលរួចហើយ ដោយអានុភាពនៃ "មិនត្រូវបានទាមទារឱ្យទទួលស្គាល់" ទេ។ ម្យ៉ាងទៀត ឃ្លាដែលចែងថា "ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៩៧ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារក៏ដោយ" នៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ តាមទ្រឹស្តី មិនចាំបាច់មានទេ ដោយសារបញ្ញត្តិនៃក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តចំពោះករណីទាំងឡាយនៃការទាមទារឱ្យទទួលស្គាល់នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ក៏ប៉ុន្តែ បញ្ញត្តិនេះត្រូវបានដាក់បញ្ចូលដើម្បីឱ្យកាន់តែច្បាស់។ ដោយឡែកចំពោះឃ្លា "ក្នុងករណីនេះ បញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ១០០១ (បណ្តឹងទាមទារឱ្យទទួលស្គាល់) នៃក្រមរដ្ឋប្បវេណីមិនត្រូវយកមកអនុវត្តឡើយ" ក៏ត្រូវបានដាក់បញ្ចូលដោយមានគោលបំណងដូចគ្នាដែរ។

កថាខណ្ឌទី ២ នៃមាត្រានេះមានគោលបំណងការពារជនទាំងឡាយដែលបានក្លាយជានីតិជនក្នុងអំឡុងពេលតិចជាង ២ ឆ្នាំ មុនកាលបរិច្ឆេទនៃការអនុវត្ត។ ដោយសារតែជននោះអាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់ក្នុងអំឡុងពេល ២ ឆ្នាំ គិតពីថ្ងៃដែលជននោះមាននីតិភាពតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ទោះបីជាជននោះបានដឹងថាជាឪពុកក្តី មិនបានដឹងក្តី នោះមានភាពចាំបាច់ក្នុងការសម្រួលដល់ការដាក់កម្រិតចំពោះ "អំឡុងពេល ១ ឆ្នាំ ដោយគិតចាប់ពីពេលដែលបានដឹងថាជាឪពុក" នៅក្នុងក្រមរដ្ឋប្បវេណី ទោះបីជាជននោះបានដឹងថាជាឪពុកក៏ដោយ។ ដូច្នេះ កថាខណ្ឌទី ២ នេះ ចែងថា កូនអាចប្តឹងទាមទារឱ្យទទួលស្គាល់ក្នុងអំឡុងពេល ១ ឆ្នាំ ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីចាប់តាំងពីកាលបរិច្ឆេទនៃការអនុវត្ត។

ដោយសារតែមិនមានអន្តរប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតក្រៅពីបញ្ញត្តិដែលបានរៀបរាប់ខាងលើ ក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តចំពោះបណ្តឹងទាមទារឱ្យទទួលស្គាល់ដែលត្រូវបានដាក់នៅមុនកាលបរិច្ឆេទនៃការអនុវត្ត។ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ មានការកម្រិតចំពោះអង្គហេតុប្រយោល និង ភស្តុតាង ជាអាទិ៍ រីឯក្រមរដ្ឋប្បវេណីគ្មានការកម្រិតបែបនេះទេ ហេតុដូច្នេះ ក្រោយកាលបរិច្ឆេទនៃការអនុវត្ត លទ្ធភាពក្នុងការទទួលស្គាល់នឹងត្រូវបានពង្រីក។ ក្នុងករណីនេះ មិនចាំបាច់ការពារសិទ្ធិដែលឪពុកបានទទួលរួចហើយក្នុងការ "មិនត្រូវទទួលស្គាល់" ដោយគ្មានអង្គហេតុប្រយោល ឬ ភស្តុតាងឡើយ។ ចំណុចនេះគឺជា "ការគាំទ្រដល់ការបង្កើតបិតុភាព (favor paternitatis)"។

ដោយសារតែមិនមានអន្តរប្បញ្ញត្តិជាក់លាក់ណាមួយពាក់ព័ន្ធទៅនឹងការទទួលស្គាល់ដោយស្ម័គ្រចិត្ត វាក្យខណ្ឌទី ១ កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ មាត្រា ៥ នៃច្បាប់នេះត្រូវយកមកអនុវត្ត ហើយរាល់ការទទួលស្គាល់ទាំងឡាយណាដែលបានធ្វើឡើងដោយយោងតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ នៅតែមានអានុភាពនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។ តាមមាត្រា ៩៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារចែងថា ឪពុកអាចទទួលស្គាល់កូនរបស់ខ្លួនដោយគ្មានល័ក្ខខ័ណ្ឌ។ ចំពោះចំណុចនេះ អន្តរប្បញ្ញត្តិមិនត្រូវបានរៀបចំឡើងក្នុងច្បាប់នេះទេ។ ដោយហេតុនេះ នៅពេលដែលឪពុកធ្វើការទទួលស្គាល់កូនដែលជានីតិជននៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ឪពុកនោះ

ត្រូវតែទទួលការយល់ព្រមពីកូននោះចំពោះការទទួលស្គាល់នោះដែរ ។

ម្យ៉ាងទៀត មាត្រា ១០២ និង មាត្រា ១០៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ចែងអំពីត្រកូលរបស់កូននៅក្រោយការទទួលស្គាល់ រីឯក្រមរដ្ឋប្បវេណីមិនមានចែងអំពីបញ្ហានេះទេ។ ដូច្នេះ មិនមានអន្តរប្បញ្ញត្តិចំពោះករណីនេះទេ ។

លើសពីនេះទៅទៀត មាត្រា ១០៦ និង មាត្រា ១០៧ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ពាក់ព័ន្ធទៅនឹងបញ្ហាស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ហើយក្រមរដ្ឋប្បវេណីមិនមានអន្តរប្បញ្ញត្តិចំពោះបញ្ហានេះទេ។

## មាត្រា ៦៧.- សុំកូនដែលបានធ្វើមុនកាលបរិច្ឆេទនៃការអនុវត្ត

ចំពោះសុំកូនដែលត្រូវបានធ្វើនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ដោយកិច្ចសន្យាសុំកូនដែលបានទទួលការបញ្ជាក់ ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ១១៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារបញ្ញត្តិស្តីពីសុំកូនពេញលេញ នៅក្នុងក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្ត នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។ ប៉ុន្តែ បញ្ញត្តិនេះមិនប៉ះពាល់ដល់ហេតុការណ៍ដែលបានកើតឡើង មុនកាលបរិច្ឆេទនៃការអនុវត្តឡើយ។

(កំណត់)

នៅក្នុងក្រមរដ្ឋប្បវេណី សុំកូនមានពីរប្រភេទគឺសុំកូនពេញលេញ និង សុំកូនធម្មតា ប៉ុន្តែ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារចែងតែអំពីសុំកូនតែមួយប្រភេទប៉ុណ្ណោះ ហើយមិនមានបញ្ជាក់ច្បាស់ទេថាតើទំនាក់ទំនងញាតិភាពជាមួយឪពុកម្តាយបង្កើតត្រូវកាត់ផ្តាច់ឬយ៉ាងណានោះទេ។ ប៉ុន្តែ ដោយសារតែល័ក្ខខ័ណ្ឌសុំកូនតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ស្រដៀងគ្នាទៅនឹងល័ក្ខខ័ណ្ឌសុំកូនពេញលេញដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី សុំកូនដែលត្រូវបានបង្កើតតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ អាចបកស្រាយថាជាសុំកូនពេញលេញតាមក្រមរដ្ឋប្បវេណី។ ហេតុដូច្នេះ មាត្រានេះចែងថា បញ្ញត្តិដែលពាក់ព័ន្ធនឹងសុំកូនពេញលេញត្រូវយកមកអនុវត្តចំពោះសុំកូនដែលត្រូវបានបង្កើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត។ វាក្យខណ្ឌទី ២ នៃមាត្រានេះគឺជាវិធានការអន្តរកាលដើម្បីរក្សានូវអានុភាពក្នុងករណី ដូចជាករណីដែលកូនចិញ្ចឹមបានទទួលមតិកពីឪពុកម្តាយបង្កើត ដោយចាត់ទុកថា ទំនាក់ទំនងញាតិលោហិតមិនត្រូវបានកាត់ផ្តាច់តាមច្បាប់ចាស់ទេ។

## មាត្រា ៦៨.- អន្តរប្បញ្ញត្តិស្តីពីការដាក់ពាក្យសុំកូន

ក្នុងករណីដែលកាលបរិច្ឆេទនៃការអនុវត្ត បានចូលមកដល់នៅពេលកំពុងតែដាក់ពាក្យសុំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់បញ្ជាក់អំពីកិច្ចសន្យាសុំកូន ដោយផ្អែកលើ

បញ្ញត្តិនៃមាត្រា ១១៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ជូនសំណុំរឿងនោះទៅតុលាការ។ ក្នុងករណីនេះ ក្រុមប្រឹក្សាឃុំ សង្កាត់អាចភ្ជាប់មតិរបស់ខ្លួនបាន ហើយតុលាការគិតពិចារណាមតិនោះ។

(កំណត់)

តាមមាត្រា ១១៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ សុំកូននឹងត្រូវបានបង្កើតឡើងដោយការធ្វើកិច្ចសន្យាសុំកូនជាលាយលក្ខណ៍អក្សរ ហើយត្រូវបានបញ្ជាក់ដោយគណៈកម្មាធិការប្រជាជនឃុំ ឬ សង្កាត់ រីឯតាមមាត្រា ១០០៧ និង មាត្រា ១០២០ នៃក្រមរដ្ឋប្បវេណី សុំកូនតម្រូវឱ្យមានដីកាសម្រេចរបស់តុលាការ។ ហេតុដូច្នេះ ដោយសារតែនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ក្រុមប្រឹក្សាឃុំ សង្កាត់មិនមានអំណាចធ្វើការបញ្ជាក់លើកិច្ចសន្យាសុំកូនទៀតទេ មាត្រានេះផ្តល់នូវនីតិវិធីចាំបាច់ដើម្បីគ្រប់គ្រងបញ្ហានេះ។ ប៉ុន្តែ អាចមានករណីដែលក្រុមប្រឹក្សាឃុំ សង្កាត់បានធ្វើការស្រាវជ្រាវអំពីអង្គហេតុដើម្បីបញ្ជាក់លើកិច្ចសន្យាសុំកូន ដោយសារក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការបញ្ជាក់នេះជាមិនខាន ប្រសិនបើក្រមរដ្ឋប្បវេណីមិនបានយកមកអនុវត្តទេ ហេតុដូច្នេះ វាក្យខណ្ឌទី ២ នៃមាត្រានេះចែងថា ក្រុមប្រឹក្សាឃុំ សង្កាត់ អាចភ្ជាប់មតិយោបល់របស់ខ្លួនទៅតុលាការបាន ហើយតុលាការគិតពិចារណាមតិយោបល់នោះ។ ការចែងបែបនេះមានន័យថា លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានយកមកប្រើប្រាស់ដែរ។

## មាត្រា ៦៩.-អំណាចមេបាក្រោយការលែងលះគ្នា

ឪពុក ឬ ម្តាយ ដែលត្រូវបានសម្រេចឱ្យរក្សាកូន ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៧៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវចាត់ទុកថា ត្រូវបានកំណត់ជាអ្នកមានអំណាច មេបា ដោយយោងតាមបញ្ញត្តិនៃមាត្រា ១០៣៧ (ការសម្រេចអំពីអ្នកមានអំណាចមេបានៅពេលលែងលះគ្នា) នៃក្រមរដ្ឋប្បវេណី។

(កំណត់)

មាត្រានេះគឺជា "បញ្ញត្តិចាត់ទុក" ដែលត្រូវបានដាក់បញ្ចូលក្នុងគោលបំណងធ្វើការបញ្ជាក់ឱ្យច្បាស់ ដោយសារមាត្រា ៧២ និង មាត្រា ៧៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារធ្វើការបែងចែករវាងអំណាចមេបា និង ការរក្សា។

## មាត្រា ៧០.-អន្តរប្បញ្ញត្តិស្ដីពីការសុំដកហូតអំណាចមេបា ជាអាទិ៍

១-តុលាការអាចប្រកាសល្បួរ ឬ ដកហូតអំណាចមេបា ឬ សិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ ដោយអង្គហេតុដែលបានកើតឡើង មុនកាលបរិច្ឆេទនៃការអនុវត្តបាន។

២-ជនដែលបានដាក់ពាក្យសុំឱ្យដកហូតអំណាចមេបា ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ១២០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ មុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវមានលក្ខណសម្បត្តិជាអ្នកដាក់ពាក្យសុំ ទោះបីមានបញ្ញត្តិនៃមាត្រា ១០៤៨ (ការប្រកាសល្បួរ ឬ ការដកហូតអំណាចមេបា) នៃក្រមរដ្ឋប្បវេណីក៏ដោយ។

(កំណត់)

មាត្រានេះជាអន្តរប្បញ្ញត្តិដែលពាក់ព័ន្ធទៅនឹងពាក្យសុំដកហូតអំណាចមេបា ជាអាទិ៍។ ដោយសារតែវាមានភាពសមរម្យដែលបញ្ញត្តិនៃក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តចំពោះករណីទាំងឡាយនៃការដកហូតអំណាចមេបា ជាអាទិ៍ នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត មាត្រានេះត្រូវបានដាក់បញ្ចូលក្នុងច្បាប់នេះ។

កថាខណ្ឌទី ១ នៃមាត្រានេះមានខ្លឹមសារដូចគ្នាទៅនឹងមាត្រា ៧៣ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីប្រទេសជប៉ុនដែលចែងអំពីការអនុវត្តបញ្ញត្តិខ្លះនៃក្រមរដ្ឋប្បវេណីដោយមានអានុភាពប្រតិសកម្មចំពោះមូលហេតុនៃការដកហូតអំណាចមេបា ជាអាទិ៍។ មាត្រានេះមានគោលបំណងដូចគ្នានឹងមាត្រា ៦៣ នៃច្បាប់នេះ អំពីមូលហេតុនៃការលែងលះ។ម្យ៉ាងទៀត "ការដកហូតអំណាចមេបា" ដែលសម្រេចដោយតុលាការនៅមុនកាលបរិច្ឆេទនៃការអនុវត្តត្រូវបានយល់ឃើញថាត្រូវនឹង "ការដកហូតអំណាចមេបា" តាមមាត្រា ១០៤៨ នៃក្រមរដ្ឋប្បវេណី។

កថាខណ្ឌទី ២ នៃមាត្រានេះពាក់ព័ន្ធទៅនឹងអន្តរប្បញ្ញត្តិស្តីពីលក្ខណសម្បត្តិជាដើមចោទ ហើយមានគោលបំណងដូចគ្នានឹងកថាខណ្ឌទី ៣ មាត្រា ៦៥ នៃច្បាប់នេះដែរ។

## មាត្រា ៧១.-ការអនុវត្តបញ្ញត្តិស្តីពីសន្តតិកម្ម

បញ្ញត្តិស្តីពីសន្តតិកម្ម ត្រូវយកមកអនុវត្ត ចំពោះតែសន្តតិកម្មដែលបានចាប់ផ្តើមក្រោយកាលបរិច្ឆេទនៃការអនុវត្តប៉ុណ្ណោះ។ ក្នុងករណីនេះ បញ្ញត្តិស្តីពីសន្តតិកម្មត្រូវយកមកអនុវត្ត ចំពោះហេតុការណ៍ដែលបានកើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្តផងដែរ។

(កំណត់)

ចំពោះសន្តតិកម្ម ក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តតែចំពោះករណីដែលមតកជនបានទទួលមរណភាពនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តប៉ុណ្ណោះ។ ក្នុងករណីនេះ បញ្ញត្តិនៃក្រមរដ្ឋប្បវេណីយកមកអនុវត្តទាំងស្រុងចំពោះសន្តតិកម្មនោះ (បញ្ញត្តិខ្លះត្រូវអនុវត្តដោយមានអានុភាពប្រតិសកម្ម) ហេតុដូច្នេះ ដើម្បីអនុវត្តបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ចំពោះបញ្ហាជាក់លាក់មួយចំនួនដែលបានកើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត (ឧទាហរណ៍ មូលហេតុអភ័ព្វបុគ្គលនៃសន្តតិកម្ម ផលប្រយោជន៍ពិសេស ភាគនៃវិភាគទាន ជាដើម) វាក្យខណ្ឌទី ២ នៃមាត្រានេះត្រូវបានរៀបចំឡើង។ គោលបំណងដែលចែងអំពីករណីនេះ ខុសគ្នាបន្តិចពីគោលការណ៍នៃកថាខណ្ឌទី ១ មាត្រា ៥ នៃច្បាប់នេះ ។

ម្យ៉ាងទៀត ដោយសារតែក្រមរដ្ឋប្បវេណីចាស់លែងមានអានុភាពជាសារវន្តរួចហើយនោះ គ្មានអន្តរប្បញ្ញត្តិណាមួយដែលពាក់ព័ន្ធនឹងសន្តតិកម្មត្រូវបានតាក់តែងឡើងទេ ហើយក៏មិនមានបញ្ហាទំនាស់ជាមួយនឹងច្បាប់ភូមិបាលដែរ។

អ្វីដែលជាបញ្ហាសំខាន់នោះគឺការធ្វើមតកសាសន៍។ ច្បាប់នេះមិនមានវិធានពិសេសពាក់ព័ន្ធនឹងបែបបទនៃការធ្វើមតកសាសន៍ទេ។ ដោយហេតុនេះ មតកសាសន៍ទាំងឡាយណាដែលបានបង្កើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ហើយដែលត្រូវបានយល់ឃើញថាមានសុពលភាពចំពោះទម្រង់ ដោយយោងតាមវិធានដែលមាននៅពេលដែលមតកសាសន៍នោះត្រូវបានធ្វើឡើង ត្រូវអនុលោមតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ប្រសិនបើមតកជនទទួលមរណភាពនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។ ប៉ុន្តែ នៅពេលបច្ចុប្បន្ននេះ មតកសាសន៍ដែលបានធ្វើដោយដៃ និង ដែលបញ្ជាក់ច្បាស់លាស់អំពីឆន្ទៈរបស់មតកជន ហើយមតកជនមានសមត្ថភាពដើម្បីធ្វើមតកសាសន៍ នៅពេលដែលខ្លួនបានធ្វើមតកសាសន៍នោះ ត្រូវចាត់ទុកថាមានសុពលភាព។ វាដូចគ្នាទៅនឹងល័ក្ខខ័ណ្ឌធ្វើមតកសាសន៍ដោយលិខិតឯកជនដែលបានចែងនៅក្នុងក្រមរដ្ឋប្បវេណីដែរ។ ដោយហេតុនោះ មិនមានអន្តរប្បញ្ញត្តិណាមួយត្រូវបានតាក់តែងឡើងទេ។

## ជំពូកទី ៦
## ប្រតិបត្តិការដែលមានកិច្ចធានា

(កំណត់)

គោលការណ៍ចំពោះការសម្របសម្រួលរវាងក្រមរដ្ឋប្បវេណី និង ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

១) អានុភាពនៃប្រតិបត្តិការដែលត្រូវបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី ដោយយោងតាមបញ្ញត្តិនៃច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា ត្រូវបន្តអត្ថិភាពនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។

២) ទទួលស្គាល់ប្រតិបត្តិការដែលនឹងធ្វើឡើងដោយយោងតាមបញ្ញត្តិនៃច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានានៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត (មានន័យថា មិនត្រូវធ្វើវិសោធនកម្មច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានាទេ)។

៣) ក្នុងករណីដែលមានភាពផ្ទុយគ្នារវាងប្រតិបត្តិការដែលត្រូវបានធ្វើឡើងនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ដោយយោងតាមបញ្ញត្តិនៃច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា និង ប្រតិបត្តិការដែលត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ត្រូវសម្របសម្រួលដោយយោងតាមបញ្ញត្តិនៃជំពូកទី ៦ នេះ។

## មាត្រា ៧២.-គោលបំណងនៃជំពូកនេះ

១-ជំពូកនេះមានគោលបំណងសម្របសម្រួល រវាងប្រតិបត្តិការដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី ដូចជាប្រាតិភោគលើចលនវត្ថុ ជាអាទិ៍ និងប្រតិបត្តិការដែលកំណត់ក្នុងច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៧/០១២ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៧ (តទៅហៅថា "ច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា")។

២-បញ្ញត្តិនៃជំពូកនេះ ត្រូវបានបញ្ចូលនៅក្នុងចំណោមច្បាប់ផ្សេងដែលកំណត់ក្នុងកថាខណ្ឌទី ២ មាត្រា ១ នៃច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា។

(កំណត់)

កថាខណ្ឌទី ១ បញ្ជាក់ឱ្យបានច្បាស់លាស់ថា ជំពូកទី ៦ នេះមានគោលបំណងសម្របសម្រួលរវាងក្រមរដ្ឋប្បវេណី និង ច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា។ មានន័យថា ក្រមរដ្ឋប្បវេណីដែលមានលក្ខណៈជាច្បាប់ទូទៅនៃនីតិឯកជនគ្របដណ្ដប់សកម្មភាពតាមនីតិឯកជនទាំងអស់ ដូចជាការបង្កើតសិទ្ធិប្រាតិភោគ អនុប្បទានសិទ្ធិលើបំណុល ជាអាទិ៍ រីឯច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានាកំណត់វិសាលភាពនៃប្រតិបត្តិការដែលច្បាប់នោះត្រូវអនុវត្តនៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ២។ ហេតុដូច្នេះ ចំពោះប្រតិបត្តិការដែលបញ្ញត្តិនៃច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានាត្រូវយកមកអនុវត្តដោយកថាខណ្ឌទី ១ មាត្រា ២ នៃច្បាប់នោះ បញ្ញត្តិនៃក្រមរដ្ឋប្បវេណីក៏ត្រូវយកមកអនុវត្តដែរ។ ករណីនេះនាំឱ្យមានភាពចាំបាច់សម្របសម្រួលរវាងច្បាប់ទាំងពីរ។

ប៉ុន្តែ មានការលំបាកខ្លាំងក្នុងការបញ្ជាក់អំពីទំនាក់ទំនងរវាងបញ្ញត្តិនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ដែលត្រូវបានតាក់តែងឡើង ដោយយកទស្សនាទាននៃច្បាប់អង់គ្លោ អាមេរិកកាំង និង បញ្ញត្តិនៃក្រមរដ្ឋប្បវេណី ដែលត្រូវបានតាក់តែងដោយយកទស្សនាទាននៃច្បាប់ទ្វីប។ ប៉ុន្តែ កម្មវត្ថុចម្បងនៃការអនុវត្តបញ្ញត្តិនៃជំពូកនេះ គឺជាករណីដែលច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាមានបញ្ញត្តិផ្សេងពីបញ្ញត្តិនៃក្រមរដ្ឋប្បវេណីចំពោះ ប្រាតិភោគលើចលនវត្ថុ ហេតុដូច្នេះ កថាខណ្ឌទី ១ នេះ ប្រើឃ្លាថា "ប្រតិបត្តិការដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី ដូចជាប្រាតិភោគលើចលនវត្ថុ ជាអាទិ៍" ទោះបីជាឃ្លានេះមានភាពមិនច្បាស់លាស់បន្តិចក៏ដោយ។ សកម្មភាព ដែលច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាយកមកជាកម្មវត្ថុនៃការអនុវត្ត មិនមែនតែប្រាតិភោគលើ ចលនវត្ថុប៉ុណ្ណោះទេ ហេតុដូច្នេះ កថាខណ្ឌទី ១ ប្រើឃ្លាដូច្នេះ។ ក្នុងជំពូកនេះ ពាក្យ "ប្រតិបត្តិការ" ត្រូវបាន ប្រើប្រាស់ក្នុងន័យជាប្រតិបត្តិការដែលច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាត្រូវយកមកអនុវត្ត ដោយយោង តាមបញ្ញត្តិនៃមាត្រា ២ នៃច្បាប់នោះ។ ហេតុដូច្នេះ "ប្រតិបត្តិការដោយយោងតាមក្រមរដ្ឋប្បវេណី" មានន័យថា ជាប្រតិបត្តិការដែលបញ្ញត្តិនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាត្រូវយកមកអនុវត្ត ហើយដែលត្រូវបាន ធ្វើឡើងដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី។ មានឧទាហរណ៍ដូចជាករណីដែលសិទ្ធិលើការបញ្ចាំចលនវត្ថុ ត្រូវបានបង្កើតឡើងដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ឬ ករណីដែលសិទ្ធិលើបំណុលត្រូវបានធ្វើ អនុប្បទាន ក្នុងគោលបំណងដាក់ប្រាតិភោគ ជាអាទិ៍។

កថាខណ្ឌទី ២ ចែងថា បញ្ញត្តិនៃជំពូកនេះមិនត្រូវបានបដិសេធ ដោយកថាខណ្ឌទី ២ មាត្រា ១ នៃច្បាប់ស្តីពី ប្រតិបត្តិការដែលមានកិច្ចធានាទេ។ តាមគោលបំណងនៃជំពូកនេះ ចំណុចនេះមានភាពច្បាស់លាស់ ប៉ុន្តែ កថាខណ្ឌទី ២ នេះ ត្រូវបានរៀបចំឡើងដើម្បីបញ្ជាក់ចំណុចនេះកាន់តែច្បាស់លាស់។

## មាត្រា ៧៣.-អានុភាពនៃប្រតិបត្តិការដែលមានកិច្ចធានា ដែលត្រូវបានធ្វើឡើងនៅ មុនកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី

ប្រតិបត្តិការដែលត្រូវបានធ្វើឡើង នៅមុនកាលបរិច្ឆេទនៃការអនុវត្តក្រម រដ្ឋប្បវេណី ដោយយោងតាមបញ្ញត្តិនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ត្រូវ មានអានុភាពបន្ត នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។

(កំណត់)

មាត្រានេះកំណត់ថា ជាគោលការណ៍ ប្រតិបត្តិការដែលត្រូវបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ក្រមរដ្ឋប្បវេណី ដោយយោងតាមបញ្ញត្តិនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ត្រូវបន្តមានអានុភាព ដែល ត្រូវបានទទួលស្គាល់ដោយច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។

## មាត្រា ៧៤.-ការប្តូរទៅប្រតិបត្តិការដោយផ្អែកលើក្រមរដ្ឋប្បវេណី

១-ក្នុងករណីដែលប្រតិបត្តិការដែលកំណត់ក្នុងមាត្រា ៧៣ (អានុភាពនៃប្រតិបត្តិការដែលមានកិច្ចធានា ដែលត្រូវបានធ្វើឡើង នៅមុនកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី) ខាងលើនេះ បំពេញលក្ខខណ្ឌដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី ប្រសិនបើភាគីបង្ហាញឆន្ទៈថា ប្តូរទៅប្រតិបត្តិការដោយផ្អែកលើបញ្ញត្តិនៃក្រមរដ្ឋប្បវេណី នោះត្រូវចាត់ទុកថាភាគីបានធ្វើប្រតិបត្តិការនោះ នៅកាលបរិច្ឆេទនៃការអនុវត្ត ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី។ ប៉ុន្តែ ការប្តូរនេះមិនអាចធ្វើឱ្យខូចប្រយោជន៍ដល់សិទ្ធិរបស់តតិយជនឡើយ។

២-ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ភាគីនៃប្រតិបត្តិការដែលត្រូវបានប្តូរនោះ មិនអាចអះអាងអានុភាពនៃប្រតិបត្តិការដោយយោងតាមបញ្ញត្តិនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឡើយ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះមានគោលបំណងបង្កើតជម្រើសឱ្យភាគីអាចបន្តអានុភាពជាប្រតិបត្តិការ ដោយយោងតាមក្រមរដ្ឋប្បវេណីនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។ ក្នុងករណីនេះ ការបង្ហាញឆន្ទៈរបស់ភាគីគឺជាល័ក្ខខ័ណ្ឌ។ ដោយសារកម្មវត្ថុនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាមានប្រភេទច្រើន កថាខណ្ឌទី ១ នេះប្រើពាក្យ "ការបង្ហាញឆន្ទៈរបស់ភាគី" ប៉ុន្តែ ក្នុងករណីធម្មតា "ការបង្ហាញឆន្ទៈរបស់ភាគី" នេះ សំដៅទៅលើការព្រមព្រៀងរវាងភាគីនៃកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគ មានន័យថា រវាងម្ចាស់សិទ្ធិប្រាតិភោគ (ម្ចាស់បំណុល) និង អ្នកបង្កើតសិទ្ធិប្រាតិភោគ។ ម្យ៉ាងទៀត យើងអាចតម្រូវឱ្យមានការលុបចោលការតម្កល់លិខិតជូនដំណឹងជាល័ក្ខខ័ណ្ឌ។

ក្នុងករណីនេះ ពេលដែលប្រតិបត្តិការនេះត្រូវបានទទួលស្គាល់ថាជាប្រតិបត្តិការដែលត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីគឺជាកាលបរិច្ឆេទនៃការអនុវត្ត។ វាក្យខណ្ឌទី ២ មានគោលបំណងការពារសិទ្ធិរបស់តតិយជនដែលកើតឡើងក្នុងអំឡុងពេលចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត ដល់ពេលដែលមានការបង្ហាញឆន្ទៈ ដោយសារអានុភាពនៃប្រតិបត្តិការដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីកើតឡើងនៅកាលបរិច្ឆេទនៃការអនុវត្ត មិនមែននៅពេលដែលមានការបង្ហាញឆន្ទៈទេ (មានន័យថា មានអានុភាពប្រតិសកម្ម)។

ម្យ៉ាងទៀត ប្រសិនបើប្រតិបត្តិការនោះត្រូវបានប្តូរទៅប្រតិបត្តិការដោយយោងតាមក្រមរដ្ឋប្បវេណី មានតែ

អានុភាពនៃប្រតិបត្តិការដោយយោងតាមក្រមរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ប៉ុណ្ណោះ ហើយអានុភាពដោយយោងតាមច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានាមិនត្រូវបានទទួលស្គាល់ឡើយ ។

## មាត្រា ៧៥.-បញ្ញត្តិសន្មត

ចំពោះប្រតិបត្តិការដែលត្រូវបានធ្វើឡើង នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ប្រសិនបើមានភាពមិនច្បាស់លាស់រវាងភាគីនៃប្រតិបត្តិការនោះថា ប្រតិបត្តិការនោះ ត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ឬ បញ្ញត្តិនៃច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា ប្រតិបត្តិការនោះត្រូវសន្មតថា ត្រូវបានធ្វើឡើងដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី។

(កំណត់)

មាត្រានេះគឺជាបញ្ញត្តិសន្មត ក្នុងករណីដែលប្រតិបត្តិការដែលត្រូវបានធ្វើឡើងមានភាពមិនច្បាស់លាស់ថាតើប្រតិបត្តិការនោះត្រូវបានធ្វើឡើងដោយយោងតាមក្រមរដ្ឋប្បវេណី ឬ ច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា។ ក្នុងករណីដែលមានភាពមិនច្បាស់លាស់នេះ មាត្រានេះសន្មតថា ប្រតិបត្តិការនោះត្រូវបានធ្វើឡើងដោយយោងតាមក្រមរដ្ឋប្បវេណី ដោយសារប្រសិនបើប្រតិបត្តិការនោះត្រូវបានធ្វើឡើងដោយយោងតាមច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា នោះភាគីនឹងតម្កល់លិខិតជូនដំណឹងនៅការិយាល័យតម្កល់ ជាអាទិ៍ ហេតុដូច្នេះមានភាពច្បាស់លាស់ថា ប្រតិបត្តិការនោះត្រូវបានធ្វើឡើងដោយយោងតាមច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា (ហេតុដូច្នេះ មិនត្រូវបានគ្របដណ្ដប់ដោយការសន្មតដោយយោងតាមមាត្រានេះទេ) ។

## មាត្រា ៧៦.-អាទិភាពរវាងប្រតិបត្តិការដោយយោងតាមច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា និង ប្រតិបត្តិការដោយយោងតាមក្រមរដ្ឋប្បវេណី

ប្រសិនបើប្រតិបត្តិការដែលត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិនៃច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា ចំពោះកម្មវត្ថុណាមួយ និងប្រតិបត្តិការដែលត្រូវបានធ្វើឡើងដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ចំពោះកម្មវត្ថុដដែល មានវិសមិតភាពអាទិភាពរវាងប្រតិបត្តិការទាំងនេះ ត្រូវសម្រេចតាមពេលវេលាដែលអាចយកប្រតិបត្តិការនោះមកតតាំងចំពោះតតិយជន។

(កំណត់)

មាត្រានេះគឺជាបញ្ញត្តិដើម្បីសម្រេចអាទិភាពរវាងប្រតិបត្តិការដោយយោងតាមក្រមរដ្ឋប្បវេណី និង ប្រតិបត្តិការដោយយោងតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា (ដែលត្រូវបានធ្វើឡើងនៅមុន និង ក្រោយកាលបរិច្ឆេទនៃការអនុវត្ត)។ ប្រតិបត្តិការដែលទទួលល័ក្ខខ័ណ្ឌតតាំងមុន ដោយយោងតាមច្បាប់នីមួយៗដែលជាមូលដ្ឋាននៃការធ្វើប្រតិបត្តិការនោះ មានអាទិភាព។ ប៉ុន្តែ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាមានកម្មវត្ថុនៃការអនុវត្តជាច្រើនប្រភេទ ហើយហាក់ដូចជាមិនអាចដោះស្រាយដោយប្រើពាក្យ "ល័ក្ខខ័ណ្ឌតតាំង" តែមួយបានទេ ហេតុដូច្នេះ មាត្រានេះចែងពីពេលវេលាដែលអាចយកប្រតិបត្តិការនោះមកតតាំងចំពោះតតិយជន។ ឧទាហរណ៍ ក្នុងករណីដែលសិទ្ធិលើការបញ្ចាំ ដោយយោងតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និង សិទ្ធិលើការញ្ចាំដោយយោងតាមក្រមរដ្ឋប្បវេណី ត្រូវបានបង្កើតឡើងលើកម្មវត្ថុតែមួយ អាទិភាពរវាងសិទ្ធិលើការបញ្ចាំទាំងពីរនេះត្រូវសម្រេចដោយប្រៀបធៀបពេលដែលលិខិតជូនដំណឹងអំពីសិទ្ធិលើការបញ្ចាំដោយយោងតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ត្រូវបានតម្កល់នៅការិយាល័យតម្កល់ និង ពេលដែលការកាន់កាប់កម្មវត្ថុនៃសិទ្ធិលើការញ្ចាំដោយយោងតាមក្រមរដ្ឋប្បវេណី ត្រូវបានផ្ទេរទៅម្ចាស់សិទ្ធិលើការបញ្ចាំ។

ម្យ៉ាងទៀត បញ្ញត្តិនៃមាត្រានេះត្រូវយកមកអនុវត្តតែចំពោះករណីដែលប្រតិបត្តិការដែលត្រូវបានធ្វើឡើងដោយយោងតាមបញ្ញត្តិនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និង ប្រតិបត្តិការដែលត្រូវបានធ្វើឡើងដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី មានវិសមិតភាពប៉ុណ្ណោះ។ ហេតុដូច្នេះ ករណីដែលច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា មានបញ្ញត្តិសម្របសម្រួល ឧទាហរណ៍ដូចជាករណីដែលតតិយជនដែលធ្វើលទ្ធកម្មនូវវត្ថុដែលជាកម្មវត្ថុនៃប្រតិបត្តិការដោយយោងតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាត្រូវទទួលការការពារដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ មាត្រា ១៤ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាជាអាទិ៍ មិនមែនជាករណីដែលប្រតិបត្តិការពីរមានវិសមិតភាពទេ (ដូច្នេះ បញ្ញត្តិនៃមាត្រានេះមិនត្រូវយកមកអនុវត្តឡើយ)។

មាត្រានេះគឺជាមូលដ្ឋានក្នុងការសម្រេចអាទិភាពរវាងប្រតិបត្តិការពីរ។ មានន័យថា កិច្ចសន្យា (ប្រតិបត្តិការ) ដែលមិនមានអាទិភាពដោយយោងតាមមាត្រានេះមិនមែនជាកិច្ចសន្យាមោឃៈរវាងភាគីនៃកិច្ចសន្យានោះឡើយ។

"កម្មវត្ថុ" នៅក្នុងមាត្រានេះ ជាចម្បង សំដៅទៅលើចលនវត្ថុ និង សិទ្ធិលើបំណុល។

## មាត្រា ៧៧.-ការការពារបុគ្គលសុច្ចរិត

បញ្ញត្តិនៃមាត្រា ៧៦ (អាទិភាពរវាងប្រតិបត្តិការដោយយោងតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និង ប្រតិបត្តិការដោយយោងតាមក្រមរដ្ឋប្បវេណី) ខាងលើនេះ មិនរារាំងការអនុវត្តមាត្រា ១៩៣ (លទ្ធកម្មដោយ សុច្ចរិតនូវកម្មសិទ្ធិ

លើចលនវត្ថុ) និង មាត្រា ១៩៤ (អនុប្បទានទូវវត្ថុលួច ឬ វត្ថុបាត់) នៃក្រម រដ្ឋប្បវេណី។

(កំណត់)

មាត្រានេះបញ្ជាក់ច្បាស់លាស់ថា កម្មវត្ថុនៃប្រតិបត្តិការដោយយោងតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា អាចក្លាយទៅជាកម្មវត្ថុនៃលទ្ធកម្មដោយសុចរិតដែលបានកំណត់នៅក្នុងមាត្រា ១៩៣ នៃក្រមរដ្ឋប្បវេណី។ មាត្រា ៧៦ ខាងលើនេះគឺជាបញ្ញត្តិដើម្បីសម្រេចអាទិភាពតាមពេលវេលានៃការបំពេញល័ក្ខខ័ណ្ឌតតាំង ក្នុងករណីដែលធ្វើអនុប្បទានសិទ្ធិលើបំណុលទៅបុគ្គលពីរនាក់ផ្សេងគ្នា ឬ ករណីដែលដាក់ចលនវត្ថុជាប្រាតិភោគសម្រាប់សិទ្ធិលើបំណុលពីរផ្សេងគ្នា ជាអាទិ៍ ។ រីឯមាត្រានេះ មានគោលបំណងការពារអនុប្បទានិកដែលទទួលកម្មវត្ថុនៃប្រតិបត្តិការពីបុគ្គលដែលគ្មានសិទ្ធិ។

(កំណត់បន្ថែម)

១) ប្រសិនបើគិតពិចារណាថា ប្រព័ន្ធនៃការតម្កល់លិខិតជូនដំណឹងមិនអាចដើរតួនាទីជាការបង្ហាញជាសាធារណៈដោយពេញលេញទេ អាចមានករណីពិសេសដែលត្រូវការពារតតិយជនដែលធ្វើប្រតិបត្តិការដោយយោងតាមក្រមរដ្ឋប្បវេណី ដោយមិនដឹងថា មានប្រតិបត្តិការដោយយោងតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាចំពោះកម្មវត្ថុដដែលនោះ។ ឧទាហរណ៍ ក្នុងករណីដែលប្រតិបត្តិការដែលត្រូវបានធ្វើឡើងដោយយោងតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និង ប្រតិបត្តិការដែលត្រូវបានធ្វើឡើងដោយយោងតាមក្រមរដ្ឋប្បវេណី ត្រូវបានបង្កើតឡើងលើចលនវត្ថុតែមួយ ប្រសិនបើប្រតិបត្តិការមុនមិនមានល័ក្ខខ័ណ្ឌតតាំងនៅពេលប្រតិបត្តិការក្រោយត្រូវបានធ្វើឡើងទេ ប៉ុន្តែក្រោយមក ប្រតិបត្តិការមុននោះទទួលល័ក្ខខ័ណ្ឌតតាំងមុនប្រតិបត្តិការក្រោយនោះ ប្រតិបត្តិការក្រោយមិនមែនជាលទ្ធកម្មពីបុគ្គលដែលគ្មានសិទ្ធិទេ ហេតុដូច្នេះ ត្រូវបកស្រាយថា បញ្ញត្តិនៃមាត្រា ៧៧ មិនអាចយកមកអនុវត្តឡើយ។ ក្នុងករណីនេះ ការការពារតតិយជនសុចរិតដែលមកក្រោយ អាស្រ័យទៅតាមការបកស្រាយ។ មានន័យថា ត្រូវការពារតតិយជនសុចរិតនោះតាមល័ក្ខខ័ណ្ឌតតាំងដោយបកស្រាយមាត្រា ៧៦ ឬ តាមលទ្ធកម្មដោយសុចរិត ដោយបកស្រាយមាត្រា ៧៧។ លើសពីនេះ ការបកស្រាយថាមិនចាំបាច់ការពារតតិយជននោះ ក៏អាចមានដែរ។

២) ក្រៅពីចំណុចខាងលើនេះ មានបញ្ហាផ្សេងៗ ដូចជាឧបាទេសកម្មលើវត្ថុ ការយកសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកមកដាក់ជាប្រាតិភោគ ប្រាតិភោគជាប្រាក់ និង អនុប្បទានសិទ្ធិលើបំណុល ជាអាទិ៍ដែលមានភាពផ្ទុយគ្នារវាងក្រមរដ្ឋប្បវេណី និង ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។ បញ្ហាទាំងនេះក៏ត្រូវដោះស្រាយដោយបញ្ញត្តិនៃជំពូកនេះដែរ។

ឧទាហរណ៍ ចំពោះចំណុចដែលប្រាតិភោគត្រូវមានអានុភាពលើថ្លៃធានារ៉ាប់រងវត្ថុប្រាតិភោគដោយឧបាទេសកម្មលើវត្ថុ អានុភាពនៃឧបាទេសកម្មលើវត្ថុនោះអាចតតាំងចំពោះតតិយជនបាន នៅពេលដែលប្រាតិភោគដើមនោះទទួលល័ក្ខខ័ណ្ឌតតាំង។ តាមការពិត ដើម្បីឱ្យទទួលស្គាល់នូវឧបាទេសកម្មលើវត្ថុ ចាំបាច់ត្រូវរឹបអូសថ្លៃធានារ៉ាប់រង ជាអាទិ៍ ប៉ុន្តែ បញ្ហានេះត្រូវបែងចែកពីបញ្ហានៃល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិប្រាតិភោគ។ បញ្ហានេះអាចកើតឡើងចំពោះប្រតិបត្តិការដោយយោងតាមក្រមរដ្ឋប្បវេណីផងដែរ។ ឧទាហរណ៍ ចំពោះឧបាទេសកម្មលើវត្ថុនៃអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកដែលមានម្ចាស់បំណុលហ៊ីប៉ូតែកច្រើននាក់ ប្រសិនបើម្ចាស់បំណុលហ៊ីប៉ូតែកទាំងអស់អនុវត្តសិទ្ធិឧបាទេសកម្មលើវត្ថុចំពោះថ្លៃធានារ៉ាប់រង ត្រូវបកស្រាយថា រវាងម្ចាស់បំណុលហ៊ីប៉ូតែកអាទិភាពនៃឧបាទេសកម្មលើវត្ថុត្រូវសម្រេចតាមលំដាប់នៃហ៊ីប៉ូតែក ដោយមិនទាក់ទងនឹងពេលវេលានៃការរឹបអូសសិទ្ធិទាមទារថ្លៃធានារ៉ាប់រងនោះទេ។

## ជំពូកទី ៧
## វិសោធនកម្ម និង និរាករណ៍នូវបទបញ្ញត្តិមួយចំនួននៃច្បាប់ជាធរមាន

### មាត្រា ៧៨.-និរាករណ៍នូវបទបញ្ញត្តិមួយចំនួននៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ត្រូវបាត់បង់អានុភាពចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត លើកលែងតែបញ្ញត្តិនៃមាត្រា ៧៦ មាត្រា ៧៧ និង បញ្ញត្តិពីមាត្រា ៧៩ ដល់មាត្រា ៨១ នៃច្បាប់នោះនៅតែមានអានុភាពនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត រហូតដល់ពេលដែលកំណត់ផ្សេងដោយច្បាប់។

(កំណត់)

មាត្រានេះមានគោលបំណងធ្វើឱ្យនិរាករណ៍នូវច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ដែលនឹងលែងមានភាពចាំបាច់នៅក្រោយពេលដែលក្រមរដ្ឋប្បវេណីមានអានុភាពអនុវត្ត។ ប៉ុន្តែ បញ្ញត្តិនៃមាត្រា ៧៦ មាត្រា ៧៧ និងចាប់ពីមាត្រា ៧៩ ដល់មាត្រា ៨១ នៃច្បាប់នោះ គួរតែឱ្យមានអានុភាពក្នុងអំឡុងពេលសមរម្យមួយ។ ដូច្នេះ វាក្យខណ្ឌទី ២ នៃមាត្រានេះត្រូវបានដាក់បញ្ចូលក្នុងគោលបំណងនេះ។

មាត្រា ៧៦ និង មាត្រា ៧៧ គឺជាបញ្ញត្តិអំពីអាហារកិច្ចក្រោយការលែងលះ។ ចំពោះសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនក្រោយការលែងលះ ប្តីប្រពន្ធ ឬ តុលាការសម្រេចដោយយោងតាមកថាខណ្ឌទី ១

កថាខណ្ឌទី ២ និង កថាខណ្ឌទី ៤ មាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ប៉ុន្តែ ចំពោះអាហារកិច្ចសម្រាប់អតីតសហព័ទ្ធក្រោយការលែងលះវិញ ក្រមរដ្ឋប្បវេណីមិនមានបញ្ញត្តិឡើយ។ មូលហេតុដែលមិនបានរៀបចំបញ្ញត្តិនេះ គឺដោយសារប្តីប្រពន្ធនឹងគ្មានទំនាក់ទំនងគតិយុត្តក្រោយការលែងលះ លើកលែងតែទំនាក់ទំនងជាមួយកូន។ ហើយប្រសិនបើសហព័ទ្ធដែលនឹងត្រូវមានអាហារកិច្ចក្រោយការលែងលះ នឹងមានភាពក្រលំបាកយ៉ាងខ្លាំងក្នុងការទ្រទ្រង់ជីវភាពដោយការលែងលះ តុលាការអាចច្រានចោលការទាមទារលែងលះ (កថាខណ្ឌទី ២ មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងទៀត ក្នុងករណីដែលសហព័ទ្ធនេះទាមទារលែងលះ ជាធម្មតា សហព័ទ្ធម្ខាងទៀតបង្កើតមូលហេតុដែលបែកបាក់ទំនាក់ទំនងអាពាហ៍ពិពាហ៍ ដូចជាអំពើផិត ឬ អំពើហិង្សា ជាអាទិ៍ ហេតុដូច្នេះ ជាសារវន្តអាចដោះស្រាយអំពីអាហារកិច្ចនោះ តាមរយៈប្រាក់សំណងជំងឺចិត្ត (ការទាមទារសំណងការខូចខាតដោយអំពើអនីត្យានុកូល) បាន។ ប៉ុន្តែ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ មានបញ្ញត្តិអំពីអាហារកិច្ចក្រោយការលែងលះ ហើយប្រសិនបើធ្វើឱ្យនិរាករណ៍នូវប្រព័ន្ធនេះភ្លាមៗ អាចមានបញ្ហា ហេតុដូច្នេះ មាត្រានេះកំណត់ថា បញ្ញត្តិនៃមាត្រា ៧៦ និង មាត្រា ៧៧ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ នៅតែមានអានុភាពក្នុងអំឡុងពេលសមរម្យមួយក្រោយកាលបរិច្ឆេទនៃការអនុវត្ត។ ចំពោះមាត្រា ៧៨ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ មិនត្រូវបានបញ្ចូលនៅក្នុងចំណោមបញ្ញត្តិដែលបន្តមានអានុភាពទេ ដោយសារបញ្ញត្តិនៃមាត្រា ៧៨ នេះ មិនគួរឱ្យមានអានុភាពបន្តទៀត (ប្រាក់ពិន័យដែលត្រូវបង់ទៅរដ្ឋ គួរតែក្លាយទៅជាចំណែកនៃអាហារកិច្ចវិញ)។

បញ្ញត្តិចាប់ពីមាត្រា ៧៩ ដល់មាត្រា ៨១ គឺជាបញ្ញត្តិទាក់ទងនឹងនីតិអន្តរជាតិឯកជន ហើយដើម្បីឱ្យអាចអនុវត្តបញ្ញត្តិទាំងនេះបានរហូតដល់ប្រទេសកម្ពុជាមានច្បាប់ស្តីពីនីតិអន្តរជាតិឯកជន មាត្រានេះឱ្យបញ្ញត្តិទាំងនោះមានអានុភាពជាបន្តទៀត។

## មាត្រា ៧៩.-និរាករណ៍នូវបទបញ្ញត្តិមួយចំនួននៃក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា

ក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច ត្រូវបាត់បង់អានុភាពចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត លើកលែងតែមាត្រា ៨៣ ដល់មាត្រា ៨៨ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច នោះនៅតែមានអានុភាព នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត រហូតដល់ពេលដែលកំណត់ផ្សេងដោយច្បាប់។

(កំណត់)

ជាគោលការណ៍ វាជាការសមស្របហើយដែលក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច ត្រូវជំនួសដោយក្រមរដ្ឋប្បវេណី។ ចំពោះផ្នែកច្បាប់ពាណិជ្ជកម្មវិញ ក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្ត លើកលែងតែមានច្បាប់ជាក់លាក់ណាមួយដែលជា

បញ្ញត្តិពិសេសចំពោះក្រមរដ្ឋប្បវេណី (ឧទាហរណ៍ ក្រមពាណិជ្ជកម្ម ជាអាទិ៍) ត្រូវបានអនុម័ត។ ផ្ទុយទៅវិញ ដោយសារក្រមរដ្ឋប្បវេណីមិនមានបញ្ញត្តិស្តីពីកិច្ចសន្យាដឹកជញ្ជូនដែលស្ថិតក្រោមបញ្ញត្តិចាប់ពីមាត្រា ៨៣ ដល់មាត្រា ៨៨ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច ទេនោះ គឺវាមានភាពសមស្របដែលត្រូវរក្សាទុកនូវអានុភាពនៃបញ្ញត្តិទាំងអស់នោះ។ វាក្យខណ្ឌទី ២ នៃមាត្រានេះ ត្រូវបានបញ្ញត្តឡើងក្នុងគោលបំណងដូច្នេះ។

## មាត្រា ៨០.-វិសោធនកម្មនូវបទប្បញ្ញត្តិមួយចំនួននៃច្បាប់ភូមិបាល ឆ្នាំ២០០១

ច្បាប់ភូមិបាលឆ្នាំ ២០០១ ត្រូវធ្វើវិសោធនកម្មដូចខាងក្រោម :

ត្រូវលុបកថាខណ្ឌទី ៣ នៃមាត្រា ៦។

ត្រូវលុបកថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ នៃមាត្រា ១០។

ត្រូវកែចំណងជើងនៃជំពូកទី ៦ ទៅជា “អំពីលទ្ធកម្មនៃកម្មសិទ្ធិ”។

ត្រូវលុបមាត្រា ៦៣ដល់មាត្រា ៦៨។

ត្រូវលុបកថាខណ្ឌទី ១ នៃមាត្រា ៦៩។

ត្រូវកែផ្នែកទី ២ នៃជំពូកទី ៦ ដូចតទៅ :

“ផ្នែកទី ២ ត្រូវបានលុបមាត្រា ៧០ ដល់មាត្រា ៧១”។

ត្រូវលុបមាត្រា ៧៥ និង មាត្រា ៧៦។

ត្រូវកែមាត្រា ៧៨ ថា “ដីដែលធ្លាក់ទៅជាទ្រព្យរដ្ឋ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១៣០០ (មរតក ដែលធ្លាក់ទៅជាទ្រព្យរដ្ឋ) នៃក្រមរដ្ឋប្បវេណី ត្រូវបញ្ចូលក្នុងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

ត្រូវលុបចាប់ពីមាត្រា ៧៩ ដល់មាត្រា ៨២។

ត្រូវលុបមាត្រា ៨៤។

ត្រូវកែចំណងជើងនៃមាតិកាទី ៣ ទៅជា “អំពីវិធានដី និង សេវភាព”។

ត្រូវកែចំណងជើងនៃជំពូកទី ៧ ទៅជា “អំពីវិធានដី”។

ត្រូវកែផ្នែកទី ១ ដល់ផ្នែកទី ៤ នៃជំពូកទី ៧ ដូចតទៅ :

“ផ្នែកទី ១ ដល់ផ្នែកទី ៤ ត្រូវបានលុប

មាត្រា ៨៥ ដល់មាត្រា ១១៣ ត្រូវបានលុប”។

ត្រូវកែចំណងជើងនៃជំពូកទី ៨ ទៅជា "អំពីសេវភាព"។

ត្រូវលុបមាត្រា ១១៧ និង មាត្រា ១១៨។

ត្រូវកែផ្នែកទី ១ និង ផ្នែកទី ២ នៃជំពូកទី ៨ ដូចតទៅ :

"ផ្នែកទី ១ និង ផ្នែកទី ២ ត្រូវបានលុប

មាត្រា ១១៩ ដល់មាត្រា ១៤១ ត្រូវបានលុប"។

ត្រូវលុបចាប់ពីមាត្រា ១៤២ ដល់មាត្រា ១៤៧។

ត្រូវលុបចាប់ពីមាត្រា ១៤៩ ដល់មាត្រា ១៦៧។

ត្រូវកែចំណងជើងនៃមាតិកាទី ៤ ទៅជា "អំពីសហកម្មសិទ្ធិ"។

ត្រូវកែជំពូកទី ៩ ដូចតទៅ :

"ជំពូកទី ៩ ត្រូវបានលុប

មាត្រា ១៦៨ ដល់មាត្រា ១៧៤ ត្រូវបានលុប"។

ត្រូវកែជំពូកទី ១១ ដូចតទៅ :

"ជំពូកទី ១១ ត្រូវបានលុប

មាត្រា ១៨៦ ដល់មាត្រា ១៩៦ ត្រូវបានលុប"។

ត្រូវកែមាតិកាទី ៥ ដូចតទៅ :

"មាតិកាទី ៥ ត្រូវបានលុប

មាត្រា ១៩៧ ត្រូវបានលុប

ជំពូកទី ១២ ដល់ជំពូកទី ១៤ ត្រូវបានលុប

មាត្រា ១៩៨ ដល់មាត្រា ២២៥ ត្រូវបានលុប"។

ត្រូវកែពាក្យ "ការដាក់ធានា" ទៅជា "ផលុបភោគ" នៅក្នុងមាត្រា ២២៩ និង មាត្រា ២៣៨។

ត្រូវកែឃ្លា "ដោយលិខិតលក់ ឱ្យ ដូរ ឬ ជម្រះមរតក ដែលត្រូវបានធ្វើឡើង ដោយ បុគ្គលដែលមាននីតិសម្បទា ដូចមានចែងក្នុងមាត្រា ៦៥ នៃច្បាប់នេះ" ទៅជា "ដោយលិខិតជាលាយលក្ខណ៍អក្សរតាមទម្រង់លិខិតយថាភូតធ្វើ ដោយអាជ្ញាធរមាន

សមត្ថកិច្ច" នៅក្នុងកថាខណ្ឌទី ២ មាត្រា ២៤៤។

ត្រូវកែមាត្រា ២៤៥ ទៅជា "កិច្ចសន្យាដើម្បីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាមទម្រង់លិខិតយថាភូត ដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចុះបញ្ជីកិច្ចសន្យានោះនៅរដ្ឋបាលសុរិយោដី"។

ត្រូវលុបមាត្រា ២៤៦។

ត្រូវលុបឃ្លា "ហើយការខូចខាតទាំងឡាយដែលបណ្ដាលមកពីអំពើនេះ ត្រូវដោះស្រាយដោយសំណងរដ្ឋប្បវេណី" នៅក្នុងមាត្រា ២៤៧។

ត្រូវលុបកថាខណ្ឌទី ២ នៃមាត្រា ២៥៣។

(កំណត់)

បញ្ញត្តិនៃច្បាប់ភូមិបាលដែលពាក់ព័ន្ធជាមួយនីតិឯកជនត្រូវលុបចោល។ ប៉ុន្តែ ច្បាប់ភូមិបាលក៏មានបញ្ញត្តិអំពីការកម្រិតជានីតិសាធារណៈ ភោគៈដើម្បីទទួលស្គាល់កម្មសិទ្ធិ និង សន្តតិកម្មលើសម្បទាន ជាអាទិ៍ ដែរ ហើយបញ្ញត្តិទាំងនេះគួររក្សាទុកឱ្យនៅដដែល។ ហេតុដូច្នេះ បញ្ញត្តិទាំងនេះត្រូវបានរក្សាទុកឱ្យនៅដដែល និង ត្រូវបានដាក់ចំណងជើងដែលមានសេចក្ដីចាំបាច់។

កថាខណ្ឌទី ៣ មាត្រា ៦ នៃច្បាប់ភូមិបាលត្រូវលុបចោល ព្រោះវាជាបញ្ញត្តិនៃនីតិឯកជនដែលពាក់ព័ន្ធនឹងការផ្ទេរ ឬ ការផ្លាស់ប្ដូរកម្មសិទ្ធិដែលត្រូវគ្រប់គ្រងដោយក្រមរដ្ឋប្បវេណី ។

មាត្រា ១០ នៃច្បាប់ភូមិបាលគឺជាបញ្ញត្តិដែលពន្យល់អំពីប្រភេទនៃកម្មសិទ្ធិ។ កថាខណ្ឌទី ១ កំណត់អំពីកម្មសិទ្ធិឯកត្តជន និង កថាខណ្ឌទី ៣ កំណត់អំពីកម្មសិទ្ធិអវិភាគដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ហើយមិនចាំបាច់មាននៅក្នុងច្បាប់ភូមិបាលទៀតទេ ដូច្នេះត្រូវលុបចោល។ កថាខណ្ឌទី ៤ នៃមាត្រា ១០ ដែលចែងអំពីសហកម្មសិទ្ធិត្រូវរក្សាទុកដោយសារបញ្ញត្តិពាក់ព័ន្ធចាប់ពីមាត្រា ១៧៥ ដល់ មាត្រា ១៨៥ នៃច្បាប់នោះនៅមានអានុភាពនៅឡើយ។ ដោយឡែកកថាខណ្ឌទី ៥ ដែលចង្អុលបង្ហាញបញ្ញត្តិពាក់ព័ន្ធ ត្រូវរក្សាទុកផងដែរ។

ចំណងជើងនៃជំពូកទី ៦ "របៀបលទ្ធកម្មនៃកម្មសិទ្ធិ" ត្រូវប្ដូរទៅជា "លទ្ធកម្មនៃកម្មសិទ្ធិ" ដោយលុបពាក្យ "របៀប" ចេញ ដែលអាចមានន័យថាជាធាតុផ្សំរដ្ឋប្បវេណី ដោយសារនៅក្នុងជំពូកនេះ មានតែបញ្ញត្តិដែលពាក់ព័ន្ធនឹងវិធានរដ្ឋបាល ដើម្បីធ្វើលទ្ធកម្មនូវកម្មសិទ្ធិទេដែលត្រូវរក្សាទុក ដោយឡែកបញ្ញត្តិផ្សេងទៀតដែលមានចរិតជាបញ្ហារដ្ឋប្បវេណី ដូចជាបញ្ញត្តិអំពីការផ្ទេរកម្មសិទ្ធិ ជាអាទិ៍ ត្រូវលុបចោលទាំងអស់។

ស្ទើរតែគ្រប់បញ្ញត្តិទាំងអស់នៃច្បាប់ភូមិបាលចាប់ពីមាត្រា ៦៣ ដល់មាត្រា ២២៥ សុទ្ធសឹងតែជាបញ្ញត្តិសារធាតុផ្នែករដ្ឋប្បវេណី ហើយជាន់គ្នាជាមួយនឹងមាត្រាជាច្រើននៃក្រមរដ្ឋប្បវេណី។ ហេតុដូច្នេះ ជាគោលការណ៍ បញ្ញត្តិទាំង

អស់នោះត្រូវលុបចោល តែមានករណីលើកលែងដូចខាងក្រោម :

-កថាខណ្ឌទី ២ នៃមាត្រា ៦៩ គឺជាវិធានសាធារណៈដែលតម្រូវឱ្យមានការបង់ពន្ធនៅពេលដាក់ពាក្យសុំចុះបញ្ជីអចលនវត្ថុ។ កថាខណ្ឌនេះត្រូវបានប៉ុនប៉ងលើកយកទៅដាក់ក្នុងមាតិកាទី ៦ "អំពីសុរិយោដី" ដែរ ប៉ុន្តែ មិនអាចរកកន្លែងសមរម្យដើម្បីដាក់បញ្ចូលបញ្ញត្តិនេះបាន ហើយជាលទ្ធផល គឺវានៅកន្លែងដដែលយ៉ាងដូច្នេះទៅ។

-មាត្រា ៧២ មាត្រា ៧៣ មាត្រា ៧៤ និង មាត្រា ៧៧ ទាក់ទងនឹងការកាន់កាប់ដើម្បីទទួលស្គាល់កម្មសិទ្ធិ ឬសន្តិកម្មនៃសម្បទាន ត្រូវរក្សាទុក ដោយហេតុថា នៅក្នុងក្រមរដ្ឋប្បវេណី មិនមានបញ្ញត្តិដែលឆ្លើយតបទៅនឹងបញ្ហានេះទេ។

-មាត្រា ៧៨ គឺជាវិធានសាធារណៈពាក់ព័ន្ធទៅនឹងចំណាត់ការលើទ្រព្យសម្បត្តិរដ្ឋ ក្នុងករណីដែលដីមួយឡូត៍ណានោះត្រូវបានត្រឡប់ទៅជាទ្រព្យសម្បត្តិរដ្ឋដោយសារគ្មានអ្នកទទួលបន្ត។ ដោយហេតុនេះ មាត្រានេះត្រូវរក្សាទុក តែដោយមានការកែប្រែទៅជាមូលហេតុដើម្បីធ្លាក់ទៅជារបស់រដ្ឋ គឺត្រូវយោងតាមបញ្ញត្តិនៃមាត្រា ១៣០០ នៃក្រមរដ្ឋប្បវេណី។

-មាត្រា ៨៣ នៅដដែល ដោយសារតែវាពាក់ព័ន្ធនឹងការធ្វើអំណោយនូវទ្រព្យសម្បត្តិរបស់រដ្ឋ។

វាទំនងជាមិនមានបង្កបញ្ហាអ្វីទេ នៅពេលដែលបញ្ញត្តិទាំងឡាយខាងលើនេះត្រូវបានរក្សាទុកឱ្យនៅមានក្នុងជំពូក "លទ្ធកម្មនៃកម្មសិទ្ធិ" ដោយហេតុថា បញ្ញត្តិទាំងឡាយនោះពាក់ព័ន្ធទៅនឹងលទ្ធកម្មនៃកម្មសិទ្ធិ។

-មាត្រា ១១៤ មាត្រា ១១៥ និង មាត្រា ១១៦ រក្សាទុកនៅដដែល ដោយបន្ថែមចំណងជើងថា "មាតិកាទី ៣ : អំពីវិធានដី"។ បញ្ញត្តិទាំងអស់នេះចែងពីវិធានសាធារណៈដែលពាក់ព័ន្ធកម្មសិទ្ធិលើដីធ្លី។

-មាត្រា ១៤៨ ក៏នៅមានសុពលភាពដែរនៅក្រោមមាតិកាដែលមានចំណងជើងថា "មាតិកាទី ៣ : អំពីវិធានដី"។ បញ្ញត្តិនេះជាវិធានសាធារណៈទាក់ទងទៅនឹងវិវាទព្រំប្រទល់ដី ហើយវាជារឿងធម្មតាទេដែលត្រូវដាក់បញ្ចូលទៅក្នុងមាតិកាទី ៣ ។

-មាត្រាចាប់ពី ១៧៥ ដល់មាត្រា ១៨៥ ទាក់ទងទៅនឹងសហកម្មសិទ្ធិ ហើយត្រូវបន្តមានអានុភាពដោយមានចំណងជើងសមរម្យរហូតទាល់តែមានច្បាប់ពាក់ព័ន្ធដែលគ្រប់គ្រងលើសហកម្មសិទ្ធិត្រូវបានរៀបចំឡើង។

ជាគោលការណ៍ បញ្ញត្តិបន្ទាប់ពីមាត្រា ២២៦ គឺជាបញ្ញត្តិស្តីពីសុរិយោដី ហើយស្ទើរតែទាំងអស់នៅមានអានុភាព។ ប៉ុន្តែ ដោយសារតែបញ្ញត្តិសារធាតុផ្នែករដ្ឋប្បវេណីត្រូវបានលុបចោល វិសោធនកម្មដែលចាំបាច់ត្រូវបានបន្ថែមចូលដូចខាងក្រោម :

-មាត្រា ២២៩ និង មាត្រា ២៣៨ ត្រូវធ្វើវិសោធនកម្ម ដោយសារតែការធ្វើឱ្យនិរាករណ៍នូវប្រព័ន្ធដាក់ធានា។

-កថាខណ្ឌទី ២ នៃមាត្រា ២៤៤ ត្រូវធ្វើវិសោធនកម្មដោយសារតែការលុបចោលមាត្រា ៦៥។

-ចំពោះវាក្យខណ្ឌទី ១ នៃមាត្រា ២៤៥ មិនមានបញ្ហាអ្វីទេ លើកលែងតែផ្នែកដែលពាក់ព័ន្ធទៅនឹងសន្តិកម្ម

(ប្រសិនបើមតកសាសន៍ដោយលិខិតឯកជនដែលត្រូវបានពិនិត្យបញ្ជាក់ដោយតុលាការស្ថិតនៅក្នុងប្រភេទនៃលិខិត "ឯកជន" ដូចមានកំណត់នៅក្នុងច្បាប់ភូមិបាល គឺវាផ្ទុយគ្នាជាមួយក្រមរដ្ឋប្បវេណី) ។ ប៉ុន្តែ ប្រសិនបើមាត្រានេះមានគោលបំណងកម្រិតនូវលិខិតដែលអាចចុះបញ្ជី វាផ្ទុយនឹងក្រមរដ្ឋប្បវេណីហើយ ។ ដោយហេតុនេះ វាក្យខណ្ឌទី ១ នេះត្រូវលុបចោល ហើយមាត្រា ២៤៥ ថ្មីដែលកំណត់អំពីលិខិតចាំបាច់ដើម្បីធ្វើការចុះបញ្ជី ត្រូវបានតាក់តែងឡើងដោយការរួមបញ្ចូលគ្នារវាងមាត្រា ២៤៤ និង មាត្រា ២៤៥ ។

-មាត្រា ២៤៦ ត្រូវលុបចោល ពីព្រោះវាជាបញ្ញត្តិដែលពាក់ព័ន្ធនឹងផ្នែករដ្ឋប្បវេណីសុទ្ធសាធ ។

-ផ្នែកក្រោយនៃមាត្រា ២៤៧ និង កថាខណ្ឌទី ២ នៃមាត្រា ២៥៣ ក៏ជាបញ្ញត្តិពាក់ព័ន្ធនឹងផ្នែករដ្ឋប្បវេណីដែរដែលចែងអំពីសិទ្ធិទាមទារសំណងការខូចខាត ត្រូវលុបចោល ពីព្រោះមាត្រា ៧៤៩ នៃក្រមរដ្ឋប្បវេណីត្រូវ យកមកអនុវត្ត។

## មាត្រា ៨១.-វិសោធនកម្មនូវបទបញ្ញត្តិមួយចំនួននៃក្រមរដ្ឋប្បវេណី

ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ២០០៧ ត្រូវធ្វើវិសោធនកម្មដូចខាងក្រោម :

ត្រូវកែឃ្លា "លក្ខណៈដើមនៃសមាសភាគនោះ" ទៅជា "លក្ខណៈដើមនៃវត្ថុនោះ" នៅក្នុងមាត្រា ១២១ (សមាសភាគនៃវត្ថុ)។

ត្រូវកែឃ្លា "ក្នុងទំហំដែលច្បាប់បានកម្រិត" ទៅជា "ក្នុងទំហំដែលច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀតបានកម្រិត" នៅក្នុងមាត្រា ១៣៨ (និយមន័យនៃកម្មសិទ្ធិ)។

ត្រូវកែពាក្យ "អាជ្ញាធរខេត្ត ក្រុង" ទៅជា "អាជ្ញាធររាជធានី ខេត្ត" នៅក្នុងវាក្យខណ្ឌទី ៣ និង វាក្យខណ្ឌទី ៤ នៃមាត្រា ១៨៥ (កម្មសិទ្ធិនៃបាតទន្លេ ឬ ស្ទឹងចាស់ដោយសារការបង្កើតផ្លូវទឹកថ្មី)។

ត្រូវកែឃ្លា "ដោយបានដឹងថាខ្លួនគ្មានសិទ្ធិកាន់កាប់ទេ"ទៅជា"ដោយបានដឹងថាខ្លួនគ្មានសិទ្ធិអំណាចក្នុងការកាន់កាប់ទេ" និង កែឃ្លា"ដោយមិនបានដឹងថាខ្លួនគ្មានសិទ្ធិទេ" ទៅជា "ដោយមិនបានដឹងថាខ្លួនគ្មានសិទ្ធិអំណាចទេ" នៅក្នុងវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រា ២៣៣ (ការកាន់កាប់

ដោយមានវិការៈ)។

ត្រូវបន្ថែមពាក្យ “ឬ ប័ណ្ណសិគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី” បន្ទាប់ពីពាក្យ “ប័ណ្ណសិគាល់សិទ្ធិកាន់កាប់អចលនវត្ថុ” នៅក្នុងកថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ នៃមាត្រា ២៤២ (ការការពារភោគីអចលនវត្ថុដែលមានប័ណ្ណ សិគាល់សិទ្ធិកាន់កាប់)។

ត្រូវកែពាក្យ “ផលុបភោគី” ទៅជា “ម្ចាស់សេវភាព” នៅក្នុងកថាខណ្ឌទី ៤ មាត្រា ២៩១ (ករណីយកិច្ចរបស់ម្ចាស់សេវភាព)។

ត្រូវកែឃ្លា “បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ” ទៅជា “បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើដោយមិនត្រឹមត្រូវនូវឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ” នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣៤៩ (ការរំលោភបំពានលើស្ថានភាព)។

ត្រូវបន្ថែមពាក្យ “ក្រៅផ្លូវតុលាការ ឬ” មុនពាក្យ “តាមផ្លូវតុលាការ” នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣៨៥ (សិទ្ធិរបស់ម្ចាស់បំណុលក្នុងការទាមទារឱ្យអនុវត្តកាតព្វកិច្ច)។

ត្រូវកែពាក្យ “ការមិនអនុវត្តកាតព្វកិច្ច” ទៅជា “ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ” នៅក្នុងមាត្រា ៣៩៣ (ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ)។

ត្រូវលុបឃ្លា “ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ” នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៤១២ (សិទ្ធិរំលាយក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬ បាត់បង់)។

ត្រូវកែពាក្យ “ប៉ុន្តែ” ទៅជា “ក្នុងករណីនេះ” នៅក្នុងវាក្យខណ្ឌទី ២ នៃមាត្រា ៤២០ (ការទទួលបន្ទុកហានិភ័យចំពោះកិច្ចសន្យាអញ្ញមញ្ញដែលមានអត្ថន័យត្រូវធ្វើ

ឬ មិនត្រូវធ្វើ)។

ត្រូវកែឃ្លា "សិទ្ធិលើបំណុលនោះ" ទៅជា "ម្ចាស់បំណុល" ហើយបន្ថែម "ឬ អ្នកដែលទទួលបន្ទុកបន្តវត្ថុពីអ្នកនោះ" បន្ទាប់ពីពាក្យ "អ្នកដែលបានទទួលផលប្រយោជន៍ពីអំពើរបស់កូនបំណុលនោះ" នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤២៨ (លក្ខខណ្ឌនៃការលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍)។

ត្រូវកែឃ្លា "ពេលដែលការទាញហេតុផលដោយផ្ទាល់មាត់" ទៅជា "ពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់" នៅក្នុងវាក្យខណ្ឌទី ២ នៃមាត្រា ៤២៩ (សិទ្ធិដែលត្រូវបានរក្សាការពារ)។

ត្រូវកែឃ្លា "នៅពេលដែលម្ចាស់បំណុលមិនព្រមចំពោះការតម្កល់ ឬ សាលក្រម ឬ សាលដីកាដែលប្រកាសថាការតម្កល់នោះមានសុពលភាព មិនទាន់ចូលជាស្ថាពរទេ" ទៅជា "នៅក្នុងអំឡុងពេលដែលម្ចាស់បំណុលមិនទាន់ព្រមចំពោះការតម្កល់ ឬ ក្នុងអំឡុងពេលដែលសាលក្រម ឬ សាលដីកាដែលប្រកាសថាការតម្កល់នោះ មានសុពលភាពមិនទាន់ចូលជាស្ថាពរទេ" នៅក្នុងវាក្យខណ្ឌទី ១ កថាខណ្ឌទី ២ នៃមាត្រា ៤៥៧ (ការតម្កល់)។

ត្រូវកែឃ្លា "មិនអាចយកហេតុនោះតតាំងចំពោះអនុប្បទាយីបានឡើយ" ទៅជា "មិនអាចយកហេតុនោះ តតាំងចំពោះអនុប្បទានិកបានឡើយ" នៅក្នុងវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រា ៥០៥ (អានុភាពនៃការជូនដំណឹង និង ការយល់ព្រម)។

ត្រូវកែឃ្លា "នៅក្នុងមាត្រា ១៣៣ (ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្សដោយការព្រមព្រៀង) មាត្រា ១៣៤ (លក្ខខណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស) មាត្រា ១៣៥ (លក្ខខណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង) មាត្រា ១៦០ (លទ្ធកម្មនៃកម្មសិទ្ធិលើ អចលនវត្ថុ) និង មាត្រា ១៨៧ (លទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ)" ទៅជា "ចាប់ពីមាត្រា ១៣៣ (ការបង្កើត ការផ្ទេរ និង ការកែ

ប្រែនូវសិទ្ធិប្រត្យក្សដោយការព្រមព្រៀង) ដល់មាត្រា ១៣៥ (លក្ខខណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង)” នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥២៨ (ការផ្ទេរកម្មសិទ្ធិ)។

ត្រូវកែពាក្យ “សិទ្ធិជួលជាអចិន្ត្រៃយ៍” ទៅជា “សិទ្ធិជួលអចិន្ត្រៃយ៍” និងបន្ថែមពាក្យ “សិទ្ធិអាស្រ័យនៅ” បន្ទាប់ពីពាក្យ “សិទ្ធិប្រើប្រាស់” នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥៣៤ (ការទទួលខុសត្រូវក្នុងការធានាក្នុងករណីដែលមានសិទ្ធិប្រត្យក្សជាផលុបភោគជាអាទិ៍)។

ត្រូវកែឃ្លា “អ្នកទិញត្រូវបានបង្ហាញ” ទៅជា “អ្នកលក់ត្រូវបានបង្ហាញ” នៅក្នុងចំណុច គ កថាខណ្ឌទី ២ នៃមាត្រា ៥៣៩ (ករណីយកិច្ចផ្តល់វត្ថុដែលគ្មានវិការៈ)។

ត្រូវបន្ថែមពាក្យ “ស្រូវ” បន្ទាប់ពីពាក្យ “ស្បៀងអាហារ” នៅក្នុងមាត្រា ៥៧៨ (និយមន័យនៃការខ្ចីបរិភោគ)។

ត្រូវកែឃ្លា “ការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ” ទៅជា “ការទាមទារដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ” នៅក្នុងកថាខណ្ឌទី ៤ នៃមាត្រា ៦០៥ (ការទទួលខុសត្រូវរបស់ភតិបតី ចំពោះវិការៈនៃវត្ថុជួល)។

ត្រូវកែពាក្យ “សមាជិកគណៈកម្មការនាយក” ទៅជា “អភិបាល” នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៧៤៨ (អំពើអនីត្យានុកូលរបស់នីតិបុគ្គល)។

ត្រូវកែពាក្យ “ចំនួនទឹកប្រាក់នៃការខូចខាត” ទៅជា “ចំនួនទឹកប្រាក់នៃសំណងការខូចខាត” នៅក្នុងមាត្រា ៧៦៣ (ការទូទាត់ប្រាក់ចំណេញ និង ខាត) និងមាត្រា ៧៦៤ (ការទូទាត់នូវកំហុស)។

ត្រូវលុបឃ្លា “សិទ្ធិលើការញាំដើម្បីធានាបំណុលអណ្តែត ឬ” នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៧៧០ (ភាពទៅជាមួយគ្នានៃសិទ្ធិប្រាតិភោគប្រត្យក្ស)។

ត្រូវកែពាក្យ “អាហារកិច្ច” ទៅជា “អាហារកាតព្វកិច្ច” នៅក្នុងកថាខណ្ឌទី ២

នៃមាត្រា ៧៨៦ (ឯកសិទ្ធិ ចំពោះសោហ៊ុយសម្រាប់បុណ្យសព) និង មាត្រា ៧៨៧ (ឯកសិទ្ធិចំពោះការផ្តល់នូវវត្ថុសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ)។

ត្រូវកែឃ្លា "ចំពោះប្រាក់ដែលអនុប្បទានិក ឬ ភតិកៈបន្តនោះទទួល" ទៅជា "ចំពោះប្រាក់ដែលអនុប្បទាយី ឬ ភតិបតីបន្តទទួល" នៅក្នុងវាក្យខណ្ឌទី ២ នៃមាត្រា ៧៩១ (ទំហំនៃវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិចំពោះការជួលអចលនវត្ថុ ក្នុងករណីអនុប្បទាននូវសិទ្ធិជួល ឬ ជួលបន្ត)។

ត្រូវកែឃ្លា "ដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលផ្សេងទៀត" ទៅជា "ដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលហ៊ីប៉ូតែកផ្សេងទៀត" នៅក្នុងវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រា ៨៦១ (អនុប្បទាន ឬ ការបោះបង់ និង ការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក)។

ត្រូវកែពាក្យ "បញ្ចូល" ទៅជា "បញ្ចូល" នៅក្នុងកថាខណ្ឌទី ១ មាត្រា ៩០៣ (ទំហំនៃការធានាកាតព្វកិច្ច)។

ត្រូវលុបឃ្លា "ដោយមិនចាំបាច់មានការយល់ព្រមពីកូនបំណុលផ្សេងទៀត" នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៩២២ (ការបង្កើតកាតព្វកិច្ចដោយសាមគ្គីភាព)។

ត្រូវកែឃ្លា "តាមសមាមាត្រនៃបន្ទុករបស់កូនបំណុលផ្សេងទៀត" ទៅជា "តាមសមាមាត្រនឹងចំនួនភាគរយនៃចំនួនទឹកប្រាក់សរុបនៃកាតព្វកិច្ច" នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ៩៣២ (សិទ្ធិទាមទារសំណងរបស់កូនបំណុលដែលបានសង)។

ត្រូវលុបឃ្លា "ឬ លែងទទួលស្គាល់" នៅក្នុងចំណងជើង និង បញ្ញត្តិនៃមាត្រា ៩៤២ (ការរលត់ញាតិភាព ដោយការកាត់កាល់ ឬ លែងទទួលស្គាល់)។

ត្រូវកែឃ្លា "ប្តី ឬ ប្រពន្ធទាំងសងខាង" ទៅជា "ប្តីប្រពន្ធទាំងសងខាង" នៅចំណុច ខ នៃមាត្រា ៩៧៥ (ការទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ច)។

ត្រូវកែឃ្លា "អចលនវត្ថុ" ទៅជា "អចលនវត្ថុសម្រាប់ការអាស្រ័យនៅរបស់

គ្រួសារ” នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៩៧៦ (ការចាត់ចែងទ្រព្យសម្បត្តិរួម របស់ប្ដីប្រពន្ធ)។

ត្រូវកែពាក្យ “ខេត្ត ក្រុង” ទៅជា “រាជធានី ខេត្ត” នៅក្នុងចំណុច ខ នៃ មាត្រា ១០៤២ (ករណីយកិច្ចពិភាក្សាអំពីចំណុចសំខាន់ៗ ទាក់ទងទៅនឹងកូន)។

ត្រូវកែឃ្លា “សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជន នៅក្រោមអាណាព្យាបាល” ទៅជា “សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន” នៅក្នុងមាត្រា ១០៧៦ (បុគ្គលដែលមិន អាចក្លាយជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន)។

ត្រូវកែពាក្យ “ខេត្ត ក្រុង” ទៅជា “រាជធានី ខេត្ត” នៅក្នុងចំណុច ខ នៃ មាត្រា ១០៤២ (ករណីយកិច្ចពិភាក្សាអំពីចំណុចសំខាន់ៗ ទាក់ទងទៅនឹងកូន)។

ត្រូវកែឃ្លា “សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជន នៅក្រោមអាណាព្យាបាល” ទៅជា “សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន” នៅក្នុងមាត្រា ១០៧៦ (បុគ្គលដែលមិន អាចក្លាយជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន)។

ត្រូវកែឃ្លា “សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់ជននៅក្រោម អាណាព្យាបាលទូទៅ” ទៅជា “សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់របស់អ្នក អាណាព្យាបាលទូទៅ” នៅក្នុងមាត្រា ១១១១ (បុគ្គលដែលមិន អាចក្លាយជាអ្នក ត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ)។

ត្រូវកែឃ្លា “នៅមុនពេលចាប់ផ្ដើមសន្តតិកម្ម” ទៅជា “នៅមុន ឬ ព្រមគ្នា នឹងពេលចាប់ផ្ដើមសន្តតិកម្ម” នៅក្នុងវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស)។

ត្រូវបន្ថែមឃ្លា “ចំពោះសន្តតិកម្មនោះ” បន្ទាប់ពីឃ្លា “បុគ្គលនោះមិនមែនជា សន្តតិជន” នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៦១ (អានុភាពនៃការបោះបង់)។

ត្រូវកែឃ្លា “ការបែងចែកត្រូវធ្វើជាលាយលក្ខណ៍អក្សរទៅតាមទម្រង់នីមួយៗ

ដែលចាំបាច់នៅក្នុងការផ្ទេរសិទ្ធិនោះ” ទៅជា “ការបែងចែកត្រូវធ្វើតាមទម្រង់ចាំបាច់ដើម្បីផ្ទេរសិទ្ធិនីមួយៗនោះ ដូចជាលិខិតជាលាយលក្ខណ៍អក្សរជាអាទិ៍” នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ១២៦៦ (ការពិភាក្សាបែងចែកមរតក)។

## មាត្រា ៨២.‐ការចាត់ចែងអំពីក្រមរដ្ឋប្បវេណីចាស់

ក្រមរដ្ឋប្បវេណីចាស់ ដែលបានអនុញ្ញាតប្រកាសឱ្យប្រើ ដោយព្រះមហាក្សត្រនៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩២០ និង ដែលត្រូវបានធ្វើវិសោធនកម្មបន្តបន្ទាប់រហូតដល់មុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មិនមានអានុភាពឡើយ។

(កំណត់)

តាមការពិតទៅ ក្រមរដ្ឋប្បវេណីចាស់មិនមានអានុភាពពិតប្រាកដទេ នៅកាលបរិច្ឆេទនៃការអនុវត្តក្រមថ្មីនេះ។ ប៉ុន្តែ ប្រសិនបើច្បាប់នេះចែងថា ត្រូវធ្វើឱ្យនិរាករណ៍នូវក្រមរដ្ឋប្បវេណីចាស់ អាចត្រូវគេយល់ឃើញថា ក្រមចាស់មានអានុភាពមកដល់ត្រឹមកាលបរិច្ឆេទនៃការអនុវត្តក្រមថ្មី។ ដើម្បីជៀសវាងការភាន់ច្រឡំ បញ្ញត្តិនេះប្រកាសថា "មិនមានអានុភាពឡើយ" ដោយយកគំរូតាមកថាខណ្ឌទី ២ មាត្រា ៩៨ នៃរដ្ឋធម្មនុញ្ញជប៉ុន។

## មាត្រា ៨៣.‐អានុភាពនៃច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត

ក្រៅពីច្បាប់ និង បទដ្ឋានគតិយុត្តដែលកំណត់ចាប់ពីមាត្រា ៧៨ (ការធ្វើឱ្យនិរាករនូវច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ) ដល់មាត្រា ៧៨២ (ការចាត់ចែងអំពីក្រមរដ្ឋប្បវេណីចាស់) ច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងទៀតដែលមានអានុភាពនៅកាលបរិច្ឆេទនៃការអនុវត្ត ហើយផ្ទុយនឹងបញ្ញត្តិនៃក្រមរដ្ឋប្បវេណីមិនត្រូវមានអានុភាពត្រឹមទំហំ ដែលផ្ទុយនឹងក្រមរដ្ឋប្បវេណី ចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត។

(កំណត់)

មាត្រានេះត្រូវបានដាក់បញ្ចូលក្នុងគោលបំណងធ្វើការបញ្ជាក់ឱ្យកាន់តែច្បាស់។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៨៤.-កាលបរិច្ឆេទនៃការអនុវត្ត**

ក្រោយពេលចូលជាធរមាននៅទូទាំងប្រទេស ច្បាប់នេះត្រូវផ្សព្វផ្សាយក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ ទើបត្រូវអនុវត្ត។

(កំណត់)

មាត្រានេះមានគោលបំណងកំណត់អំពីកាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ ហើយដាក់កាលបរិច្ឆេទនេះឱ្យត្រូវគ្នានឹងកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី។

(កំណត់ពន្យល់បន្ថែម)

បញ្ហាដែលលើកឡើងខាងក្រោមនេះទាក់ទងទៅនឹងការអនុវត្តមាត្រា ៥ នៃច្បាប់នេះ និង ការកំណត់ពេលវេលាអនុវត្តក្រមរដ្ឋប្បវេណី :

(១) ការទាមទារឱ្យបញ្ឈប់ការរំលោភសិទ្ធិបុគ្គលដោយផ្អែកលើសិទ្ធិបុគ្គល (មាត្រា ១១ និង មាត្រា ១២)

វាមានបញ្ហាថាតើក្រមរដ្ឋប្បវេណីអនុវត្តចំពោះករណីដែលការរំលោភសិទ្ធិបុគ្គលបានកើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ហើយលទ្ធផលនៃសកម្មភាពរំលោភនោះនៅតែបន្តមាននៅក្រោយកាលបរិច្ឆេទនៃការអនុវត្តដែរឬទេ។ បញ្ហានេះមានលក្ខណៈដូចគ្នានឹងអំពើអនីត្យានុកូល។ នៅក្នុងករណីអំពើអនីត្យានុកូល (ដែលនឹងមានពិភាក្សានៅផ្នែកក្រោយ) ដោយសារតែអំពើអនីត្យានុកូលបំពេញល័ក្ខខ័ណ្ឌតាមផ្លូវច្បាប់ នៅពេលដែលលទ្ធផលនៃអំពើនោះកើតឡើង ហេតុដូច្នេះ ប្រសិនបើលទ្ធផលនោះកើតឡើងក្រោយកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តចំពោះករណីទាំងនោះ ដោយយល់ឃើញថា "បញ្ហា" នៃវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ មាត្រា ៥ នៃច្បាប់នេះ កើតឡើងនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។ ចំពោះការរំលោភសិទ្ធិបុគ្គលក៏ដូចគ្នាដែរ ដូច្នេះ ក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តចំពោះករណីដែលការរំលោភត្រូវបានកើតនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ហើយលទ្ធផលនៃសកម្មភាពរំលោភនោះនៅមានបន្តនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។ ឧទាហរណ៍ ការបោះពុម្ពផ្សាយបរិហារកេរ្តិ៍ចំពោះបុគ្គលណាម្នាក់បានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តក៏ប៉ុន្តែ នៅតែ បន្តលក់នៅក្រោយកាលបរិច្ឆេទនៃការអនុវត្តយ៉ាងដូច្នេះ គេអាចទាមទារឱ្យបញ្ឈប់ការលក់នោះដោយយោង តាមបញ្ញត្តិនៃមាត្រា ១២ នៃក្រមរដ្ឋប្បវេណីបាន។

(២) ការទាមទារឱ្យរំលត់ផលុបភោគ (មាត្រា ២៦៧ នៃក្រមរដ្ឋប្បវេណី)

មាត្រា ២៦៧ នៃក្រមរដ្ឋប្បវេណីចែងថា ក្នុងករណីដែលផលុបភោគីបានធ្វើអំពើដែលផ្ទុយនឹងខ្លឹមសារនៃផលុបភោគ កម្មសិទ្ធិករអាចទាមទារទៅតុលាការឱ្យរំលត់ផលុបភោគបាន។ រីឯមាត្រា ១៣៥ នៃច្បាប់ភូមិបាលក៏ចែងអំពីបណ្តឹងទាមទារឱ្យបាត់បង់សិទ្ធិរបស់ផលុបភោគីដែរ។ ក្នុងករណីនេះ ប្រសិនបើមូលហេតុដែលបានចែងនៅក្នុងកថាខណ្ឌទី ១ មាត្រា ១៣៥ នៃច្បាប់ភូមិបាល បានកើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត សិទ្ធិទាមទារឱ្យបាត់បង់សិទ្ធិរបស់ផលុបភោគីត្រូវបានបង្កើតឡើងដោយផ្អែកលើបញ្ញត្តិនេះដែលត្រូវចាត់ទុកថាជា "បញ្ហា" ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ មាត្រា ៥ នៃច្បាប់នេះ។ ដោយហេតុនេះ កម្មសិទ្ធិករអាចប្តឹងទាមទារឱ្យបាត់បង់សិទ្ធិរបស់ផលុបភោគី ដោយផ្អែកលើកថាខណ្ឌទី ១ មាត្រា ១៣៥ នៃច្បាប់ភូមិបាលបាន ទោះបីជានៅក្រោយកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ។ លើសពីនេះទៅទៀត កថាខណ្ឌទី ២ នៃមាត្រា ១៣៥ នោះ (ម្ចាស់បំណុលនៃផលុបភោគីមានសិទ្ធិប្តឹងទៅតុលាការដើម្បីសុំបន្តសិទ្ធិរបស់ផលុបភោគី

ដោយធានាការជួសជុលនូវរាល់វិការភាពដែលមាន និង ធានាសំរាប់អនាគត) កថាខណ្ឌទី ៣ នៃមាត្រានោះ (ដោយយោលទៅតាមកាលៈទេសៈ និង ហេតុផលផ្សេងៗ តុលាការអាចប្រកាសការរលត់ដាច់ខាតនៃផលុបភោគ ឬ គ្រាន់តែបង្គាប់ឱ្យប្រគល់អចលនវត្ថុឱ្យអសារកម្មសិទ្ធិករដោយបង់ប្រាក់ប្រចាំឆ្នាំឱ្យផលុបភោគី ឬសិទ្ធិវន្តរបស់ជននេះនូវទឹកប្រាក់មួយចំនួនជាកំណត់) អាចយកមកអនុវត្តចំពោះករណីនេះ ហើយម្ចាស់បំណុលនៃផលុបភោគីអាចធ្វើសកម្មភាពដែលចាំបាច់ទៅតាមនោះបាន ។

(៣) កាតព្វកិច្ចអនិយត (ចាប់ពីមាត្រា ៣២០ នៃក្រមរដ្ឋប្បវេណី)

ក្នុងករណីដែលកាតព្វកិច្ចអនិយតបានកើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ក៏ប៉ុន្តែ សិទ្ធិជ្រើសរើសនៅមិនទាន់បានអនុវត្តនៅឡើយ បញ្ញត្តិនៃមាត្រា ៣២០ នឹងមិនយកមកអនុវត្តឡើយ ដោយបកស្រាយបានថាការកើតឡើងនូវកាតព្វកិច្ចអនិយតគឺក្លាយជា "បញ្ហា" ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ មាត្រា ៥ នៃច្បាប់នេះ ហើយថា ការអនុវត្តសិទ្ធិជ្រើសរើសគឺគ្រាន់តែជាសកម្មភាពបន្ទាប់បន្សំតែប៉ុណ្ណោះ។ ក្នុងករណីនេះ "ការអនុវត្តសិទ្ធិជ្រើសរើស" មិនត្រូវចាត់ទុកថាជា "បញ្ហា" ទេ។ ករណីនេះគឺដូចគ្នានឹងករណីដែលកិច្ចសន្យាត្រូវបានរំលាយនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ដោយផ្អែកលើសិទ្ធិរំលាយដែលត្រូវបានបង្កើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត។

(៤) ការផ្តល់សច្ចានុមតិ (កថាខណ្ឌទី ៣ មាត្រា ៣៥៨ និង មាត្រា ៣៧០ នៃក្រមរដ្ឋប្បវេណី)

ទាក់ទងទៅនឹងកថាខណ្ឌទី ៣ មាត្រា ៣៥៨ នៃក្រមរដ្ឋប្បវេណី (ការផ្តល់សច្ចានុមតិដោយបុគ្គលដែលមានសិទ្ធិលុបចោល) គេអាចបកស្រាយថា ការបង្ហាញឆន្ទៈដែលមានវិការៈដែលជាបុរេល័ក្ខខ័ណ្ឌនៃការផ្តល់សច្ចានុមតិអាចត្រូវបកស្រាយថាជា "បញ្ហា" ដែលមានចែងនៅក្នុងវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ មាត្រា ៥ នៃច្បាប់នេះ ហើយគេអាចបកស្រាយបានដែរថា ទោះបីជាសច្ចានុមតិត្រូវបានផ្តល់នៅក្រោយកាលបរិច្ឆេទនៃការអនុវត្តក៏ដោយ ក៏អានុភាពនៃសច្ចានុមតិនេះត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមកដែរ។ ប៉ុន្តែ ដោយសារតែការបង្ហាញឆន្ទៈដែលមានវិការៈត្រូវមានសុពលភាពជាស្ថាពរដោយការផ្តល់សច្ចានុមតិ ការផ្តល់សច្ចានុមតិនោះគឺឆ្លើយតបទៅនឹងពាក្យថា "បញ្ហា" ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ មាត្រា ៥ នៃច្បាប់នេះ។ ដោយហេតុនោះ គួរតែបកស្រាយបានថា ការបង្ហាញឆន្ទៈដែលមានវិការៈដែលធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត អាចផ្តល់សច្ចានុមតិបាននៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ មាត្រា ៣៥៨ នៃក្រមរដ្ឋប្បវេណី។

ការបកស្រាយនេះត្រូវយកទៅអនុវត្តដូចគ្នាផងដែរចំពោះសច្ចានុមតិលើអំពើតំណាងដែលគ្មានសិទ្ធិ (មាត្រា

៣៧០ នៃក្រមរដ្ឋប្បវេណី)។ អំពើតំណាងដែលគ្មានសិទ្ធិដែលត្រូវបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តអាចផ្តល់សច្ចានុមតិនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ដោយយោងតាមបញ្ញត្តិនៃមាត្រា ៣៧០ នៃក្រមរដ្ឋប្បវេណីបាន។ ក្នុងករណីនេះ អានុភាពដែលទាក់ទងនឹងការតំណាងត្រូវអនុលោមតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី។

ក្នុងករណីខ្លះ សកម្មភាពមោឃៈអាចត្រូវបានផ្តល់សច្ចានុមតិបាន ទោះបីជាមិនមានបញ្ញត្តិណាមួយដែលចែងជាក់លាក់នៅក្នុងក្រមរដ្ឋប្បវេណីក៏ដោយ។ ក្នុងករណីនេះ សកម្មភាពមោឃៈនោះនឹងក្លាយទៅជាសកម្មភាពសុពលតាមផ្លូវច្បាប់ដោយសច្ចានុមតិ ហេតុដូច្នេះ ការផ្តល់សច្ចានុមតិនោះត្រូវចាត់ទុកថាជា "បញ្ហា" ដែលបានចែងនៅក្នុងវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ មាត្រា ៥ នៃច្បាប់នេះ។ ដោយហេតុនោះ សកម្មភាពមោឃៈដែលបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តអាចត្រូវបានផ្តល់សច្ចានុមតិនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។ មូលហេតុគឺដោយសារតែសកម្មភាពដែលនាំឱ្យមានសុពលភាពដល់សកម្មភាពមោឃៈនោះ បានធ្វើឡើងនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។

(៥) ឧបាទេសកម្មដោយម្ចាស់បំណុល (ចាប់ពីមាត្រា ៤២២ នៃក្រមរដ្ឋប្បវេណី)

គោលបំណងនៃឧបាទេសកម្មដោយម្ចាស់បំណុលគឺដើម្បីពង្រឹងនូវអានុភាពនៃសិទ្ធិលើបំណុល។ ដោយហេតុនេះ ម្ចាស់បំណុលអាចធ្វើឧបាទេសកម្មដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីបានត្រឹមតែទំនាក់ទំនងនៃសិទ្ធិលើបំណុលដែលត្រូវបានបង្កើតឡើងនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តប៉ុណ្ណោះ។ ក្នុងករណីនេះ ម្ចាស់បំណុលអាចយកសិទ្ធិលើបំណុល (របស់កូនបំណុល) ដែលត្រូវបានបង្កើតឱ្យមានអត្ថិភាពរួចហើយ មកធ្វើកម្មវត្ថុនៃឧបាទេសកម្មបាន។ ដូច្នេះ សិទ្ធិលើបំណុលដែលត្រូវបានបង្កើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ក៏អាចក្លាយជាកម្មវត្ថុនៃឧបាទេសកម្មបានដែរ។ ជាឧទាហរណ៍ A អាចអនុវត្តសិទ្ធិឧបាទេសកម្មចំពោះទំនាក់ទំនងនៃសិទ្ធិលើបំណុលដែលបានកើតឡើងរវាង B និង C នៅមុនកាលបរិច្ឆេទនៃការអនុវត្តរួចបានដោយផ្អែកលើទំនាក់ទំនងនៃសិទ្ធិលើបំណុលដែលបានកើតឡើងរវាង A និង B នៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។

ម្យ៉ាងទៀត ការអនុញ្ញាតឱ្យ A អនុវត្តសិទ្ធិឧបាទេសកម្មនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តចំពោះករណីដែលទំនាក់ទំនងនៃសិទ្ធិលើបំណុលបានកើតឡើងរវាង A និង B នៅមុនកាលបរិច្ឆេទនៃការអនុវត្ត មិនសមរម្យទេ ពីព្រោះការអនុវត្តបែបនេះនឹងពង្រឹងអានុភាពនៃសិទ្ធិលើបំណុលដែលត្រូវបានបង្កើតឡើងរួចហើយដោយច្បាប់ថ្មី។ ដោយគិតពិចារណាថា របបឧបាទេសកម្មនេះមានគោលបំណងការពារសិទ្ធិលើបំណុលដែលកំពុងមានអត្ថិភាព គេអាចគិតឃើញថា របបឧបាទេសកម្ម ក៏អាចអនុវត្តចំពោះសិទ្ធិលើបំណុលដែលបានកើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តដែរ។ ប៉ុន្តែ វាគួរតែត្រូវបានបកស្រាយថា របបឧបាទេសកម្មនេះត្រូវអនុវត្តចំពោះសិទ្ធិលើបំណុលដែល

បានកើតឡើងនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តប៉ុណ្ណោះ ដោយសាររបបនេះគឺជាផ្នែកមួយនៃលក្ខណៈដើមនៃសិទ្ធិលើបំណុល។

(៦) ការលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ (ចាប់ពីមាត្រា ៤២៨ នៃក្រមរដ្ឋប្បវេណី)

របបលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍នេះ ក៏ត្រូវបានតាក់តែងឡើងដើម្បីពង្រឹងអានុភាពនៃសិទ្ធិលើបំណុល ដូចឧបាទេសកម្មដោយម្ចាស់បំណុលដែរ។ ហេតុដូច្នេះ អំពើដែលនាំឱ្យខូចខាតផលប្រយោជន៍អាចត្រូវបានលុបចោល ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីបាន ដោយផ្អែកលើសិទ្ធិលើបំណុលដែលត្រូវបានបង្កើតឡើង នៅក្រោយកាលបរិច្ឆេទនៃការអនុវត្តតែប៉ុណ្ណោះ។ អំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ដែលអាចត្រូវបានលុបចោល គឺជាអំពើដែលបានធ្វើឡើងនៅក្រោយពេលដែលសិទ្ធិលើបំណុលត្រូវបានបង្កើតឡើង។

វាមិនសមហេតុផលទេក្នុងការអនុញ្ញាតឱ្យលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ដោយអនុវត្តមាត្រា ៤២៨ នៃក្រមរដ្ឋប្បវេណី ក្នុងករណីដែលអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍នោះត្រូវបានធ្វើឡើងនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ចំពោះសិទ្ធិលើបំណុលដែលត្រូវបានបង្កើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ដោយបកស្រាយថា អំពើដែលនាំឱ្យខូចខាតផលប្រយោជន៍នោះ គឺជា "បញ្ហា" ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រា ៥ ដោយសារការអនុញ្ញាតបែបនេះនឹងធ្វើការពង្រឹងនូវអានុភាពនៃសិទ្ធិលើបំណុលដែលត្រូវបានបង្កើតឡើងរួចហើយនោះ។

(៧) អនុប្បទានសិទ្ធិលើបំណុល និង ការទទួលកាតព្វកិច្ច (ចាប់ពីមាត្រា ៥០១ នៃក្រមរដ្ឋប្បវេណី)

ក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តចំពោះអនុប្បទានសិទ្ធិលើបំណុល ឬ ការទទួលកាតព្វកិច្ច ដែលបានធ្វើឡើងនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តតែប៉ុណ្ណោះ ដោយសារតែអនុប្បទានសិទ្ធិលើបំណុល ឬ ការទទួលកាតព្វកិច្ចនោះ ត្រូវចាត់ទុកថាជា "បញ្ហា" ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រា ៥។ ចំពោះអនុប្បទានសិទ្ធិលើបំណុល ឬ ការទទួលកាតព្វកិច្ច ដែលបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តវិញ ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក។

ក្នុងករណីសិទ្ធិលើបំណុលដែលបានបង្កើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវបានធ្វើអនុប្បទាននៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ឬ ករណីដែលកាតព្វកិច្ចដែលបានបង្កើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តត្រូវបានទទួលនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តចំពោះអនុប្បទានសិទ្ធិលើបំណុល ឬ ការទទួលកាតព្វកិច្ចនោះ។ ចំពោះករណីនេះ បញ្ហាថាតើសិទ្ធិលើបំណុលនោះអាចធ្វើអនុប្បទាន ឬ

តើកាតព្វកិច្ចនោះអាចទទួលបានដែរឬយ៉ាងណានោះ ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ហើយវាជាចំណុចដែលត្រូវធ្វើការកត់សម្គាល់។ ប្រសិនបើសិទ្ធិលើបំណុលមិនអាចធ្វើអនុប្បទានតាមច្បាប់ចាស់ទេ សិទ្ធិលើបំណុលនោះក៏មិនអាចត្រូវបានធ្វើអនុប្បទានបាននៅក្រោយកាលបរិច្ឆេទនៃការអនុវត្តដែរ ពីព្រោះលក្ខណៈនៃសិទ្ធិលើបំណុលនោះមិនផ្លាស់ប្តូរទេ។

(៨) សិទ្ធិទាមទារឱ្យសងមកវិញ នូវសោហ៊ុយ (មាត្រា ៦០៤ មាត្រា ៦២៨ មាត្រា ៦៤៦ មាត្រា ៦៨៦ និង មាត្រា ៧៣៤ នៃក្រមរដ្ឋប្បវេណី)

បញ្ញត្តិនៃមាត្រា ៦០៤ (សិទ្ធិទាមទារឱ្យសងមកវិញ នូវសោហ៊ុយរបស់ភតិកៈ) នៃក្រមរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តចំពោះករណីដែលភតិកៈបានចំណាយសោហ៊ុយចាំបាច់ដែលត្រូវជាបន្ទុករបស់ភតិបតីចំពោះវត្ថុជួល ឬ បានចំណាយសោហ៊ុយដើម្បីកែលំអវត្ថុជួល ឬ ចំណាយផ្សេងៗទៀតដើម្បីបង្កើនតម្លៃ នៅមុនកាលបរិច្ឆេទនៃការអនុវត្ត ដោយផ្អែកលើភតិសន្យាដែលនៅបន្តមានអានុភាពនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត ពីព្រោះនៅក្នុងករណីនេះ ការចេញចំណាយសោហ៊ុយត្រូវចាត់ទុកថាជា "បញ្ហា" ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រា ៥។ ស្រដៀងគ្នានេះដែរ មាត្រា ៦២៨ (បន្ទុកលើសោហ៊ុយ) នៃក្រមរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលអ្នកខ្ចីបានចេញចំណាយសោហ៊ុយចាំបាច់ក្រៅពីសោហ៊ុយចាំបាច់ធម្មតា ឬ បានចំណាយសោហ៊ុយដើម្បីកែលំអ ឬ ចំណាយផ្សេងដើម្បីបង្កើនតម្លៃវត្ថុខ្ចីនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ដោយផ្អែកលើកិច្ចសន្យាខ្ចីប្រើដែលបន្តមានអានុភាពនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។

ចំពោះបញ្ញត្តិនៃមាត្រា ៦៤៦ (សិទ្ធិទាមទារឱ្យសងមកវិញ ជាអាទិ៍ នូវសោហ៊ុយរបស់អាណត្តិគាហក) នៃក្រមរដ្ឋប្បវេណីស្តីពីអាណត្តិ មាត្រា ៦៨៦ (ករណីយកិច្ចសងសោហ៊ុយវិញ របស់អ្នកផ្ញើ) ស្តីពីបញ្ញើ និង មាត្រា ៧៣៤ (សិទ្ធិទាមទារឱ្យសងសោហ៊ុយវិញរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល) ស្តីពីការគ្រប់គ្រងដោយឈឺឆ្អាល ក៏ដូចគ្នានឹងករណីទាំងពីរខាងលើដែរ។

(៩) អំពើអនីត្យានុកូល (ចាប់ពីមាត្រា ៧៤២ នៃក្រមរដ្ឋប្បវេណី)

ក្រមរដ្ឋប្បវេណីមិនត្រូវយកមកអនុវត្តចំពោះករណីដែលអំពើអនីត្យាកូលត្រូវបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តឡើយ ហើយលទ្ធផលនៃអំពើនោះក៏បានកើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តដែរ។ ករណីនេះត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក។ បញ្ហាគឺស្ថិតនៅត្រង់ថាតើត្រូវដោះស្រាយយ៉ាងដូចម្តេចចំពោះករណីដែលអំពើអនីត្យានុកូលត្រូវបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ក៏ប៉ុន្តែលទ្ធផលនៃអំពើនោះកើតឡើងនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។ នៅក្នុងករណីនេះ បញ្ញត្តិដែលពាក់ព័ន្ធទៅនឹងអំពើអនីត្យានុកូល

នៃក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តដោយចាត់ទុកថា "បញ្ហា" ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ មាត្រា ៥ នៃច្បាប់នេះ បានកើតឡើងនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។ ការអនុវត្តបែបនេះ ដោយសារតែវាត្រូវបានបកស្រាយថា ការកើតឡើងនៃលទ្ធផល គឺជាល័ក្ខខ័ណ្ឌមួយនៃអំពើអនីត្យានុកូល មានន័យថា អំពើអនីត្យានុកូលមិនទាន់ត្រូវបានបង្កើតឡើងពេញលេញនៅឡើយទេ រហូតទាល់លទ្ធផលនៃអំពើនោះកើតឡើង។

ចំពោះអំពើអនីត្យានុកូលដែលគ្មានល័ក្ខខ័ណ្ឌនៃកំហុសដើម្បីឱ្យទទួលខុសត្រូវ វាមានហេតុផលសមរម្យដែលយកពេលដែលលទ្ធផលនៃអំពើនោះកើតឡើងមកធ្វើជាមូលដ្ឋាន ដើម្បីធ្វើការបែងចែកការអនុវត្តច្បាប់ចាស់ ឬក្រមរដ្ឋប្បវេណីថ្មី ពីព្រោះថា ការជួសជុលនូវលទ្ធផលនៃអំពើអនីត្យានុកូលនោះមានសារៈសំខាន់។ ប៉ុន្តែ ចំពោះអំពើអនីត្យានុកូលដែលតម្រូវឱ្យមានកំហុសជាល័ក្ខខ័ណ្ឌវិញ អាចមានការបកស្រាយថា បញ្ញត្តិដែលមាននៅពេលអំពើនោះត្រូវបានធ្វើឡើងជាបញ្ញត្តិសារៈសំខាន់ ដូច្នេះ ត្រូវយកពេលដែលអំពើនោះត្រូវបានធ្វើឡើងមកធ្វើជាមូលដ្ឋាន។ ប៉ុន្តែ ដោយសាររបបអំពើអនីត្យានុកូលមានគោលបំណងឱ្យសងសំណងការខូចខាតដែលកើតឡើងពីអំពើនោះ វាមានហេតុផលសមរម្យដែលយកពេលដែលលទ្ធផលនៃអំពើអនីត្យានុកូលនោះកើតឡើងធ្វើជាមូលដ្ឋាន។

ចំពោះការទទួលខុសត្រូវចំពោះផលិតផល ក៏ដូចគ្នានឹងករណីខាងលើដែរ។ មានន័យថា បញ្ញត្តិនៃមាត្រា ៧៥១ (ការទទួលខុសត្រូវចំពោះផលិតផលរបស់អ្នកផលិតវត្ថុ) នៃក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តចំពោះករណីដែលផលិតផលដែលត្រូវបានប្រគល់នៅមុនកាលបរិច្ឆេទនៃការអនុវត្ត បានបង្កឱ្យមានការខូចខាតនៅក្រោយកាលបរិច្ឆេទនៃការអនុវត្ត។

(១០) សិទ្ធិឃាត់ទុក (ចាប់ពីមាត្រា ៧៧៤ នៃក្រមរដ្ឋប្បវេណី)

ចំពោះសិទ្ធិឃាត់ទុក មិនមានអន្តរប្បញ្ញត្តិពិសេសណាមួយទេ។ មាត្រា ៧៧១ នៃក្រមរដ្ឋប្បវេណីចែងថា សិទ្ធិឃាត់ទុកត្រូវកើតឡើង ប្រសិនបើមានកាន់កាប់វត្ថុរបស់អ្នកដទៃ និង មានសិទ្ធិលើបំណុលដែលកើតមានឡើងចំពោះវត្ថុនោះ។ មាត្រានេះត្រូវយកមកអនុវត្តចំពោះករណីដែលបុគ្គលម្នាក់ឃាត់ទុកវត្ថុដែលទាក់ទងនឹងសិទ្ធិលើបំណុលដែលត្រូវបានបង្កើតឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត (មាត្រានេះត្រូវយកមកអនុវត្តផងដែរចំពោះករណីដែលបណ្ដឹងទាមទារឱ្យប្រគល់វត្ថុវិញ កំពុងត្រូវបានចាត់ការ ប៉ុន្តែ នៅក្រោយពេលដែលការទាញហេតុផលដោយផ្ទាល់មាត់ក្នុងការជំនុំជម្រះអង្គហេតុត្រូវបានបញ្ចប់ ភាគីដែលកាន់កាប់វត្ថុមិនអាចអនុវត្តសិទ្ធិឃាត់ទុកបានទេ ដោយសារសិទ្ធិតវ៉ាត្រូវរលត់)។ ប៉ុន្តែដូចបញ្ញត្តិនៃមាត្រា ៦០៤ (សិទ្ធិទាមទារឱ្យសងវិញ នូវសោហ៊ុយរបស់ភតិក:) អាចបកស្រាយថា មាត្រា ៧៧៧ មិនត្រូវយកមកអនុវត្តចំពោះសោហ៊ុយចាំបាច់ ជាអាទិ៍ ដែលត្រូវបានបង់នៅមុនកាលបរិច្ឆេទនៃការអនុវត្តទេ ហេតុដូច្នេះ គ្មានសោហ៊ុយចាំបាច់ ជាអាទិ៍ ណាមួយអាចត្រូវបានទាមទារយកមកវិញ ដោយផ្អែកលើមាត្រានេះទេ។

(១១) កិច្ចសន្យាធានា (ចាប់ពីមាត្រា ៩០០ នៃក្រមរដ្ឋប្បវេណី)

ក្រមរដ្ឋប្បវេណីមិនយកមកអនុវត្តចំពោះកិច្ចសន្យាធានាដែលបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្តទេ។ ទោះបីជាស្ថានភាពនៃការធានានោះនៅមានជាបន្តនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តក៏ដោយក៏ត្រូវបានបកស្រាយថា វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ មាត្រា ៥ នៃច្បាប់នេះមិនត្រូវយកមកអនុវត្តទេ។ ចំពោះការធានាបំណុលអណ្តែត វិសាលភាព និង អំឡុងពេល ជាអាទិ៍ នៃការធានាបំណុលអណ្តែតត្រូវបានកំណត់នៅក្នុងកិច្ចសន្យាដែលបានធ្វើឡើងនៅមុនកាលបរិច្ឆេទនៃការអនុវត្ត ប៉ុន្តែវាមានភាពសមរម្យក្នុងការអនុវត្តបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ដូចជាការអនុញ្ញាតឱ្យរំលាយកិច្ចសន្យាធានាបំណុលអណ្តែតដែលមិនកំណត់អំឡុងពេលឆ្ពោះទៅអនាគត ដោយយោងតាមបញ្ញត្តិនៃមាត្រា ៩០២ នៃក្រមរដ្ឋប្បវេណី។ មានន័យថា បញ្ញត្តិនៃវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ មាត្រា ៥ នៃច្បាប់នេះ គួរតែត្រូវយកមកអនុវត្តដោយយល់ឃើញថា ការធានាបំណុលអណ្តែតគឺជាទំនាក់ទំនងគតិយុត្តជាបន្ត។ បញ្ញត្តិនៃមាត្រា ៥៨ ត្រូវបានរៀបចំឡើងដោយយកចំណុចនេះជាបុរេល័ក្ខខ័ណ្ឌ។

(១២) ការចាត់ចែង ជាអាទិ៍ នូវអចលនវត្ថុសម្រាប់ការអាស្រ័យនៅ (មាត្រា ៩៧៧ នៃក្រមរដ្ឋប្បវេណី)

ចំពោះមាត្រា ៩៧៧ នៃក្រមរដ្ឋប្បវេណី ស្តីពីការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក ច្បាប់នេះមិនមានអន្តរប្បញ្ញត្តិពិសេសទេ។ ហេតុដូច្នេះ បញ្ញត្តិនៃមាត្រា ៩៧៧ នោះ ត្រូវយកមកអនុវត្តចំពោះករណីដែលអចលនវត្ថុសម្រាប់ការអាស្រ័យនៅត្រូវបានចាត់ចែងនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តតែប៉ុណ្ណោះ។ ចំពោះមាត្រា ៩៧៦ (ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ) នៃក្រមរដ្ឋប្បវេណី ក៏ដូចគ្នាដែរ។ មានន័យថា បញ្ញត្តិនៃមាត្រា ៩៧៦ នោះ ត្រូវយកមកអនុវត្តចំពោះករណីដែលប្តីប្រពន្ធណាម្ខាងចាត់ចែងទ្រព្យសម្បត្តិរួមដោយគ្មានការយល់ព្រមរបស់សហព័ទ្ធម្ខាងទៀតនៅក្រោយកាលបរិច្ឆេទនៃការអនុវត្តតែប៉ុណ្ណោះ។ ចំពោះការចាត់ចែងនៅមុនកាលបរិច្ឆេទនៃការអនុវត្តវិញ ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ដោយសារការអនុវត្តប្រតិសកម្ម នាំឱ្យមានការខូចខាតផលប្រយោជន៍ដែលមិនអាចព្យាករទុកជាមុនដល់តតិយជនបាន។

ម្យ៉ាងទៀត ចំពោះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គ្មានអន្តរប្បញ្ញត្តិពិសេសនៅក្នុងច្បាប់នេះទេ ដោយសារច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ គ្មានបញ្ញត្តិស្តីពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ ប៉ុន្តែ ដោយសារចំណងអាពាហ៍ពិពាហ៍ គឺជាទំនាក់ទំនងគតិយុត្តជាបន្ត បញ្ញត្តិនៃក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តក្រោយកាលបរិច្ឆេទនៃការអនុវត្ត។ ចំពោះប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់វិញ ក្រមរដ្ឋប្បវេណីបញ្ចូលបញ្ញត្តិទាំងអស់ដែលបានកំណត់នៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ហេតុដូច្នេះ គ្មានបញ្ហានឹងកើតឡើងទេ។